# ច្បាប់ព្រហ្មទណ្ឌពិសេស




## ទាក់ទងនឹងសេរីភាពខាងការបញ្ចេញមតិ

The Asia Foundation

មជ្ឈមណ្ឌលសិទ្ធិមនុស្សកម្ពុជា
Cambodian Center for Human Rights

# ច្បាប់ព្រហ្មទណ្ឌពិសេស

ទាក់ទងនឹងសេរីភាពខាងការបញ្ចេញមតិ

# មាតិកា


**ជំពូក ១ ៖ បទបរិហារកេរ្តិ៍ជាសាធារណៈ**......1

១. ប្រវត្តិច្បាប់......4

២. និយមន័យនៃបទបរិហារកេរ្តិ៍ជាសាធារណៈ......4

៣. ធាតុផ្សំនៃបទបរិហារកេរ្តិ៍......4

ក. ភាពជាសាធារណៈ......5

ខ. ធាតុសត្យានុម័ត ៖ ការអះអាងបំផ្លើស ឬការទម្លាក់កំហុសលើអំពើណាមួយ......6

គ. ការខូចខាតដល់កិត្តិយស......10

ឃ. បុគ្គលដែលត្រូវរងការបរិហារកេរ្តិ៍......11

ង. ធាតុអត្តនោម័ត ៖ អសុទ្ធចិត្ត......12

៤. បន្ទុកភស្តុតាង......14

៥. មធ្យោបាយការពារ......14

ក. មតិយោបល់......14

ខ. ការពិត......14

គ. សុទ្ធចិត្ត......15

៦. បញ្ហានីតិវិធី ៖ តួនាទីព្រះរាជអាជ្ញា និងដើមបណ្តឹងរដ្ឋប្បវេណី......18

៧. ដើមបណ្តឹងរដ្ឋប្បវេណី......18

នីតិវិធីបណ្តឹងនៃការសុំទទួលស្គាល់ជាភាគីដើមបណ្តឹងរដ្ឋប្បវេណីនៅប្រទេសបារាំង......20

**ជំពូក ២ ៖ ការប្តឹងបរិហារបង្កាច់កេរ្តិ៍**......24

១. ប្រវត្តិច្បាប់......24

២. និយមន័យច្បាប់នៃបទប្តឹងបរិហារបង្កាច់កេរ្តិ៍......25

៣. ធាតុផ្សំនៃបទបរិហារកេរ្តិ៍បង្កាច់កេរ្តិ៍......25

ក. ការដាក់បណ្តឹង......25

ខ. ជនរងគ្រោះ......26

គ. អ្នកទទួលបណ្ដឹង ...26
ឃ. ធាតុអត្តនោម័តៈ អសុទ្ធចិត្ត (មិនស្មោះត្រង់) ...27
៤. បន្ទុកភស្តុតាង ...29
ក. ខាងខាងចោទត្រូវបញ្ជាក់ថា ចុងចោទដឹងថាអង្គហេតុនៅក្នុងបណ្ដឹងជាអង្គហេតុមិនពិត ...29
ខ. ចុងចម្លើយមិនចាំបាច់បង្ហាញពីសុទ្ធចិត្តឡើយ ...29
៥. មធ្យោបាយការពារ ...29
ក. បណ្ដឹងដែលស្វែងរកការសង្គ្រោះផ្នែករដ្ឋប្បវេណី ឬមិនមែនព្រហ្មទណ្ឌ ...29
ខ. សេចក្ដីថ្លែងការណ៍មិនត្រឹមត្រូវក្នុងអង្គហេតុមិនបង្កើតបានជាអសុទ្ធចិត្តឡើយ ...29
គ. ការធ្វេសប្រហែសមិនបង្កើតបានជាអសុទ្ធចិត្តឡើយ ...29
៦. បញ្ហានីតិវិធី ...29
៧. ភាពខុសគ្នារវាង ការបរិហារកេរ្តិ៍ និងការបរិហារបង្កាច់កេរ្តិ៍ ...30
ក. បណ្ដឹងបរិហារកេរ្តិ៍៖ គឺជាការថ្លែងអង្គហេតុទាក់ទងនឹងជនណាម្នាក់(ជាជនរងគ្រោះ) ទៅកាន់តតិយជន។ ...30
ខ. បណ្ដឹងបរិហារបង្កាច់កេរ្តិ៍៖ គឺជាការថ្លែងអង្គហេតុទាក់ទងនឹងជនណាម្នាក់ (ជាជនរងគ្រោះ)ទៅកាន់អាជ្ញាធរមានសមត្ថកិច្ច, តុលាការ, មន្ត្រីនគរបាលជាដើម។ ...30
**ជំពូក ៣ ៖ ការញុះញង់** ...32
១. ប្រវត្តិនៃច្បាប់ ...32
២. និយមន័យ ...32
៣. ការទទួលខុសត្រូវនៃការញុះញង់ដោយការផ្ដើមគំនិត (Incitement by instigation) ...33
ក. អំពើជាសត្យានុម័តនៃការញុះញង់ ...33
ខ. ចេតនានៃអ្នកញុះញង់ ...35
គ. ព្យសនកម្ម (លទ្ធផល) ...37
៤. ទិដ្ឋភាពរួមនៃបទល្មើសញុះញង់ដោយផ្ទាល់ (Direct Incitement) ...42
៥. ធាតុផ្សំនៃបទល្មើសញុះញង់ដោយផ្ទាល់ ...47
ក. ធាតុផ្សំនីត្យានុកូលភាព ...47
ខ. ធាតុផ្សំសត្យានុម័ត ...47
គ. ធាតុផ្សំអត្តនោម័ត ...48

ឃ. លទ្ធផល ........ 48

៦. បទល្មើសញុះញង់ដោយផ្ទាល់ និងជាសាធារណៈ (៤៩៥មាត្រា ) ........ 48

ក. ធាតុផ្សំសត្យានុម័ត ........ 48

ខ. ធាតុផ្សំអត្តនោម័ត ........ 48

គ. លទ្ធផល ........ 50

៧. បន្ទុកភស្តុតាងនៃបទល្មើសញុះញង់ជាសាធារណៈ និង ដោយផ្ទាល់ ........ 50

ក. ភាពជាសាធារណៈនៃអំពើ ........ 50

ខ. ការញុះញង់ដោយផ្ទាល់ ........ 50

គ. ចេតនា ........ 50

៨. មធ្យោបាយការពារ ........ 51

ក. ការញុះញង់ឲ្យប្រព្រឹត្តបទឧក្រិដ្ឋ ........ 51

ខ. ការញុះញង់ឲ្យប្រព្រឹត្តអំពើបង្កឲ្យមានភាពវឹកវរធ្ងន់ធ្ងរដល់សន្តិសុខសង្គម ........ 51

៩. ការប្រៀបធៀបជាមួយប្រទេសផ្សេងទៀត ........ 52

**ជំពូក ៤ ៖ បទប្រឆាំងនឹងអ្នករាជការសាធារណៈ** ........ 56

១. ប្រវត្តិនៃច្បាប់ ........ 56

២. និយមន័យ ........ 56

៣. ធាតុផ្សំនៃបទប្រឆាំងនឹងអ្នករាជការសាធារណៈ ........ 56

ក. លក្ខខណ្ឌជាមុន ៖ ឋានៈ និង សកម្មភាពរបស់ជនដែលត្រូវរងការប្រឆាំង ........ 56

ខ. ធាតុផ្សំសត្យានុម័ត ៖ ការប្រព្រឹត្តអំពើហិង្សាទៅលើអ្នករាជការ ........ 58

គ. ធាតុផ្សំអត្តនោម័ត ........ 59

៤. បន្ទុកភស្តុតាង ........ 59

ក. ការបំពេញមុខងារសាធារណៈ ........ 59

ខ. ការបង្ហាញពីអំពើហិង្សា ........ 60

៥. មធ្យោបាយការពារ ........ 60

ក. ការតទល់អកម្ម ........ 60

៦. បញ្ហាខាងនីតិវិធី ........ 60

ក. បទល្មើសប្រឆាំងនឹងអ្នករាជការសាធារណៈ និង ហិង្សាដោយចេតនា ....................60
ខ. ការប៉ុនប៉ង ....................60
គ. ការញុះញង់ ....................60
ឃ. ដើមបណ្តឹងរដ្ឋប្បវេណី ....................60
៧. ប្រៀបធៀបជាមួយច្បាប់ប្រទេសដទៃទៀត ....................61
៨. ការប្រៀបធៀបទៅនឹងបទហិង្សា ....................61
មាត្រា ២១៧ បទហិង្សាដោយចេតនា ....................61
មាត្រា ២២៨ បទហិង្សាស្រាល ....................61
**ជំពូក ៥ ៖ ការបំផ្លិចបំផ្លាញ ការធ្វើឲ្យទ្រុឌទ្រោម និងការធ្វើឲ្យខូចខាត** ....................63
១. ប្រវត្តិនៃច្បាប់ ....................63
២. និយមន័យ ....................63
៣. ធាតុផ្សំនៃការបំផ្លិចបំផ្លាញ ការធ្វើឲ្យទ្រុឌទ្រោម និងការធ្វើឲ្យខូចខាត ....................64
ក. លក្ខខណ្ឌជាមុន ....................64
ខ. ធាតុផ្សំសត្យានុម័ត ....................66
គ. ធាតុផ្សំអត្តនោម័ត ....................67
៤. បន្ទុកភស្តុតាង ....................67
៥. មធ្យោបាយការពារ ....................67
៦. បញ្ហាខាងនីតិវិធី ....................68
ក. កម្មសិទ្ធិមិនទាន់បានកំណត់ដាច់ស្រេច ....................68
ខ. តើការឃុំខ្លួនបណ្តោះអាសន្នអាចធ្វើទៅបានទេនៅពេលដែលកម្មសិទ្ធិមិនទាន់កំណត់ដាច់ស្រេច?.75
៧. បទបំផ្លាញ ធ្វើឲ្យទ្រុឌទ្រោម និងធ្វើឲ្យខូចខាតក្នុងទម្រង់ផ្សេងៗ ....................75
**ជំពូក ៦ ៖ កុបកម្ម** ....................78
១. ប្រវត្តិនៃច្បាប់ ....................78
២. និយមន័យ ....................79
៣. ធាតុផ្សំនៃកុបកម្ម ....................81
ក. ធាតុផ្សំសត្យានុម័ត ....................81

ខ. ធាតុផ្សំអត្តនោម័ត ........ 82
គ. ព្យសនកម្ម ........ 83
៤. បន្ទុកភស្តុតាង ........ 84
៥. មធ្យោបាយការពារ ........ 84
**ជំពូក ៧ ៖ បទផ្សព្វផ្សាយនូវអត្ថាធិប្បាយដើម្បីធ្វើសម្ពាធលើយុត្តាធិការ** ........ 86
១. ប្រវត្តិនៃច្បាប់ ........ 92
២. និយមន័យ ........ 92
៣. ធាតុផ្សំនៃបទផ្សព្វផ្សាយនូវការអត្ថាធិប្បាយដើម្បីធ្វើសម្ពាធលើយុត្តាធិការ (មាត្រា ៥២២) ........ 93
ក. លក្ខខណ្ឌជាមុននៃបទល្មើស ........ 93
ខ. ធាតុផ្សំសត្យានុម័ត ........ 94
គ. ធាតុផ្សំអត្តនោម័ត ........ 94
៤. ធាតុផ្សំនៃបទផ្សព្វផ្សាយក្នុងគោលបំណងធ្វើការគាបសង្កត់សាក្សី (មាត្រា ៥៤៩) ........ 95
ក. លក្ខខណ្ឌជាមុននៃបទល្មើស ........ 95
ខ. ធាតុផ្សំសត្យានុម័ត ........ 95
គ. ធាតុផ្សំអត្តនោម័ត ........ 95
៥ . ធាតុផ្សំនៃបទធ្វើឲ្យបាត់ជំនឿលើសេចក្តីសម្រេចរបស់តុលាការ (៥២៣មាត្រា ) ........ 95
ក. លក្ខខណ្ឌជាមុននៃបទល្មើស ........ 96
ខ. ធាតុផ្សំសត្យានុម័ត ........ 96
គ. ធាតុផ្សំអត្តនោម័ត ........ 96
៦. បន្ទុកភស្តុតាង ........ 97
៧. មធ្យោបាយការពារ ........ 97
**ជំពូក ៨ ៖ សេចក្តីជូនដំណឹងលេខ ៤៧៤ ៣៣០ និង ០៥២** ........ 100
១. ប្រវត្តិនៃសេចក្តីជូនដំណឹងលេខ ៤៧៤, ៣៣០ និង ០៥២ ........ 100
២. ការអនុវត្តសេចក្តីជូនដំណឹង ........ 101
៣. ករណីដែលបានកើតឡើងទាក់ទងនឹងសេចក្តីជូនដំណឹងលេខ ៣៣០ និង ០៥២ ........ 101
៤. វិភាគអំពីមូលដ្ឋានគតិយុត្តនៃលិខិតជូនដំណឹង ........ 103

៥. ឧបាស្រ័យក្នុងករណីមានការរំលោភសិទ្ធិដែលរដ្ឋធម្មនុញ្ញប្រទានឲ្យ ........................................... 104

**ឧបសម្ព័ន្ធ** ........................................................................................................................... 107

**មាត្រា ១៩ និង ២០ នៃកតិកាសញ្ញាស្តីពីសិទ្ធិពលរដ្ឋនិងនយោបាយ** .............................. 109

មាត្រា ១៩ ........................................................................................................................... 109

មាត្រា ២០ ........................................................................................................................... 109

**អត្ថាធិប្បាយទូទៅលេខ៣៤** .............................................................................................. 110

# បុព្វកថា

កូនសៀវភៅនេះត្រូវបានតាក់តែងឡើងសម្រាប់ប្រើប្រាស់ក្នុងការបណ្តុះបណ្តាលមេធាវី និងគ្រូបង្គោល នៅក្នុងគម្រោង "គាំទ្រសង្គមស៊ីវិលនៅប្រទេសកម្ពុជា" ដែលគាំទ្រដោយការិយាល័យប្រជាធិបតេយ្យ សិទ្ធិមនុស្ស និងពលកម្មនៃក្រសួងការបរទេសសហរដ្ឋអាមេរិក និងអនុវត្តដោយមូលនិធិអាស៊ី មជ្ឈមណ្ឌលសិទ្ធិមនុស្សកម្ពុជា និង ក្រុមមេធាវីសំរិទ្ធ។

មេរៀនភាគច្រើននៅក្នុងកូនសៀវភៅនេះត្រូវបានជ្រើសរើស ដោយសារគម្រោងមើលឃើញថាក្នុងករណីជាច្រើន កូនក្តីរបស់មេធាវីតែងរងនូវការចោទប្រកាន់តាមផ្លូវតុលាការ នៅពេលដែលគេបានអនុវត្តសិទ្ធិសំដែងចេញរបស់គេ ហើយមេរៀននេះអាចប្រើជាជំនួយដល់មេធាវី និងគ្រូបង្គោលនៅក្នុងបេសកកម្មការពារក្តី ឬផ្សព្វផ្សាយដល់ប្រជាពលរដ្ឋឲ្យបានយល់សិទ្ធិតាមផ្លូវច្បាប់ និងព្រំដែននៃការអនុវត្តសិទ្ធិទាំងនោះ។

ដោយហេតុថា យើងខ្វះយុទ្ធសាស្រ្តដើម្បីដោះស្រាយបញ្ហាផ្លូវច្បាប់ខ្លះ កូនសៀវភៅនេះបានលើកយកកតិកាសញ្ញាស្តីពីសិទ្ធិពលរដ្ឋ និងសិទ្ធិនយោបាយ ព្រមទាំងអត្ថាធិប្បាយរបស់គណកម្មាធិការសិទ្ធិមនុស្សរបស់អង្គការសហប្រជាជាតិទាក់ទងនឹងកតិកាសញ្ញានេះ យុទ្ធសាស្រ្តរបស់ប្រទេសបារាំងដែលបោះពុម្ពជាសេចក្តីអធិប្បាយជាប់ទៅនឹងមាត្រានីមួយៗនៅក្នុងសៀវភៅ Dalloz អំពីក្រមព្រហ្មទណ្ឌបារាំង យុទ្ធសាស្រ្តដែលកើតចេញពីសេចក្តីសម្រេចរបស់តុលាការអាមេរិក និងឯកសារដទៃទៀតមកពីប្រទេសផ្សេងទៀត មកធ្វើការប្រៀបធៀបជាមួយមាត្រាច្បាប់ខ្មែរ។

កូនសៀវភៅនេះកើតចេញពីការចូលរួមផ្តល់មតិពីសំណាក់មេធាវីដែលចុះកិច្ចសន្យាផ្តល់សេវាកម្មជាមួយមជ្ឈមណ្ឌលសិទ្ធិមនុស្សកម្ពុជាផងដែរ នៅក្នុងឱកាសទទួលការបណ្តុះបណ្តាលនៅមូលនិធិអាស៊ី។

យើងសូមថ្លែងអំណរគុណដល់លោក កុយ នាម អ្នកគ្រប់គ្រងកម្មវិធីច្បាប់ និង សិទ្ធិមនុស្សនៃអង្គការមូលនិធិអាស៊ី ដែលបានចំណាយពេលតាក់តែងកូនសៀវភៅនេះឡើង លោក កែ ប៊ុនធឿន ដែលបានជួយបកប្រែអត្ថបទខ្លះពីភាសាអង់គ្លេសមកជាភាសាខ្មែរ លោក គង់ ពីសី ដែលបានជួយពិនិត្យឡើងវិញនូវអត្ថបទក្នុងសៀវភៅនេះ និងការិយាល័យឧត្តមស្នងការអង្គការសហប្រជាជាតិទទួលបន្ទុកសិទ្ធិមនុស្សនៅកម្ពុជា ដែលបានអនុញ្ញាតឲ្យបញ្ចូលអត្ថបទជាភាសាខ្មែរនៃអត្ថាធិប្បាយលេខ ៣៤ របស់គណកម្មាធិការសិទ្ធិមនុស្សនៃសហប្រជាជាតិ។

យើងស្វាគមន៍ចំពោះការជួយផ្តល់មតិដើម្បីកែលម្អកូនសៀវភៅនេះតាមរយៈការផ្ញើលិខិតមកកាន់មជ្ឈមណ្ឌលសិទ្ធិមនុស្សកម្ពុជា (ម.ស.ម.ក) ដែលមានអាសយដ្ឋានដូចខាងក្រោម៖

ផ្ទះលេខ ៧៩៨ ផ្លូវលេខ ៩៩ សង្កាត់បឹងត្របែក ខណ្ឌចំការមន ប្រអប់ប្រៃសនីយ៍ ១៥០៦ រាជធានីភ្នំពេញ ព្រះរាជាណាចក្រកម្ពុជា

ទូរស័ព្ទ ៖ (+៨៥៥) ២៣ ៧២ ៦៩ ០១

អ៊ីម៉ែល ៖ info@cchrcambodia.org

ឬ លោក កុយ នាម

ផ្ទះលេខ ៥៩ ផ្លូវឧកញ៉ាពេជ្រ ភ្នំពេញ

អ៊ីមែល៖ neam.koy@asiafoundation.org

CC BY NC SA

# អក្សរកាត់ដែលប្រើក្នុងសៀវភៅនេះ

Bull. Crim.   ព្រឹត្តិបត្តិសាលដីកានៃសភាព្រហ្មទណ្ឌនៃសាលាវិនិច្ឆ័យបារាំង

T. corr. (Tribunal, Chambre correctionnelle) សាលាក្តី ផ្នែកមជ្ឈិម

TGI (Tribunal de grande instance) សាលាដំបូង

JCP (Juris-Classeur périodique (Semaine juridique), édition générale: មូលដ្ឋានទិន្នន័យសំរាប់ការស្រាវជ្រាវគតិយុត្តចេញប្រចាំ, ការផ្សាយទូទៅ

Crim. (Chambre criminelle de la cour de cassation) សភាព្រហ្មទណ្ឌនៃសាលាវិនិច្ឆ័យ

Gaz. Pal. (La Gazette du Palais) ទស្សនាវដ្ដីនៃវិមានយុត្តិធម៌ (តុលាការ)

Ibid. (Au même endroit) នៅកន្លែងដដែល។

S. (Receuil Sirey) កម្រងទូទៅនៃច្បាប់និងសាលដីកាដែលបង្កើតឡើងដោយលោក Jean-Baptiste Sirey (1762-1845)។

# ជំពូក ១

# បទបរិហារកេរ្តិ៍ជាសាធារណៈ

## ១. ប្រវត្តិច្បាប់

សេរីភាពខាងការបញ្ចេញមតិ និងការបោះពុម្ពផ្សាយគឺជាធាតុមួយយ៉ាងសំខាន់នៅក្នុងសង្គមប្រជាធិបតេយ្យ។ រដ្ឋធម្មនុញ្ញកម្ពុជាការពារនូវសេរីភាពខាងការបញ្ចេញមតិ និងសេរីភាពខាងបការបោះពុម្ព ផ្សាយ។ មនុស្សគ្រប់រូបអាចប្រើប្រាស់សេរីភាពនេះបានយ៉ាងទូលំទូលាយកុំឲ្យតែធ្វើឲ្យដរាបណាពុំប៉ះពាល់កិត្តិយសរបស់អ្នកដទៃ ដល់ទំនៀមទម្លាប់ល្អរបស់សង្គម ដល់សណ្តាប់ធ្នាប់សាធារណៈ និងដល់សន្តិសុខជាតិ(មាត្រា ៤១)។ កតិកាសញ្ញាអន្តរជាតិស្តីពីសិទ្ធិពលរដ្ឋ និងសិទ្ធិនយោបាយដែលកម្ពុជាបានផ្ល់សច្ចា ប័នក៏មានចែងអំពីសេរីភាព និងដែនកំណត់នៃការប្រើប្រាស់សេរីភាពនេះដែរ។ មាត្រា ១៩ នៃកតិកាសញ្ញាចែងថា ៖

១. មនុស្សគ្រប់រូបមានសិទ្ធិប្រកាន់នូវមតិដោយគ្មានការជ្រៀតជ្រែក

២. មនុស្សគ្រប់រូបមានសិទ្ធិដើម្បីបានសេរីភាពនៃការសំដែងចេញ។ សិទ្ធិនេះរាប់បញ្ចូលទាំងសេរីភាពដើម្បីស្វែងរក ទទួល និងបញ្ចេញព័ត៌មាន និងគំនិតគ្រប់ប្រភេទ ដោយមិនគិតពីព្រំដែនទោះជាដោយផ្ទាល់មាត់ក្តី ដោយសរសេរក្តី ឬជាការបោះពុម្ពក្តី ក្នុងទម្រង់ជាសិល្បៈក្តី ឬតាមរយៈមធ្យោបាយផ្សព្វផ្សាយតាមការជ្រើសរើសរបស់គេក្តី។

៣. ការអនុវត្តសិទ្ធិដែលចែងក្នុងកថាខណ្ឌ ទី ២ នៃមាត្រានេះនាំយកទៅជាមួយនូវករណីយកិច្ច និងការទទួលខុសត្រូវ។ ដូច្នេះ ការអនុវត្តនេះអាចស្ថិតក្រោមការរឹតត្បិតខ្លះ ប៉ុន្តែការរឹតត្បិតទាំងនោះត្រូវចែងដោយច្បាប់ និង តាមការចាំបាច់ប៉ុណ្ណោះ ៖

(ក) សម្រាប់ការគោរពសិទ្ធិ ឬ កេរ្តិ៍ឈ្មោះអ្នកដទៃ

(ខ) សម្រាប់ការការពារសន្តិសុខជាតិ ឬ ការការពារសណ្តាប់ធ្នាប់សាធារណៈ ឬ សុខភាព ឬសីលធម៌សាធារណៈ

យោងតាមកតិកាសញ្ញានេះ សេរីភាពទាំងនេះអាចរឹតត្បិតបាន លុះត្រាតែមានច្បាប់ចែងនិងក្នុងករណីចាំបាច់ប៉ុណ្ណោះ។

ទាក់ទងនឹងសេរីភាពនៃខាងការបញ្ចេញមតិ និងសេរីភាពខាងការបោះពុម្ពផ្សាយ រដ្ឋធម្មនុញ្ញកម្ពុជាបំពេញមុខងារពីរៈ (១) ធានានូវសេរីភាពរបស់មនុស្សម្នាក់ ទន្ទឹមគ្នានឹង (២) ការពារកិត្តិយស និងកេរ្តិ៍ឈ្មោះរបស់អ្នកដទៃ ការពារទំនៀមទម្លាប់ល្អ សណ្តាប់ធ្នាប់សាធារណៈ និងសន្តិសុខជាតិ។ ដូច្នេះ ត្រូវមានតុល្យភាពផ្នែកធម្មនុញ្ញនៅក្នុងការបំពេញមុខងារទាំងនេះ។ ឥឡូវនេះអាចមានសំណួរចោទសួរថាតើ ពេលណាជាពេលចាំបាច់ដើម្បីកម្រិតនូវសេរីភាពខាងការបញ្ចេញមតិ ដើម្បីការពារកេរ្តិ៍ឈ្មោះអ្នកដទៃ ការពារសណ្តាប់ធ្នាប់សាធារណៈ ឬសន្តិសុខជាតិនោះ។ ជាធម្មតា បញ្ហាតែងតែកើតមានឡើងនៅក្នុងការប្រើប្រាស់

សេរីភាពខាងការបញ្ចេញមតិ និងការយកចិត្តទុកដាក់អំពីកេរ្តិ៍ឈ្មោះអ្នកដទៃ ឬ អំពីសណ្តាប់ធ្នាប់សាធារណៈ។ មនុស្សខ្លះអាចរំលោភបំពាននូវសេរីភាពនេះដើម្បីវាយប្រហារអ្នកដទៃដោយទុច្ចរិត។ មនុស្សខ្លះទៀតអាចប្រើ ឬយកលេសរឿងកេរ្តិ៍ឈ្មោះមកបិទបាំងភាពទុច្ចរិតរបស់ខ្លួន ឧទាហរណ៍ មារយាទឧក្រិដ្ឋ ឬពុករលួយរបស់ខ្លួនជាដើម។ ចំពោះរដ្ឋាភិបាលវិញ រដ្ឋាភិបាលអាចធ្វើយុត្តិកម្មវិធានការរបស់ខ្លួន ដើម្បីបដិសេធការប្រើប្រាស់សេរីភាពខាងការបញ្ចេញមតិរបស់ប្រជាពលរដ្ឋ ដោយលើកយកសណ្តាប់ធ្នាប់សាធារណៈមកធ្វើជាខអាង។

សេរីភាពខាងបញ្ចេញមតិ និងសេរីភាពខាងការបោះពុម្ពផ្សាយអណ្តែតនៅក្នុងបរិស្ថានមួយដែលស្មុគ្រស្មាញ និងគ្មាននិយមន័យច្បាស់លាស់។ សេរីភាពនេះត្រូវបានរិតត្បិតដោយកត្តានានាដូចជា សណ្តាប់ធ្នាប់សាធារណៈ សន្តិសុខជាតិ សុខភាពសាធារណៈ និងកេរ្តិ៍ឈ្មោះរបស់ឯកត្តបុគ្គលជាដើម (នេះមិនទាន់គិតដល់ការការពារកេរ្តិ៍ឈ្មោះស្ថាប័នដែលច្បាប់ប្រទេសខ្លះ (ដូចជាកម្ពុជាជាដើម) បានអនុម័ត)។ ការព្យាយាមពង្រីកកត្តាបរិស្ថានទាំងនេះនឹងធ្វើឲ្យប៉ះពាល់ដល់សេរីភាពខាងការបញ្ចេញមតិ និងសេរីភាពខាងការបោះពុម្ពផ្សាយ។ សូមមើលរូបខាងក្រោម។ រង្វង់មូលដែលនៅព័ទ្ធជុំវិញរង្វង់មូលកណ្តាល គឺជាកត្តាបរិស្ថាន ដែលធ្វើឲ្យរង្វង់មូលកណ្តាល (ដែលតំណាងឲ្យសេរីភាពខាងការបញ្ចេញមតិ និងសេរីភាពខាងការបោះពុម្ពផ្សាយ) ចង្អៀតបើរង្វង់ព័ទ្ធជុំវិញនោះរីកចូល។




សេរីភាពខាងការបញ្ចេញមតិ និងសេរីភាពខាងការបោះពុម្ពផ្សាយពឹងផ្អែកលើកត្តាបរិស្ថានទាំងនេះ។ បើរដ្ឋពង្រីកព្រំដែនសន្តិសុខជាតិ សណ្តាប់ធ្នាប់សាធារណៈឲ្យធំ នោះសេរីភាពខាងការបញ្ចេញមតិ និងសេរីភាពខាងការបោះពុម្ពផ្សាយកាន់តែរួញទៅ។ ឧទាហរណ៍ បើរដ្ឋកំណត់ថា ការខូចសណ្តាប់ធ្នាប់សាធារណៈរួមមានការធ្វើឲ្យកខ្វក់ទីសាធារណៈ នោះសេរីភាពក្នុងការប្រជុំដើម្បីសំដែងមតិអាចជួបប្រទះនឹងការរារាំងបាន ព្រោះក្រុមមនុស្សច្រើនអាចធ្វើឲ្យទីសាធារណៈកខ្វក់បាន។ ការធ្វើឲ្យកខ្វក់ទីសាធារណៈខុសគ្នាពីសុខភាពសាធារណៈ។ ការហាមប្រាមការបញ្ចេញសេរីភាពដោយសំអាងលើមូលហេតុ សុខភាពសាធារណៈ មានដូចជាការហាមប្រាមបាតុកម្ម ក្នុងខណៈដែលទីក្រុងឬតំបន់មួយកំពុងជួបប្រទះនឹងជម្ងឺរាតត្បាតអាសន្នរោគ ឬជម្ងឺឆ្លងកាចសាហាវដទៃទៀតជាដើម។ បើអនុញ្ញាតឲ្យធ្វើបាតុកម្មក្នុងកាលៈទេសៈបែបនេះ វានឹងនាំឲ្យអន្តរាយដល់វិធានការបង្ការជម្ងឺរាតត្បាត។

ដើម្បីដោះស្រាយបញ្ហាប្រទាំងប្រទើសគ្នា រវាងសេរីភាព និងកត្តារឹតត្បិតទាំងនេះមានន័យថា ដើម្បីសម្របសម្រួលទំនាស់រវាងសេរីភាពនិងការរឹតត្បិត គណៈកម្មាធិការសិទ្ធិមនុស្សអង្គការសហប្រជាជាតិបានចេញនូវអត្ថាធិប្បាយទូទៅលេខ ៣៤ នៅក្នុងកិច្ចប្រជុំលើកទី ១០២ ពីថ្ងៃទី១១ ដល់ទី២៩ ខែកក្កដា ២០១១[1] ថា នៅពេលដែលរដ្ឋជាភាគី "ដាក់នូវការរឹតត្បិតនៃការអនុវត្តសេរីភាពខាងការបញ្ចេញមតិ ការកម្រិតនេះមិនត្រូវឲ្យអន្តរាយដល់សេរីភាពនេះឡើយ" ហើយ "ការរឹតត្បិតទាំងនេះត្រូវឆ្លងឲ្យរួចពីតេស្តដាច់ខាតនៃភាពចាំបាច់ និងភាពសមាមាត្រ"។ តេស្តនៃភាពចាំបាច់ត្រូវបានរំលោភបំពាន បើវិធានការណាមួយដើម្បីការពារ (ជាឧទាហរណ៍) កេរ្តិ៍ឈ្មោះអ្នកដទៃ នៅតែអាចរកបាន ដោយមិនចាំបាច់កម្រិតនូវសិទ្ធិខាងការបញ្ចេញមតិ។ បើមានការដាក់កម្រិតសិទ្ធិមួយ គេត្រូវប្រើវិធានការដែលជ្រៀតជ្រែកតិចបំផុតក្នុងចំណោមវិធានការទាំងឡាយដែលធ្វើឲ្យបានសម្រេចមុខងារការពារ។

ទាក់ទងនឹងការបរិហារកេរ្តិ៍ អត្ថាធិប្បាយទូទៅលេខ ៣៤ បានថែងថា ច្បាប់បរិហារកេរ្តិ៍មួយ គួរតែមិនត្រូវកំណត់ជាទោសទណ្ឌនោះទេ ហើយបើរដ្ឋទាំងឡាយណានៅរក្សាទុកទោសព្រហ្មទណ្ឌចំពោះបទបរិហារកេរ្តិ៍ រដ្ឋនោះត្រូវអនុញ្ញាតឲ្យអ្នកដែលជាប់ចោទពីបទបរិហារកេរ្តិ៍មានមធ្យោបាយការពារខ្លួនតាមផ្លូវច្បាប់។ មធ្យោបាយការពារទាំងនោះរួមមាន (១) មធ្យោបាយការពារឈរលើការពិត (២) ទម្រង់នៃការបញ្ចេញមតិដែលមិនមែនជាកម្មវត្ថុនៃការផ្ទៀងផ្ទាត់បាន (៣) សេចក្តីថ្លែងការណ៍មិនពិត និងមិនស្របតាមច្បាប់ដែលត្រូវបានបោះពុម្ពដោយច្រឡំ ប៉ុន្តែដោយគ្មានគំនិតទុច្ចរិត (៤) ផលប្រយោជន៍សាធារណៈដែលជាកម្មវត្ថុនៃការតិះដៀល[2]។ នេះមានន័យថា ច្បាប់បរិហារកេរ្តិ៍ ត្រូវបើកឲ្យជនជាប់ចោទពីបទបរិហារកេរ្តិ៍អាចលើកយកមធ្យោបាយបួនមកការពារខ្លួនពីការចោទប្រកាន់។ ទីមួយ កាលណានិយាយអ្វីមួយដែលជាការពិត អ្នកនិយាយត្រូវរួចខ្លួនពីការចោទប្រកាន់ ទោះបីសំដីរបស់គេមានលក្ខណៈធ្វើឲ្យប៉ះពាល់ដល់កិត្តិយសក៏ដោយ។ ទីពីរ ច្បាប់មិនត្រូវដាក់ទោសចំពោះការនិយាយស្តីណាដែលគេហៅថាជា "មតិ" ដោយសារគេមិនអាចផ្ទៀងផ្ទាត់មតិមួយថាពិត ឬមិនពិត ខុស ឬត្រូវបាន។ ទីបី ច្បាប់មិនត្រូវដាក់ទោសលើសំដីណាដែលថ្លែងដោយគ្មានគំនិតព្យាបាទគេ គឺសំដីដែលថ្លែងឡើងដោយការច្រឡំ។ ទីបួន ច្បាប់មិនត្រូវដាក់ទោសដល់សំដីណាដែលថ្លែងឡើងក្នុងគោលបំណងលើកឡើងពីបញ្ហាដែលជាប្រយោជន៍សាធារណៈ។

អត្ថាធិប្បាយទូទៅនោះក៏បានស្នើទៅរដ្ឋជាភាគីថា ត្រូវកំណត់ព្រំដែននៃសំណងសមល្មមសម្រាប់ភាគីដែលឈ្នះក្តី។[3] បន្ថែមពីលើនេះទៀត អត្ថាធិប្បាយទូទៅលេខ ៣៤ បានផ្តល់អនុសាសន៍ថា នៅក្នុងការនិយាយពីរឿងនយោបាយ គេត្រូវឲ្យតម្លៃខ្ពស់ដល់ការបញ្ចេញមតិដោយគ្មានការរាំងស្ទះ ដូច្នេះហើយ "ទម្រង់នៃការបញ្ចេញមតិដែលចាត់ទុកថាការជេរដល់បុគ្គលសាធារណៈគឺមិនទាន់គ្រប់គ្រាន់ ដើម្បីធ្វើយុត្តិកម្មដល់ការដាក់ទោសទេ ថ្វីបើបុគ្គលសាធារណៈអាចទទួលផលប្រយោជន៍ពីបទបញ្ញត្តិនៃអនុសញ្ញាក៏ដោយ"[4] ។ អត្ថាធិប្បាយនោះបានលើកឡើងថា គ្រប់បុគ្គលសាធារណៈ រួមមានអ្នកដែលមានអំណាចនយោបាយខ្ពស់បំផុត ដូចជាប្រមុខរដ្ឋ និងប្រមុខរដ្ឋាភិបាលជាដើម ជាកម្មវត្ថុសមស្របនៃការរិះគន់ និងការជំទាស់ខាងនយោបាយ[5] ។

---

[1] សូមមើលអត្ថបទជាភាសាអង់គ្លេស http://www2.ohchr.org/english/bodies/hrc/comments.htm)

[2] កថាខណ្ឌទី ៤៧ អត្ថាធិប្បាយទូទៅ លេខ៣៤។

[3] ដូចកំណត់ខាងលើ។

[4] កថាខ័ណ្ឌ ៣៨ អត្ថាធិប្បាយទូទៅលេខ ៣៤។

[5] ដូចកំណត់ខាងលើ។

នៅក្នុងប្រទេសកម្ពុជា ច្បាប់បរិហារកេរ្តិ៍ត្រូវបានអនុម័តជាការឆ្លើយតបទៅនឹងការការពារនៅក្នុងរដ្ឋធម្មនុញ្ញសម្រាប់ការពារកិត្តិយសអ្នកដទៃ(មាត្រា៤១)។ នៅក្នុងឆ្នាំ២០០៩ បទបរិហារកេរ្តិ៍បានកំណត់នៅក្នុងក្រមព្រហ្មទណ្ឌមាត្រា៣០៥។ ច្បាប់នេះមានប្រភពមកពីច្បាប់បារាំងមាត្រា២៩ ចុះថ្ងៃទី២៩ ខែកក្កដា ឆ្នាំ១៩៨១។ មុនក្រមនេះ ច្បាប់បរិហារកេរ្តិ៍ត្រូវបានអនុម័តដោយឧត្តមក្រុមប្រឹក្សាជាតិជាន់ខ្ពស់ដែលជាអង្គភាពរដ្ឋបាលអន្តរកាលសម្រាប់កម្ពុជាពីឆ្នាំ១៩៩២-១៩៩៣ ដោយមានជំនួយពីអាជ្ញាធរបណ្តោះអាសន្នអង្គការសហប្រជាជាតិប្រចាំនៅកម្ពុជា(ហៅកាត់ថា អ៊ុនតាក់)។ នៅក្នុងច្បាប់អ៊ុនតាក់នេះ បទបរិហារកេរ្តិ៍ត្រូវបានកំណត់និយមន័យដូចគ្នានឹងក្រមព្រហ្មទណ្ឌបច្ចុប្បន្នដែរ ប៉ុន្តែបុគ្គលដែលត្រូវគេបរិហារកេរ្តិ៍គឺសំដៅតែទៅលើ "បុគ្គលឯកជន" ប៉ុណ្ណោះ មិនមែនស្ថាប័នទេ។ ច្បាប់នេះមានស្តង់ដាខ្ពស់ក្នុងការតម្រូវឲ្យបង្ហាញភស្តុតាងពី "ចេតនាទុច្ចរិត" (malice) នៅក្នុងករណីបរិហារកេរ្តិ៍បុគ្គលសាធារណៈ ដើម្បីដាក់ទោសដល់អ្នកបរិហារកេរ្តិ៍។ ចេតនាទុច្ចរិតនេះមានន័យថា អ្នកបរិហារកេរ្តិ៍ដឹងថាអង្គហេតុដែលថ្លែងនោះមិនពិត ប៉ុន្តែនៅតែចែកចាយ បោះពុម្ព ឬចែកបន្តព័ត៌មានមិនពិតនោះ។ ច្បាប់បរិហារកេរ្តិ៍អ៊ុនតាក់បានដាក់ទណ្ឌកម្មពន្ធនាគារពី ៨ (ប្រាំបី) ថ្ងៃ ដល់ ១ (មួយ) ឆ្នាំ។ ចំពោះក្រមព្រហ្មទណ្ឌកម្ពុជាបច្ចុប្បន្នវិញ មិនមានការបែងចែករវាងការបរិហារកេរ្តិ៍បុគ្គលឯកជននិងបុគ្គលសាធារណៈទេ ប៉ុន្តែទណ្ឌកម្មនៅក្នុងក្រមព្រហ្មទណ្ឌបច្ចុប្បន្នវិញ ទោសមានត្រឹមតែការពិន័យជាប្រាក់ប៉ុណ្ណោះ។

## ២. និយមន័យនៃបទបរិហារកេរ្តិ៍ជាសាធារណៈ

**មាត្រា ៣០៥ នៃក្រមព្រហ្មទណ្ឌ**

គ្រប់ការអះអាងដោយបំផ្លើស ឬការទម្លាក់កំហុសដោយអសុទ្ធចិត្តលើអំពើណាមួយដែលនាំឲ្យប៉ះពាល់ដល់កិត្តិយស ឬកិត្តិស័ព្ទនៃបុគ្គល ឬនៃស្ថាប័នគឺជាការបរិហារកេរ្តិ៍។

ត្រូវពិន័យជាប្រាក់ពី ១ សែនរៀលទៅ ១០ លានរៀល បទបរិហារកេរ្តិ៍ដែលប្រព្រឹត្តតាមមធ្យោបាយណាមួយដូចតទៅ ៖

១. តាមសំដី ទោះជាប្រភេទណាក៏ដោយដែលបញ្ចេញនៅទីសាធារណៈ ឬនៅក្នុងសាលប្រជុំសាធារណៈ។

២. តាមលិខិត ឬគំនូរ ទោះជាប្រភេទណាក៏ដោយដែលផ្សព្វផ្សាយនៅក្នុងចំណោមសាធារណជន ឬដាក់តាំងឲ្យសាធារណជនមើល។

៣. តាមមធ្យោបាយទូរគមនាគមន៍ សោតទស្សន៍សម្រាប់សាធារណជន។

## ៣. ធាតុផ្សំនៃបទបរិហារកេរ្តិ៍

មាត្រា ៣០៥ គឺជាបទបរិហារកេរ្តិ៍ជាសាធារណៈ ដែលខុសប្លែកពីបទបរិហារកេរ្តិ៍មិនសាធារណៈ។ បទបរិហារកេរ្តិ៍ជាសាធារណៈ មានចរិតលក្ខណៈជាការថ្លែងការណ៍ដែលធ្វើឡើងជាសាធារណៈ។ ភាពជាសាធារណៈ គឺជាធាតុផ្សំចម្បងមុនគេនៃមាត្រា ៣០៥។ មាត្រា ៣០៥ មិនផ្តន្ទាទោសបទបរិហារកេរ្តិ៍មិនសាធារណៈទេ។ នៅក្នុងច្បាប់បារាំង បទបរិហារកេរ្តិ៍មិនសាធារណៈគឺគ្រាន់តែជាបទល្មើសលហុកម្រិតទី១ ដោយដាក់ទណ្ឌកម្ម សងជម្ងឺចិត្តតិចតួចប៉ុណ្ណោះ (៣៨អឺរ៉ូ) (មាត្រា R ៦២១.១)។ ច្បាប់យកចិត្តទុកដាក់ការបរិហាកេរ្តិ៍ជាសាធារណៈ ព្រោះអំពើនេះនឹងនាំឲ្យមានផលអវិជ្ជមានយ៉ាងធ្ងន់ធ្ងរដល់ជនដែលរងគ្រោះពី

អំពើបរិហារកេរ្តិ៍នេះ ដោយសារស្នាមឈ្មោះអាក្រក់ត្រូវបានដឹងសុះសាយ និងទូលំទូលាយ ជាងអំពើបរិហារកេរ្តិ៍មិនសាធារណៈ (ដែលសារបរិហារកេរ្តិ៍ត្រូវបានដឹងឮដល់មនុស្សតែចំនួនតូច)។

### ក. ភាពជាសាធារណៈ

ដូចបានបង្ហាញក្នុងមាត្រាខាងលើ មានវិធីជាច្រើនដែលត្រូវប្រើដើម្បីបរិហារកេរ្តិ៍ និងមធ្យោបាយដើម្បីផ្សព្វផ្សាយសារបរិហារកេរ្តិ៍ទៅតតិយជន។ វិធីដែលគេប្រើសម្រាប់បរិហារកេរ្តិ៍មាន ពាក្យសំដី លិខិត ឬគំនូរ សារ ការផ្សាយជាសំលេង ឬការបោះពុម្ពផ្សាយ។ វិធីទាំងនេះត្រូវបានប្រើដើម្បីធ្វើឲ្យសាររបស់អ្នកបរិហារកេរ្តិ៍គេបានទៅដល់សាធារណជន ដើម្បីឲ្យបទបរិហារកេរ្តិ៍ក្លាយទៅជាបទបរិហារកេរ្តិ៍ជាសាធារណៈ។ បញ្ហាដែលលំបាក គឺការកំណត់ថាតើអ្វីទៅជាភាពសាធារណៈ។

ដើម្បីឲ្យបទបរិហារកេរ្តិ៍មួយក្លាយទៅជាបទបរិហារកេរ្តិ៍សាធារណៈ មាត្រា ៣០៥ បានកំណត់ការបញ្ចេញសំដីឬពាក្យនៅទីសាធារណៈ សាលប្រជុំជាសាធារណៈ ទំនាក់ទំនងសាធារណៈ ឬការបង្ហាញជាសាធារណៈ។

<u>**ទីសាធារណៈ**</u> ៖ គ្មាននិយមន័យតាមផ្លូវច្បាប់អំពីទីកន្លែងជាសាធារណៈទេ។ ប៉ុន្តែមានប្រភេទទីកន្លែងពីរដែលជាទូទៅចាត់ទុកថាជាសាធារណៈ។ ទីកន្លែងមួយដែលហៅថាជាទីសាធារណៈដោយលក្ខណៈធម្មជាតិរបស់វាគឺជាទីកន្លែងបើកចំហដល់មនុស្សទូទៅអាចចេញចូលបានដោយសេរី ឧទាហរណ៍ សួនច្បារ វិសាលដ្ឋាន (ទីលាននៅក្នុងក្រុង) ផ្លូវថ្នល់ ពហុកីឡាដ្ឋាន។ល។ ទីកន្លែងទាំងនេះមិនមែនជាកម្មសិទ្ធិរបស់នរណាម្នាក់ឡើយ។ កន្លែងផ្សេងទៀតដែលជាកម្មសិទ្ធិរបស់ជនណាមួយ ប៉ុន្តែម្ចាស់បើកសម្រាប់មនុស្សទូទៅចូលដូចជា ភោជនីយដ្ឋាន រោងល្ខោន កន្លែងទទួលភ្ញៀវសណ្ឋាគារ ទីធ្លាចំហនៃមន្ទីរពេទ្យ ទាំងអស់នេះត្រូវបានគេចាត់ទុកថាជាទីកន្លែងសាធារណៈ ពីព្រោះមនុស្សទូទៅអាចចេញចូលបានដោយគ្មានការហាមឃាត់។

ទីកន្លែងដែលមិនចាត់ទុកជាសាធារណៈគឺការិយាល័យ (ប្រហែលជាលើកលែងកន្លែងទទួលភ្ញៀវ) ពីព្រោះគេកម្រិតការចេញចូលសំរាប់តែបុគ្គលិក និងអតិថិជនជាកំណត់ប៉ុណ្ណោះ។ ប្រសិនបើទីកន្លែងណាមួយត្រូវបានកំណត់សម្រាប់តែបុគ្គលិកការិយាល័យ និងមិនមែនសម្រាប់អ្នកខាងក្រៅ មិនថាកន្លែងនោះមានចំនួនបុគ្គលិកប៉ុន្មាននាក់នៅទីនោះទេ ទីកន្លែងនោះមិនត្រូវបានចាត់ទុកថា ជាទីសាធារណៈឡើយ[6]។

<u>**សាលប្រជុំសាធារណៈ**</u> ៖ ច្បាប់ក៏មិនបានឲ្យនិយមន័យអំពីអ្វីដែលហៅថា សាលប្រជុំសាធារណៈដែរ។ យុទ្ធសាស្ត្របារាំងហាក់ដូចជាចង់បែងចែកឲ្យដាច់ការប្រជុំនៃសមាជិកនៃក្រុមឯកជនពីការប្រជុំដែលមានគោលបំណងឲ្យសាធារណជនចូលស្តាប់បាន។ ឧទាហរណ៍ ការជួបប្រជុំសមាជិកភាគហ៊ុន ឬក្រុមប្រឹក្សាភិបាលរបស់ក្រុមហ៊ុន វាមិនមែនជាការប្រជុំជាសាធារណៈទេ ហើយការប្រជុំបុគ្គលិកក្រុមហ៊ុនក៏មិនចាត់ទុកជាសាធារណៈដែរ។ ប៉ុន្តែ ការប្រជុំបុគ្គលិកដោយគ្មានដាក់លក្ខខណ្ឌហាមឃាត់អ្នកខាងក្រៅចូលរួមការប្រជុំសមាជិកសហជីពទាំងនេះចាត់ទុកថាកិច្ចប្រជុំសាធារណៈ។ ដូច្នេះ មានលក្ខណៈវិនិច្ឆ័យបីដែល

---

[6] យុត្តិសាស្ត្របារាំង (Crim. 3 juill. 1980, Bull.crim No. 215; Rev.sc. crim 1981) ចែងថា "សាលទទួលទានអាហារនៃភោជនីយដ្ឋានមួយដែលបំរុងទុកសម្រាប់តែបុគ្គលិកនៃក្រុមហ៊ុនមួយ មិនត្រូវចាត់ទុកកន្លែងនោះជាទីសាធារណៈឡើយ សំរាប់គោលបំណងនៃមាត្រា ២៣ នៃច្បាប់ចុះថ្ងៃទី២៩ ខែកក្កដា ឆ្នាំ១៨៨១ ឲ្យតែទីកន្លែងនេះមិនបង្កើតឡើងសម្រាប់ឲ្យអ្នកក្រៅក្រុមហ៊ុនចេញចូលបាន ហើយចំពោះបុគ្គលិកក្រុមហ៊ុនវិញ ទោះបីបុគ្គលិកមានចំនួនប៉ុន្មាននាក់ក៏ដោយ [ចូលមកកន្លែងនោះ] ទីកន្លែងប្រភេទនេះមិនត្រូវចាត់ទុកជាទីសាធារណៈ សម្រាប់គោលបំណងនៃមាត្រានេះឡើយ"។

ចាត់ទុកថា ជាកិច្ចប្រជុំសាធារណៈគឺ (១) ចំនួននៃអ្នកចូលរួម (២) លក្ខខណ្ឌនៃការឲ្យចូល (វិធានកម្រិតការចូលរួម) និង (៣) សមាសភាពនៃអ្នកចូលរួម (សមាជិក និងមិនមែនជាសមាជិក)[7]។

__សាធារណជន__ ៖ ជាន័យទូទៅ សាធារណជនសំដៅដល់មនុស្សទូទៅ ជាពិសេសតតិយជន។

__ការដាក់តាំងឲ្យសាធារណជនមើល__ ៖ ការបិទផ្សាយព័ត៌មាននៅលើផ្ទាំងប្រកាសព័ត៌មានតែមួយមុខ មិនចាត់ទុកថាជាការដាក់តាំងឲ្យសាធារណជនមើលឡើយ លើកលែងតែផ្ទាំងប្រកាសព័ត៌មាននោះមានមុខងារសម្រាប់ផ្សាយព័ត៌មានជាសាធារណៈ។ ឧទាហរណ៍ នៅក្នុងយុទ្ធសាស្ត្របារាំងការបិទផ្សាយក្រដាសបរិហារកេរ្តិ៍នៅលើផ្ទាំងប្រកាសពត៌មាននៅក្នុងរោងចក្រមួយអំពីការបណ្តេញកម្មករ មិនហៅថាជាការដាក់តាំងឲ្យសាធារណជនមើលទេ បើមានតែកម្មកររោងចក្រអាចមើលផ្ទាំងនោះបាន (ទោះកម្មករមានចំនួនប៉ុន្មានក៏ដោយ)[8] ។ ប៉ុន្តែ បើអ្នកខាងក្រៅអាចចូលមើលបាន ផ្ទាំងប្រកាសព័ត៌មានការបិទផ្សាយនេះ នឹងក្លាយជាការដាក់តាំងឲ្យសាធារណជនមើល។ ការបិទសំណេរបរិហារកេរ្តិ៍ នៅលើក្លោងទ្វារនៃល្វែងចូលសាលាដែលជាកន្លែងមនុស្សទូទៅ ជាសមាជិក ឬមិនមែនសមាជិកសាលាអាចមើលឃើញ ការដាក់តាំងឲ្យសាធារណជនមើល[9] គឺជាការដាក់តាំងឲ្យសាធារណជនមើល។

__មធ្យោបាយទូរគមនាគមន៍ និងសោតទស្សន៍សម្រាប់សាធារណជន__ ៖ នេះរួមមានការផ្សាយនូវពាក្យ ឬ សម្ភារៈបរិហារកេរ្តិ៍ តាមវិទ្យុ ទូរទស្សន៍ ឬអ៊ិនធើណែត។ វិទ្យុ និងទូរទស្សន៍ ជាក់ស្តែងគឺជាមធ្យោបាយសម្រាប់សាធារណជន។ អ៊ិនធើណែតជាទូទៅមានគោលបំណងសម្រាប់ផ្សាយទៅសាធារណជន។ ប៉ុន្តែអ៊ីម៉ែលអាចជាសាធារណៈ ឬមិនជាសាធារណៈ អាស្រ័យទៅលើប្រភេទនៃការប្រាស្រ័យទាក់ទងគ្នា។ អ៊ីម៉ែល ឬអត្ថបទសារតាមទូរស័ព្ទដែលឆ្លើយឆ្លងពីមនុស្សម្នាក់ទៅមនុស្សម្នាក់ទៀតមិនចាត់ទុកជាសាធារណៈឡើយ។ គេអាចចោទសួរថា តើអ៊ីម៉ែល ឬទូរស័ព្ទទៅបុគ្គលិក ឬបញ្ជីដែលមានឈ្មោះស្រាប់អាចជាការផ្សព្វផ្សាយជាធារណៈឬយ៉ាងណា?។

## ខ. ធាតុសត្យានុម័ត ៖ ការអះអាងបំផ្លើស ឬការទម្លាក់កំហុសលើអំពើណាមួយ

__ការអះអាងបំផ្លើស ឬទម្លាក់កំហុស__ ៖ ការអះអាងបំផ្លើស (ភាសាបារាំង Allégation) គឺការថ្លែងថាមនុស្សម្នាក់បានធ្វើអំពើអ្វីមួយជាក់លាក់ ជាទូទៅ គ្មានមូលដ្ឋាន ឬ ជាការមិនពិត។ ពាក្យបារាំង Allégation នេះមានន័យថា ជាការអះអាង ការប្រកាស ទាក់ទងនឹងអំពើណាមួយ ឬច្រើន ហើយការមាន ឬមិនមានអំពើនោះទាមទារឲ្យមានការបង្ហាញជាភស្តុតាងថែមទៀត ឬជាការអះអាង ការប្រកាសទាក់ទងនឹងការលើកឡើងបែបស្រមើស្រមៃ[10]។ ឧទាហរណ៍ ដូចជាការដែលអ្នកស្រីធីតាថ្លែងថា គាត់បានបាត់ខ្សែកមួយខ្សែ ហើយគ្មានអ្នកណាក្រៅពីលោកចិត្តទេដែលបានលួចខ្សែកនោះ ព្រោះលោកចិត្តបានចូលក្នុងផ្ទះគាត់។ ជួនកាល ការអះអាងបំផ្លើសគឺជាការឮតាមគេ ឬជាចចាមអារ៉ាម។

ការទំលាក់កំហុស តាមភាសាបារាំង Imputation គឺជាការភ្ជាប់ការទទួលខុសត្រូវទៅអ្នកណាមួយពីសកម្មភាព អំពើ ឬការប្រព្រឹត្តណាមួយដែលអាចស្តីបន្ទោសអ្នកនោះបាន[11] ។ គឺជាការថ្លែងដោយចោទ

---

[7] Jean Larguier, Anne-Marie Larguier, Droit pénal spécial, Dalloz, 11th Edition, 2000, p. 148.

[8] Crim. 8 October 1974, Bull.crim No. 280

[9] Crim. 10 juillet 1973, Bull.crim. No. 321

[10] សូមមើលនៅក្នុងទំព័រ http://www.dictionnaire-juridique.com/definition/allegation.php

[11] សូមមើលនៅក្នុងទំព័រ http://www.cnrtl.fr/lexicographie/imputer

ប្រកាន់ថាមនុស្សម្នាក់បានធ្វើអំពើមួយអាក្រក់ឬមិនត្រឹមត្រូវ។ ការទំលាក់កំហុសអាចធ្វើតាមរបៀបដូចតទៅនេះ ៖

- ថ្លែងថាអំពើមួយជាស្នាដៃរបស់អ្នកណាម្នាក់
- ចោទថាអ្នកណាម្នាក់បានធ្វើអំពើមួយ
- និយាយបញ្ឆិតបញ្ឆៀងថាអ្នកណាម្នាក់បានធ្វើអំពើមួយ

**<u>អំពើ</u>** ៖ អំពើ (ភាសាបារាំង Fait) គឺជាកិរិយានៃការធ្វើអ្វីមួយ អាចជាកាយវិការ ការប្រព្រឹត្ត ការនិយាយ ការសរសេរ ការគូររូបជាដើម។ អំពើសំដៅដល់អ្វីដែលធ្វើឲ្យកើតឡើងមានមែន។ អំពើបង្កើតជាព្រឹត្តិការណ៍ (ភាសាអង់គ្លេស Fact)។ ដូច្នេះ អំពើជាកម្មវត្ថុនៃការផ្ទៀងផ្ទាត់ មានន័យថា គេអាចដឹងថា អំពើមួយត្រូវបានធ្វើ ឬមិនបានធ្វើ ដោយសារគេអាចផ្ទៀងផ្ទាត់បាន។ ឧទាហរណ៍ អ្នកស្រីធីតា (ឧទាហរណ៍ខាងលើ) ថ្លែងពីអំពើ "លួច" ។ "លួច" អាចផ្ទៀងផ្ទាត់បានដោយការស៊ើបអង្កេត ឬការស្រាវជ្រាវ។

ក្នុងន័យច្បាប់ អំពើគឺជាអ្វីដែលគេអាចបញ្ជាក់ និងជំទាស់/ច្រានចោល ដើម្បីរកឲ្យឃើញថាអំពើនោះមានមែន ឬមិនមាន។ ការថ្លែងពីអំពើដែលមានមែនគឺជា សេចក្តីថ្លែងពីការពិត។ ការថ្លែងពីអំពើដែលមិនមានសោះ គឺជាការថ្លែងមិនពិត។

ការថ្លែងពីអំពើខុសគ្នាពីការថ្លែងពីមតិយោបល់។ ក្នុងខណៈដែលគេអាចនិយាយថាសេចក្តីថ្លែងពីអំពើមួយជាសេចក្តីថ្លែងពិត គេមិនអាចនិយាយថាការថ្លែងពីមតិមួយពិតឬមិនពិតនោះទេ ព្រោះគេមិនអាចធ្វើការបញ្ជាក់ថាមតិមួយពិត ឬមិនពិតនោះទេ។ គេអាចវិនិច្ឆ័យថាមតិមួយជាមតិសមរម្យឬមិនសមរម្យ សមហេតុផល ឬមិនសមហេតុផល។ ក្នុងពេលដែលអំពើនាំឲ្យមាន "ការផ្ទៀងផ្ទាត់ដោយសត្យានុម័ត" មតិយោបល់នាំឲ្យមាន "ការវិនិច្ឆ័យដោយអត្តនោម័ត "ឬ"ការវិនិច្ឆ័យទៅតាមជំនឿឬគុណតម្លៃ" របស់អ្នកណាម្នាក់។

ឧទាហរណ៍ ក និយាយថា ខ មានពិន្ទុ IQ ច្រើនជាង ៣០ នេះជាសេចក្តីថ្លែងពីអំពើ ពីព្រោះគេអាចដាក់ ខ ឲ្យធ្វើតេស្តបាន ដើម្បីវាស់ពិន្ទុ។ ប៉ុន្តែបើ ក និយាយថា ខ ជាមនុស្សល្ងង់ នេះមិនមែនជាសេចក្តីថ្លែងពីអំពើទេ ព្រោះការវិនិច្ឆ័យរបស់ ក ថា ខ មើលទៅដូចជាល្ងង់ ប៉ុន្តែការវិនិច្ឆ័យរបស់បុគ្គលផ្សេងទៀតគិតថា ខ ប្រហែលជាមិនអីទេ។ មតិយោបល់គឺជាអ្វីដែលប្រៀបធៀប (Relative) ដែលអាចប្រែប្រួលពីបុគ្គលម្នាក់ទៅបុគ្គលម្នាក់ទៀត។

**<u>ភាពបែងចែកគ្នាមិនដាច់រវាងអំពើ និងមតិ</u>** ៖ ការបែងចែករវាងអំពើ និងមតិជារឿងសំខាន់នៅក្នុងរឿងក្តីបរិហារកេរ្តិ៍ ព្រោះច្បាប់ផ្តន្ទាទៅលើសេចក្តីថ្លែងពីអំពើដែលធ្វើឲ្យប៉ះពាល់ដល់កិត្តិយសអ្នកដទៃប៉ុណ្ណោះ តែមិនផ្តន្ទាសេចក្តីថ្លែងពីមតិទេ (សូមមើលផងដែរមាត្រា ២០ នៃច្បាប់ស្តីពីរបបសារព័ត៌មានដែលលើកលែងការទទួលខុសត្រូវក្នុងការសំដែងមតិ)។

ជួនកាលសេចក្តីថ្លែងខ្លះមានការលាយឡំគ្នារវាងអំពើ និងមតិដែលមិនងាយនឹងបែងចែកឲ្យដាច់ពីគ្នា មានន័យថាតើមនុស្សម្នាក់ចង់ថ្លែងពីមតិ ឬចង់ប្រាប់ថាអំពើមួយបានកើតឡើង។ ឧទាហរណ៍ ក សង្កេតឃើញថា ខ ពាក់គ្រឿងអលង្ការថ្លៃៗ និងចាយវាយប្រាក់ច្រើននៅតាមហាងនានា ហើយគាត់បាននិយាយរឿងនេះទៅប្រាប់មិត្តគាត់ថា ខ ជាអ្នកមាន។ ការថ្លែងនេះមានការលាយឡំគ្នារវាង អំពើ និងមតិ ពីព្រោះការសង្កេតផ្តល់ជាអង្គហេតុថា ខ មានប្រាក់ច្រើន និងមានទ្រព្យធនថ្លៃៗ។ ការថ្លែងថា ខ ជាអ្នកមានគឺជា

យោបល់ដែលចេញពីអង្គហេតុទាំងនោះ (ការចំណាយលើគ្រឿងអលង្ការ និងការចាយវាយប្រាក់ច្រើន)។ ការថ្លែងថាមនុស្សម្នាក់ដែលមានប្រាក់ខែតិច និងបើកឡានថ្លៃៗជាមនុស្សពុករលួយ ក៏ជាការថ្លែងដែលមានការលាយឡំរវាងអង្គហាតុ (អំពើ) និង មតិដែរ ដោយពាក្យ "ពុករលួយ" ត្រូវបានទាញចេញពីអង្គហេតុដែលថា បុគ្គលនោះមានប្រាក់ខែតិចសោះ ប៉ុន្តែអាចមានឡានថ្លៃៗជិះ។ នៅក្នុងសេចក្តីថ្លែងមួយដែលលាយឡំដោយអំពើផង និងមតិផងជារួម តើគេត្រូវកំណត់យកមួយណាជាសេចក្តីថ្លែងពីអំពើ? ឬជាសេចក្តីថ្លែងពីមតិ?។ ជាឧទាហរណ៍ យើងសូមលើក យកមកពិចារណានូវលក្ខណៈវិនិច្ឆ័យបួនដែលលើកឡើងដោយតុលាការឧទ្ធរណ៍របស់សហរដ្ឋអាមេរិកនៅក្នុងរឿងក្តី Ollman v. Evans ដើម្បីកំណត់ថាតើសេចក្តីថ្លែងមួយជាសេចក្តីថ្លែងពីអំពើ ឬជាសេចក្តីថ្លែងពីមតិ ៖

(១) *ភាពជាក់ច្បាស់នៃសេចក្តីថ្លែង៖* តើពាក្យដែលប្រើនោះមានន័យជាក់ច្បាស់ ឬឥតព្រលាំដែរឬទេ ព្រោះថាអ្នកអានមិនទំនងជាធ្វើសេចក្តីសន្និដ្ឋានថាជាអំពើ ចេញពីសេចក្តីថ្លែងមួយដែលមានន័យព្រលាំនោះទេ។ តុលាការបញ្ជាក់ថា ការចោទប្រកាន់មនុស្សណាម្នាក់ពីការប្រព្រឹត្តឧក្រិដ្ឋកម្ម មិនមែនជាមតិទេ គឺការចោទបែបនេះមានន័យជាក់ច្បាស់។ អ្នកអាន ឬអ្នកស្តាប់ទូទៅនឹងសន្និដ្ឋានថាការប្រព្រឹត្តឧក្រិដ្ឋកម្មជាអំពើ (អង្គហេតុ) ដែលធ្វើឲ្យមនុស្សត្រូវចោទប្រកាន់នោះខូចខាតធ្ងន់ណាស់។ ឧទាហរណ៍ ការចោទប្រកាន់មន្ត្រីម្នាក់ថាបានរំលោភសេពសន្ថវៈ ហើយបង់លុយឲ្យជនរងគ្រោះកុំឲ្យប្តឹង ជាសេចក្តីថ្លែងពីអំពើ ការចោទប្រកាន់ថាចៅក្រមពុករលួយ នៅក្នុងបរិបទនៃសេវាកម្មសាធារណៈ មានន័យថា ចៅក្រមនោះស៊ីសំណូក ឬបំពានករណីយកិច្ចរាជការ ដូច្នេះ វាជាសេចក្តីថ្លែងពីអំពើរបស់ចៅក្រមនោះ មិនមែនមតិរបស់អ្នកចោទប្រកាន់ទេ។

ប៉ុន្តែ កាលណាពាក្យមួយនាំឲ្យមានន័យដែលអាចឲ្យគេអាចបកស្រាយបានច្រើនយ៉ាង ពាក្យនោះមិនអាចចាត់ទុកថាជាសេចក្តីថ្លែងពីអំពើទេ។ ឧទាហរណ៍ ពាក្យចៅក្រម "គ្មានសមត្ថភាព" ជាពាក្យដែលទូលំទូលាយពេក មិនអាចកំណត់ឲ្យដឹងថាអំពើណាមួយដែលបញ្ជាក់ពីការគ្មានសមត្ថភាពនោះ។ តុលាការថា ពាក្យថា អ្នករាយការណ៍ម្នាក់ពាក់ព័ន្ធនឹង "ការរាយការណ៍ឲ្យតែបាន និងគ្មានការទទួលខុសត្រូវ" និង "មានបច្ចេកទេសរាយការណ៍អន់" មានន័យ មិនជាក់ច្បាស់ពេកណាស់ ដែលគេមិនអាចចាត់ថាជាសេចក្តីថ្លែងពីអំពើបានទេ។

សរុបមក កាលណាអ្នកអានឃើញសេចក្តីថ្លែងមួយមានន័យព្រលាំ អ្នកនោះមិនអាចសន្និដ្ឋានថា តើអ្នកថ្លែងនោះចង់និយាយពាក្យដូចខ្លួនប្រើ ឬចង់និយាយផ្សេងពីហ្នឹង។

តុលាការក្នុងរឿងក្តីខាងលើស្នើគំនិតថា តុលាការត្រូវវិភាគសេចក្តីថ្លែងដើម្បីកំណត់ថាសេចក្តីថ្លែងនោះមានន័យច្បាស់គ្រប់គ្រាន់ដើម្បីឲ្យគេដឹងថាជាសេចក្តីថ្លែងពីអំពើ ឬមិនមែនជាអំពើ។

(២) *ភាពអាចផ្ទៀងផ្ទាត់បាននៃសេចក្តីថ្លែង* ៖ នេះជាកត្តាទីពីរដែលត្រូវពិចារណា គឺថាតើសេចក្តីថ្លែងមួយអាចផ្ទៀងផ្ទាត់បានដែរឬទេ។ តុលាការបញ្ជាក់ហេតុផលនៃវិធីនេះថា អ្នកអានគ្មានហេតុផលអ្វីនឹងមើលឃើញថាសេចក្តីថ្លែងមួយដែលមិនអាចផ្ទៀងផ្ទាត់បាន ជាសេចក្តីថ្លែងដែលនាំឲ្យគេយល់ថាជាអំពើ(អង្គហេតុ)ពិតប្រាកដនោះទេ។ បើគេគ្មានមធ្យោបាយអាចផ្ទៀងផ្ទាត់បាន ដូច្នេះការសម្រេចផ្នែកអង្គហេតុនៅក្នុងរឿងក្តីមួយ មុខជាត្រូវផ្អែកតែលើការស្មានប៉ុណ្ណោះ។ ដូច្នេះការសម្រេចបែបនេះមិនអាចយកជាការបានទេ។

(៣) *បរិបទពេញលេញនៃសេចក្តីថ្លែង* ៖ បន្ថែមលើលក្ខណៈវិនិច្ឆ័យទាំងពីរខាងលើ តុលាការស្នើឲ្យពិចារណាលើលក្ខណៈវិនិច្ឆ័យមួយទៀតគឺ តើសេចក្តីថ្លែងមួយត្រូវបានធ្វើនៅក្នុងបរិបទណា ព្រោះបរិបទនៃសេចក្តីថ្លែងនោះនឹងជះឥទ្ធិពលលើអ្នកអានឬអ្នកស្តាប់ជាមិនខាន។ នេះមានន័យថា កាលណាអ្នកអានបានមើលអត្ថបទទាំងមូល អត្ថបទនោះនឹងបញ្ចេញសញ្ញាដល់អ្នកអានឲ្យដឹងថា តើអត្ថបទនោះចង់បង្ហាញពីសេចក្តីថ្លែងពីអំពើ ឬពីសេចក្តីថ្លែងពីមតិ។ គេអាចធ្វើការបែងចែករវាងអំពើ និង មតិបានតែនៅក្នុងបរិបទនោះប៉ុណ្ណោះ។

បរិបទដែលត្រូវយកមកពិចារណាគឺបរិបទភាសា និងបរិបទសង្គម។ ឧទាហរណ៍ សេចក្តីថ្លែងនៅក្នុងអត្ថបទមួយ បើអានតែសេចក្តីថ្លែងនោះតែឯង សេចក្តីថ្លែងនោះជាសេចក្តីថ្លែងពីអំពើ តែបើយកសេចក្តីថ្លងនោះទៅផ្គួបបញ្ចូលក្នុងអត្ថបទទាំងមូល គេឃើញសេចក្តីថ្លែងនោះទៅជាសេចក្តីថ្លែងពីមតិទៅវិញ។ ឧទាហរណ៍ នៅក្នុងអត្ថបទមួយ អ្នកនិពន្ធសរសេរនៅក្នុងឃ្លាមួយថា លោកវេជ្ជបណ្ឌិត "មានទ្រឹស្តីមួយគឺគាត់ចង់លះបង់ជីវិតមួយចោល" ហើយនៅក្នុងឃ្លាមួយទៀតអ្នកនិពន្ធសរសេរជាសំណួរថា "តើគេត្រូវបញ្ឈប់វេជ្ជបណ្ឌិតនោះបែបណាបាន? តើមានកុមារប៉ុន្មាននាក់ទៀតដែលត្រូវស្លាប់?"។ វេជ្ជបណ្ឌិតជាដើមបណ្តឹងអះអាងថា សេចក្តីថ្លែងរបស់អ្នកនិពន្ធនោះគឺចង់នាំព័ត៌មានទៅសាធារណជនថា គាត់មានបំណងសម្លាប់អ្នកជម្ងឺ ហើយអ្នកជម្ងឺដទៃទៀតកំពុងស្ថិតក្នុងគ្រោះថ្នាក់នឹងត្រូវគាត់សម្លាប់ដែរ។ តុលាការនិយាយថា ការពិពណ៌នាពិតប្រាកដរបស់អ្នកនិពន្ធ គឺអំពីវិធីព្យាបាលនិងកាលៈទេសៈដែលនាំឲ្យអ្នកជម្ងឺស្លាប់ មិនមែនអំពើសម្លាប់មនុស្សរបស់វេជ្ជបណ្ឌិតនោះទេ ដូច្នេះសេចក្តីថ្លែងនោះជាមតិរបស់អ្នកនិពន្ធ។

ជូនកាលទៀត អ្នកនិពន្ធប្រើភាសាបែបព្រមានឲ្យដឹងជាមុន នៅក្នុងអត្ថបទរបស់ខ្លួន ដូចជាប្រើពាក្យថា "តាមយោបល់របស់..." ឬ ដាក់ជាសំណួរថា "តើ...?" ដែលជាសញ្ញាព្រមានឲ្យអ្នកអានដឹងថាអ្វីដែលនិយាយបន្តទៅទៀតនោះជាមតិរបស់ខ្លួន ឬ ជាការអញ្ជើញអ្នកអានឲ្យពិចារណាទៅលើរឿងអ្វីមួយ។ តុលាការទទួលស្គាល់ថាការប្រើភាសាព្រមានជាមុនមិនមែនបង្កើតអភ័យឯកសិទ្ធិដល់គ្រប់សេចក្តីថ្លែងបរិហារកេរ្តិ៍នោះទេ។ បើសេចក្តីថ្លែងមួយពោរពេញទៅដោយព័ត៌មានបង្ហាញពីអំពើ (អង្គហេតុ) ដូចជាការចោទប្រកាន់ពីការប្រព្រឹត្តឧក្រិដ្ឋកម្មជាដើម នៅក្នុងរឿងដូច្នេះ ទោះបីប្រើភាសាព្រមានជាមុនក៏ដោយ ក៏ភាសានោះមិនអាចបន្សាបការ "សន្និដ្ឋានទៅខាងអំពើ" (Factual conclusion) បានដែរ។ ប៉ុន្តែ បើសេចក្តីថ្លែងបង្ហាញមិនសូវច្បាស់ពីអំពើ (អង្គហេតុ) ទេនោះ សេចក្តីថ្លែងនោះនឹងធ្វើឲ្យអ្នកអានយល់ផ្សេងពីនេះយ៉ាងច្រើន។ តុលាការយល់ថា នៅក្នុងសេចក្តីថ្លែងព្រមានជាមុន និងសេចក្តីថ្លែងដែលចោទជាសំណួរ បើគេថ្លឹងឲ្យធ្ងន់ទៅខាងមតិ តុលាការនឹងផ្តល់សេរីភាពទៅឲ្យអ្នកកាសែត អ្នកនិពន្ធ អ្នកធ្វើអត្ថាធិប្បាយដើម្បីនាំបញ្ហាដែលមានសារសំខាន់ជាសាធារណៈ ទៅឲ្យសាធារណជនដឹង និងធ្វើការពិនិត្យពិច័យលើបញ្ហានោះ។

(៤) *ការវិភាគពីបរិបទសង្គមទូលំទូលាយ* ៖ ជាការវិភាគបរិបទសង្គមដ៏ទូលំទូលាយ ដែលធ្វើឲ្យគេដឹងថា តើសេចក្តីថ្លែងនោះស៊ីគ្នានឹងបរិបទនោះដែរឬទេ។ តុលាការនិយាយថា ប្រភេទនៃការសរសេរ ឬការនិយាយខ្លះ ជាប្រពៃណី ឬជាការសន្មតរបស់សង្គម នឹងបញ្ចេញសញ្ញាដល់អ្នកអានឬអ្នកស្តាប់ថាវាជាមតិ។ ឧទាហរណ៍ ការដែលនិយាយថា កម្មករម្នាក់ជា "ជនក្បត់" នៅពេលដែលកម្មករនោះឆ្លងកាត់គំនូសដែលកម្មករធ្វើកូដកម្មបានគូសកុំឲ្យកម្មករឆ្លងកាត់ចូលទៅធ្វើការ។ តុលាការថាពាក្យវោហារបំភ្លៃនិងបំផ្លើសបែបនេះកើតមានស្ទើរតែគ្រប់កន្លែងដែលមានជម្លោះការងារ ដូច្នេះ មិន

មានន័យថា កម្មករដែលឆ្លងកាត់គំនូសនោះជាជនក្បត់ដូចដែលថានោះទេ។ នេះជាមតិរបស់តួដករប៉ុណ្ណោះ។

ជួនកាលសេចក្តីថ្លែងខ្លះរិះគន់ និយាយបង្អាប់លេងអ្នកណាម្នាក់ ឧទាហរណ៍ ការនិយាយពីអ្នកធ្វើអត្ថាធិប្បាយកីឡាម្នាក់ថា "គាត់ជាអ្នកធ្វើអត្ថាធិប្បាយតែម្នាក់គត់នៅក្នុងក្រុងនេះ ដែលបានចូលថ្នាក់រៀន ដើម្បីឲ្យគ្រូបង្រៀនគាត់ឲ្យនិយាយឲ្យបានត្រឹមត្រូវជាងមុន" ជាសេចក្តីថ្លែងពីមតិព្រោះវាជាប្រពៃណីនៃការនិយាយបង្អាប់លេង គេតែងតែប្រើរូបកំប្លែង និង ប្រើពាក្យឡេបខាយ។ គាត់មិនចង់និយាយថា អ្នកធ្វើអត្ថាធិប្បាយនោះពិតជាបានទៅរៀនសាលាកែប្រែនោះទេ។

មនុស្សទូទៅតែងចាត់ថា អត្ថបទវិចារណកថា ជាការសម្តែងមតិរបស់អ្នកសរសេរ រីឯអត្ថបទសរសេរនៅទំព័រមុខ ជាអត្ថបទសរសេរពីហេតុការណ៍ដែលកើតឡើងដូច្នេះជាសេចក្តីថ្លែងពីអំពើ។

សេចក្តីថ្លែង ដែលគេមិនអាចហៅឲ្យជាក់ស្តែងថាជាមតិ ឬជាអំពើនោះ ត្រូវហៅថាជាសេចក្តីថ្លែងកូនកាត់។ តុលាការនេះនិយាយថា សេចក្តីថ្លែងកូនកាត់គឺជាសេចក្តីថ្លែងដែលមនុស្សភាគច្រើននឹងចាត់ទុកថាពិត ឬ មិនពិត អាស្រ័យលើអំពើ ឬអង្គហេតុនៅពីក្រោយដែលមិនបានបង្ហើបនៅក្នុងសេចក្តីថ្លែងដែលនៅចំពោះមុខ។ នេះមានន័យថា បើការសរសេរនោះមិនអស់សេចក្តីដែលមិនអាចឲ្យគេសន្និដ្ឋានថាជា អំពើ ឬ មតិទេនោះ គេអាចស្រាវជ្រាវរកអង្គហេតុខាងក្រៅសាច់រឿងដែលកំពុងសរសេរនោះ ដើម្បីយកមកវិភាគឲ្យដឹងប្រាកដថា តើវាជាអំពើ ឬមតិ។ បើសេចក្តីថ្លែងមតិនោះ នាំឲ្យគេសន្និដ្ឋានថាមតិនោះកើតចេញពីការសំអាងលើអំពើ (អង្គហេតុ) សេចក្តីថ្លែងនោះមិនមែនជាមតិទេ។

គំនិតខាងលើនេះស្របគ្នានឹងយុត្តិសាស្ត្របារាំង ដែលថាអំពើមួយអាចបញ្ជាក់បានមិនត្រឹមតែដោយកាលៈទេសៈដែលទាក់ទងនឹងរឿងក្តីដែលកំពុងជជែកគ្នានោះទេ ប៉ុន្តែអាចបញ្ជាក់បានដោយកាលៈទេសៈខាងក្រៅផងដែរ ដើម្បីបំភ្លឺរឿងក្តីដែលកំពុងជជែកគ្នានេះ[12]។

## គ. ការខូចខាតដល់កិត្តិយស

ដូចមានការពិភាក្សាខាងលើហើយ ពាក្យពេចន៍មិនមែនមានខ្លឹមសារតែមួយគ្មានពីរនោះទេ។ ពាក្យពេចន៍ខ្លះអាចមានន័យវិជ្ជមានសម្រាប់បុគ្គលម្នាក់ ប៉ុន្តែអវិជ្ជមានសម្រាប់បុគ្គលផ្សេងទៀត។ ពាក្យពេចន៍ខ្លះមានន័យទៅតាមបរិបទ។ អត្ថន័យនៃពាក្យក៏មានន័យប្រែប្រួលទៅតាមពេលវេលា និងទីកន្លែងដែរ។ ឧទាហរណ៍ បុគ្គល ក និយាយថា ដានី ជាស្រីខាវ៉ាអូខេ។ មនុស្សខ្លះអាចមើលឃើញថា "ស្រីខាវ៉ាអូខេ" ជាការងារមិនសមរម្យ។ មនុស្សខ្លះទៀតអាចគិតថាជាការងារធម្មតាដូចគេដូចឯង។ ឧទាហរណ៍មួយផ្សេងទៀតគឺការនិយាយថាបុគ្គលម្នាក់នោះឈឺដោយសារជម្ងឺអេដស៍។ ជម្ងឺអេដស៍តែម្តងមិនមែនជាការខូចកិត្តិយសអ្វីទេ ប៉ុន្តែដោយសារការលាបពណ៌របស់សង្គម ការភ្ជាប់អ្នកណាម្នាក់ជាមួយជម្ងឺអេដស៍ គឺជាការបង្ខូចកេរ្តិ៍។

កិត្តិយសត្រូវបានកំណត់និយមន័យថា ជាការគោរព និងការសរសើរដែលអ្នកដទៃផ្តល់ឲ្យមនុស្សម្នាក់ (វចនានុក្រមច្បាប់ Black Law Dictionary) ជាការគោរព និងការសរសើរ ដែលអ្នកដទៃមានចំពោះ

[12] Crim. 12 mars 1969, Bull. Crim. No 120: ដើម្បីធ្វើមូលវិចារណ៍លើលក្ខណៈគតិយុត្ត ដើម្បីហៅថាសេចក្តីថ្លែងមួយជាសេចក្តីថ្លែងបរិហារកេរ្តិ៍ ចៅក្រមត្រូវយកមកពិចារណាមិនត្រឹមតែកាលៈទេសៈដែលលើកឡើងនៅក្នុងការចោទប្រកាន់នោះទេ តែរឿងខាងក្រៅទៀតដែលអាចបង្ហាញឲ្យឃើញថាពាក្យដែលជាប់ការចោទប្រកាន់នោះមានន័យពិតប្រាកដ និងដើម្បីអាចបញ្ជាក់ពីលក្ខណៈនៃបទល្មើសនោះ។

មនុស្សម្នាក់។ ការធ្វើឲ្យប៉ះពាល់ដល់កិត្តិយសគឺជាការបណ្ដាលឲ្យបាត់បង់នូវការគោរព និងការសរសើរចំពោះបុគ្គលនោះ។ របៀបម្យ៉ាងទៀតក្នុងការកំណត់និយមន័យ នៃការធ្វើឲ្យការប៉ះពាល់កិត្តិយសគឺជាការ "និយាយដែលធ្វើឲ្យរងរបួសដល់កិត្តិយសអ្នកដទៃ ដោយលាតត្រដាងជននោះឲ្យគេស្អប់ខ្ពើម ប្រមាថ ចំអកឡកឡឺយ ឬសំដៅទៅបន្ទាបរូបគាត់ក្នុងសេចក្ដីគោរពនិងរាប់អានពីសមាជិកសង្គមដែលមានការគិតត្រឹមត្រូវ"[13]។ ការបាត់បង់កិត្តិយសអាចនាំឲ្យបាត់បង់ឱកាសការងារ ជំនឿលើវិជ្ជាជីវៈ ជំនឿលើអាជីវកម្ម ឬឱកាសផ្សេងៗទៀត។ ដោយហេតុថា ការខូចខាតកិត្តិយសត្រូវបានកំណត់ចេញពីទស្សនវិស័យនៃសមាជិកសង្គម ដូច្នេះសំណួរអាចលើកឡើងថា តើអ្នកណាជាអ្នកត្រូវបង្ហាញថាការខូចខាតកិត្តិយសដែលកើតមាន? ជាចៅក្រម ឬសមាជិកសង្គម។ នៅក្នុងប្រទេសដែលមានគណៈវិនិច្ឆ័យ (Jury) ចៅក្រមជាអ្នកវាយតម្លៃថាសំដីមួយមានលក្ខណៈបរិហារកេរ្តិ៍ (ធ្វើឲ្យខូចកិត្តិយសអ្នកដទៃ) សម្រាប់សំដីដែលងាយៗនឹងដឹងថាមានលក្ខណៈបរិហារកេរ្តិ៍ តែបើសំដីខ្លះដែលចៅក្រមមានមន្ទិលថាដូចជាមិនមានលក្ខណៈបរិហារកេរ្តិ៍ ដូច្នោះចៅក្រមលើករឿងនោះឲ្យគណៈវិនិច្ឆ័យជាអ្នកសម្រេចវិញ [14] ។ នេះដោយសារតែគេយកមតិរបស់សង្គមទូទៅថា តើគេយល់ថាពាក្យមួយជាពាក្យធ្វើឲ្យប៉ះពាល់ដល់កិត្តិយសរបស់អ្នកដទៃ ឬពាក្យនោះគ្មានជាតិពិសពុលអ្វីទេ។ ឧទាហរណ៍ ដូចជានៅប្រទេសខ្មែរ តើការនិយាយថាមន្ត្រីរាជការម្នាក់មានសម្បត្តិច្រើនមានន័យថាជាការសរសើរ ឬជាការរិះគន់ថាមន្ត្រីនោះជាជនពុករលួយ? ក្នុងសហគមន៍ខ្លះ គេសរសើរអ្នកមានទ្រព្យសម្បត្តិច្រើន ដោយគេមិនខ្វល់ថាសម្បត្តិនោះមានប្រភពចេញមកពីណាទេ។ តែនៅក្នុងសហគមន៍ខ្លះ មន្ត្រីដែលមានទ្រព្យសម្បត្តិច្រើនជាកម្មវត្ថុនៃការរិះគន់ ឬការពេបជ្រាយ ដោយសារគេសង្ស័យថាទ្រព្យនោះបានមកពីអំពើពុករលួយ។

## ឃ. បុគ្គលដែលត្រូវរងការបរិហារកេរ្តិ៍

មាត្រា ៣០៥ នៃក្រមព្រហ្មទណ្ឌមានគោលបំណងការពារមិនត្រឹមតែកិត្តិយស ឬកិត្តិសព្ទរបស់បុគ្គលឯកជនប៉ុណ្ណោះទេ ប៉ុន្តែការពាររហូតដល់ស្ថាប័នទៀតផង។ មាត្រា ៣០៥ មិនបានចង្អុលបង្ហាញថាស្ថាប័នណាអាចរងការបរិហារកេរ្តិ៍បាន ដូចជាស្ថាប័នឯកជន ឬសាធារណៈ ជាស្ថាប័នពាណិជ្ជកម្ម ឬស្ថាប័នស៊ីវិល ឬអង្គភាពរដ្ឋាភិបាលជាដើម។

ដោយហេតុថាច្បាប់បរិហារកេរ្តិ៍គ្របដណ្ដប់តែទៅលើកិត្តិយស ឬកិត្តិសព្ទរបស់ "បុគ្គល" ការបរិហារកេរ្តិ៍ ឬនិយាយបន្ទុះបង្អាប់ផលិតផលមួយ ត្រូវស្ថិតនៅក្រៅវិសាលភាពនៃច្បាប់បរិហារកេរ្តិ៍។ ឧទាហរណ៍ ការនិយាយថាកៅស៊ូកង់ម៉ាក ក មានគុណភាពអន់ មិនមែនជាការបរិហារកេរ្តិ៍ក្រុមហ៊ុនដែលផលិតកៅស៊ូកង់នោះទេ ដូច្នេះ ច្បាប់បរិហារកេរ្តិ៍ មិនអាចអនុវត្តលើករណីនេះបានទេ។

ពាក្យសំដីបរិហារកេរ្តិ៍ ជាទូទៅមិនលាតត្រដាងពីអត្តសញ្ញាណនៃបុគ្គលដែលត្រូវគេបង្ខូចកេរ្តិ៍ឡើយ។ ទោះបីជាយ៉ាងនេះក្ដី ច្បាប់នៅក្នុងគ្រប់ប្រព័ន្ធច្បាប់ទាំងអស់អនុញ្ញាតឲ្យគេទាញសេចក្ដីសន្និដ្ឋានអត្តសញ្ញាណបាន។ ឧទាហរណ៍ អ្នកកាសែតម្នាក់បានសរសេរថា "យោធានៅឈរជើងនៅតំបន់ ក បានរុករានយកព្រៃសហគមន៍ ដោយសេរីគ្មានការគ្រប់គ្រង"។ មេបញ្ជាការអង្គភាពនៅតំបន់នោះអាចសន្និដ្ឋានថា អ្នកនិយាយចង់និយាយពីខ្លួន ព្រោះអង្គភាពនោះស្ថិតនៅក្រោមបញ្ជារបស់ខ្លួន។ ទោះបីជាពាក្យសំដីនោះមិនពោលដោយចំៗសំដៅលើបុគ្គលម្នាក់ ឬច្រើននាក់ក៏ដោយ ក៏អត្តសញ្ញាណរបស់ពួកគេអាចត្រូវ

[13] ជានិយមន័យដែលប្រើនៅក្នុងរឿងក្ដីអង់គ្លេស Sim v. Stretch [1936]។

[14] Andrew T. Kenyon, Defamation: Comparative Law and Practice, UCL Press, 2007, p.35.

សន្និដ្ឋានចេញពីអត្ថន័យពីកាលៈទេសៈខាងក្រៅដែលនាំឲ្យអ្នកស្តាប់ ឬទស្សនិកជនអាចយល់បាន ឬអាចបញ្ជាក់អះអាងពីអត្តសញ្ញាណរបស់បុគ្គលដែលទទួលការជៀមដាមបាន។

ប៉ុន្តែបើពាក្យនិយាយនោះមានលក្ខណៈទូលំទូលាយពេកដែលមិនអាចកំណត់ពីអត្តសញ្ញាណរបស់បុគ្គលជាក់លាក់ណាបាន នោះក៏គ្មានបទល្មើសបរិហារកេរ្តិ៍កើតឡើងដែរ។

ចំពោះ**ការបរិហារកេរ្តិ៍ស្ថាប័ន**វិញ គេមិនដឹងច្បាស់ថាតើមាត្រា ៣០៥ នេះចង់គ្របដណ្តប់តែស្ថាប័នឯកជន ដូចជា អង្គភាពអាជីវកម្ម ឬគ្របដណ្តប់ស្ថាប័នសាធារណៈ ដូចជាក្រសួងផងដែរ។ បើច្បាប់មានគោលបំណងគ្របដណ្តប់លើស្ថាប័នសាធារណៈ នោះបុគ្គលនីមួយៗអាចនឹងងាយធ្លាក់ចូលទៅក្នុងការដាក់ទោសទណ្ឌពីបទបរិហារកេរ្តិ៍ណាស់ ពោលគឺនៅពេលណាដែលពួកគេចោទសួរអំពីតម្លាភាពរបស់អង្គភាពរដ្ឋាភិបាល។ យោងតាមអត្ថាធិប្បាយ លេខ ៣៤ របស់គណៈកម្មាធិការសិទ្ធិមនុស្សរបស់អង្គការសហប្រជាជាតិ គណៈកម្មាធិការនេះហាមប្រាមការចោទប្រកាន់ពីបទបរិហារកេរ្តិ៍ ដោយចែងថា "***រដ្ឋជាភាគីមិនត្រូវហាមឃាត់ការរិះគន់ស្ថាប័ន ដូចជា កងទ័ព ឬរដ្ឋបាលជាដើម***"[15]។ ដូច្នេះ ការចោទប្រកាន់បទបរិហារកេរ្តិ៍ស្ថាប័នសាធារណៈ ជាការផ្ទុយទៅនឹងស្មារតីនៃ កតិកាសញ្ញាស្តីពីសិទ្ធិពលរដ្ឋ និងសិទ្ធិនយោបាយ។

## ង. ធាតុអត្តនោម័ត ៖ អសុទ្ធចិត្ត

ច្បាប់ស្តីពីបទបរិហារកេរ្តិ៍ ដាក់ទណ្ឌកម្មចំពោះតែបុគ្គលណា ដែលបញ្ចេញពាក្យសំដីដោយ អសុទ្ធចិត្តប៉ុណ្ណោះ។ អសុទ្ធចិត្ត គឺជាចេតនាធ្វើឲ្យមានព្យសនកម្ម។ ច្បាប់កម្ពុជាមិនបានចែងណែនាំពីអ្វីដែលហៅថាអសុទ្ធចិត្តនោះឡើយ។ ក្នុងករណីដែលប្រទេសកម្ពុជាគ្មានយុទ្ធសាស្ត្រដើម្បីពន្យល់ពាក្យ អសុទ្ធចិត្តនៅក្នុងករណីបទបរិហារកេរ្តិ៍ ដូច្នេះតុលាការអាចក្រឡេកទៅរកអត្ថាធិប្បាយលេខ ៣៤ នៃគណៈកម្មាធិការសិទ្ធិមនុស្សដើម្បីយកជាគោលនាំផ្លូវក៏បាន ព្រោះអត្ថាធិប្បាយនេះភ្ជាប់កាតព្វកិច្ចចំពោះប្រទេសកម្ពុជា។ ម្យ៉ាងវិញទៀតយុត្តិសាស្ត្របារាំងក៏ជាគំរូមួយល្អផងដែរ ព្រោះយុត្តិសាស្ត្រនេះមានគោលគំនិតស្រដៀងគ្នានឹងគោលគំនិតក្នុងអត្ថាធិប្បាយលេខ ៣៤ លើរឿងនេះ។

អត្ថាធិប្បាយលេខ ៣៤ ចែងថា "**នៅក្នុងករណីណាក៏ដោយ គេត្រូវទទួលស្គាល់ថាការរិះគន់អំពីអ្វីមួយដែលជាកម្មវត្ថុនៃផលប្រយោជន៍សាធារណៈជាមធ្យោបាយការពារ**"[16] មានន័យថា ចុងចោទអាចលើកឡើងថាសំដីរបស់ខ្លួនមិនមែនមានគោលដៅវាយប្រហារបុគ្គលទេ តែសំដីនោះទាក់ទងផលប្រយោជន៍សាធារណៈ ដែលសាធារណជនគួរតែបានដឹងរឿងនោះ គឺចុងចោទមិនមានគំនិតអសុទ្ធចិត្តដើម្បីវាយប្រហារដើមបណ្តឹងបរិហារកេរ្តិ៍នោះទេ។ ចំពោះការនិយាយប៉ះពាល់ដល់បុគ្គលសាធារណៈវិញ អត្ថាធិប្បាយលេខ ៣៤ បានបញ្ជាក់ថាច្បាប់ "គួរចៀសវាងដាក់ទោស ឬចាត់ជាខុសច្បាប់នូវការនិយាយមិនពិតដែលបានបោះពុម្ពផ្សាយដោយភ័ន្តច្រឡំតែគ្មានគំនិតព្យាបាទអ្នកណាម្នាក់" (កថាខ័ណ្ឌទី ៤៧)។ នេះមានន័យថា កាលណាការនិយាយណាមួយប៉ះពាល់ដល់កិត្តិយសរបស់បុគ្គលសាធារណៈ តុលាការត្រូវដាក់បន្ទុកដល់ដើមចោទ (ជាបុគ្គលសាធារណៈ) ដើម្បីបង្ហាញថាការនិយាយរបស់ចុងចោទនោះ ពោរពេញទៅដោយគំនិតព្យាបាទ (គំនិតចង់បំផ្លាញ) មិនមែនដោយសារការធ្វេសប្រហែស ឬការភ័ន្តច្រឡំទេ។ ដូច្នេះ បើគេរកមិនឃើញធាតុព្យាបាទនៅក្នុងការនិយាយទេនោះ តុលាការមិនត្រូវដាក់ទណ្ឌកម្មដល់អ្នកនិយាយប៉ះពាល់ដល់បុគ្គលសាធារណៈឡើយ។

---

[15] គណៈកម្មាធិការសិទ្ធិមនុស្ស, អត្ថាធិប្បាយ លេខ ៣៤ កថាខណ្ឌទី ៣៨។

[16] ប្រភពដូចគ្នា ត្រង់កថាខ័ណ្ឌទី ៤៧។

ក្នុងការកំណត់ថាសំដីមួយជាសំដីពេញទៅដោយអសុទ្ធចិត្ត តុលាការអាចយកយុត្តិសាស្ត្របារាំងជាគោលគំនិតណែនាំក៏បាន។ យុទ្ធសាស្ត្របារាំងបានកំណត់លក្ខណៈវិនិច្ឆ័យសរុបខាងក្រោម ដើម្បីកំណត់ថាមានសុទ្ធចិត្តឬគ្មាន នៅពេលមានការនិយាយមួយដែលត្រូវបានចោទថាបរិហារកេរ្តិ៍អ្នកដទៃ ៖

១. មានគោលបំណងសមរម្យ (La legitimité du but poursuivi)

២. គ្មានភាពជាសត្រូវនឹងគ្នា (L´absence d´animosité personelle)

៣. មានការអង្កេតហ្មត់ចត់មុននិយាយ (Le sérieux de l´enquête)

៤. និយាយដោយមានការថ្លឹងថ្លែង (La prudence dans l´expression ou modération)

**<u>មានគោលបំណងសមរម្យ</u> ៖** ពាក្យសំដីដែលបន្លឺឡើងគឺក្នុងគោលបំណងផ្តល់ព័ត៌មានទៅសាធារណជនឲ្យដឹងពីសាច់រឿងណាដែលទាក់ទងនឹងផលប្រយោជន៍ ឬជាក្តីកង្វល់នៃសាធារណជន។ ឧទាហរណ៍ ការនិយាយ ឬរបាយការណ៍អំពីតម្លាភាព និងគណនេយ្យភាពរបស់រដ្ឋាភិបាលគឺជារឿងដែលបម្រើឲ្យផលប្រយោជន៍សាធារណៈ។ ការកេងបន្លំថវិកាជាតិក៏ជារឿងដែលសាធារណៈចង់ដឹង។ សេចក្តីរាយការណ៍ពីការធ្វើឲ្យខូចបរិស្ថាន សុខភាព ការរំលោភយកដីធ្លី ឬការបណ្តេញចេញក៏ជាចំណុចសំខាន់សម្រាប់សាធារណជនត្រូវដឹងដែរ។

**<u>គ្មានភាពជាសត្រូវនឹងគ្នា</u> ៖** និយាយឲ្យងាយស្តាប់ទៅ ពាក្យដែលនិយាយស្តីមិនត្រូវធ្វើឡើង ដើម្បីធ្វើការសងសឹកដល់បុគ្គលណាមួយឡើយ។ ប៉ុន្តែ ពាក្យសំដីដែលមិនពិរោះពិសារអំពីអ្នកណាម្នាក់ក៏មិនមែនសុទ្ធតែមានន័យថាការសងសឹកផ្ទាល់ខ្លួននោះដែរ។ គេត្រូវពិនិត្យមើលទំនាក់ទំនងរវាងអ្នកត្រូវគេបង្ខូចកេរ្តិ៍ និងអ្នកបង្ខូចកេរ្តិ៍។ ឧទាហរណ៍ សមាជិកម្នាក់នៃសមាគមមួយដែលអំពាវនាវឲ្យពិនិត្យមើលប្រធានសមាគមអំពីការប្រើប្រាស់ថវិកាសមាគម មិនមែនមានន័យថា ជាការសងសឹកនោះទេ លើកលែងតែ ជាឧទាហរណ៍ ប្រធានបានដាក់វិន័យសមាជិកនោះកាលពីមុន ហើយសមាជិកនេះបានអំពាវនាវឲ្យត្រួតពិនិត្យមើលការកេងបន្លំ សូម្បីតែគ្មានតម្រុយនៃការគៃបន្លំណាមួយសោះក៏ដោយ។ ប៉ុន្តែគេអាចប្រមាណមើលបានពីគោលបំណងនៃការអំពាវនាវនោះផងដែរ។ ការរិះគន់របស់អ្នកនយោបាយប្រឆាំងទៅលើសមាជិករដ្ឋាភិបាល នៅក្នុងការអនុវត្តមុខងារត្រួតពិនិត្យរបស់គេ មិនត្រូវចាត់ទុកជាភាពជាសត្រូវនឹងគ្នាទេ ព្រោះជាការអនុវត្តតួនាទីរបស់គណបក្សប្រឆាំង។

**<u>មានការអង្កេតហ្មត់ចត់មុននិយាយ</u>** ៖ ការអង្កេតហ្មត់ចត់គឺមិនមែនមានន័យរហូតដល់ទៅរកភស្តុតាងបញ្ជាក់ពីភាពពិតនៃអង្គហេតុដែលត្រូវបានចោទប្រកាន់នោះឡើយ ប៉ុន្តែការអង្កេតនេះគួរត្រូវបានធ្វើដោយមានការប្រុងប្រយ័ត្នមុនពេលនិយាយពីរឿងនោះ។ ការធ្វើបែបនេះគឺដើម្បីធានាពីភាពសត្យានុម័ត (Objectivity) នៃពាក្យសំដីដែលនិយាយ។ បុគ្គលដែលគេចោទថានិយាយពាក្យបរិហារកេរ្តិ៍នោះត្រូវប្រឹងប្រែងឲ្យអស់លទ្ធភាពដើម្បីឲ្យព័ត៌មានដែលខ្លួននិយាយនោះមានមូលដ្ឋានគ្រាន់បើ។ ប្រសិនបើចុងចោទប្រឌិតរឿងនោះ គាត់មិនអាចបង្ហាញពី "សុទ្ធចិត្ត" នៅក្នុងពាក្យសំដីរបស់គាត់បានឡើយ។

**<u>និយាយដោយមានការថ្លឹងថ្លែង</u>** ៖ ការបញ្ចេញពាក្យសំដីត្រូវធ្វើឡើងដោយមានការប្រយ័ត្នប្រយែង និង មានការថ្លឹងថ្លែង។ ពាក្យសំដីដែលមានការថ្លឹងថ្លែងគឺមិនត្រូវមានការបំផ្លើស ឬការនិយាយបង្ករឿង។ ឧទាហរណ៍ ការប្រើពាក្យថា "ក្បត់ជាតិ" ឬ "មានពិរុទ្ធ" នេះមិនមែនជាការបញ្ចេញមតិដោយប្រយ័ត្នប្រយែងនោះទេ។ ការនិយាយដោយមានការថ្លឹងថ្លែងត្រូវរួមបញ្ចូលទស្សនៈផ្ទុយផងដែរ។ ឧទាហរណ៍ បើអ្នកនិយាយម្នាក់បានអង្កេតហ្មត់ចត់លើរឿងណាមួយហើយ គាត់គួរបង្ហាញពីព័ត៌មានដែលផ្ទុយពីរឿងដែលគាត់រកឃើញដែរដើម្បីបញ្ជាក់ថាគាត់បានបង្ហាញព័ត៌មានគ្រប់ជ្រុងជ្រោយ មិនមែនស្តាប់តែប្រភពម្ខាងនោះទេ។

## ៤. បន្ទុកភស្តុតាង

នៅសហរដ្ឋអាមេរិក ការបរិហារកេរ្តិ៍ជាសាធារណៈ ឬ"បរិហារកេរ្តិ៍តាមការសរសេរ" (Libel) ជាអំពើអនីត្យានុកូល (Tort)។ បន្ទុកក្នុងការបញ្ជាក់បង្ហាញធាតុផ្សំនៃបទល្មើសបរិហារកេរ្តិ៍គឺស្ថិតនៅលើដើមចោទ។ ឧទាហរណ៍ការបញ្ជាក់ពីការមិនពិត និងចេតនាទុច្ចរិតជាបន្ទុករបស់ភាគីដើមចោទ (សូមមើលឧទាហរណ៍រឿងក្តីរវាង New York Times និង Sullivan)។

នៅប្រទេសបារាំង ការបរិហារកេរ្តិ៍ជាសាធារណៈគឺជាបទមជ្ឈិម និងត្រូវបានកាត់ក្តីដោយ តុលាការព្រហ្មទណ្ឌ។ ចេតនាទុច្ចរិតត្រូវបានសន្មតសម្រាប់ចុងចោទ គឺមិនមែនខាងអយ្យការ ឬ ភាគីរដ្ឋប្បវេណីឡើយ។ ហេតុដូច្នេះ ចុងចោទត្រូវតែទទួលបន្ទុកបង្ហាញភស្តុតាងពីសុទ្ធចិត្តរបស់ខ្លួន។

## ៥. មធ្យោបាយការពារ

### ក. មតិយោបល់

មតិយោបល់ត្រូវបានទទួលការការពារដោយរដ្ឋធម្មនុញ្ញកម្ពុជា មាត្រា៤១ និងច្បាប់ស្តីពីរបបសារព័ត៌មាន មាត្រា២០។

**មាត្រា ៤១ (រដ្ឋធម្មនុញ្ញ)**

ប្រជាពលរដ្ឋខ្មែរមានសេរីភាពខាងការបញ្ចេញមតិរបស់ខ្លួន សេរីភាពខាងការបោះពុម្ពផ្សាយ និងសេរីភាពខាងការប្រជុំ។

**មាត្រា ២០ (ច្បាប់ស្តីពីរបបសារព័ត៌មាន)**

អំពើប្រព្រឹត្តរបស់និយោជក និពន្ធនាយក ឬអ្នកនិពន្ធអត្ថបទដែលរំលោភច្បាប់ព្រហ្មទណ្ឌ ត្រូវទទួលទោសតាមច្បាប់ព្រហ្មទណ្ឌ។ ប៉ុន្តែទោះជាយ៉ាងណាក៏ដោយ ក៏គ្មានជនណាម្នាក់ត្រូវចាប់ចង ឬជាប់ពន្ធនាគារ ដោយសារការបញ្ចេញមតិឡើយ។

ដូច្នេះរាល់ការបញ្ចេញមតិយោបល់មិនត្រូវបានដាក់ទោស ដោយច្បាប់ព្រហ្មទណ្ឌរួមទាំងច្បាប់បរិហារកេរ្តិ៍ផងដែរ។

ដូចដែលពិភាក្សាខាងលើ មតិយោបល់មិនអាចផ្ទៀងផ្ទាត់បានទេ ដូច្នេះគេមិនអាចបង្ហាញភស្តុតាងថាមតិយោបល់មួយពិត ឬមិនពិត ត្រូវឬខុស ឡើយ។ ច្បាប់បរិហារកេរ្តិ៍ផ្តន្ទាទោសតែការថ្លែងណាដែល**មិនពិត**ដែលធ្វើឲ្យប៉ះពាល់កិត្តិយសអ្នកដទៃប៉ុណ្ណោះ។

### ខ. ការពិត

ការពិតគឺជាមធ្យោបាយការពារចំពោះបណ្តឹងពីបទបរិហារកេរ្តិ៍។ ទោះបីជាការនិយាយមួយបានប៉ះពាល់ដល់កិត្តិយសរបស់អ្នកណាម្នាក់ក៏ដោយ តែបើការនិយាយរឿងនោះជារឿងពិត អ្នកនិយាយមិនទទួលខុសត្រូវពីបទបរិហារកេរ្តិ៍ទេ។ ឧទាហរណ៍ ការនិយាយថាមន្ត្រីម្នាក់បានទទួលសំណូក ថ្វីពាក្យស៊ីសំណូកនេះធ្វើឲ្យខូចកិត្តិយសរបស់មន្ត្រីនោះក៏ដោយ ក៏អ្នកនិយាយនោះមិនអាចត្រូវបានដាក់ទោសពីបទបរិហារកេរ្តិ៍បានដែរ។

## គ. សុទ្ធចិត្ត

លក្ខណៈវិនិច្ឆ័យដើម្បីកំណត់អំពីនិយមន័យនៃសុទ្ធចិត្ត ត្រូវបានបង្ហាញនៅផ្នែកខាងលើរួចហើយ។ ឧទាហរណ៍ នៃរឿងក្តីមួយដែលតុលាការសិទ្ធិមនុស្សអឺរ៉ុបបានសម្រេចយកធ្វើជាគំរូ ដើម្បីស្វែងយល់ពីលក្ខណៈវិនិច្ឆ័យនៃសុទ្ធចិត្ត។

នេះជារឿងក្តីរបស់លោក Noël Mamère ជាសមាជិកសភាបារាំងមកពីគណបក្សបៃតង ដែលបានដាក់បណ្តឹងទៅតុលាការសិទ្ធិមនុស្សអឺរ៉ុបជំទាស់ទៅនឹងតុលាការកំពូលបារាំង (French Cour de cassation) ដែលដាក់ទោសគាត់ពីបទបរិហារកេរ្តិ៍។ ដំណើររឿងមានដូចខាងក្រោមនេះ។

នៅពេលនិយាយជាមួយទូរទស្សន៍បារាំង២ (TV France 2) ក្នុងឆ្នាំ១៩៩៩ លោក Mamère បានឆ្លើយតបទៅនឹងអ្នកចូលរួមផ្សេងទៀត ដែលរំលឹកអំពីហេតុការន៍នៃការផ្ទុះរោងចក្រនុយក្លេអ៊ែរនៅ Chernobyl នៅសហភាពសូវៀតក្នុងឆ្នាំ១៩៨៦ ថា "ជាច្រើនសប្តាហ៍បន្ទាប់ពីការផ្ទុះនោះមក នៅតែមានពពកនៃសារធាតុសេស្សូមបានឆ្លងចូលក្នុងប្រទេសបារាំង ហើយនេះជាលទ្ធផលនៃការផ្ទុះរោងចក្រនុយក្លេអ៊ែរ Chernobyl ។ ខ្ញុំបានបង្ហាញរឿងនេះដល់កាសែត នៅម៉ោង១៣ ក្នុងឆ្នាំ១៩៨៦ ជាថ្ងៃនៃមហន្តរាយនៅ Chernobyl បានកើតឡើង។ មានបុគ្គលបីសាចម្នាក់ឈ្មោះ Pellerin ធ្វើការនៅក្នុងអាជ្ញាធរមជ្ឈិមសម្រាប់ការការពារប្រឆាំងនឹងកាំរស្មីអ៊ីយ៉ុង នៅតែនិយាយច្រំដែលៗប្រាប់យើងថា ប្រទេសបារាំងជាប្រទេសខ្លាំងមានគំនិតថាខ្លួនឯងជាអាស្ទេរិក (Asterix complex)[17] ថាពពកនៃកាំរស្មីពី Chernobyl មិនបានហោះកាត់ព្រំដែនប្រទេសរបស់យើងទេ។"[18] លោក Pellerin ជាពេទ្យឯកទេសខាងកាំរស្មីអគ្គិសនីវិទ្យា និងជាសាស្ត្រា ចារ្យផ្នែកជីវរូបសាស្ត្រ និងជារដ្ឋមន្ត្រីសុខភាព និងការងារ ដែលដឹកនាំក្រសួងកណ្តាលសម្រាប់ការការពារប្រឆាំងនឹងកាំរស្មីអ៊ីយ៉ុងក្នុងអំឡុងពេលដែលមានមហន្តរាយនៅ Chernobyl។ បេសកកម្មរបស់គាត់គឺត្រូវគ្រប់គ្រងកម្រិតនៃការរាលដាលឆ្លងកំទេចកាំរស្មីនៅក្នុងដែនដីប្រទេសបារាំង និងផ្តល់ព័ត៌មានបន្ទាន់ទៅក្រសួងទាំងអស់អំពីបញ្ហានេះ។

ក្នុងខែតុលា ឆ្នាំ២០០០ លោក Mamère ត្រូវបានសាលាដំបូងក្រុងប៉ារីសកោះហៅឲ្យបំភ្លឺលើបណ្តឹងពីបទបរិហារកេរ្តិ៍ដែលប្តឹងដោយលោក Pellerin។ គាត់ត្រូវបានតុលាការផ្តន្ទាទោសឲ្យបង់ប្រាក់ពិន័យចំនួន១ម៉ឺនហ្វ្រង់ និងសងជម្ងឺចិត្តចំនួន៥ម៉ឺនហ្វ្រង់ និងបង្គាប់ចុះផ្សាយសាលក្រមតុលាការនៅលើទំព័រកាសែតទៀត ដោយចំណាយប្រាក់ខ្លួនឯង។ លោក Mamère បានប្តឹងទៅសាលាឧទ្ធរណ៍ក្រុងប៉ារីស។ សាលាឧទ្ធរណ៍ក្រុងប៉ារីសបានតម្កល់សាលក្រមសាលាដំបូង ដោយមានមូលហេតុថា លោក Mamère ខ្វះការថ្លឹងថ្លែងនៅក្នុងការនិយាយស្តីៈ

១. ការប្រើពាក្យពេចន៍ដូចជា "**នៅតែនិយាយច្រំដែលៗប្រាប់យើង**" លោក Mamère ទទួច**យ៉ាងខ្លាំង** និង**គ្មានអ្វីគួរមន្ទិល** ថាលោក Mr Pellerin **មានចេតនាកុហកច្រំដែលៗ** និងថាគាត់បាន**ក្រឡៃការពិតមករហូតគ្មានផ្លាស់ប្តូរនិងដោយដឹងខ្លួន**។

២. គាត់ក៏បាននិយាយពីលោក Pellerin ថាជា"**បីសាច**" ដែលនេះមិនមែនជា**ការបញ្ចេញសំដីអព្យាក្រឹត** ជាពិសេសកាលណាប្រើពាក្យនេះភ្ជាប់ជាមួយអ្វីម្យ៉ាងដូចជាគ្រោះមហន្តរាយ Chernobyl នេះ។

---

[17] *The Adventures of Asterix* is a series of comic books by a French author. Asterix is small but confident, whereas his companion, Obelix, is big and strong, but not very clever

[18] រឿងក្តី Mamère v. France សាលដីការបស់តុលាការសិទ្ធិមនុស្សអឺរ៉ុប, កថាខ័ណ្ឌ៥។

គាត់ក៏និយាយដែរថា ភាគីរដ្ឋប្បវេណីកើតគំនិត "**ចាត់ខ្លួនឯងជាអាស្តេរិច**"[19] ដូចនេះធ្វើឲ្យលោក Pellerin ជាមនុស្ស**គួរឲ្យសើចចំអក** និងជាមនុស្ស**មិនគួរឲ្យទុកចិត្តបាន**។

៣. ការដែលលោក Mamère មិនទុកមុខ ការនិយាយបង្រ្កប ចរិតប្រមាថកាតទានលើភាគីរដ្ឋប្បវេណី**បង្ហាញអំពីការខ្វះខាតនូវមជ្ឈន្តិកភាព** (ភាពនៅជាកណ្តាល, ភាពមិនហួសហេតុ) **នៃសំដីរបស់គាត់**។

៤. ដោយហេតុថាគាត់ខ្វះលក្ខខណ្ឌមួយក្នុងចំណោមលក្ខខណ្ឌផ្សេងទៀតនៃធាតុផ្សំសុទ្ធចិត្ត ចុងចម្លើយមិនត្រូវបានចាត់ទុកថា បាននិយាយដោយសុទ្ធចិត្តនោះទេ ដូច្នេះហើយ តុលាការក៏មិនចាំបាច់ពិនិត្យលើទិដ្ឋភាពផ្សេងទៀតនៃធាតុផ្សំសុទ្ធចិត្តដែរ។

៥. ដូច្នេះគាត់ត្រូវផ្តន្ទាទោស។

តុលាការកំពូលបារាំងក្នុងខែតុលា ឆ្នាំ២០០២ បានតម្កល់សាលដីកាសាលាឧទ្ធរណ៍ទៀត។ បន្ទាប់មក រឿងក្តីនេះត្រូវបានប្តឹងបន្តទៅតុលាការសិទ្ធិមនុស្សអឺរ៉ុបក្នុងខែមេសា ឆ្នាំ២០០៣។

ក្នុងខែឧសភា ឆ្នាំ២០០៦ គណៈកម្មការដើម្បីស្រាវជ្រាវ និងព័ត៌មានឯករាជ្យស្តីពីវិទ្យុសកម្ម និងសមាគមបារាំងនៃអ្នកមានជម្ងឺក្រពេញទីរ៉ូអីតបានទទួលស្គាល់ថាមន្ត្រីនាពេលនោះបានកុហក និងប៉ាន់ប្រមាណមិនដល់នូវកំទេចវិទ្យុសកម្មហោះពី Chernobyl ធ្លាក់ចូលប្រឡាក់ប្រឡូកប្រទេសបារាំង។ តុលាការអឺរ៉ុបបានចេញនូវសាលក្រមរបស់ខ្លួនក្នុងខែវិច្ឆិកា ឆ្នាំ២០០៦។ នៅក្នុងសាលក្រមនោះ តុលាការអឺរ៉ុបមិនយល់ស្របតាមតុលាការបារាំងដែលថាលោក Mamère គ្មានសុទ្ធចិត្តនោះទេ ដោយមានសំអាងហេតុផលថា[20]៖

- ការនិយាយរបស់លោក Mamère ពាក់ព័ន្ធនឹងប្រធានបទដែលជាក្តីបារម្ភជាទូទៅ ពោលគឺការការពារបរិស្ថាន និងសុខភាពសាធារណៈ។ **[ធាតុផ្សំនៃសុទ្ធចិត្ត ៖ គោលបំណងសមរម្យ]**
- លោក Mamère និយាយក្នុងសមត្ថភាពគាត់ជាអ្នកតំណាងរាស្ត្រដែលជាប់ឆ្នោតម្នាក់ដែលលះបង់សម្រាប់បុព្វហេតុអេកូឡូស៊ី ដូច្នេះសំដីរបស់គាត់ត្រូវចាត់ទុកថា ការសម្តែងមតិខាងនយោបាយ ឬ"សកម្មជន" **[ធាតុផ្សំនៃសុទ្ធចិត្ត ៖ គ្មានភាពជាសត្រូវ** មិនមានជាតុស្អប់ឬគំនុំជាមួយលោក Pellerin ឡើយ)] ។
- បុគ្គលដែលនិយាយអំពីសាច់រឿងដែលជាក្តីបារម្ភជាទូទៅគួរមានឱកាសរួចពីការទទួលខុសត្រូវពេលណាគេបានសម្តែងសុទ្ធចិត្ត ឬនិយាយការពិត (ក្នុងករណីគាត់អះអាងពីអំពើ ឬព្រឹត្តិការណ៍អ្វីមួយ)។
- តាមបញ្ញត្តិនៃមាត្រា ៣៥ នៃច្បាប់ឆ្នាំ១៨៨១ តុលាការបារាំង បានរាំងជនជាប់ចោទក្នុងការឲ្យប្រើភស្តុតាងខាងអង្គហេតុនៃអំពើបរិហារកេរ្តិ៍ ដែលបានកន្លងមកជាង ១០ ឆ្នាំហើយទេ (ហេតុការណ៍នៃមហន្តរាយឆ្នាំ១៩៨៦) [21] ។ តុលាការអឺរ៉ុបមិនយល់ស្របជាមួយនឹងការអះអាងបែប

[19] អាស្តេរិច ឬ Asterix ជាតួអង្គក្នុងគំនូរតុកក្តាមាឌតូច តែមានប្រាជ្ញា ដែលរស់នៅក្នុងផ្នែកមួយនៃប្រទេសបារាំងសម័យដើមដែលគ្មានបច្ចាមិត្តណាមកដណ្តើមបាន សូម្បីទីកន្លែងផ្សេងៗនៃប្រទេសបារាំងត្រូវបានដោយពួករ៉ូម៉ាំងក្តី។ មានន័យថាមនុស្សគិតថាខ្លួនឯងពូកែលើគេរហូត។

[20] រឿងក្តី Mamère v. France សាលដីការបស់តុលាការសិទ្ធិមនុស្សអឺរ៉ុប, កថាខ័ណ្ឌ២៤ និង ២៥។

[21] រដ្ឋាភិបាលបារាំងអះអាងថា គោលការណ៍នេះមានហេតុផលមកពីឆន្ទៈរបស់អ្នកធ្វើច្បាប់បារាំងចង់ហាមឃាត់មិនឲ្យជំទាស់ដើម្បីរកការពិតទាក់ទងនឹងព្រឹត្តិការណ៍ចាស់ដោយគ្មានកំណត់ពេលវេលានោះទេ។ រដ្ឋាភិបាលបារាំងបន្ថែមទៀតថា អ្នកប្តឹងសាទុក្ខ (Maère) ទោះក្នុងករណីណាក៏ដោយមានឱកាសឈ្នះក្តីតិចណាស់ សូម្បីតែគាត់ត្រូវផ្អែកលើមធ្យោបាយការពារបែបនោះក៏ដោយ។

នេះទេ។ ក្នុងន័យទូទៅ តុលាការអឺរ៉ុបយល់ស្របនឹងតក្កភាព (ភាពមានហេតុផល) នៃការកំណត់អាជ្ញាយុកាលប្រភេទនេះ ព្រោះថាកាលណាព្រឹត្តិការណ៍ដែលបានអះអាងកន្លងផុតកាន់តែយូរទៅ គេកាន់តែពិបាកក្នុងការកំណត់ការពិតនៃព្រឹត្តិការណ៍នោះណាស់។ ប៉ុន្តែ ចំពោះព្រឹត្តិការណ៍ប្រវត្តិសាស្ត្រ ឬព្រឹត្តិការណ៍វិទ្យាសាស្ត្រវិញ អង្គហេតុថ្មីអាចផុសចេញច្រើនឆ្នាំក្រោយមកដែលធ្វើឲ្យការជជែកវែកញែកកាយបានព័ត៌មានកាន់តែសម្បូណ៌ ហើយការជជែកវែកញែកនោះជួយធ្វើឲ្យប្រជាពលរដ្ឋកាន់តែយល់ដឹងពីអ្វីដែលបានកើតឡើង។

- ស្តីពីការខ្វះនូវមជ្ឈន្តិកភាព (ភាពជាកណ្តាល) (Modération ou prudence dans l'expression) តុលាការអឺរ៉ុបមានមូលហេតុយ៉ាងនេះ ៖

  ១. តាមមតិរបស់តុលាការ ពាក្យសំដីដែលកើតជាការប្តឹងផ្តល់គ្នានៅក្នុងរឿងនេះ ទោះបីជាការចំអកឡុកឡឺយក្តី ក៏នៅតែស្ថិតក្នុងព្រំដែននៃការនិយាយបំផ្លើស ឬការនិយាយបង្កហេតុដែលនៅទទួលបានដែរ។ តុលាការរកមិនឃើញថាមានភាសាជេរប្រមាថច្បាស់ទែងនៅក្នុងពាក្យដែលគាត់និយាយនោះទេ ព្រោះថា ៖ ថ្វីបើគាត់ហៅលោក Pellerin ថាជា"តួបិសាច"ក្តី អត្ថន័យពិតប្រាកដនៃពាក្យគឺជាការប្រៀបធៀប ហើយការដែលថាលោក Mamère មិនសូវនិយាយសំដៅទៅលោក Pellerin ជាបុគ្គល ប៉ុន្តែជាតំណាងនៃអង្គភាពមួយដែលនៅជួរមុខទាក់ទងនឹងការផ្តល់ព័ត៌មានទៅសាធារណជនអំពីឥទ្ធិពលនៃមហន្តរាយ Chernobyl មានទៅលើប្រទេសបារាំង ដែលជាព្រឹត្តិការណ៍បីសាច បញ្ជាក់ឲ្យឃើញថាលោក Mamère មិននិយាយផ្ទាល់ទៅរក Pellerin ដែរ។

  ២. ចំពោះពាក្យថា "ចាត់ខ្លួនជាអាស្ទេរិច" នោះ វាគ្រាន់តែជារូបភាពនៃពពកវិទ្យុសកម្មមួយ "ជាប់គាំង" ត្រឹមព្រំដែនប្រទេសបារាំង ដែលគេអាចមើលឃើញដូចរូបត្លុកនៃស្ថានភាពមួយដែលលោក Mamère មើលឃើញ ដោយរំលឹកជាពិសេសពី ឥរិយាបថដ៏មានទំនុកចិត្តនៃអាជ្ញាធរនាំឲ្យបាត់សុភវិនិច្ឆ័យចំពោះទីតាំងភូមិសាស្ត្រនៃប្រទេសបារាំង (សូម្បីតែឥទ្ធិពលពិតប្រាកដពីមហន្តរាយពិតរបស់ Chernobyl មកលើប្រទេសបារាំង ក៏គ្មាននរណាដឹងច្បាស់ដែររហូតមកដល់សព្វថ្ងៃ)។

  ៣. ចំពោះឃ្លាដែលថា "និយាយច្រំដែលៗប្រាប់យើង..." ជាជាងនិយាយកុហកដោយចេតនាច្រំដែលៗ គេអាចមើលឃើញថា ឃ្លានេះគ្រាន់តែជាការនិយាយដល់សេចក្តីថ្លែងការណ៍ជាច្រើនដងរបស់នាយកនៃអាជ្ញាធរមជ្ឈិមសម្រាប់ការការពារប្រឆាំងនឹងកាំរស្មីអ៊ីយ៉ុងតាមបណ្តាញផ្សាយព័ត៌មានដែលកាលនោះដើមបណ្តឹងសាទុក្ខ (ដែលនៅពេលមហន្តរាយកើតឡើងដើមបណ្តឹងសាទុក្ខ[Mamère]ជាសាក្សីជាប់នឹងព្រឹត្តិការណ៍ជាងគេ)។

  ៤. ពាក្យសំដីទាំងនោះត្រូវពិចារណានៅក្នុងបរិបទរបស់វា ៖ ដើមបណ្តឹងសាទុក្ខបញ្ចេញប្រតិកម្មភ្លាមៗទៅលើការលើកឡើងរបស់អ្នកចូលរួមពិភាក្សាម្នាក់ទៀតអំពីសៀវភៅមួយដែលឧទ្ទិសជូនជនរងគ្រោះនៃមហន្តរាយ Chernobyl និងអំពីអារម្មណ៍រំជួលរបស់គាត់ដែលដុះចេញពីការអានសៀវភៅនោះ នៅក្នុងកម្មវិធីមួយដែលមិនសូវមានព័ត៌មានផ្សាយតែមានឆាកកំសាន្តច្រើន ហើយជាកម្មវិធីដែលទទួលបានប្រជាប្រិយភាពដោយសារតែនិយាយបំភ្លៃការពិត និងរបៀបជាបង្កឲ្យភាពចំរូងចំរាស់។

- តាមទស្សនៈរបស់តុលាការ ហេតុផលដែលបានផ្តល់ដោយតុលាការក្នុងស្រុក(តុលាការបារាំង)

សម្រាប់គាំទ្រការរកឃើញរបស់ខ្លួនថាគ្មានសុទ្ធចិត្ត ស្តែងឲ្យឃើញនូវការបកស្រាយដ៏រឹងកំ-ព្រឹសនូវពាក្យសំដីដើមបណ្តឹងសាទុក្ខ ដែលមិនងាយស្រួលនឹងសម្រុះសម្រួលជាមួយនឹងសេរីភាពខាងការបញ្ចេញមតិ។

- តុលាការអឺរ៉ុបមិនយល់ស្របជាមួយនឹងតុលាការបារាំងដែលថា Mamère ខ្វះសុទ្ធចិត្ត។

## ៦. បញ្ហានីតិវិធី ៖ តួនាទីព្រះរាជអាជ្ញា និងដើមបណ្តឹងរដ្ឋប្បវេណី

**ក.** ទោះបីការបរិហារកេរ្តិ៍ជាសាធារណៈជាបទល្មើសមជ្ឈិមក្តី ក៏ព្រះរាជអាជ្ញាមិនអាចផ្តើមបណ្តឹងដោយខ្លួនឯងបានឡើយ។ បណ្តឹងត្រូវតែធ្វើចេញពីបុគ្គលដែលត្រូវបានគេបរិហារកេរ្តិ៍ (មាត្រា ៣០៩ ក្រមព្រហ្មទណ្ឌ)។ បណ្តឹងអាជ្ញាបរិហារកេរ្តិ៍នេះនឹងត្រូវរំលត់ភ្លាម បើដើមបណ្តឹងបានដកពាក្យបណ្តឹង។

**ខ.** ព្រះរាជអាជ្ញាអាចជាដើមបណ្តឹងអាជ្ញាបាន កាលបើការបរិហារកេរ្តិ៍កើតចេញពីមូលហេតុជាតិកំណើត ជាតិពិន្ទុ ពូជសាសន៍ ឬសាសនា។

**គ.** បើជនដែលត្រូវគេបរិហារកេរ្តិ៍ចង់ប្តឹងបណ្តឹងព្រហ្មទណ្ឌដើម្បីទាមទារសំណងខូចខាត គាត់ត្រូវតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណី (ក្រមនីតិវិធីព្រហ្មទណ្ឌ៖ មាត្រា ២ ស្តីពីការបែងចែកបណ្តឹងព្រហ្មទណ្ឌនិងបណ្តឹងរដ្ឋប្បវេណី មាត្រា ៥ ស្តីពីការតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណី) ។

## ៧. ដើមបណ្តឹងរដ្ឋប្បវេណី

យោងតាមក្រមនីតិវិធីព្រហ្មទណ្ឌ មាត្រា៥ ជនរងគ្រោះនៃបទឧក្រិដ្ឋ ឬបទមជ្ឈិមអាចដាក់ពាក្យបណ្តឹង ដោយតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណីនៅចំពោះមុខចៅក្រមស៊ើបសួរ។ បញ្ហាមួយកើតឡើង ៖ ដោយហេតុថាបណ្តឹងបរិហារកេរ្តិ៍ ទាមទារឲ្យមានដើមបណ្តឹងរដ្ឋប្បវេណីប្តឹងទៅព្រះរាជអាជ្ញាដើម្បីឲ្យព្រះរាជអាជ្ញាដំណើរការបណ្តឹងបាន សំណួរចោទសួរថា តើជនរងគ្រោះអាចតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណីជាមួយចៅក្រមស៊ើបសួរនោះយ៉ាងដូចម្តេចវិញ? តើបណ្តឹងអាជ្ញាគួរត្រូវបានដាក់មុន ហើយបន្ទាប់មកតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណីនៅពេលក្រោយជាមួយចៅក្រមស៊ើបសួរ ពេលដែលចៅក្រមស៊ើបសួរទទួលដីកាបញ្ជូនរឿងឲ្យស៊ើបសួរឬ?

មានជម្រើសពីរសម្រាប់ជនរងគ្រោះដើម្បីតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណី។ ជម្រើសទីមួយគឺ ជនរងគ្រោះត្រូវតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណី នៅពេលដែលព្រះរាជអាជ្ញាបានដាក់ដីកាបញ្ជូនរឿងឲ្យស៊ើបសួរទៅចៅក្រមស៊ើបសួរ។ ជម្រើសមួយទៀតគឺ ជនរងគ្រោះដាក់ពាក្យបណ្តឹងទៅចៅក្រមស៊ើបសួរ។

- **<u>ជម្រើសទី ១ បណ្តឹងអាជ្ញាផ្តើមឡើងដោយព្រះរាជអាជ្ញា</u>** ៖ ជនរងគ្រោះពីបទបរិហារកេរ្តិ៍ត្រូវប្តឹងទៅព្រះរាជអាជ្ញាសិន ដើម្បីឲ្យព្រះរាជអាជ្ញាចាត់ការបណ្តឹងព្រហ្មទណ្ឌ។ រួចមកដើមបណ្តឹងត្រូវប្តឹងចៅក្រមស៊ើបសួរ នៅពេលដែលដីកាបញ្ជូនរឿងឲ្យស៊ើបសួរបានមកដល់ដៃចៅក្រមស៊ើបសួរដើម្បីតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណី។ ជនរងគ្រោះអាចប្រកាសដល់ចៅក្រមស៊ើបសួរថា គាត់ជាភាគីនៃដើមបណ្តឹងរដ្ឋប្បវេណីពេលដែលចៅក្រមស៊ើបសួរបើកការស៊ើបសួរ (មាត្រា១៣៧នៃក្រមនីតិវិធីព្រហ្មទណ្ឌ)។ ជនរងគ្រោះអាចប្រកាសខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណីដោយផ្ទាល់មាត់ ឬដោយលិខិតទៅចៅក្រមស៊ើបសួរបាន។ តែតាមជម្រើសនេះគេនៅតែមានចំណោទសួរថា តើព្រះរាជអាជ្ញាអាចចាត់ការបណ្តឹងបរិហារកេរ្តិ៍

តាមរយៈបណ្តឹងសាមញ្ញ (បណ្តឹងរបស់មនុស្សម្នាក់ដែលមិនទាន់បានតាំងខ្លួនជា ដើមបណ្តឹងរដ្ឋប្បវេណី) បានដែរឬទេ[22] ។ បណ្តឹងសាមញ្ញគឺជាបណ្តឹងដែលអនុញ្ញាតឲ្យជនរងគ្រោះទាមទារឲ្យផ្តន្ទាទោសចារីនៃបទល្មើស ដោយជនរងគ្រោះផ្តល់ព័ត៌មានដល់ប៉ូលីសកងអាវុធហត្ថ ឬ ព្រះរាជអាជ្ញា[23]។ សំណួរមួយទៀត បើព្រះរាជអាជ្ញាប្រើនីតិវិធីនាំយកមកជម្រះផ្ទាល់[24] (ដោយមិនបើកការស៊ើបសួរដោយចៅក្រមស៊ើបសួរ) តើជនរងគ្រោះត្រូវតាំងខ្លួនជាមួយចៅក្រមជំនុំជម្រះបានដែរ ឬទេ[25] ? បើជនរងគ្រោះមិនអាចតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណីបាន តើគាត់អាចទាមទារការខូចខាតបានដែរ ឬទេ?[26]។

- **<u>ជម្រើសទី ២ ការដាក់បណ្តឹងជាមួយចៅក្រមស៊ើបសួរ</u>** ៖ ស្ថានភាពនេះកើតឡើងបានលុះណាតែគ្មានដីកាបញ្ជូនរឿងឲ្យស៊ើបសួរដែលធ្វើឡើងដោយព្រះរាជអាជ្ញា។ ជនរងគ្រោះអាចទៅជួប និងដាក់បណ្តឹងដោយផ្ទាល់ជាមួយនឹងចៅក្រមស៊ើបសួរ (មាត្រា១៣៨ ក្រមនីតិវិធីព្រហ្មទណ្ឌ)។ ជនរងគ្រោះត្រូវប្រកាសចំពោះមុខចៅក្រមស៊ើបសួរអំពីបណ្តឹងខ្លួនថាខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណី។ បន្ទាប់មកបណ្តឹងរបស់ជនគ្រោះនឹងត្រូវបញ្ជូនទៅព្រះរាជអាជ្ញា (មាត្រា១៣៩ក្រមនីតិវិធីព្រហ្មទណ្ឌ)។ ចេញពីចំណុចនេះលំហូរធម្មតានៃនីតិវិធីបណ្តឹងអាជ្ញាចាប់ផ្តើម។ បន្តពីនេះទៅព្រះរាជអាជ្ញាក្លាយជាដើមបណ្តឹងនៃបណ្តឹងអាជ្ញា។ បន្ទាប់ពីពិនិត្យលើបណ្តឹងមានធាតុផ្សំគ្រប់គ្រាន់ហើយ ព្រះរាជអាជ្ញាបញ្ជូនដីកាបញ្ជូនរឿងឲ្យស៊ើបសួរទៅចៅក្រមស៊ើបសួរ។
- **<u>ការតម្កល់</u> ៖** ក្នុងឋានៈខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណី ជនរងគ្រោះត្រូវបង់ប្រាក់តម្កល់ទៅតុលាការដើម្បីជាកិច្ចធានាទល់នឹងបណ្តឹងដោយបំពានឬបណ្តឹងអូសបន្លាយ (មាត្រា១៤១ ក្រមនីតិវិធីព្រហ្មទណ្ឌ) នេះម្យ៉ាង ហើយម្យ៉ាងវិញទៀត សម្រាប់ឲ្យតុលាការដំណើរការរឿងក្តីនោះផងដែរ (មាត្រា១៤០ ក្រមនីតិវិធីព្រហ្មទណ្ឌ)។ តុលាការនឹងលើកបណ្តឹងចោល បើប្រាក់តម្កល់មិនត្រូវបានបង់តាមកាលកំណត់។ ប៉ុន្តែ បើដើមបណ្តឹងរដ្ឋប្បវេណីនោះជាជនក្រីក្រពុំមានលទ្ធភាពបង់ តុលាការអាចលើកលែងការបង់ប្រាក់តម្កល់នោះបាន។
  នៅចុងបញ្ចប់នីតិវិធី ប្រាក់តម្កល់នឹងត្រូវប្រគល់ឲ្យដើមបណ្តឹងរដ្ឋប្បវេណីវិញ។ ប៉ុន្តែបើបណ្តឹងធ្វើដោយបំពាន តុលាការនឹងសម្រេចពិន័យដើមបណ្តឹងរដ្ឋប្បវេណីនោះ ប៉ុន្តែប្រាក់ពិន័យនោះមិនត្រូវលើសពីប្រាក់ដែលបានដាក់តម្កល់ឡើយ។ បុគ្គលដែលត្រូវបានគេប្តឹង

---

[22] មាត្រា ៦ ក្រមនីតិវិធីព្រហ្មទណ្ឌ ៖ "បុគ្គលគ្រប់រូបដែលប្រកាសថា ខ្លួនជាអ្នករងគ្រោះនៃបទល្មើស អាចដាក់ពាក្យប្តឹងបាន។ ពាក្យប្តឹងសាមញ្ញ គ្មានអានុភាពនាំឲ្យធ្វើការចោទប្រកាន់ជាបទព្រហ្មទណ្ឌទេ។"

[23] សូមមើលនិយមន័យនៃ "បណ្តឹងសាមញ្ញ" នៅក្នុងទំព័រ http://www.leparticulier.fr/jcms/p1_1520856/la-plainte-simple។

[24] មាត្រា ២៩១ ក្រមនីតិវិធីព្រហ្មទណ្ឌ ៖ "ក្នុងរឿងព្រហ្មទណ្ឌសាលាដំបូងត្រូវបានទទួលបណ្តឹងដោយ៖ ...ដីកាបញ្ជូនទៅតុលាការជំនុំជម្រះដោយផ្ទាល់របស់ព្រះរាជអាជ្ញា"។

[25] មាត្រា ៣១១ ក្រមនីតិវិធីព្រហ្មទណ្ឌ៖ "ក្នុងពេលសវនាការ ការតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណីធ្វើតាមការប្រកាសប្តឹងសាមញ្ញនៅចំពោះមុខក្រឡាបញ្ជី។ ការប្តឹងនេះត្រូវចុះនិទ្ទេសនៅក្នុងកំណត់ហេតុនៃសវនាការ។ ការតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណី មិនអាចទទួលបានទេក្រោយពីសេចក្តីសន្និដ្ឋានសុំរបស់ព្រះរាជអាជ្ញាលើអង្គសេចក្តី។ ជនរងគ្រោះដែលបានតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណីរួចហើយនៅពេលស៊ើបសួរនោះ មិនចាំបាច់បំពេញទម្រង់ការនេះជាថ្មីទៀតទេនៅមុខតុលាការ។"

[26] មាត្រា ២ ក្រមនីតិវិធីព្រហ្មទណ្ឌ ៖ "...បណ្តឹងរដ្ឋប្បវេណី មានគោលបំណងធ្វើឲ្យបានការជួសជុលការខូចខាត ដែលបណ្តាលមកពីអំពើល្មើសដល់ភាគីរងគ្រោះ ហើយក្នុងគោលបំណងនេះ ឲ្យអ្នករងគ្រោះបានទទួលសំណងជម្ងឺចិត្តធួនល្មមនឹងព្យសនកម្មដែលខ្លួនបានទទួល។"

ដោយបំពានអាចដាក់បណ្ដឹងទាមទារសំណងនៃការខូចខាតពីដើមបណ្ដឹងរដ្ឋប្បវេណីនោះបាន។

ក្រមនីតិវិធីព្រហ្មទណ្ឌមិនកំណត់អំពីចំនួនជាក់លាក់នៃប្រាក់តម្កល់នេះឡើយ។

ជម្រើសទី ២ អាចធ្វើទៅបាន កាលបើស្ថាប័នចៅក្រមស៊ើបអង្កេតមានអត្ថិភាពជាអង្គភាពមួយ ឧទាហរណ៍ ជាមន្ទីរចៅក្រមស៊ើបសួរមិនមែនជាការតែងតាំងចៅក្រមស៊ើបសួរចំពោះកិច្ច ដូចក្នុងករណីនៃការអនុវត្តនៅប្រទេសកម្ពុជាបច្ចុប្បន្ននេះទេ។ ប្រទេសកម្ពុជាគ្មានចៅក្រមស៊ើបអង្កេតជាអចិន្ត្រៃយ៍ទេ។ គាត់ត្រូវបានព្រះរាជអាជ្ញាតែងតាំងពេលណាមានរឿងព្រហ្មទណ្ឌដែលត្រូវបានបញ្ជូនមកឲ្យស៊ើបសួរប៉ុណ្ណោះ។

## នីតិវិធីបណ្ដឹងនៃការសុំទទួលស្គាល់ជាភាគីដើមបណ្ដឹងរដ្ឋប្បវេណីនៅប្រទេសបារាំង

(ប្រភព: http://vosdroits.service-public.fr/F20798.xhtml)

ក. បុរេលក្ខខណ្ឌសម្រាប់ការដាក់បណ្ដឹងសុំទទួលស្គាល់ជាភាគីដើមបណ្ដឹងរដ្ឋប្បវេណី

ទី១ ៖ ជនរងគ្រោះត្រូវដាក់ពាក្យបណ្ដឹងសាមញ្ញ[27]មួយជាមួយព្រះរាជអាជ្ញា។

ទី២ ៖ ព្រះរាជអាជ្ញាមិនព្រមធ្វើបណ្ដឹងអាជ្ញា ហើយចេញដីកាតម្កល់រឿងមិនចាត់ការ ដោយចេញលិខិតប្រាប់ទៅដើមបណ្ដឹងសាមញ្ញថាខ្លួនមិនចាត់ការក្នុងរឿងនេះទេ។

ខ. ដាក់ពាក្យបណ្ដឹងដោយតាំងខ្លួនជាដើមបណ្ដឹងរដ្ឋប្បវេណី

ជំហានទី ១ ៖ រៀបចំបណ្ដឹង ដោយចង្អុលបង្ហាញពីអាសយដ្ឋានរបស់ភាគីដើមបណ្ដឹងរដ្ឋប្បវេណី និងចុងចម្លើយ ពីចេតនាចង់តាំងខ្លួនជាដើមបណ្ដឹងរដ្ឋប្បវេណី ពីប្រភេទនៃបទល្មើស និងបទបញ្ញត្តិច្បាប់ដែលយកមកអនុវត្ត រៀបរាប់ពីអង្គហេតុដែលពាក់ព័ន្ធ បញ្ជីសាក្សី (បើមាន) និង ចំនួនសំណងនៃការខូចខាត ចុះកាលបរិច្ឆេទ និងចុះហត្ថលេខា។

ជំហានទី ២ ៖ ផ្ញើសំណុំឯកសារនេះទៅការិយាល័យចៅក្រមស៊ើបសួរ ដោយផ្ញើទៅកាន់ប្រធានការិយាល័យចៅក្រមស៊ើបសួរ។

ចំពោះបទល្មើសឧក្រិដ្ឋ បទល្មើសសារព័ត៌មាន ឬបទល្មើសបោះឆ្នោត ជនរងគ្រោះមិនចាំបាច់ប្ដឹងទៅព្រះរាជអាជ្ញាសិនទេ។ ជនរងគ្រោះត្រូវដាក់បណ្ដឹងផ្ទាល់ទៅចៅក្រមស៊ើបសួរតែម្ដង។

គ. អត្ថប្រយោជន៍នៃការដាក់ពាក្យជាដើមបណ្ដឹងរដ្ឋប្បវេណី

១. ដើម្បីឲ្យបណ្ដឹងអាជ្ញាមានដំណើរការ

២. មេធាវីដើមបណ្ដឹងរដ្ឋប្បវេណីអាចមើលសំណុំរឿងបាន

៣. ភាគីដើមបណ្ដឹងរដ្ឋប្បវេណីត្រូវទទួលដំណឹងអំពីដំណើរការទៅមុខនៃរឿងក្ដី

៤. ភាគីដើមបណ្ដឹងរដ្ឋប្បវេណីអាចស្នើសុំឲ្យចៅក្រមស៊ើបសួរចាត់វិធានការស៊ើបអង្កេតជាក់លាក់ណាមួយ

៥. ភាគីដើមបណ្ដឹងរដ្ឋប្បវេណីអាចធ្វើបណ្ដឹងឧទ្ធរណ៍បាន។

---

[27] បណ្ដឹងមួយដែលបុគ្គលម្នាក់បានដាក់ទៅព្រះរាជអាជ្ញាដើម្បីជូនព័ត៌មានថា គាត់ជាជនរងគ្រោះនៃបទល្មើសមួយ ហើយស្នើឲ្យព្រះរាជអាជ្ញាធ្វើបណ្ដឹងអាជ្ញាចំពោះជនល្មើស និងទាមទារសំណងនៃការខូចខាត។ បណ្ដឹងសាមញ្ញមួយអាចដាក់ដោយផ្ទាល់ទៅព្រះរាជអាជ្ញា ឬតាមរយៈប៉ូលីស។ បណ្ដឹងនេះមិនចាំបាច់និយាយឲ្យបានច្បាស់លាស់អំពីប្រភេទនៃបទល្មើស និងបញ្ញត្តិច្បាប់ដែលត្រូវចោទប្រកាន់ជនល្មើសឡើយ។

## ឃ. <u>គុណវិបត្តិនៃដើមបណ្តឹងរដ្ឋប្បវេណី</u>

១. ត្រូវបង់ប្រាក់កម្រៃជាកិច្ចធានាបណ្តឹងដោយបំពាន

២. ត្រូវចង្អុលបង្ហាញពីបទល្មើសជាក់លាក់ និងបញ្ញត្តិច្បាប់ដែលអាចយកមកអនុវត្តបាន។ កិច្ចការនេះ ត្រូវការមានអ្នកជំនាញច្បាប់ជួយព្រាងពាក្យបណ្តឹង

៣. អាចមើលសំណុំរឿងបានតែចំពោះមេធាវីប៉ុណ្ណោះ

៤. ដើមបណ្តឹងរដ្ឋប្បវេណីមិនអាចជាសាក្សីបានទេ។ តុលាការអាចស្តាប់តែចម្លើយរបស់គាត់ប៉ុណ្ណោះ

៥. បើភាគីដើមបណ្តឹងរដ្ឋប្បវេណីចាញ់ក្តី គាត់ត្រូវសងសំណងនៃការខូចខាតទៅចុងចម្លើយ ថ្លៃដំណើរការនីតិវិធី (ឬក្នុងករណីខ្លះអាចទទួលខុសត្រូវចំពោះបណ្តឹងបរិហារបង្កាច់កេរ្តិ៍)។

# គន្ថនិទ្ទេស (ឯកសារយោង)


1. Code Pénal : Nouveau Code Pénal, Ancien Code Pénal, Dalloz, 1994-95
2. Jean Larguier, Anne-Marie Larguier, Droit pénal spécial, Dalloz, 11e édition, 2000
3. Michaele Sanders, Fact/Opnion Disticntion: An Analysis of the Subjectivity of Language and Law, Marquetter Law Review, 1987 (Available at http://scholarship.law.marquette.edu/cgi/viewcontent.cgi?article=1846&context=mulr)
4. Jeffrey L. Kirchmeier, The Illusion of the Fact-Opinion Distinction in Defamation Law, Case Western Reserve Law Review, 1988-89
5. 750 F2d 970 Ollman v. Evans (http://openjurist.org/print/288567)
6. Sim v. Stretch [1936] 2 All ERR 1237, 1240, per Lord Atkin.
7. Sarah Thornthon v. Telegraph Media Group Limited (http://www.5rb.com/docs/Thornton%20v%20Telegraph%20Media%20Group%20Ltd%20%5B2010%5D%20EWHC%201414%20(QB).pdf)
8. Cour de cassation, Chambre criminelle, Arrêt no. 2939 du 17 juin 2008, available at :http://www.courdecassation.fr/jurisprudence_2/chambre_criminelle_578/arrets_579/br_arret_11684.html#
9. Porter plainte avec constitution de partie civile, available at : http://vosdroits.service-public.fr/F20798.xhtml

# ជំពូក ២

# ការប្តឹងបរិហារបទ្ទាប់គេរ្កី

## ១. ប្រវត្តិច្បាប់

សិទ្ធិជាមូលដ្ឋានរបស់បុគ្គលម្នាក់ ដើម្បីរកដំណោះស្រាយ និងសំណងនៅពេលដែលសិទ្ធិរបស់គេត្រូវរំលោភបំពានមានចែងនៅក្នុងមាត្រា ២ នៃកតិកាសញ្ញាអន្តរជាតិស្តីពីសិទ្ធិពលរដ្ឋ និងសិទ្ធិនយោបាយ។ រដ្ឋត្រូវធានាថាការរំលោភសិទ្ធិ និងសេរីភាពដែលមានចែងក្នុងកតិកាសញ្ញានេះ ត្រូវតែទទួលការដោះស្រាយដោយតុលាការ ឬអាជ្ញាធរដែលមានសមត្ថកិច្ច ៖

**មាត្រា ២.៣ កតិកាសញ្ញាអន្តរជាតិស្តីពីសិទ្ធិពលរដ្ឋ និងសិទ្ធិនយោបាយ**

៣. រដ្ឋភាគីនីមួយៗនៃកតិកាសញ្ញានេះប្តេជ្ញា ៖

(ក) ធានាថាជនណាដែលត្រូវគេរំលោភសិទ្ធិ ឬសេរីភាពរបស់ខ្លួនដែលទទួលស្គាល់ដោយកតិកាសញ្ញានេះ ជននោះមានសិទ្ធិឲ្យមានសំណងត្រឡប់ដោយមានប្រសិទ្ធភាព ទោះបីការរំលោភនោះត្រូវបានប្រព្រឹត្តដោយជនដែលបំពេញមុខនាទីរាជការក្តី។

(ខ) ធានាថាជនណាដែលប្តឹងឲ្យមានការដោះស្រាយបែបនេះ ត្រូវមានសិទ្ធិឲ្យអាជ្ញាធរមានសមត្ថកិច្ចខាងយុត្តិធម៌ខាងរដ្ឋបាល ឬខាងនីតិបញ្ញត្តិ ឬអាជ្ញាធរមានសមត្ថកិច្ចដទៃទៀតសម្រេចឲ្យខ្លួន ដោយយោងតាមច្បាប់របស់រដ្ឋនោះ និងត្រូវបង្កើតលទ្ធភាពនៃការប្តឹងទៅតុលាការផង។

(គ) ធានាថា អាជ្ញាធរមានសមត្ថកិច្ចត្រូវអនុវត្តនូវសេចក្តីសម្រេចដែលផ្តល់ជាសំណងជម្ងឺចិត្ត។

បុគ្គលម្នាក់មានសេរីភាពក្នុងការធ្វើបណ្តឹងទៅតុលាការពេលដែលសិទ្ធិ និងសេរីភាពរបស់គាត់ត្រូវបានរំលោភបំពាន ហើយតុលាការមានកាតព្វកិច្ចត្រូវដោះស្រាយបញ្ហានេះឲ្យបុគ្គលនោះ។ សិទ្ធិដូចគ្នានេះក៏មានចែងនៅក្នុងរដ្ឋធម្មនុញ្ញមាត្រា ៣៩ កម្ពុជាដែលទាក់ទងនឹងការរំលោភបំពានដែលបង្កឡើងដោយភ្នាក់ងាររដ្ឋ ឬអង្គការសង្គម ៖

**មាត្រា ៣៩ នៃរដ្ឋធម្មនុញ្ញ**

ប្រជាពលរដ្ឋខ្មែរ មានសិទ្ធិប្តឹងបរិហារ ប្តឹងតវ៉ា ឬប្តឹងទារសំណងជួសជុលការខូចខាត ដែលបណ្តាលមកពីអំពើខុសច្បាប់របស់អង្គការរដ្ឋ របស់អង្គការសង្គម និងរបស់បុគ្គលិកនៃអង្គការទាំងនោះ។ ការដោះស្រាយបណ្តឹងតវ៉ា និងសំណងជួសជុលការខូចខាតជាសមត្ថកិច្ចរបស់តុលាការ។

នៅក្នុងបណ្តឹងព្រហ្មទណ្ឌ សិទ្ធិស្វែងរកការសង្គ្រោះពីការរំលោភពីបទល្មើសព្រហ្មទណ្ឌ មានចែងក្នុងមាត្រា ៥ និងមាត្រា ៦ នៃក្រមនីតិវិធីព្រហ្មទណ្ឌ។

សិទ្ធិក្នុងការស្វែងរកការជួសជុលតាមផ្លូវតុលាការ ខុសពីការប្រើប្រាស់តុលាការដើម្បីរំលោភសិទ្ធិបុគ្គលផ្សេងទៀត ដោយបង្វែរអង្គហេតុដើម្បីទម្លាក់ការទទួលខុសត្រូវទៅលើបុគ្គលនោះ។

សិទ្ធិក្នុងការស្វែងរកការជួសជុលមានន័យថា នរណាម្នាក់ដែលបាត់សិទ្ធិរបស់ខ្លួន ឬទទួលរងការរំលោភពីបុគ្គលផ្សេងទៀត មានសិទ្ធិសុំឲ្យតុលាការជួសជុលសិទ្ធិរបស់ខ្លួនឡើងវិញ។ បុគ្គលដែលប្រើប្រាស់តុលាការដើម្បីទម្លាក់ការទទួលខុសត្រូវទៅលើនរណាម្នាក់ ជាជនដែលមិនទទួលរងនូវការបាត់បង់សិទ្ធិណាមួយផងនោះទេ ប៉ុន្តែគាត់ជាអ្នករំលោភសិទ្ធិគេ។ គាត់ជាអ្នកប្រព្រឹត្តអំពើល្មើសបរិហារបង្កាច់កេរ្តិ៍។

បទប្តឹងបរិហារបង្កាច់កេរ្តិ៍មានលក្ខណៈសមមូលនឹងការប្តឹងដោយទុច្ចរិត (Malicious prosecution) នៅក្នុងប្រព័ន្ធច្បាប់អម្បូរខំម៉ុនល័រ។ ភាពខុសគ្នាគឺថាបទប្តឹងបរិហារបង្កាច់កេរ្តិ៍ជាបទល្មើសព្រហ្មទណ្ឌ រីឯការប្តឹងដោយទុច្ចរិតជាអំពើអនីត្យានុកូល[28]។ បទប្តឹងបរិហារបង្កាច់កេរ្តិ៍មិនចែងនៅក្នុងច្បាប់ព្រហ្មទណ្ឌអ៊ុនតាក់ទេ។ បទល្មើសនេះមានចែងនៅក្នុងក្រមព្រហ្មទណ្ឌឆ្នាំ២០០៩។

និយាយឲ្យងាយស្តាប់ បទប្តឹងបរិហារបង្កាច់កេរ្តិ៍ជាបទល្មើសនៃការប្រើប្រាស់បណ្តឹងព្រហ្មទណ្ឌដោយខុស ដើម្បីបង្ករបួសស្នាមដល់នរណាម្នាក់ដែលមិនបានប្រព្រឹត្តអំពើល្មើសណាមួយសោះ។ វាដូចគ្នាទៅនឹងការប្រឌិតរឿងក្តីមួយដើម្បីធ្វើឲ្យមានការផ្តន្ទាទោសនរណាម្នាក់។ ការមិនបានជោគជ័យនៅក្នុងការផ្តន្ទាទោសនរណាម្នាក់នៅក្នុងបណ្តឹងព្រហ្មទណ្ឌគឺមានភាពខុសគ្នាទាំងស្រុងនឹងបទប្តឹងបរិហារបង្កាច់កេរ្តិ៍។ ការគ្រាន់តែលោកអ្នកមិនបានជោគជ័យក្នុងបណ្តឹងព្រហ្មទណ្ឌ គឺមិនដូចគ្នាទៅនឹងការចោទប្រកាន់ដោយព្យាបាទឡើយ។

ថ្វីបើបទប្តឹងបរិហារបង្កាច់កេរ្តិ៍អាចប៉ះពាល់ដល់កិត្តិយសរបស់អ្នកដទៃ បទល្មើសនេះមិនមែនជាការបរិហារកេរ្តិ៍នោះទេ។ ខណៈដែលការបរិហារកេរ្តិ៍គឺជាបទល្មើសនៃការនិយាយការប្តឹងបរិហារបង្កាច់កេរ្តិ៍គឺជាបទល្មើសមួយនៃការប្តឹង។

## ២. និយមន័យច្បាប់នៃបទប្តឹងបរិហារបង្កាច់កេរ្តិ៍

មាត្រា ៣១១នៃក្រមព្រហ្មទណ្ឌចែងថា ៖

> ការប្តឹងបរិហារបង្កាច់កេរ្តិ៍ គឺជាអំពើប្តឹងបរិហារអំពីអំពើដែលគេដឹងថាមិនពិត ហើយដែលនាំឲ្យមានទណ្ឌកម្មព្រហ្មទណ្ឌ ឬវិន័យ កាលបើការប្តឹងបរិហារនេះត្រូវបានផ្ញើទៅដល់ ៖
> - អាជ្ញាធរមានសមត្ថកិច្ចដើម្បីចាត់ការដូចជា ចៅក្រម មន្ត្រីនគរបាលយុត្តិធម៌ ឬយោជក ឬ
> - បុគ្គលដែលមានអំណាចប្តឹងទៅអាជ្ញាធរមានសមត្ថកិច្ច។

ការប្តឹងបរិហារបង្កាច់កេរ្តិ៍ត្រូវផ្តន្ទាទោសដាក់ពន្ធនាគារពី ១ (មួយ) ខែ ទៅ ១ (មួយ) ឆ្នាំ និងពិន័យជាប្រាក់ពី ១០០.០០០ (មួយសែន) រៀល ទៅ ២.០០០.០០០ (ពីរលាន) រៀល ។

## ៣. ធាតុផ្សំនៃបទបរិហារកេរ្តិ៍បង្កាច់កេរ្តិ៍

### ក. ការដាក់បណ្តឹង

បណ្តឹងមួយដែលដាក់ទៅតុលាការឬអាជ្ញាធរណាមួយ អាចមានការរៀបរាប់ពីអង្គហេតុមួយចំនួនដែលតាមអង្គហេតុនោះ តុលាការឬអាជ្ញាធរវិនិច្ឆ័យដាក់ទោសព្រហ្មទណ្ឌឬវិន័យទៅលើបុគ្គលណាមួយដែលគេស្គាល់អត្តសញ្ញាណ ឬដែលគេអាចស្គាល់អត្តសញ្ញាណ។ បណ្តឹងបែបនេះអាចជាមូលហេតុនាំឲ្យមានបទប្តឹងបរិហារបង្កាច់កេរ្តិ៍។ ពាក្យបណ្តឹងបរិហារបង្កាច់កេរ្តិ៍មានប្រសិទ្ធិភាពចាប់ពីពេលដែលបណ្តឹង

[28] សូមមើលទំព័រះ http://www.encyclo.co.uk/define/malicious%20prosecution : បណ្តឹងបរិហារបង្កាច់កេរ្តិ៍ គឺជាអំពើអនីត្យានុកូលដោយចេតនានៃច្បាប់កំម៉ុនល័រ ដែលមានធាតុផ្សំ (១) ដាក់ពាក្យបណ្តឹង (ជារដ្ឋប្បវេណីក្តី ឬ ព្រហ្មទណ្ឌក្តី) ដោយចេតនា និង ដោយគំនិតព្យាបាទ (២) ហើយដែលគ្មានមូលដ្ឋានជាគំរុយបន្តិចសោះ។

នោះបានទៅដល់ដៃតុលាការ ឬ អាជ្ញាធរមានសមត្ថកិច្ចចាត់ការបណ្តឹងនោះ។ បើមានតែពាក្យបណ្តឹង តែបណ្តឹងនោះមិនទាន់ធ្លាក់ទៅក្នុងដៃតុលាការ ឬអាជ្ញាធរមានសមត្ថកិច្ចចាត់ការបណ្តឹងនោះទេ នោះបណ្តឹងនោះគ្មានប្រសិទ្ធិភាពទេ ហើយជនរងគ្រោះក៏មិនអាចប្តឹងអ្នកកាន់បណ្តឹងពីបទបរិហារបង្កាច់កេរ្តិ៍បានដែរ។ ការកំណត់ថាបណ្តឹងត្រូវតែទៅដល់ដៃតុលាការ ឬ អាជ្ញាធរមានសមត្ថកិច្ចចាត់ការបណ្តឹងនោះ ក៏ដោយសារតែច្បាប់មិនចង់ដាក់ទណ្ឌកម្ម "ការប៉ុនប៉ង" ប្រព្រឹត្តបទល្មើសប្តឹងបរិហារបង្កាច់កេរ្តិ៍[29]។ បណ្តឹងបរិហារបង្កាច់កេរ្តិ៍អាចជាពាក្យបណ្តឹងសរសេរ ឬជាបណ្តឹងផ្ទាល់មាត់ (ដូចជាបណ្តឹងផ្ទាល់មាត់រាយការណ៍ប្រាប់នគរបាល ឬព្រះរាជអាជ្ញាជាដើម)។

តាមច្បាប់បារាំង ដើម្បីចោទប្រកាន់ពីបទប្តឹងបរិហារបង្កាច់កេរ្តិ៍ គេត្រូវតែសំអាងលើគោលការណ៍សយម្ភូតភាព ( Principe de Spontanéity; Principle of spontaneity) មានន័យថាបណ្តឹងបរិហារបង្កាច់កេរ្តិ៍ត្រូវតែផុសចេញពីចិត្តឯង (Crim. 16 oct. 1969: Bull. Crim. n° 254)។ បណ្តឹងបរិហារបង្កាច់កេរ្តិ៍ ជាបណ្តឹងដែលផ្តើមឡើងដោយម្ចាស់បណ្តឹងផ្ទាល់ដែលនិយាយ ឬពោលកុហកមួលបង្កាច់ជនណាម្នាក់នៅចំពោះមុខអាជ្ញាធរមានសមត្ថកិច្ច (Crim. 16 juin 1988)។ បើមនុស្សម្នាក់ឆ្លើយឲ្យការណ៍ទៅចៅក្រម ឬអាជ្ញាធរមានសមត្ថកិច្ច នៅពេលសួរចម្លើយដោយនិយាយកុហកដើម្បីទម្លាក់កំហុសទៅលើអ្នកណាម្នាក់ ការឆ្លើយកុហកនោះ មិនមែនជាការផ្តើមបណ្តឹងដោយចិត្តឯងទេ[30]។ ជនជាប់ចោទម្នាក់ ដែលត្រូវបានបញ្ជូនមកតុលាការបដិសេធថាខ្លួនមិនបានចុះហត្ថលេខាលើកំណត់ហេតុដែលធ្វើដោយកងអាវុធហត្ថនោះ ហើយចោទថាកងអាវុធហត្ថមានកំហុសធ្វើឲ្យខូចប្រយោជន៍របស់ខ្លួន។ ចម្លើយនេះមិនត្រូវបានចាត់ទុកថាជាបណ្តឹងបរិ-ហារបង្កាច់កេរ្តិ៍ទេ ព្រោះមានការខ្វះខាតសយម្ភូតភាព និងអសុទ្ធចិត្ត (Crim. 28 oct. 1943: Bull. Crim. n° 108; S. 1944. 1. 35)។

### ខ. ជនរងគ្រោះ

នៅក្នុងបទប្តឹងបរិហារបង្កាច់កេរ្តិ៍ អត្តសញ្ញាណរបស់ជនរងគ្រោះអាចសន្និដ្ឋានចេញពីពាក្យសំដីនៅក្នុងបណ្តឹងបាន ដោយមិនចាំបាច់ទាល់តែចង់ចោទនិយាយចំឈ្មោះអ្នកណាម្នាក់នោះទេ។ មានករណីមួយដែលមនុស្សម្នាក់បានប្រឌិតរឿងដើម្បីធ្វើឲ្យគេគិតថា មនុស្សម្នាក់ទៀតបានប្រព្រឹត្តចោរកម្ម ហើយទៅប្រាប់និយោជករបស់មនុស្សនោះថាខ្លួនបានរកឃើញអ្នកលួច តែមិនបានបង្ហាញអត្តសញ្ញាណច្បាស់ៗថាជាអ្នកណាទេ។ ការនិយាយដោយមិនបង្ហាញអត្តសញ្ញាណច្បាស់ តែអាចឲ្យនិយោជកដឹងថាអ្នកណាទំនងជាអ្នកលួច។ ដូច្នេះ ជននោះអាចមានទោសពីបទប្តឹងបរិហារបង្កាច់កេរ្តិ៍ បើការរាយការណ៍របស់ខ្លួនបញ្ឆិតបញ្ឆៀងទៅរកអត្តសញ្ញាណរបស់មនុស្សម្នាក់ទៀតនោះ(Crim. 7 juin 1963: Bull. Crim. n° 197)។

ជនរងគ្រោះនៃបណ្តឹងបរិហារបង្កាច់កេរ្តិ៍អាចជានីតិបុគ្គលផងដែរ (Crim. 22 juin 1991: Bull. Crim. n° 142)។ កាលណាការប្តឹងបរិហារមួយសំដៅធ្វើឲ្យមានការដាក់វិន័យលើនីតិបុគ្គលមួយ ដូចជាការប្តឹងបរិហារមួលបង្កាច់ក្នុងគោលបំណងឲ្យមានការដកហូតយកអាជ្ញាប័ណ្ណប្រកបវិជ្ជាជីវៈ ឬអាជ្ញាប័ណ្ណពាណិជ្ជកម្មណាមួយ នីតិបុគ្គលនោះជាជនរងគ្រោះនៃបទប្តឹងបរិហារបង្កាច់កេរ្តិ៍។

### គ. អ្នកទទួលបណ្តឹង

[29] Michèle-Laure Rassat, Droit pénal spécial, Dalloz, 6e édition, 2011, p.565.

[30] សូមមើល Code Pénal, Dalloz 110e edition 2011, p. 792។

អ្នកទទួលបណ្តឹងគឺជាអ្នកដែលមានសមត្ថកិច្ចចាត់ការបណ្តឹងនោះ។ អាជ្ញាធរដែលមានសមត្ថកិច្ចដើម្បីចាត់ការលើបណ្តឹងមាន ចៅក្រម មន្ត្រីនគរបាលយុត្តិធម៌ ឬនិយោជកនៃដើមបណ្តឹងបរិហារបង្កាច់កេរ្តិ៍។ មាត្រា ៣១១ បញ្ជាក់ថា "បុគ្គលដែលមានអំណាចប្តឹងទៅអាជ្ញាធរមានសមត្ថកិច្ច" ក៏ជាប្រភេទបុគ្គលដែលទទួលបណ្តឹងបរិហារបង្កាច់កេរ្តិ៍ដែរ។ ការកំណត់ "បុគ្គល" នោះជាអ្នកណា ជាការសំខាន់មួយ ព្រោះថាកាលណាបណ្តឹងដែលមានលក្ខណៈជាបណ្តឹងបរិហារបង្កាច់កេរ្តិ៍ធ្លាក់ទៅដល់ដៃបុគ្គលនោះហើយ បណ្តឹងនោះនឹងមានអានុភាពអវិជ្ជមានមកលើម្ចាស់បណ្តឹងវិញ។ ឧទាហរណ៍ បើមនុស្សម្នាក់ដាក់បណ្តឹងទៅមនុស្សម្នាក់ដែលគ្មានអំណាចចាត់ការបន្តដើម្បីប្តឹងទៅអាជ្ញាធរមានសមត្ថកិច្ច នោះបណ្តឹងនោះគ្មានអានុភាពព្រហ្មទណ្ឌមកលើម្ចាស់បណ្តឹងវិញទេ។ ប៉ុន្តែ តើមេឃុំចូលក្នុងប្រភេទនៃបុគ្គលដែលមានអំណាចប្តឹងទៅអាជ្ញាធរមានសមត្ថកិច្ចដែរឬទេ?។ បើចម្លើយឆ្លើយថាគាត់មានអំណាចប្តឹងទៅអាជ្ញាធរមានសមត្ថកិច្ចចាត់ការបណ្តឹង ដូច្នេះ ហេតុអ្វីវាស្ត្រសាមញ្ញម្នាក់ដែលជួយឈឺឆ្អាលមិត្តភ័ក្រ្ត ឬសាច់ញាតិរបស់ខ្លួនក្នុងការជួយបញ្ជូនបណ្តឹងទៅអាជ្ញាធរមានសមត្ថកិច្ច ជាបុគ្គលគ្មានអំណាចប្តឹងទៅអាជ្ញាធរមានសមត្ថកិច្ច? តើបណ្តឹងមួយដែលបានដល់ដៃបុគ្គលដែលបានពោលមកនេះ ចាប់មានប្រសិទ្ធភាព ដើម្បីចាត់ទុកថាមានបណ្តឹងបរិហារបង្កាច់កេរ្តិ៍ហើយឬនៅ?។ ការកំណត់ចំណុចដែលបណ្តឹងមានប្រសិទ្ធភាព គឺជាការសំខាន់ក្នុងការកំណត់ពិរុទ្ធភាពនៃម្ចាស់បណ្តឹង។ តើមេឃុំ ឬមិត្តភ័ក្រ្ត ឬសាច់ញាតិជាបុគ្គលជាអ្នកមានអំណាចប្តឹងទៅអាជ្ញាធរមានសមត្ថកិច្ច ឬគ្រាន់តែជាអ្នកបញ្ជូនបណ្តឹងតែប៉ុណ្ណោះទេ? បើច្បាប់ចាត់ទុកគាត់ទាំងនេះត្រឹមតែជាអ្នកបញ្ជូនបណ្តឹងដែលធ្លាក់នៅក្នុងដៃរបស់គាត់ មិនអាចចាត់ទុកថាមានប្រសិទ្ធភាពចូលជាបណ្តឹងបរិហារបង្កាច់កេរ្តិ៍នៅឡើយទេ។ ដំណាក់ការនេះ ជាដំណាក់ការប៉ុនប៉ងប្តឹងនៅឡើយ ហើយការប៉ុនប៉ងប្តឹងបរិហារបង្កាច់កេរ្តិ៍មិនអាចទទួលទណ្ឌកម្មបានទេ។

បណ្តឹងមួយចាប់មានប្រសិទ្ធភាព នៅពេលដែលបណ្តឹងនោះធ្លាក់ក្នុងដៃរបស់អ្នកមានសមត្ថកិច្ចចាត់ការបណ្តឹង។ បើគេពឹងពាក់មនុស្សម្នាក់ដែលមានអំណាចប្តឹងឲ្យបញ្ជូនបណ្តឹងទៅអាជ្ញាធរមានសមត្ថកិច្ចក្នុងការចាត់ការឬដោះស្រាយ ហើយចាត់ទុកថាបណ្តឹងបរិហារបង្កាច់កេរ្តិ៍នោះមិនបានសម្រេច (ឬប្រសិទ្ធភាព) អញ្ចឹងមានតែគេអាចចាត់ទុកថាបណ្តឹងដែលដាក់ឲ្យមនុស្សដែលគ្មានសមត្ថកិច្ចដោយផ្ទាល់ដើម្បីចាត់ការជាបណ្តឹងបានសម្រេចដែរ ប៉ុន្តែអ្វីដែលសំខាន់ជាងគេនោះគឺថាល្មើកណាការប៉ុនប៉ងមិនត្រូវទទួលទោស បទបរិហារបង្កាច់កេរ្តិ៍ដែលផ្ញើទៅឲ្យអ្នកកណ្តាលមិនអាចត្រូវបានចោទប្រកាន់ទេ ពីព្រោះបទល្មើសមិនទាន់បានសំរេច ព្រោះវាមិនទាន់ដល់ដៃអ្នកដែលមានអំណាចចាត់ការ[31]។

### ឃ. ធាតុអត្តនោម័ត ៖ អសុទ្ធចិត្ត (មិនស្មោះត្រង់)

អសុទ្ធចិត្តត្រូវបានកំណត់ដោយ (១) ការដឹងអង្គហេតុនៃបណ្តឹងថាមិនពិត (២) ចេតនាធ្វើឲ្យមានទណ្ឌកម្មព្រហ្មទណ្ឌ ឬទណ្ឌកម្មវិន័យ។

<u>ការដឹងអង្គហេតុមិនពិត</u> ៖ ជាទូទៅ គេទទួលស្គាល់ថា គ្រប់បណ្តឹងទាំងអស់មិនមែនសុទ្ធតែមានព័ត៌មានពិតទាក់ទងនឹងអង្គហេតុដែលដើមបណ្តឹងបរិយាយនោះទេ។ អ្នកធ្វើបណ្តឹងអាចមានព័ត៌មានមួយចំនួនដែលគាត់ជឿថាជារឿងពិត ជាហេតុដែលនាំឲ្យគាត់សន្និដ្ឋានថាចុងចោទឬចុងចម្លើយមានការទទួលខុសត្រូវ។ ជំនឿនេះ ជាធម្មតា ជាមូលដ្ឋាននៅស្ទើរតែគ្រប់បណ្តឹងសម្រាប់ឲ្យដើមបណ្តឹងស្វែងរកការដោះស្រាយពីតុលាការ។ តុលាការមានកាតព្វកិច្ចក្នុងការស្វែងរកការពិតចំពោះការចោទប្រកាន់ដែលធ្វើឡើង

[31] Michèle-Laure Rassat, Droit pénal spécial, Dalloz, 6e édition, 2011, p.565.

ដោយអ្នកដាក់បណ្តឹង។ ក្នុងករណីខ្លះ តុលាការអាចឈានដល់សេចក្តីសន្និដ្ឋាននៃអង្គហេតុមួយ ដូចការចោទប្រកាន់របស់អ្នកធ្វើបណ្តឹងដែរ។ ករណីខ្លះទៀត តុលាការអាចលើកបណ្តឹងចោល ដោយហេតុថា ការស៊ើបអង្កេតមិនអាចឈានដល់ការធ្វើសេចក្តីសន្និដ្ឋានចំពោះអង្គហេតុ ដូចការចោទប្រកាន់របស់អ្នកដាក់បណ្តឹង។ បណ្តឹងគឺជាការស្រាវជ្រាវរកការពិត។ ដូច្នេះ ការស្វែងរកការពិតគឺខុសពីការដឹងនូវអង្គហេតុមិនពិត។

ការដឹងអង្គហេតុមិនពិតខុសពីការថ្លែងអង្គហេតុមិនជាក់ច្បាស់។ ក្នុងយុត្តិសាស្ត្របារាំង អង្គហេតុមិនពិតត្រូវបានកំណត់ដោយការសម្រេចស្ថាពររបស់តុលាការឲ្យភាគី ជាជនដែលរងបណ្តឹងបរិហារបង្កាច់កេរ្តិ៍រួចខ្លួន ដោយប្រកាសថាអង្គហេតុដែលជាមូលដ្ឋាននៃបណ្តឹងបរិហារបង្កាច់កេរ្តិ៍នោះមិនពិត។ ប៉ុន្តែ គេក៏ទទួលស្គាល់ផងដែរថាការឲ្យរួចខ្លួន ឬលើកលែងការចោទប្រកាន់ដោយសារមានវិមតិសង្ស័យ មិនមែនមានន័យថាអង្គហេតុដែលប្តឹងបរិហារនោះជាអង្គហេតុមិនពិតនោះទេ (Crim. 19 juin 1991, សូមមើល អត្ថាធិប្បាយលេខ ៦១ Dalloz Code Pénal 110e edition. ទ.៧៩៨)។ អង្គហេតុដែលនាំឲ្យមន្ទិលគឺជាអង្គហេតុដែលអាចមិនពិត តែមិនមែនមិនពិតតែម្តងនោះទេ។ ដូច្នេះការលើកលែងការចោទប្រកាន់លើចុងចោទណាម្នាក់មិនមែនជាមូលដ្ឋានដាច់ខាតធ្វើឲ្យចុងចោទនោះប្តឹងបកទៅលើដើមចោទពីបទប្តឹងបរិហារបង្កាច់កេរ្តិ៍នោះទេ។ នៅក្នុងរឿងក្តីមួយទៀត តុលាការបារាំងនិយាយថា "ភាពមិនពិតនៃអង្គហេតុដែលត្រូវបានអះអាងនៅក្នុងបណ្តឹងបរិហារបង្កាច់កេរ្តិ៍ដាច់ខាតនាំឲ្យមានសេចក្តីសម្រេចដោះលែងជាស្ថាពរជនដែលត្រូវបង្កាច់កេរ្តិ៍។ សាលាឧទ្ធរណ៍មានកំហុសក្នុងការដែលខ្លួនសំរេចដោះលែងជនជាប់ចោទពីបទបរិហារបង្កាច់កេរ្តិ៍ម្នាក់ ដោយសំអាងហេតុថាដើមបណ្តឹងរដ្ឋប្បវេណី [ជនរងគ្រោះពីបទបរិហារបង្កាច់កេរ្តិ៍] ត្រូវបានសំរេចឲ្យរួចខ្លួន ដោយសារមានវិមតិសង្ស័យ ហើយសេចក្តីសម្រេចបែបនេះមិនរាប់ថាជាការកំណត់ការមិនពិតនៃអង្គហេតុដែលអះអាងក្នុងបណ្តឹងបរិហារបង្កាច់កេរ្តិ៍នោះទេ។ សាលាឧទ្ធរណ៍ត្រូវស្រាវជ្រាវថែមទៀតដើម្បីឲ្យឃើញថា តើនៅពេលប្តឹងបរិហារបង្កាច់កេរ្តិ៍នោះ តើជនជាប់ចោទបានដឹងថាអង្គហេតុដែលខ្លួនប្តឹងនោះពិត ឬមិនពិត" [32](អត្ថាធិប្បាយលេខ ៦២ នៅទំព័រដូចគ្នាក្នុងសៀវភៅដដែល)។

ការធ្វេសប្រហែសក្នុងការបង្ហាញអង្គហេតុមិនត្រូវបានចាត់ទុកដូចការដឹងអង្គហេតុមិនពិតនោះទេ។

<u>ចេតនាបង្កឲ្យមានទណ្ឌកម្មព្រហ្មទណ្ឌ ឬទណ្ឌកម្មវិន័យ</u> ៖ បើវាជាបណ្តឹងរដ្ឋប្បវេណីដែលមានចេតនា ដើម្បីទទួលការសង្គ្រោះរដ្ឋប្បវេណី ទោះបីជាចុងចម្លើយនិយាយថា អង្គហេតុដែលគាត់ដឹងនោះមិនពិតក៏ដោយ ពេលនោះមិនមានបទប្តឹងបរិហារបង្កាច់កេរ្តិ៍ទេ ព្រោះបណ្តឹងរដ្ឋប្បវេណីនោះមិនបានទាមទារឲ្យមានការដាក់ទណ្ឌកម្មព្រហ្មទណ្ឌ ឬសុំឲ្យមានវិធានការវិន័យណាមួយឡើយ។ ឧទាហរណ៍ ការប្តឹងទាមទារកម្មសិទ្ធិលើដីធ្លី ដែលអ្នកប្តឹងដោយបំពាន មិនអាចជាកម្មវត្ថុនៃការប្តឹងបរិហារបង្កាច់កេរ្តិ៍ទេ ព្រោះវាមិនមែនជាបណ្តឹងទាមទារឲ្យមានការដាក់ទណ្ឌកម្មផ្នែកព្រហ្មទណ្ឌ។

---

[32] កំណត់អ្នកនិពន្ធ៖ យុត្តិសាស្ត្រនេះអាចសម្រាយបានតាមឧទាហរណ៍ដូចតទៅនេះ៖ ក ចោទ ខ ថាបានលួចទោចក្រយានមួយគ្រឿង។ តុលាការដោះលែង ខ ដោយហេតុថាអង្គហេតុលួចនោះគឺមានវិមតិសង្ស័យ។ តុលាការឧទ្ធរណ៍ក៏ដោះលែង ក ដែរ ដោយហេតុថា ខ ត្រូវបានដោះលែងដោយសារមានវិមតិសង្ស័យនៃអង្គហេតុលួចនេះ។ តុលាការកំពូលមានមតិថា តុលាការឧទ្ធរណ៍ដោះលែង ក ហ្នឹងគឺមិនត្រឹមត្រូវទេ ដោយសារតែសាលាឧទ្ធរណ៍សំអាងតែលើវិមតិសង្ស័យនៃអង្គហេតុដែលអះអាងដោយ ក ហើយការសំរេចបែបនេះមិនផ្អែកលើការរកឲ្យឃើញថា អង្គហេតុដែលអះអាងនោះជាអង្គហេតុខុសឬត្រូវទេ (មានន័យថា តុលាការឧទ្ធរណ៍ត្រូវរកភាពខុសឬត្រូវនៃអង្គហេតុ)។ តុលាការកំពូលធ្វើការណែនាំបន្ថែមទៀតថា តុលាការឧទ្ធរណ៍ត្រូវស្រាវជ្រាវថែមទៀតថា តើនៅពេលធ្វើបណ្តឹងបរិហារបង្កាច់កេរ្តិ៍នោះ ក បានដឹងឬមិនបានដឹងភាពពិតនៃអង្គហេតុដែលខ្លួនបានអះអាងក្នុងបណ្តឹងនោះ ពោលគឺតើ ក បានដឹងអង្គហេតុមិនពិតហើយៗនៅតែធ្វើបណ្តឹងដែរឬទេ។

## ៤.	បន្ទុកភស្តុតាង

### ក.	ខាងចោទត្រូវបញ្ជាក់ថា ចុងចោទដឹងថាអង្គហេតុនៅក្នុងបណ្តឹងជាអង្គហេតុមិនពិត

ការផ្តន្ទាទោសអាចធ្វើទៅបានលុះណាតែចុងចោទសារភាពថា អង្គហេតុដែលគាត់បានចោទនៅក្នុងបណ្តឹងនោះខុស។ បើមិនដូច្នេះទេ តុលាការត្រូវ ទី១ ទទួលបន្ទុកភស្តុតាងដើម្បីបង្ហាញឲ្យឃើញថាអង្គហេតុដែលថែងនៅក្នុងបណ្តឹងនោះជាអង្គហេតុមិនពិត ហើយបន្ទាប់មកត្រូវបង្ហាញថាចុងចោទក៏ដឹងថាអង្គហេតុនោះមិនពិតដែរ។

### ខ.	ចុងចម្លើយមិនចាំបាច់បង្ហាញពីសុទ្ធចិត្តឡើយ

ការរកឲ្យឃើញនូវអសុទ្ធចិត្តរបស់ចុងចម្លើយជាកាតព្វកិច្ចរបស់តុលាការ ហើយចុងចោទគ្មានកាតព្វកិច្ចត្រូវបង្ហាញថាខ្លួនឯងមានសុទ្ធចិត្តទេ។

## ៥.	មធ្យោបាយការការពារ

### ក.	បណ្តឹងដែលស្វែងរកការសង្គ្រោះផ្នែករដ្ឋប្បវេណី ឬមិនមែនព្រហ្មទណ្ឌ

បណ្តឹងបរិហារកេរ្តិ៍ គឺមិនមែនជាបណ្តឹងបរិហារបង្កាច់កេរ្តិ៍ឡើយ។

ជម្លោះដីធ្លី៖ វាមិនមែនជាបណ្តឹងបរិហារបង្កាច់កេរ្តិ៍ទេ កាលណាបុគ្គលម្នាក់ដាក់បណ្តឹងសុំឲ្យតុលាការប្រកាសអំពីកម្មសិទ្ធិលើដីនោះ ទោះបណ្តឹងនោះចោទថាបុគ្គលម្នាក់ទៀតបានរំលោភ យកដីពីគាត់ក៏ដោយ ព្រោះបណ្តឹងនេះមិនបានស្វែងរកការដាក់ទោសព្រហ្មទណ្ឌលើជនដែលគាត់ចោទប្រកាន់នោះទេ។

### ខ.	សេចក្តីថ្លែងការណ៍មិនត្រឹមត្រូវក្នុងអង្គហេតុមិនបង្កើតបានជាអសុទ្ធចិត្តឡើយ

ការថ្លែងអង្គហេតុមិនជាក់លាក់មិនទាន់គ្រប់គ្រាន់ដើម្បីចាត់ទុកថាបណ្តឹងមួយជាបណ្តឹងបរិហារបង្កាច់កេរ្តិ៍ឡើយ។ ចុងចោទត្រូវតែបានដឹងថាអង្គហេតុដែលបាននិយាយនោះមិនជាក់លាក់ទាំងស្រុង ឬមួយផ្នែកខ្លះ។

### គ.	ការធ្វេសប្រហែសមិនបង្កើតបានជាអសុទ្ធចិត្តឡើយ

ការចោទប្រកាន់ពីបទប្តឹងបរិហារបង្កាច់កេរ្តិ៍ទាមទារឲ្យបង្ហាញពីចេតនាទុច្ចរិតទៅលើមនុស្សម្នាក់ទៀត។ ការថ្លែងអង្គហេតុមិនពិត ដោយសារការធ្វេសប្រហែស ឬការច្រឡំមិនគ្រប់គ្រាន់ដើម្បីបង្កើតជាអសុទ្ធចិត្តឡើយ។

## ៦.	បញ្ញានីតិវិធី

**ក.** អាជ្ញាយុកាល ៖ មានកំណត់ពេលមួយឆ្នាំរាប់ចាប់ពីការទទួលបណ្តឹងដោយអាជ្ញាធរមានសមត្ថកិច្ចដើម្បីចាត់ការលើបណ្តឹងនោះ។

**ខ.** ការចោទប្រកាន់ពីបទប្តឹងបរិហារបង្កាច់កេរ្តិ៍ មិនអាចចាប់ផ្តើមបានទេរហូតទាល់តែបណ្តឹងអាជ្ញារបស់ចុងចោទត្រូវបានបញ្ចប់សព្វគ្រប់សិន។

## ៧. ភាពខុសគ្នារវាង ការបរិហារកេរ្តិ៍ និងការបរិហារបង្កាច់កេរ្តិ៍

**ក. បណ្តឹងបរិហារកេរ្តិ៍ ៖** គឺជាការថ្លែងអង្គហេតុទាក់ទងនឹងជនណាម្នាក់ (ជាជនរងគ្រោះ) ទៅកាន់តតិយជន។

**ខ. បណ្តឹងបរិហារបង្កាច់កេរ្តិ៍ ៖** គឺជាការថ្លែងអង្គហេតុទាក់ទងនឹងជនណាម្នាក់ (ជាជនរងគ្រោះ) ទៅកាន់អាជ្ញាធរមានសមត្ថកិច្ច មានតុលាការ មន្ត្រីនគរបាលជាដើម។

# ជំពូក ៣

# ការញុះញង់

## ១. ប្រវត្តិច្បាប់

ក្នុងច្បាប់ព្រហ្មទណ្ឌ ការញុះញង់មិនមែនជាបទល្មើសស្វយ័តទេ មានន័យថាការញុះញង់មិនមែនជាបទល្មើសដូចជាបទល្មើសចោរកម្ម បទល្មើសឃាតកម្មជាដើមនោះទេ តែវាជាអំពើដែលផ្ញើខ្លួនជាមួយនឹងបទល្មើសផ្សេងៗទៀតដែលការញុះញង់នោះប្រាថ្នាចង់ឲ្យកើតឡើង។

ការញុះញង់ គឺជាការញុាំងឲ្យអ្នកណាធ្វើអំពើអ្វីមួយ ដែលអាចជាអាក្រក់ ឬមិនអាក្រក់។ ប៉ុន្តែ នៅក្នុងភាសានិយាយទូទៅការញុះញង់នាំមកនូវន័យអវិជ្ជមាន មានន័យថា ទោះបីការញុះញង់មានបំណងអ្វីក៏ដោយគេច្រើនចាត់ទុកថា ការញុះញង់ជាអំពើអាក្រក់។ ឧទាហរណ៍ បើមនុស្សម្នាក់បញ្ចុះបញ្ចូលឲ្យក្រុមមួយប្រឆាំងតវ៉ានឹងការរឹបអូសយកដីធ្លី ឬប្រឆាំងតវ៉ានឹងវិធានការណាមួយរបស់អាជ្ញាធររដ្ឋាភិបាល គេច្រើនហៅថា ឬចោទថាជននោះញុះញង់ឲ្យមានអំពើប្រឆាំងនឹងអាជ្ញាធររដ្ឋ ហើយគេមើលឃើញថាការញុះញង់នេះជាអំពើអវិជ្ជមាន។ មានរបាយការណ៍ជាច្រើនពីអង្គការក្រៅរដ្ឋាភិបាលអំពីការចោទប្រកាន់នៅក្នុងតុលាការ ពីបទញុះញង់ប្រឆាំងនឹងគោលនយោបាយអភិវឌ្ឍន៍របស់រដ្ឋាភិបាល ឬការញុះញង់ប្រឆាំងនឹងអាជ្ញាធរជាដើម។

គោលដៅតែមួយគត់នៃច្បាប់ស្តីពីការញុះញង់គឺដើម្បីទប់ស្កាត់ការប្រព្រឹត្តអំពើខុសច្បាប់ ឬបទ-ល្មើស។ បើការញុះញង់មានគោលបំណងស្របច្បាប់នោះវាមិនមែនជាការញុះញង់ដែលត្រូវផ្តន្ទាទោសនោះទេ។ ពាក្យសំដីដែលគេហៅថា "ញុះញង់" បែបនោះវាគ្រាន់តែជាការផ្តល់ដំបូន្មាន ឬជាការជំរុញឲ្យធ្វើអ្វីមួយដែលច្បាប់មិនហាមឃាត់ប៉ុណ្ណោះ។

ការញុះញង់កើតចេញពីពាក្យសំដី ការសំដែងកិរិយា ឬកាយវិការណាមួយ។ ពាក្យសំដី, កិរិយា និងកាយវិការជាមធ្យោបាយនៃការសម្តែងចេញរបស់មនុស្ស។ ច្បាប់ស្តីពីការញុះញង់ផ្តោតទៅលើការទប់ស្កាត់សំដី កិរិយា និងកាយវិការ ដែលបង្កឲ្យកើតមានអំពើខុសច្បាប់។ ដូច្នេះ ច្បាប់ស្តីពីការញុះញង់ត្រូវតែកំណត់ព្រំដែនឲ្យច្បាស់លាស់ថា សំដី កិរិយា ឬកាយវិការបែបណាដែលត្រូវហាមឃាត់ ដើម្បីការពារសេរីភាពខាងការបញ្ចេញមតិ និងការពាររបៀបរៀបរយនិងសុវត្ថិភាពនៃសង្គម។ ច្បាប់ស្តីពីការញុះញង់ល្អ គឺជាច្បាប់ដែលផ្តល់តុល្យភាពរវាងសេរីភាពខាងការបញ្ចេញមតិ និងការការពារសុខុមាលភាពសង្គម។

## ២. និយមន័យ

នៅក្នុងក្រមព្រហ្មទណ្ឌ ការញុះញង់ដែលអាចត្រូវផ្តន្ទាទោសបានលុះត្រាតែការញុះញង់នោះសំដៅឲ្យមានការប្រព្រឹត្តបទឧក្រិដ្ឋ ឬបទមជ្ឈិម ឬនាំឲ្យមានការប៉ុនប៉ងប្រព្រឹត្តបទឧក្រិដ្ឋ ឬបទមជ្ឈិម។ បើការញុះញង់មិននាំឲ្យមានការប្រព្រឹត្តបទល្មើសព្រហ្មទណ្ឌទេនោះ នោះគេមិនអាចផ្តន្ទាទោសការញុះញង់បានទេ។ ការញុះញង់ឲ្យប្រព្រឹត្តបទល្មើសលហុក៏មិននាំឲ្យមានការដាក់ទណ្ឌកម្មដែរ។

នៅក្នុងច្បាប់ព្រហ្មទណ្ឌខ្មែរ ការញុះញង់ចែកជាប្រភេទគឺ ការផ្តើមគំនិត និងការញុះញង់ដោយផ្ទាល់។ ការផ្តើមគំនិត ជាការញុះញង់មួយដែលមិនមែនជាបទល្មើសស្វយ័ត រីឯការញុះញង់ដោយផ្ទាល់ជាបទល្មើសស្វយ័ត។ នៅផ្នែកប្រវត្តិនៃច្បាប់យើងបានពិភាក្សាថា ការញុះញង់មិនមែនជាបទល្មើសទេ តែជាអំពើដែលផ្ញើខ្លួនជាមួយនឹងបទល្មើសមួយទៀត ចុះហេតុអ្វីបានជា "ការញុះញង់ដោយផ្ទាល់" ជាបទល្មើសទៅវិញ។ យើងនឹងពិភាក្សារឿងនេះនៅផ្នែកខាងក្រោយៗ។ ឥឡូវនេះ យើងផ្តោតទៅលើការញុះញង់ដោយការផ្តើមគំនិតសិន។ ការផ្តើមគំនិតត្រូវបានចែងនៅក្នុងមាត្រា ២៨ នៃក្រមព្រហ្មទណ្ឌ ដែលមានសេចក្តីដូចខាងក្រោមនេះ ៖

> ត្រូវចាត់ទុកជាអ្នកផ្តើមគំនិតក្នុងបទឧក្រិដ្ឋ ឬបទមជ្ឈិមចំពោះបុគ្គលណាដែល ៖
>
> ១. ជំរុញឲ្យប្រព្រឹត្តបទឧក្រិដ្ឋ ឬបទមជ្ឈិមនោះ តាមការណែនាំ ឬការបញ្ជា។
>
> ២. បង្កឲ្យមានបទឧក្រិដ្ឋ ឬបទមជ្ឈិមនោះ ដោយផ្តល់អំណោយ ដោយការសន្យា ឬការគំរាមកំហែង ការញុះញង់ ការលួងលោម ឬក៏ដោយការរំលោភអាជ្ញា ឬអំណាចរបស់ខ្លួន។
>
> ការផ្តើមគំនិតនឹងអាចផ្តន្ទាទោសបានលុះត្រាតែបទឧក្រិដ្ឋ ឬបទមជ្ឈិមត្រូវបានសម្រេច ឬបានប៉ុនប៉ង។
>
> អ្នកផ្តើមគំនិតនៃបទឧក្រិដ្ឋ ឬបទមជ្ឈិមត្រូវផ្តន្ទាទោសដូចគ្នានឹងចារីដែរ។

## ៣. ការទទួលខុសត្រូវនៃការញុះញង់ដោយការផ្តើមគំនិត (Incitement by instigation)

អ្នកផ្តើមគំនិតមិនមែនជាអ្នកប្រព្រឹត្តបទល្មើសទេ តែជាអ្នកនៅពីក្រោយ ជាអ្នកជំរុញឲ្យអ្នកដទៃប្រព្រឹត្តបទល្មើសណាមួយ។ ដើម្បីឲ្យអ្នកផ្តើមគំនិតទទួលខុសត្រូវចំពោះបទល្មើសដែលត្រូវបានញុះញង់ បទល្មើសនោះត្រូវតែបានប្រព្រឹត្ត ឬត្រូវបានប៉ុនប៉ងប្រព្រឹត្តដោយចារីចម្បង (បុគ្គលដែលប្រព្រឹត្តអំពើល្មើស) (មាត្រា២៨)។ ការផ្តើមគំនិតអាចធ្វើបានតាមមធ្យោបាយ "ណែនាំ" (មាត្រា២៨.១) (Instruction) ឬមធ្យោបាយបង្កហេតុ (មាត្រា២៨.២) (Provocation)។ ការញុះញង់ត្រូវផ្តើមដោយចេតនាដើម្បីសម្រួល ឬ ជំរុញឲ្យអ្នកណាម្នាក់អាចប្រព្រឹត្តបទល្មើសមួយ ឬច្រើន។

### ក. អំពើជាសត្យានុម័តនៃការញុះញង់

ការញុះញង់មានពីរសណ្ឋាន ៖ ការបង្ក និងការណែនាំ។

#### (១) ការបង្ក

ការបង្កអាចផ្តន្ទាទោសបាន លុះត្រាតែការបង្កនោះត្រូវបំពេញនូវលក្ខខណ្ឌរួមគ្នាគឺការញុះញង់នោះត្រូវ *អមដោយកាលៈទេសៈ* (ឬស្ថានដាក់ទម្ងន់) ខ្លះ និងត្រូវធ្វើ *ដោយត្រង់* ចំពោះទៅរក *ឯកទត្តបុគ្គល* ជាក់លាក់ណាមួយ[33]។

#### (២) អមដោយកាលៈទេសៈ ឬស្ថានដាក់ទម្ងន់

ការញុះញង់ដោយការផ្តើមគំនិតត្រូវបានធ្វើតាមរយៈមធ្យោបាយផ្សេងៗ ដើម្បីជំរុញឲ្យការប្រព្រឹត្តមានចលនា។ មធ្យោបាយទាំងនោះមាន ការលើកទឹកចិត្ត ការផ្តល់ពត៌មានសំរាប់ប្រព្រឹត្តបទល្មើស និងការការបង្ខំចិត្តជាដើម។

---

[33] Gaston Stefani et al., Droit pénal general, Dalloz, 15e édition, 1994, p. 261.

ការឲ្យអំណោយ ការសន្យា ការគំរាមកំហែង ៖ ឧទាហរណ៍ ការផ្តល់ប្រាក់ដើម្បីឲ្យមនុស្សម្នាក់ធ្វើសក្ខីកម្មក្លែងក្លាយ, ការសន្យាដល់ជនណាម្នាក់ថានឹងឲ្យរង្វាន់ជាប្រាក់មួយចំនួន បើជននោះអាចបង្ករបួសស្នាមដល់មនុស្សម្នាក់ទៀត ការគំរាមកំហែងថានឹងបើកការសម្ងាត់របស់ជនណាម្នាក់ បើជននោះមិនព្រមសហការនៅក្នុងការជួញដូរគ្រឿងញៀន។ ទាំងនេះជាឧបករណ៍ជំរុញចិត្តឲ្យមនុស្សម្នាក់ទៀតប្រព្រឹត្តបទល្មើស។

ការបញ្ជា ៖ ឧទាហរណ៍ នាយប៉ូលីសម្នាក់ដែលបញ្ជាឲ្យកូនចៅរបស់ខ្លួនចាប់ឃុំមនុស្សម្នាក់ដែលបានទិញរថយន្តពីមនុស្សម្នាក់ទៀតដោយសុចរិត។ ការចាប់ខ្លួនដោយខុសច្បាប់ក្រោមបញ្ជារបស់នាយប៉ូលីសនាំឲ្យនាយប៉ូលីសនោះមានការទទួលខុសត្រូវជាអ្នកផ្តើមគំនិត ឬញុះញង់ឲ្យមានការឃុំខ្លួនដោយខុសច្បាប់។ នៅក្នុងរឿងក្តីបារាំងមួយ (Bull. Crim. N° 70) អ្នកដំណើរម្នាក់បានពន្យុះអ្នកបើកបររថយន្តម្នាក់ថា "ជាន់ទៅ ជាន់ទៅ កុំឈប់" ហើយអ្នកបើកបររថយន្តនោះធ្វើតាម ដោយបោះពួយរថយន្តដោយចេតនាធ្វើឲ្យកងអារុធហត្ថម្នាក់របួសធ្ងន់ក្នុងខណៈដែលគាត់កំពុងបើកទ្វាររថយន្ត។ អ្នកដំណើរនោះមានទោសពីការផ្តើមគំនិតដោយការបង្ក។

ការរំលោភអាជ្ញា ឬអំណាច ៖ ឧទាហរណ៍ នាយកក្រុមហ៊ុនមួយបានប្រើឲ្យកម្មករជាអ្នកដឹកជញ្ជូនម្នាក់ដឹកទំនិញខុសច្បាប់ចូលពីព្រំដែនថៃមកភ្នំពេញ។ កម្មករ ដោយដឹងថាទំនិញនោះខុសច្បាប់ តែបង្ខំចិត្តដឹកដោយខ្លាចនាយកសងសឹកបញ្ឈប់ការងារខ្លួន។ នាយកក្រុមហ៊ុននេះរំលោភអំណាចក្នុងឋានៈខ្លួនជាមេកើយ ដែលគ្មានអំណាចណាមួយដើម្បីបង្គាប់ឲ្យគេធ្វើអំពើខុសច្បាប់។ នៅក្នុងយុត្តិសាស្ត្របារាំង ការរំលោភអំណាចមិនអាស្រ័យលើលក្ខខណ្ឌដែលថាអំណាចដែលយកទៅបំពាននោះជាអំណាចស្របច្បាប់នោះទេ។ បើអ្នកណាម្នាក់មានអំណាចខាងសីលធម៌ ហើយយកអំណាចនោះទៅបំពានក៏ជាការគ្រប់គ្រាន់ដើម្បីដាក់ទោសជននោះជាអ្នកផ្តើមគំនិតដោយការបង្កដែរ (Crim. 24 nov. 1953: Bull. Crim. No 304)។ ឧទាហរណ៍ ការទាមទារសគុណពីមនុស្សណាម្នាក់ឲ្យធ្វើអំពើអ្វីមួយដែលខុសច្បាប់គឺជាការរំលោភអាជ្ញាឬអំណាច។

យុត្តិសាស្ត្របារាំងបញ្ជាក់ថា នៅក្នុងករណីនៃការផ្តើមគំនិត ឬការញុះញង់ដោយការបង្ក ការឲ្យយោបល់ (advice) ឬការស្នើ (suggestion) ទទេៗ ឲ្យមនុស្សណាម្នាក់ប្រព្រឹត្តបទល្មើសណាមួយ ប៉ុន្តែគ្មានការដាក់សម្ពាធ ឬគ្មានអមទៅដោយកាលៈទេសៈជំរុញចិត្តដូចបានរៀបរាប់ខាងលើនេះទេ នោះការឲ្យយោបល់ឬការស្នើនោះមិនអាចចាត់ទុកជាការបង្កបានទេ ដូច្នេះអ្នកដែលនិយាយនោះមិនទទួលខុសត្រូវក្នុងឋានៈជាផ្តើមគំនិតឬអ្នកញុះញង់ទេ (Crim. 24 déc. 1942: JCP 1944. II. 2651 (2e esp)។ ឧទាហរណ៍ មនុស្សម្នាក់ដែលផ្តល់យោបល់ដល់សង្សាររបស់ខ្លួន ថាគាត់អាចចាក់ថ្នាំដើម្បីពន្លូតកូន មនុស្សនោះមិនទទួលខុសត្រូវក្នុងឋានៈជាអ្នកណែនាំឲ្យប្រព្រឹត្ត[34]។ ការផ្តល់សេចក្តីណែនាំត្រូវតែមានព័ត៌មានជាក់ច្បាស់ (Precise) ព្រោះកាលណាព័ត៌មានដែលផ្តល់នៅក្នុងសេចក្តីណែនាំនោះមានន័យទូលំទូលាយពេកសេចក្តីណែនាំនោះមិនទាន់គ្រប់គ្រាន់នៅឡើយដើម្បីឲ្យអ្នកផ្តល់សេចក្តីណែនាំនោះទទួលខុសត្រូវជាអ្នកផ្តើមគំនិត[35]។

### (៣) ដោយត្រង់

---

[34] Catherine Elliot, French Criminal Law, Willan Publishing, 2001, p.89. ដកស្រង់ពីយុត្តិសាស្ត្រ Crim. 24 déc. 1942, S, 1944.I.7.

[35] ដូចប្រភពខាងលើ ទ. ៨៩។

ដើម្បីឲ្យការញុះញង់មួយទទួលខុសត្រូវបាន អ្នកបង្កត្រូវបញ្ជាក់អំពីគំនិតធ្វើបទល្មើសរបស់ខ្លួន ដោយពាក្យសំដីច្បាស់ ដែលធ្វើឲ្យចារីចំបងយល់ពីគំនិតដែលអ្នកបង្កចង់បាន។ មានន័យថាសំដីដែលអ្នកបង្កនិយាយមិនអាចមានន័យលើសពីមួយបានទេ។ នេះជាការផ្ចិតគំនិតព្រហ្មទណ្ឌពីអ្នកផ្ដើមគំនិតទៅអ្នកប្រព្រឹត្ត ដើម្បីអនុវត្តគំនិតនោះ។

**(៤) ឯកទត្តបុគ្គល**

សារដែលអ្នកបង្កចង់បញ្ចុះបញ្ចូលឲ្យមានការប្រព្រឹត្តបទល្មើសណាមួយត្រូវតែសំដៅទៅរកជនណាម្នាក់យ៉ាងជាក់លាក់គឺមិនមែនទៅកាន់មនុស្សទូទៅនោះទេ ដែលគេមិនដឹងថាអ្នកបង្កចង់សំដៅទៅអ្នកណាមួយជាប្រាកដនោះទេ[36]។

**(៥) ការណែនាំ**

"ការណែនាំ"ខុសគ្នាពីការបង្កគ្រង់ថា ការបង្កទាមទារឲ្យមានការជំរុញ ដូចជាការផ្ដល់អំណោយ ការសន្យា ការបញ្ជា ការបំពានអំណាចជាដើម ដើម្បីជំរុញទឹកចិត្តឲ្យចារីចំបងប្រព្រឹត្តបទល្មើស រីឯការណែនាំវិញមិនចាំបាច់មានការជំរុញទេ។ ការផ្ដល់គំនិត ឬការផ្ដល់ព័ត៌មាន ដើម្បីឲ្យអ្នកប្រព្រឹត្តយកគំនិត ឬព័ត៌មាននោះទៅប្រើក្នុងការប្រព្រឹត្តបទល្មើសណាមួយ គឺគ្រប់គ្រាន់ដើម្បីចាត់ទុកជាការញុះញង់ដោយការផ្ដើមគំនិត (Crim. 31 jan. 1974: Bull crim. No 50; Crim. 28 oct. 1965: JCP 1966)។

ដើម្បីឲ្យការណែនាំនេះជាធាតុផ្សំនៃការញុះញង់ ដែលត្រូវផ្ដន្ទាទោស អ្នកផ្ដើមគំនិតត្រូវតែដឹងថាការណែនាំនោះនឹងសម្រាប់យកទៅប្រព្រឹត្តបទល្មើស។ សេចក្ដីណែនាំត្រូវតែ[37] ៖

១. មានភាពច្បាស់លាស់ឲ្យអ្នកអនុវត្តយល់ន័យពិតប្រាកដនៃសេចក្ដីណែនាំនោះ មិនមែនជាសេចក្ដីណែនាំដែលមានន័យទូលំទូលាយធ្វើឲ្យអ្នកអនុវត្តមិនអាចចាប់ន័យបានថាអ្វីជាប្រាកដនោះទេ

២. ជាការចង្អុលបង្ហាញដែលធ្វើឲ្យការអនុវត្តសេចក្ដីណែនាំនោះអាចធ្វើទៅកើត ឬអាចសម្រួលនូវការអនុវត្តបទល្មើសបាន

៣. អ្នកណែនាំនោះដឹងពីមូលហេតុនៃសេចក្ដីណែនាំរបស់ខ្លួន (មិនមែនដោយសារការភ្លាត់មាត់ ឬអចេតនា) ថាខ្លួនចង់បានអ្វី និងដឹងថាការណែនាំនោះសម្រាប់ធ្វើឲ្យបានសម្រេចនូវបទល្មើស។

## ខ. ចេតនានៃអ្នកញុះញង់

ដើម្បីឲ្យអ្នកញុះញង់ទទួលខុសត្រូវផ្នែកព្រហ្មទណ្ឌបាន ចេតនារបស់អ្នកញុះញង់ និងចេតនារបស់អ្នកប្រព្រឹត្តត្រូវស៊ីគ្នា។ នៅក្នុងករណីនៃការញុះញង់ដោយការបង្កចេតនារបស់អ្នកបង្កត្រូវចម្លងចូលក្នុងខួរក្បាលរបស់អ្នកប្រព្រឹត្ត។ នៅក្នុងការញុះញង់ដោយការណែនាំ មនសិការរបស់អ្នកញុះញង់អំពីបទល្មើសត្រូវមានព្រមជាមួយគ្នានឹងការផ្ដល់ការណែនាំ។[38]

---

[36] Gaston Stefani et al., Droit penal general, Dalloz, 15 ed. p. 261; Catherine Elliot, French Criminal Law, Willan Publishing, 2001, p.88.

[37] Gaston Stefani et al., Droit pénal général, Dalloz, 15e ed. p. 262.

[38] ប្រភពដូចខាងលើត្រង់ទំព័រ ២៦៧។

ដោយហេតុថា អ្នកផ្ដើមគំនិតគឺអ្នកសមគំនិតជាមួយចារីចំបង អ្នកផ្ដើមគំនិតត្រូវតែមានចេតនាចង់ឲ្យបទល្មើសមួយត្រូវបានប្រព្រឹត្ត ឬត្រូវតែបានដឹងថាខ្លួនរួមចំណែកនៅក្នុងការជំរុញឲ្យអនុវត្តបទល្មើសចម្បង ៖

១. បទឧក្រិដ្ឋ ឬ

២. បទមជ្ឈិម

គេអាចកំណត់ចេតនារបស់អ្នកផ្ដើមគំនិតបាន ដោយមើលទៅលើបំណងរបស់គាត់ដើម្បីផ្ចិតគំនិតរបស់គាត់ ទៅលើខួរក្បាលរបស់អ្នកប្រព្រឹត្ត។

ក្នុងករណីនៃការផ្ដើមគំនិតដោយការបង្ក អ្នកផ្ដើមគំនិតឬអ្នកញុះញង់ត្រូវតែបានចែករំលែកនូវចេតនារបស់គាត់តាមរយៈការលើកទឹកចិត្ត ការណែនាំ ឬការបញ្ជា។ អ្នកផ្ដើមគំនិតត្រូវមានចេតនាជាក់លាក់ចង់ឲ្យអ្នកដែលត្រូវញុះញង់ប្រព្រឹត្តបទឧក្រិដ្ឋ ឬបទមជ្ឈិមណាមួយ។ ឧទាហរណ៍ បើអ្នកផ្ដើមគំនិតបញ្ចុះបញ្ចូលឲ្យធ្វើបាតុកម្មដោយសន្តិវិធី ប៉ុន្តែអ្នកធ្វើបាតុកម្មនោះបែរជាធ្វើបាតុកម្មដោយប្រព្រឹត្តអំពើចោរកម្ម ឬប្លន់ទៅវិញ នោះអ្នកផ្ដើមគំនិតមិនទទួលខុសត្រូវលើអំពើចោរកម្ម ឬប្លន់នោះឡើយ ព្រោះចេតនារបស់អ្នកប្រព្រឹត្តបទល្មើសឆក់ប្លន់ មិនស៊ីគ្នាជាមួយនឹងអ្នកផ្ដើមគំនិត។ និយាយម្យ៉ាងទៀត គំនិតរបស់អ្នកផ្ដើមគំនិតមិនបានផ្ចិតទៅក្នុងខួរក្បាលរបស់អ្នកប្រព្រឹត្តទេ។ ប្រសិនបើអ្នកផ្ដើមគំនិតណែនាំឲ្យសហចារីរបស់ខ្លួនឲ្យសម្លាប់ A ហើយដោយគ្មានការច្រឡំ សហចារីនោះបែរទៅជាសម្លាប់ B ទៅវិញ នោះអ្នកផ្ដើមគំនិតមិនទទួលខុសត្រូវលើអំពើឃាតកម្ម B ឡើយ ព្រោះចេតនារបស់គាត់មិនមែនចង់ឲ្យ B ស្លាប់ទេ។[39] មានរឿងក្ដីបារាំងមួយ ដែលនៅក្នុងនោះ ម្ចាស់បំណុលបានឲ្យកាំភ្លើងខ្លីពីរដើមទៅមនុស្សម្នាក់ដើម្បីយកទៅគំរាមកូនបំណុលម្នាក់ឲ្យសងប្រាក់ ប៉ុន្តែមនុស្សនោះបានសម្លាប់អ្នកយាមផ្ទះទៅវិញក្រោយពីបានឈ្លោះប្រកែកគ្នា (Crim. 13 janv. 1955, D., 1995.291)។ តុលាការបានសម្រេចថា ម្ចាស់បំណុលនោះមិនទទួលខុសត្រូវចំពោះឃាតកម្មនោះទេ[40]។

ប៉ុន្តែ បើបទល្មើសដែលគិតទុកដោយអ្នកញុះញង់ និងបទល្មើសដែលបានប្រព្រឹត្តខុសគ្នាត្រឹមតែស្ថាននៃការប្រព្រឹត្តទេនោះ យុត្តិសាស្ត្របារាំងចាត់ទុកថា អ្នកញុះញង់មិនអាចរួចពីការទទួលខុសត្រូវនោះទេ[41]។ ឧទាហរណ៍ នៅក្នុងករណីមួយមនុស្សម្នាក់បានផ្ដល់ព័ត៌មានដើម្បីជួយឲ្យមនុស្សម្នាក់ទៀតប្រព្រឹត្តបទលួចធម្មតានៅផ្ទះមួយ តែមនុស្សម្នាក់ទៀតនោះ បែរជាដឹកនាំមនុស្សមួយក្រុម ទម្លុះចូលផ្ទះនោះនៅពេលយប់ ដែលជាបទល្មើសលួចមានស្ថានទម្ងន់ ក្នុងករណីបែបនេះ យុត្តិសាស្ត្របារាំងចែងថា "អ្នកប្រព្រឹត្តត្រូវស្មានទុកជាមុននូវរាល់ទម្រង់ទាំងអស់នៃបទល្មើសដែលអាចកើតចេញពីការប្រព្រឹត្តបទល្មើសនេះ" (Crim. 31 déc. 1947, Bull. n° 270)។ នៅក្នុងឧទាហរណ៍ខាងមុននេះ ការគាស់ទម្លាយលំនៅឋានគឺជាទម្រង់មួយនៃការលួចប៉ុណ្ណោះ មិនមែនបទល្មើសដាច់ដោយឡែកដែលទាមទារឲ្យមានអង្គហេតុខុសគ្នាស្រឡះនោះទេ។ ដូច្នេះបើអ្នកផ្ដើមគំនិតម្នាក់ឲ្យកាំភ្លើងទៅសហចារីរបស់គាត់ដើម្បីទៅលួចម៉ូតូ ហើយពេលកំពុងលួចនោះម្ចាស់ម៉ូតូមកដល់ហើយស្រែក ពេលនោះសហចារីនោះបានបាញ់ម្ចាស់ម៉ូតូស្លាប់ នោះអ្នកផ្ដើមគំនិតត្រូវទទួលខុសត្រូវពីបទលួច ដែលមានស្ថានទម្ងន់ដោយសារមរណភាពនៃជនរងគ្រោះ (មាត្រា

[39] ខាធើរីន អ៊ីឡូត ច្បាប់ព្រហ្មទណ្ឌបារាំង វីឡែន បោះពុម្ពផ្សាយ ឆ្នាំ២០១១ ទំ.៩០-៩១។

[40] ប្រភពដូចគ្នា សូមមើលទំ. ៩០។

[41] ប្រភពដូចគ្នាខាងលើ ទំ. ៩០។

៣៦០ ក្រមព្រហ្មទណ្ឌខ្មែរ) ពីព្រោះអ្នកផ្ដើមគំនិតគួរតែបានមើលឃើញជាមុនថា ការលួចដោយមានកាំភ្លើង វាអាចកើតចេញនូវទម្រង់ផ្សេងៗនៃការលួចដែលប្រើប្រាស់អាវុធ។

កិរិយា ឬសំដីធ្វេសប្រហែស ឬមិនអាចគ្រប់គ្រងបាន ជាកត្តាមិនទាន់គ្រប់គ្រាន់ដើម្បីកំណត់ចេតនាដើម្បីញុះញង់ឡើយ។ អ្នកញុះញង់ត្រូវមានឆន្ទៈដើម្បីចូលដៃ (s'associer) ដោយចេតនាទៅក្នុងអំពើល្មើសរបស់អ្នកប្រព្រឹត្តផ្ទាល់ គឺអ្នកញុះញង់និងអ្នកប្រព្រឹត្តផ្ទាល់ ធ្វើសកម្មភាពរួមគ្នា និងព្រមព្រៀងគ្នាសំដៅឲ្យបានលទ្ធផលល្មើសច្បាប់[42]។ ដូច្នេះ បុគ្គលដែលបានប្រព្រឹត្តកំហុសដោយការធ្វេសប្រហែស មិនអាចប្ដឹងចោទប្រកាន់ក្នុងឋានៈជាអ្នកសមគំនិត (ជាអ្នកផ្ដើមគំនិត) បានទេ ទោះបីការធ្វេសប្រហែសរបស់គាត់ ជាកំហុសរដ្ឋប្បវេណី និងនាំឲ្យគាត់ជាប់ការទទួលខុសត្រូវរដ្ឋប្បវេណីក៏ដោយ[43]។

នៅក្នុងករណីនៃការញុះញង់ ឬផ្ដើមគំនិតដោយការណែនាំគំនិត ឬព័ត៌មានដែលអ្នកណែនាំបានផ្ដល់នោះត្រូវបានអ្នកប្រព្រឹត្តយកទៅអនុវត្ត។ បើគំនិតនោះមិនត្រូវបានអនុវត្តទេ មានន័យថា ចេតនារបស់អ្នកណែនាំ និង ចេតនារបស់អ្នកប្រព្រឹត្តមិនស៊ីគ្នាទេ។

### គ. ព្យសនកម្ម (លទ្ធផល)

ដើម្បីឲ្យការញុះញង់ដោយការផ្ដើមគំនិតអាចផ្ដន្ទាទោសបាន ៖

១. បទល្មើសឧក្រិដ្ឋ ឬបទល្មើសមជ្ឈិមពិតជាបានប្រព្រឹត្តរួចរាល់ ឬ

២. បទល្មើសឧក្រិដ្ឋ ឬបទល្មើសមជ្ឈិមនោះបានប៉ុនប៉ង។

ទោះបីជាអ្នកផ្ដើមគំនិតបានបញ្ជាឲ្យបុគ្គលម្នាក់ប្រព្រឹត្តអំពើចោរកម្ម ឬប្លន់ តែបើបុគ្គលនោះមិនបានប្រព្រឹត្តអំពើល្មើសនោះទេ អ្នកផ្ដើមគំនិត និងបុគ្គលនោះមិនអាចត្រូវបានផ្ដន្ទាទោសចំពោះការបញ្ជានោះដែរ។

បើគ្មានបទល្មើសចោរកម្ម ឬប្លន់កើតឡើងជាក់ស្ដែងទេ ប៉ុន្តែបុគ្គលនោះបានប៉ុនប៉ងប្រព្រឹត្តអំពើល្មើស អ្នកញុះញង់ និងបុគ្គលនោះត្រូវទទួលខុសត្រូវចំពោះបទល្មើសដែលត្រូវបានប៉ុនប៉ងនោះ។

**<u>ការប៉ុនប៉ងប្រព្រឹត្តបទឧក្រិដ្ឋ</u> ៖** ការប៉ុនប៉ងប្រព្រឹត្តបទឧក្រិដ្ឋមាននៅជាមួយគ្រប់បទល្មើសឧក្រិដ្ឋ (មាត្រា២៧) នេះមានន័យថា ការប៉ុនប៉ងប្រព្រឹត្តបទឧក្រិដ្ឋឃាតកម្មមានជានិច្ច ព្រោះឃាតកម្មជាបទឧក្រិដ្ឋ (ដាក់ពន្ធនាគារចាប់ពី៥ឆ្នាំឡើងទៅ)។ បុគ្គលដែលបានប្រព្រឹត្តអំពើឃាតកម្មមិនសម្រេច គេអាចចោទពីបទប៉ុនប៉ងឃាតកម្មបាន។

**<u>ការប៉ុនប៉ងក្នុងបទមជ្ឈិម</u> ៖** ការប៉ុនប៉ងប្រព្រឹត្តបទមជ្ឈិមមានអត្ថិភាពបាន លុះណាតែមានច្បាប់កំណត់ (មាត្រា២៧)។ ឧទាហរណ៍ ការប៉ុនប៉ងរុកកួនខាងផ្លូវភេទ មានអត្ថិភាព ពីព្រោះច្បាប់មានចែងពីបទល្មើសប៉ុនប៉ងរុកកួនខាងផ្លូវភេទ (មាត្រា២៥១) ដែលបែកខ្ញែងចេញពីបទមជ្ឈិមបទរុកកួនខាងផ្លូវភេទ (មាត្រា២៥០) ដែលផ្ដន្ទាទោសដាក់ពន្ធនាគារពីប្រាំមួយថ្ងៃដល់បីខែ។ ប៉ុន្តែគ្មានការប៉ុនប៉ងចាប់ឃុំឃាំង និងបង្ខាំងដោយខុសច្បាប់ឡើយ ពីព្រោះច្បាប់មិនបានចែងពីបទល្មើសប៉ុនប៉ងចាប់ឃុំឃាំង និងបង្ខាំងដោយខុសច្បាប់នេះទេ គឺមានតែបទចាប់ឃុំឃាំងនិងបង្ខាំងដោយខុសច្បាប់ប៉ុណ្ណោះ ដែលត្រូវផ្ដន្ទាទោសដាក់ពន្ធនាគារពី១ឆ្នាំ ដល់ ៣ឆ្នាំ (មាត្រា២៥៣)។ ដូច្នេះបើបុគ្គលម្នាក់មិនបានសម្រេចបទល្មើសឃុំខ្លួនបុគ្គលណាមួយដោយខុសច្បាប់ទេ មនុស្សដែលញុះញង់ឲ្យឃុំខ្លួនមនុស្សម្នាក់ទៀតមិនអាចត្រូវចោទប្រកាន់ពីបទ

---

[42] Gaston Stefani et al., <u>Droit pénal général</u>, Dalloz, 15e ed. p. 266.

[43] ប្រភពដូចខាងលើ។

ញុះញង់ប៉ុនប៉ងឃុំខ្លួនដោយខុសច្បាប់ឡើយ ពីព្រោះគ្មានប្រភេទបទល្មើសប៉ុនប៉ងចាប់ឃុំឃាំង និងបង្ខាំងដោយខុសច្បាប់ឡើយ។

**<u>និយមន័យនៃការប៉ុនប៉ង</u> ៖** មាត្រា ២៧ បានកំណត់អំពីនិយមន័យនៃការប៉ុនប៉ងថា ៖

ការប៉ុនប៉ងក្នុងបទឧក្រិដ្ឋ ឬក្នុងករណីដែលច្បាប់បានចែងទុកក្នុងបទមជ្ឈិម អាចត្រូវផ្តន្ទាទោសបានកាលណាលក្ខខណ្ឌខាងក្រោមនេះត្រូវបានបំពេញ ៖

- ចារីបានចាប់ផ្តើមអនុវត្តបទល្មើស មានន័យថាចារីបានប្រព្រឹត្តអំពើដែលមានគោលបំណងដោយផ្ទាល់ដើម្បីប្រព្រឹត្តបទល្មើស និង
- ចារីមិនបានបញ្ឈប់អំពើរបស់ខ្លួនទៅវិញដោយស្ម័គ្រចិត្ត តែត្រូវបានរាំងស្ទះ ឬអាក់ខានដោយឥទ្ធិពលនៃកាលៈទេសៈក្រៅឆន្ទៈរបស់ខ្លួន ។

អំពើត្រៀមបម្រុងដែលពុំមានគោលបំណងដោយផ្ទាល់ដើម្បីប្រព្រឹត្តបទល្មើសមិនមែនជាការចាប់ផ្តើមអនុវត្តទេ ។

ការប៉ុនប៉ងក្នុងបទលហុ ពុំទទួលការផ្តន្ទាទោសទេ។

ដំណើរការនៃការប្រព្រឹត្តបទល្មើសមានភាពប្រទាក់ក្រឡាគ្នាដូចខាងក្រោមនេះ ៖

<u>ការគិត</u> ៖ តើត្រូវប្រព្រឹត្ត ឬមិនប្រព្រឹត្ត

<u>ការប្តេជ្ញាចិត្ត</u> ៖ សម្រេចចិត្តប្រព្រឹត្តបទល្មើស

<u>ការរៀបចំ</u> ៖ ជាការធ្វើផែនការ និងការរៀបចំគ្រប់មធ្យោបាយទាំងអស់ដើម្បីប្រព្រឹត្តបទល្មើស។ នៅក្នុងសំណុំរឿងលេខ ០០១ អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជាបានកំណត់ថា "ការរៀបចំផែនការទាមទារឲ្យមនុស្សម្នាក់ ឬច្រើននាក់រៀបប្លង់អំពើដែលបង្កើតបានជាបទល្មើសមួយ ឬច្រើន ដែលត្រូវប្រព្រឹត្តបទល្មើសនៅពេលក្រោយ។ គេត្រូវបង្ហាញថា ការធ្វើផែនការជាកត្តារួមចំណែកមួយយ៉ាងធំដល់អំពើប្រព្រឹត្តបទល្មើស" (កថាខ័ណ្ឌ ៥១៨)។

<u>ការអនុវត្ត</u> ៖ ការធ្វើឲ្យផែនការក្លាយទៅជាសកម្មភាព

<u>លទ្ធផល</u> ៖

- ផែនការបានសម្រេច
- ផែនការបរាជ័យ

ជាគោលការណ៍ទូទៅនៃច្បាប់ ការរៀបចំមិនត្រូវបានដាក់ទណ្ឌកម្មនៅឡើយទេ ដោយសារតែវាមានភាពរហ័សពេកក្នុងការកំណត់ពីភាពឃើញច្បាស់នៃបទល្មើស មានន័យថា ច្បាប់មិនដាក់ទណ្ឌកម្មលើការរៀបចំទេ ពីព្រោះការបង្ហើបឲ្យឃើញឬការស្តែងចេញជាបទល្មើសនៅមិនទាន់លេចចេញច្បាស់នៅឡើយ។ ការចាប់ផ្តើមអនុវត្តការប្រព្រឹត្តបទល្មើសកើតនៅពេលអំពើរបស់ចុងចោទបើកបង្ហាញឲ្យឃើញពីឆន្ទៈជាស្ថាពររបស់គេដែលគ្មានស្រពិចស្រពិល និងដែលផ្សារភ្ជាប់ជាមួយគោលដៅ និងកៀកមែនទែនទៅនឹងគោលដៅដែលជនជាប់ចោទចង់ទៅដល់[44]។ ច្បាប់គិតថា បើនៅស្រពិចស្រពិលនៅឡើយ គួរទុកការរៀបចំឲ្យជាប្រយោជន៍ដល់ជនសង្ស័យ (គោលការណ៍វិមតិសង្ស័យត្រូវបានជាប្រយោជន៍ដល់ជនសង្ស័យ)។

ដើម្បីឲ្យគេទទួលខុសត្រូវពីបទល្មើសប៉ុនប៉ង ចារីត្រូវមានចេតនាប្រព្រឹត្តបទល្មើសដែលមិនអាចដកថយបាន។ ឆន្ទៈរបស់គាត់ក្នុងការប្រព្រឹត្តបទល្មើសត្រូវតែមានបន្តរហូតដល់កាលៈទេសៈជាក់លាក់ខាង

[44] Gaston Stefani et al., <u>Droit pénal général</u>, Dalloz, 15$^{e}$ ed. p. 198-199.

ក្រៅណាមួយរារាំងដើម្បីបញ្ឈប់សកម្មភាពរបស់គាត់ ឧទាហរណ៍ គាត់ត្រូវបានប៉ូលីសចាប់បាន។ បើនៅត្រង់ចំណុចមួយបន្ទាប់ពីការរៀបចំការប្រព្រឹត្តបទល្មើស ចារីសម្រេចថាខ្លួនមិនគួរធ្វើអំពើអាក្រក់បែបនេះដល់ជនរងគ្រោះទេ ដូច្នេះចេតនារបស់គាត់អាចដកមកវិញបាន ហេតុដូច្នេះគ្មានបទល្មើសប៉ុនប៉ងកើតឡើងឡើយ។

មានតេស្តមួយចំនួនដើម្បីកំណត់ឲ្យដឹងថាអំពើមួយជាអំពើប៉ុនប៉ង។ នៅក្នុងក្រមព្រហ្មទណ្ឌខ្មែរ មានតេស្តនៃផលវិបាកដោយផ្ទាល់។ តុលាការកំពូលបារាំងបានកំណត់តេស្តមួយចំនួនដែរ។

**ការតេស្តវិបាកដោយផ្ទាល់ ៖** ការប៉ុនប៉ងត្រូវបានគេរកឃើញដោយហេតុការណ៍បញ្ជាក់ថាជនល្មើស បានចូលទៅក្នុងដំណាក់ការអនុវត្ត ហើយធ្វើអំពើអ្វីម្យ៉ាងដែលមានគោលដៅតម្រង់ដោយផ្ទាល់ទៅរកការប្រព្រឹត្តបទល្មើសដែលគ្រោងទុក ព្រមទាំងមានចេតនាប្រព្រឹត្តបទល្មើសនោះ។ អំពើទាំងឡាយដែលតភ្ជាប់ដោយផ្ទាល់ទៅនឹងបទល្មើសមួយ គឺជាអំពើទាំងឡាយណាដែលបង្កើតបានយ៉ាងសមរម្យនូវចំណងតភ្ជាប់គ្នារវាងអំពើទាំងនោះនិងការប្រព្រឹត្តបទល្មើស។ ឧទាហរណ៍ ការភ្ជង់កាំភ្លើងទៅរកជនរងគ្រោះ ដោយដាក់ម្រាមដៃនៅលើកៃ ជាការតភ្ជាប់នៃអំពើត្រៀមកាច់កៃទៅនឹងការសម្លាប់មនុស្សនោះ។ អំពើដែលមិនតភ្ជាប់ដោយផ្ទាល់ទៅនឹងបទល្មើសមួយទៀត គឺជាអំពើដែលអាចមិននាំទៅរកការប្រព្រឹត្តបទល្មើស។ ឧទាហរណ៍ ការទិញកាំភ្លើងអាចមិនតភ្ជាប់ដោយផ្ទាល់ទៅនឹងការសម្លាប់មនុស្សទេ ព្រោះការទិញកាំភ្លើងអាចជាការយកទៅប្រើដើម្បីការពារខ្លួន។

## តេស្តនៃវិបាកដោយផ្ទាល់

| ដំណាក់ការត្រៀមបំរុង (ក) | ដំណាក់ការអនុវត្ត ( អំពើដែលតម្រង់ផ្ទាល់ទៅរកការប្រព្រឹត្ត) (ខ) | កាលៈទេសៈដែលចូលមកជ្រៀតជ្រែក (គ) | ការប្រព្រឹត្តបានសម្រេច (ឃ) |
|---|---|---|---|
| ប៉ូលីសស្តាប់ឮមនុស្សបីនាក់ពិភាក្សាគ្នាពីផែនការប្លន់ហាងមាសនៅផ្សារថ្មី | ក្រុមនេះត្រូវបានគេឃើញមានកាន់កាំភ្លើង និងបិទមុខ ចេញពីពោធិ៍ចិនតុងនិងធ្វើដំណើរតាមដងមហាវិថីរុស្ស៊ី រួចមកដល់ធនាគារកាណាឌីយ៉ាក៏បត់ទៅរកផ្សារថ្មី ៖<br>អំពើតម្រង់ផ្ទាល់ លាក់អត្តសញ្ញាណ កាន់កាំភ្លើង បត់ | កាលៈទេសៈដែលមកបង្អាក់ការសម្រេចការប្រព្រឹត្តបទល្មើស ប៉ូលីសឃើញហើយបញ្ឈប់។ ការប៉ុនប៉ងប្លន់កើតឡើង។ | ហាងមាសត្រូវបានប្លន់។ គោលដៅនៃអំពើត្រូវបានសម្រេច។ |

ទៅផ្សារថ្មី អាចឲ្យគេ
កំណត់ពីការតភ្ជាប់គ្នា
ដោយផ្ទាល់រវាងអំពើទាំង
អស់នេះ និង ការប្លន់ (អំពើ
ដែលគិតមកដើម្បីតភ្ជាប់
ជាមួយគោលដៅ)។ (ខ)
នាំតភ្ជាប់ដោយផ្ទាល់
ជាមួយនឹង (ឃ)។

មានតេស្តមួយទៀត ដែលតុលាការបារាំងបានយកមកប្រើដើម្បីកំណត់ថា តើអំពើមួយជាការប៉ុនប៉ងឬយ៉ាងណា។ តេស្តនោះហៅថា "តេស្តនៃវិបាកដោយផ្ទាល់ និងកៀកបង្កើយ"។ តេស្តនេះមិនខុសពីតេស្តនៃវិបាកដោយផ្ទាល់ទេ ប៉ុន្តែតេស្តនេះផ្តោតទៅលើពេលវេលា និងទីកន្លែង ជាសញ្ញានៃការចាប់ផ្តើមការអនុវត្តបទល្មើស។

**តេស្តនៃវិបាកដោយផ្ទាល់ និងកៀកបង្កើយ ៖** ការប៉ុនប៉ងត្រូវបានគេកត់សំគាល់ដោយអំពើដែលត្រូវមានវិបាកដោយផ្ទាល់និងកៀកបង្កើយដល់ការសម្រេចបទល្មើស ដោយអំពើនោះបានឈានដល់ដំណាក់ការអនុវត្តបទល្មើស។

## <u>តេស្តនៃវិបាកដោយផ្ទាល់ និងកៀកបង្កើយ</u>

(Conséquence directe et immédiate)

| **ដំណាក់ការត្រៀមបម្រុង**<br>**(ក)** | **ដំណាក់ការអនុវត្ត**<br>( អំពើដែលមានវិបាកដោយផ្ទាល់និងកៀកបង្កើយដល់ការសំរេចការប្រព្រឹត្ត) **(ខ)** | **កាលៈទេសៈដែលចូលមកជ្រៀតជ្រែក**<br>**(គ)** | **ការប្រព្រឹត្តបានសម្រេច**<br>**(ឃ)** |
|---|---|---|---|
| រៀបចំសម្ភារៈនិងគូសប្លង់ប្លន់ ហើយធ្វើដំណើរទៅកាន់ធនាគារ(អំពើនេះអាចតភ្ជាប់ដោយផ្ទាល់ជាមួយការប្លន់)។ | ជ្រៀតចូលធនាគារនិងចាំស្ទាក់រថយន្តដឹកប្រាក់ចេញពីធនាគារ។<br>*<u>ដោយផ្ទាល់</u>* ៖ អំពើដាក់ការពួនស្ទាក់មានតំណភ្ជាប់ | កាលៈទេសៈដែលបង្អាក់ការសម្រេចការប្រព្រឹត្តបទល្មើស ៖ អ្នកយាមធនាគារឃើញ | ធនាគារត្រូវបានប្លន់<br>(គោលដៅនៃអំពើត្រូវបានសម្រេច) |

| | | | |
|---|---|---|---|
| | ជាមួយការប្លន់(អំពើដែលគូសមកដើម្បីតភ្ជាប់ដោយផ្ទាល់ជាមួយនឹងគោលដៅ) (ខ) នាំទៅរក (ឃ) ដោយត្រង់តែម្តង<br>*កៀកបង្កើយ* ៖ ការដាក់ការពួនស្ទាក់នៅសល់តែមួយជំហានទៀតកៀកបង្កើយនឹងការប្លន់(ពេលនិងទីកន្លែងរវាងកិច្ចអនុវត្ត និងការសម្រេចការប្រព្រឹត្តនៅខ្លី) | ហើយបញ្ឈប់អ្នកទាំងនោះ ៖<br>មានការប៉ុនប៉ងប្លន់ | |
| | មនុស្សម្នាក់ចូលក្នុងឡាន, អង្គុយមុខចង្កូត ហើយសិកសោចូលកុងតាក់បញ្ឆេះ។<br>*ដោយផ្ទាល់* ៖ សិកសោជាការតភ្ជាប់ដោយផ្ទាល់ជាមួយនឹងការបញ្ឆេះម៉ាស៊ីនរួចបរចេញ (លួច)<br>*កៀកបង្កើយ* ៖ សោនៅក្នុងកុងតាក់បញ្ឆេះ ៖ នៅសល់ពីរជំហានខ្លីទៅកាន់ការបញ្ឆេះនិងបរចេញទៅ។ | អ្នកយាមឃើញ ហើយបញ្ឈប់មនុស្សនោះ៖<br>មានការប៉ុនប៉ងលួច | ឡានបរចេញបាត់ (លួច) |
| | មនុស្សម្នាក់បើកទូដែកដែលមានលុយនិងអលង្ការ<br>*ដោយផ្ទាល់* ៖ បើកទូជាការតភ្ជាប់ដោយផ្ទាល់ជាមួយនឹងការយកប្រាក់ទៅបាត់ (លួច) | ឆ្មាំចូលមកនិងបញ្ឈប់<br>ការបើកទូមិនរួច | យកប្រាក់ចេញទៅ |

| | | | |
|---|---|---|---|
| | *កៀកបង្កើយ* ៖ការបើកទូជាជំហានកៀកបង្កើយជាមួយនឹងការដកយកប្រាក់ចេញទៅ | ព្រោះទូនោះមាំពេកមិនមែនជាកាលៈទេសៈបង្អាក់ទេ | |

| | | | |
|---|---|---|---|
| | ចាប់សង្សារបង្ខាំងនៅក្នុងសណ្ឋាគារ ហើយទូរស័ព្ទភ្ញៀវមករួមភេទ<br>*ដោយផ្ទាល់* ៖ បង្ខាំងចលនាស្ត្រីហើយហៅភ្ញៀវតភ្ជាប់ដោយផ្ទាល់ជាមួយការផ្គត់ផ្គង់ភេទឲ្យមនុស្សម្នាក់ទៀត (សញ្ជារកម្ម)<br>*កៀកបង្កើយ* ៖ការបង្ខាំងធ្វើឲ្យស្ត្រីនោះត្រៀមខ្លួនជាស្រេចឲ្យបម្រើផ្លូវភេទ។ | ភ្ញៀវមិនមកៈ ប៉ុនប៉ងពេស្យាកម្ម | ពេស្យាកម្ម |

តេស្តទាំងពីរមិនមានភាពខុសគ្នាប៉ុន្មានទេ។ តេស្តនៃផលវិបាកដោយផ្ទាល់និងកៀកបង្កើយជាតេស្តដែលទាមទារឲ្យការស្តែងចេញជាបទល្មើសកាន់តែប្រត្យក្សឡើង។

## ៤. ទិដ្ឋភាពរួមនៃបទល្មើសញុះញង់ដោយផ្ទាល់ (Direct Incitement)

នៅក្នុងប្រព័ន្ធច្បាប់ព្រហ្មទណ្ឌបារាំងមានបទល្មើសពីរយ៉ាង គឺបទល្មើសជាសម្ភារៈ (infraction matérielle) និង បទល្មើសជាទម្រង់ (infraction formelle)។ បទល្មើសជាសម្ភារៈ គឺជាបទល្មើសដែលនាំមកនូវលទ្ធផលគឺ ការខូចខាត រីឯបទល្មើសជាទម្រង់ ជាបទល្មើសដែលកើតចេញពីការធ្វើអំពើមួយដែលច្បាប់ដាក់ទោស ទោះបីអំពើនោះមិននាំឲ្យកើតជាលទ្ធផលអ្វីមួយក៏ដោយ[45]។ គេអាចហៅបទល្មើសជាសម្ភារៈថា ជា"បទល្មើសដែលបង្កើតលទ្ធផល" (infraction de résultat) រីឯបទល្មើសជាទម្រង់ គេហៅថា

45 http://fr.jurispedia.org/index.php/Distinction_des_infractions_mat%C3%A9rielles_des_infractions_formelles_(fr)

"បទល្មើសនៃមធ្យោបាយ" (infraction de moyen)[46] គឺបទល្មើសត្រូវបានសម្រេចតែម្តងនៅពេលណាគេប្រើមធ្យោបាយណាមួយដែលច្បាប់ហាមឃាត់ ទោះបីគោលដៅនៃមធ្យោបាយដែលប្រើនោះមិនបានទៅដល់គោលដៅនោះក៏ដោយ។

បទល្មើសញុះញង់ដោយផ្ទាល់ខុសគ្នាពីការញុះញង់ដោយការផ្តើមគំនិត ដោយសារការញុះញង់ដោយការផ្តើមគំនិតទាមទារឲ្យមានការប្រព្រឹត្តបានសម្រេច ឬការប៉ុនប៉ងប្រព្រឹត្ត (ដែលជាបទល្មើសជាសម្ភារៈ) រីឯការញុះញង់ដោយផ្ទាល់វិញមិនទាមទារជាចាំបាច់ឲ្យមានការប្រព្រឹត្តនូវអំពើដែលគេញុះញង់នោះទេ មានន័យថា ពាក្យសំដីញុះញង់ខ្លួនឯងនេះតែម្តងជាបទល្មើស (បទល្មើសជារូបរាង)។ បទញុះញង់ដោយផ្ទាល់ គឺជាបទល្មើសដែលអ្នកញុះញង់បញ្ចេញសំដី កិរិយា ឬប្រើរូបភាព ឬមធ្យោបាយអ្វីផ្សេងទៀតក្នុងគោលបំណងញុាំងឲ្យមនុស្សម្នាក់ ឬច្រើននាក់ប្រព្រឹត្តអំពើអ្វីមួយតាមការញុះញង់នោះ។

ជាគោលការណ៍ទូទៅ ច្បាប់មិនផ្តន្ទាទោសដល់ការញុះញង់ណាដែលគ្មានបានផលនោះទេ។ មានន័យថា បើការញុះញង់មិននាំទៅដល់ការប្រព្រឹត្តបទល្មើស ឬ ការប៉ុនប៉ងប្រព្រឹត្តបទល្មើសទេនោះ ច្បាប់ក៏មិនផ្តន្ទាទោសលើការញុះញង់នោះដែរ ទោះបីជាមតិសាធារណជនយល់ឃើញថាការញុះញង់នោះមិនសមស្របក្តី។ តាមទ្រឹស្តីនេះ ច្បាប់ផ្តន្ទាទោសការញុះញង់បាន លុះត្រាតែអំពើដែលប្រព្រឹត្តដោយអ្នកទទួលការញុះញង់ជាអំពើចូលជាបទល្មើសដែលត្រូវផ្តន្ទាដោយច្បាប់ព្រហ្មទណ្ឌដែរ ដូចជាប្លន់ ឃាតកម្មជាដើម។

ប៉ុន្តែ មានស្ថានការណ៍ខ្លះ អំពើដែលប្រព្រឹត្តដោយអ្នកទទួលការញុះញង់ ជាអំពើដែលមិនអាចផ្តន្ទាទោសបាន ថ្វីបើអំពើញុះញង់នោះជាអំពើអាក្រក់ដែលត្រូវចៀសវាង។ ឧទាហរណ៍ លោក ក បញ្ចុះបញ្ចូលឲ្យកុមារា ខ លេបថ្នាំសម្លាប់ខ្លួនឯង។ ក្នុងករណីនេះ កុមារា ខ ប្រព្រឹត្តអត្តឃាតកម្ម ហើយអត្តឃាតកម្មមិនមែនជាបទល្មើសដែលត្រូវផ្តន្ទាទោសទេ។ លោក ក ជាមនុស្សអាក្រក់ណាស់ តែបើតាមគោលការណ៍ទូទៅនៃច្បាប់ព្រហ្មទណ្ឌ គេមិនអាចដាក់ទោសលោក ក បានទេ ព្រោះអំពើអត្តឃាតមិនអាចផ្តន្ទាទោសបាន។ បើអំពើអត្តឃាតមិនអាចផ្តន្ទាទោសបាន ដូច្នេះអ្នកញុះញង់ឲ្យមានអត្តឃាតកម្មក៏មិនអាចផ្តន្ទាទោសបានដែរ។ ការនេះគេហៅថាភាពទាល់ច្រកនៃច្បាប់។ ដូច្នេះក្រុមនីតិករ គឺអ្នកធ្វើច្បាប់ (ដូចជាតំណាងរាស្ត្ររដ្ឋាភិបាលជាដើម) ត្រូវរកច្រកចេញឲ្យបានដើម្បីដោះស្រាយបញ្ហានេះ។ ដំណោះស្រាយ គឺការបង្កើតបទល្មើសញុះញង់ឯករាជមួយ ដែលគេហៅថា "បទល្មើសញុះញង់ដោយផ្ទាល់"។ នេះជាវិធីនៃនីតិកម្មបែបបារាំង។ ចំពោះបញ្ហាអត្តឃាតនេះ គេបង្កើតបទល្មើសមួយឈ្មោះថា បទល្មើសញុះញង់ដោយផ្ទាល់ឲ្យធ្វើអត្តឃាត។ បទល្មើសញុះញង់ដោយផ្ទាល់នេះមិនទាមទារឲ្យមានលទ្ធផលទេ។ ដូច្នេះ ការបង្កើតបទល្មើសញុះញង់ដោយផ្ទាល់នេះ ជះឥទ្ធិពលទៅលើសេរីភាពរបស់មនុស្ស ជាពិសេសសេរីភាពខាងការបញ្ចេញមតិ ព្រោះវាមិនទាមទារឲ្យមានលទ្ធផល ហើយមនុស្សម្នាក់អាចទទួលទោសយ៉ាងងាយដោយសារតែមាត់។ ដូច្នេះ គេបង្កើតបទល្មើសញុះញង់សម្រាប់តែការណាដែលចាំបាច់ការពារហានិភ័យធំដុំដែលអាចកើតឡើងបើគ្មានការទប់ស្កាត់ជាមុន។

ហេតុផលដែលត្រូវបង្កើតបទល្មើសញុះញង់ គឺដើម្បីការពារហានិភ័យដែលកើតឡើងជា**បន្ទាន់ និងធ្ងន់ធ្ងរ**ពីអំពើញុះញង់។ ហានិភ័យដែលអាចកើតឡើងពីការញុះញង់មានដូចជា ការបង្កើតចលាចល ការប្រើអាវុធនៅក្នុងចំណោមក្រុមមនុស្សជាដើម។ អំពើទាំងនេះទាមទារឲ្យមានការទប់ស្កាត់កុំឲ្យកើតឡើងបាន ព្រោះថាបើបានកើតឡើងហើយ វានាំឲ្យមានអន្តរាយដល់អាយុជីវិត ដូច្នេះត្រូវការពារឲ្យបានកុំឲ្យយឺត

[46] ប្រភពដូចខាងលើ។

ពេលទាន់។ ហេតុផលខ្លះទៀតដូចជាការពារកុមារកុំឲ្យធ្លាក់ចូលក្នុងការល្បួងឲ្យប្រព្រឹត្តអំពើអាក្រក់ព្រោះកុមារងាយនឹងទទួលឥទ្ធិពលមិនល្អនោះណាស់។

ក្រមព្រហ្មទណ្ឌខ្មែរ ដែលជាក្រមចម្លងពីប្រទេសបារាំង បានអនុម័តយកបទល្មើសញុះញង់ដោយផ្ទាល់មួយចំនួនមាន ៖ បទបទញុះញង់ឲ្យបោះបង់ទារក (មាត្រា ៣៣០) បទល្មើសញុះញង់ដោយផ្ទាល់ទៅលើអនីតិជនឲ្យប្រើគ្រឿងស្រវឹង សុំទាន និងប្រព្រឹត្តបទឧក្រិដ្ឋ ឬមជ្ឈិម (មាត្រា ៣៤៣-៣៤៥) បទញុះញង់ឲ្យកាន់អាវុធប្រឆាំងនឹងអាជ្ញាធរស្របច្បាប់ (មាត្រា ៤៦៤) បទញុះញង់ឲ្យប្រជាពលរដ្ឋកាន់អាវុធប្រឆាំងនឹងប្រជាពលរដ្ឋមួយផ្នែកទៀត (មាត្រា ៤៦៥) បទញុះញង់ឲ្យយោធិនចូលបម្រើរដ្ឋបរទេស (មាត្រា ៤៦៨) បទញុះញង់កុំឲ្យយោធិនស្តាប់បង្គាប់ (មាត្រា ៤៧១) បទញុះញង់ឲ្យមានការរើសអើង (មាត្រា ៤៩៦) បទញុះញង់ឲ្យប្រព្រឹត្តអំពើប្រឆាំងនឹងអ្នករាជការសាធារណៈ (មាត្រា ៥០៥) បទញុះញង់ឲ្យប្រព្រឹត្តបទឧក្រិដ្ឋ (មាត្រា ៤៩៥)។ បទល្មើសញុះញង់ខាងក្រោយគេនេះ (មាត្រា ៤៩៥) អាចមានផលប៉ះពាល់ដល់សេរីភាពក្នុងការបញ្ចេញមតិ ដោយសារន័យទូលំទូលាយពេក។

ដើម្បីការពារសេរីភាពនៃការនិយាយស្តី និងការបញ្ចេញមតិ អង្គនីតិបញ្ញត្តិគួរយកសេចក្តីអត្ថាធិប្បាយរបស់គណៈកម្មាធិការសិទ្ធិមនុស្សរបស់អង្គការសហប្រជាជាតិជាគោលការណ៍ណែនាំ។ សេចក្តីអត្ថាធិប្បាយនេះ ដែលភាសាអង់គ្លេសហៅថា General Comment ជាការបកស្រាយរបស់គណៈកម្មាធិការសិទ្ធិមនុស្សលើកតិសញ្ញាស្តីពី សិទ្ធិពលរដ្ឋ និងសិទ្ធិនយោបាយ ដើម្បីស្រាយបំភ្លឺន័យ និងវិសាលភាពអនុវត្តនៃមាត្រានានានៃកតិកាសញ្ញា។ ដោយសារប្រទេសជាសមាជិកនៃកតិសញ្ញាមានកាតព្វកិច្ចត្រូវអនុវត្តបទបញ្ញត្តិនៃកតិកាសញ្ញា (មាត្រា ២) សេចក្តីអធិប្បាយលើកតិកាសញ្ញាគឺជាប្រទីបសម្រាប់នាំផ្លូវឲ្យរដ្ឋជាភាគីអនុវត្តឲ្យស្របតាមចេតនានៃកតិកាសញ្ញា។ ប្រទេសខ្មែរបានធ្វើសច្ចាប័នលើកតិកាសញ្ញាស្តីពីសិទ្ធិពលរដ្ឋនិងសិទ្ធិនយោបាយរួចហើយ ដូច្នេះ ប្រទេសខ្មែរត្រូវតែអនុវត្តតាមសេចក្តីអធិប្បាយលើកតិកាសញ្ញានេះ។

សេចក្តីអធិប្បាយលេខ ៣៤ នៃកតិកាសញ្ញាស្តីពីសិទ្ធិពលរដ្ឋ និងសិទ្ធិនយោបាយបានណែនាំថាការដាក់កំហិតលើសេរីភាពនៃការបញ្ចេញមតិនិងការនិយាយស្តីអាចធ្វើបាន តែក្នុងហេតុផលការពារ (១) សន្តិសុខជាតិ (២) សណ្តាប់ធ្នាប់សាធារណៈ (៣) សីលធម៌ និង (៤) សុខភាពសាធារណៈ។

ប៉ុន្តែ ទោះជាមានការដាក់កំហិតលើសេរីភាពក្នុងការនិយាយស្តីនៅក្នុងវិស័យទាំងនេះក្តី រដ្ឋមិនមែនចេះតែធ្វើច្បាប់ហាមប្រាមការនិយាយស្តីតាមតែចិត្តនឹកឃើញនោះទេ។ ច្បាប់អាចដាក់កំហិតការនិយាយស្តីបានតែក្នុងករណី (១) ចាំបាច់ (២) សមាមាត្រ និង (៣) មានន័យជាក់ច្បាស់គ្រប់គ្រាន់ (sufficient precision) ដែលគេមិនអាចយកទៅបកស្រាយតាមចិត្តចង់។ ឧទាហរណ៍ រដ្ឋមិនអាចអនុម័តច្បាប់ដាក់ទោសការញុះញង់ឲ្យប្រឆាំងនឹងផែនការអភិវឌ្ឍរបស់រដ្ឋាភិបាលបានទេ ព្រោះវាអាចធ្វើឲ្យប៉ះពាល់ដល់សេរីភាពនៃការសម្តែងមតិចំពោះផែនការនោះ។ បើក្រឡេកទៅមើលមាត្រា ៤៩៥ នៃក្រមព្រហ្មទណ្ឌវិញ បញ្ហាមួយដំបូងគេដែលចោទឡើងគឺ ការមិនមានលក្ខណៈ "ជាក់ច្បាស់គ្រប់គ្រាន់"។ មាត្រានេះចែងថា ៖

> អំពើញុះញង់ដោយផ្ទាល់ឲ្យប្រព្រឹត្តបទឧក្រិដ្ឋ ឬប្រព្រឹត្ត**អំពើបង្កឲ្យមានភាពវឹកវរធ្ងន់ធ្ងរដល់សន្តិសុខសង្គម** តាមមធ្យោបាយណាមួយក្នុងចំណោមមធ្យោបាយដែលមានចែងនៅក្នុងមាត្រា ៤៩៤ (លក្ខខណ្ឌអត្ថិភាពនៃការញុះញង់) នៃក្រមនេះ ត្រូវផ្តន្ទាទោសដាក់ពន្ធនាគារពី ៦ (ប្រាំមួយ) ខែ ទៅ ២ (ពីរ) ឆ្នាំ និងពិន័យជាប្រាក់ពី ១.០០០.០០០ (មួយលាន) រៀល ទៅ ៤.០០០.០០០ (បួនលាន) រៀល ប្រសិនបើការញុះញង់នេះគ្មានប្រសិទ្ធភាពទេ។ [*ន័យសង្កត់បន្ថែម*]

មាត្រា ៤៩៤ ចែងថា ៖

ដើម្បីអនុវត្តផ្នែកនេះ ការញុះញង់អាចត្រូវផ្តន្ទាទោសកាលបើអំពើនេះត្រូវបានប្រព្រឹត្ត ៖

១. ដោយសំដីតាមប្រភេទណាក៏ដោយ ដែលប្រកាសនៅទីកន្លែងសាធារណៈ ឬនៅក្នុងពេលប្រជុំជាសាធារណៈ។

២. ដោយសំណេរ ឬគំនូរ តាមប្រភេទណាក៏ដោយ ដែលត្រូវផ្សព្វផ្សាយនៅក្នុងចំណោមសាធារណជន ឬតាំងឲ្យសាធារណជនមើល។

៣. ដោយគ្រប់មធ្យោបាយទូរគមនាគមន៍សោតទស្សន៍សម្រាប់សាធារណជន។

អ្វីដែលមានលក្ខណៈមិនជាក់ច្បាស់គ្រប់គ្រាន់នៅក្នុងមាត្រា ៤៩៥ គឺពាក្យ "ភាពរឹករវធ្ងន់ធ្ងរ" និងពាក្យ "សន្តិសុខសង្គម"។ ពាក្យ "ភាពរឹករវធ្ងន់ធ្ងរ" នាំមកនូវការបកស្រាយទូលំទូលាយ ដូចជាថាស្ថានភាពប៉ុនណាទៅដែលហៅថាធ្ងន់ធ្ងរ។ ន័យទូលំទូលាយនាំមកនូវការបកស្រាយតាមចិត្ត (តាមការចូលចិត្តឬការចង់ផ្ទាល់ខ្លួន) របស់ចៅក្រមដែលជាការផ្ទុយនឹងគោលការណ៍ នៃការបកស្រាយតឹងរឹងដែលចែងនៅក្នុងមាត្រា ៥ នៃក្រមព្រហ្មទណ្ឌដែលចែងថា ៖

> ក្នុងរឿងព្រហ្មទណ្ឌ ច្បាប់ត្រូវបកស្រាយយ៉ាងតឹងរឹង។ ចៅក្រមមិនអាចពង្រីកវិសាលភាពអនុវត្ត ឬប្រព្រឹត្តតាមសទិសភាពបានឡើយ។

យោងតាមសេចក្តីអត្ថាធិប្បាយខាងលើ រដ្ឋជាសមាជិកអាចធ្វើច្បាប់កម្រិតសេរីភាពបុគ្គលដើម្បីការពារ (១) សន្តិសុខជាតិ (២) សណ្តាប់ធ្នាប់សាធារណៈ (៣) សីលធម៌ និង (៤) សុខភាពសាធារណៈ។ "សន្តិសុខសង្គម" ជាទូទៅមានន័យថាជាគោលនយោបាយរបស់រដ្ឋាភិបាលដើម្បីផ្តល់ការឧបត្ថម្ភផ្នែកសេដ្ឋកិច្ចដល់មនុស្សគ្មានការងារធ្វើ មនុស្សជរា មនុស្សពិការ ។ល។ (សូមមើលអត្ថន័យនៅក្នុងច្បាប់ស្តីពីរបបសន្តិសុខសង្គមសម្រាប់ជនទាំងឡាយដែលស្ថិតនៅក្រោមបទបញ្ញត្តិនៃច្បាប់ស្តីពីការងារ មាត្រា ១)។ តើសន្តិសុខសង្គមនេះមានន័យជា សន្តិសុខជាតិ ឬសណ្តាប់ធ្នាប់សាធារណៈ ឬអ្វីផ្សេងទៀត? កាលណាច្បាប់មានន័យល្ហឹងល្ហើយ ដូច្នេះវាបើកដៃឲ្យមន្ត្រីអនុវត្តច្បាប់ ឬចៅក្រមចង់បកស្រាយច្បាប់នោះឲ្យមានន័យជាអ្វីក៏បាន។ ពលរដ្ឋក៏មិនអាចគណនាទុកបានជាមុនថាតើអំពើ ឬសំដីណាខ្លះដែលអាចចាត់ចូលជាការញុះញង់បង្កឲ្យមានភាពរឹករវធ្ងន់ធ្ងរដល់សន្តិសុខសង្គមនោះបានឡើយ។

បើ "សន្តិសុខសង្គម" ជាពាក្យចង់សំដៅដល់ "សណ្តាប់ធ្នាប់សាធារណៈ" នោះគេអាចយោងទៅលើអត្ថបទមួយដែលមានចំណងជើងថា "គោលការណ៍ស៊ៀរ៉ាគុសស្តីពីបទបញ្ញត្តិនៃការដាក់កំហិត និងបដិបញ្ញត្តិនៅក្នុងកតិកាសញ្ញាអន្តរជាតិស្តីពីសិទ្ធិពលរដ្ឋ និងសិទ្ធិនយោបាយ" ឆ្នាំ១៩៨៤[47] (The Siracusa Principles on the Limitation and Derogation Provisions in the International Covenant on Civil and Political Rights)។ គោលការណ៍នេះបានអនុម័តចេញពីសន្និសិទនៅទីក្រុង ស៊ៀរ៉ាគុស ប្រទេសអ៊ីតាលី ដែលមានអ្នកជំនាញការច្បាប់ និងសិទ្ធិមនុស្សមកពីអង្គការល្បីៗក្នុងពិភពលោកចូលរួម។ គោលការណ៍នេះឲ្យនិយមន័យនៃពាក្យខ្លះដូចតទៅ ៖

"នៅក្នុងសង្គមប្រជាធិបតេយ្យ" មានន័យថារដ្ឋមានបន្ទុកត្រូវបង្ហាញថាការដាក់កំហិតមិនត្រូវធ្វើឲ្យខូចខាតដល់ការប្រព្រឹត្តទៅនៃប្រជាធិបតេយ្យនៅក្នុងសង្គមទេ។ ដោយសារមិនមានគំរូតែមួយនៃសង្គម

[47] សូមមើលនៅក្នុងទំព័រ http://www.refworld.org/docid/4672bc122.html

ប្រជាធិបតេយ្យ សង្គមដែលទទួលស្គាល់ គោរព និងការពារសិទ្ធិមនុស្សដែលចែងនៅក្នុងធម្មនុញ្ញសហប្រជាជាតិ និងសេចក្តីថ្លែងការណ៍ជាសកលនៃសិទ្ធិមនុស្សអាចត្រូវមើលឃើញថាត្រូវតាមនិយមន័យនេះ។

"សណ្តាប់ធ្នាប់សាធារណៈ" អាចមានន័យជាការសរុបវិធានទាំងអស់ដែលធានាការប្រព្រឹត្តទៅសង្គម ឬគោលការណ៍គ្រឹះមួយចង្កោមដែលសង្គមត្រូវបានកសាងឡើង។ ការគោរពសិទ្ធិមនុស្សគឺជាផ្នែកមួយនៃសណ្តាប់ធ្នាប់សាធារណៈ។

គេត្រូវបកស្រាយសណ្តាប់ធ្នាប់សាធារណៈ នៅក្នុងបរិបទនៃគោលបំណងនៃសិទ្ធិមនុស្សណាមួយដែលត្រូវដាក់កំហិត ដោយសារមូលហេតុនៃសណ្តាប់ធ្នាប់សាធារណៈនេះ។

អង្គការ ឬភ្នាក់ងាររដ្ឋដែលទទួលខុសត្រូវក្នុងការថែរក្សាសណ្តាប់ធ្នាប់សាធារណៈ ត្រូវដាក់ឲ្យស្ថិតនៅក្រោមការត្រួតពិនិត្យ នៅក្នុងការប្រើប្រាស់អំណាចរបស់គេ តាមរយៈសភា តុលាការ ឬ អង្គឯករាជ្យមានសមត្ថកិច្ចដទៃទៀត។

"សន្តិសុខជាតិ" ជាហេតុផលនៃការដាក់កំហិតលើសិទ្ធិរបស់ពលរដ្ឋដើម្បីការពារការរស់រានមានជីវិតរបស់ប្រទេសជាតិ បូរណភាពទឹកដី ឬឯករាជភាពនយោបាយទល់នឹងកម្លាំង ឬការគំរាមកំហែងប្រើកម្លាំង។ ហេតុផលសន្តិសុខជាតិមិនអាចយកមកប្រើដើម្បីដាក់កំហិត ដើម្បីទប់ស្កាត់ការគំរាមកំហែងនៅត្រឹមតែកន្លែងណាមួយ ឬការគំរាមកំហែងដាច់ដោយឡែកៗដល់ច្បាប់ និងសណ្តាប់ធ្នាប់។

ហេតុផលសន្តិសុខជាតិមិនអាចយកមកប្រើជាលេសសម្រាប់ការដាក់កំហិតដែលមានលក្ខណៈធំល្វឹងល្វើយ ឬតាមចិត្តនឹកឃើញ ហើយបើអាចយកហេតុផលនេះមកប្រើ គឺប្រើបានតែក្នុងករណីមានមធ្យោបាយការពារគ្រប់គ្រាន់ និងមានឧបាស្រ័យដ៏មានប្រសិទ្ធភាពទល់នឹងការបំពាននៃការប្រើហេតុផលនេះ។ ការរំលោភសិទ្ធិមនុស្សជាប្រព័ន្ធធ្វើឲ្យលំរលាយដល់សន្តិសុខជាតិ និងអាចឲ្យអន្តរាយដល់សន្តិភាពនិងសន្តិសុខអន្តរជាតិ។ រដ្ឋដែលទទួលខុសត្រូវនៅក្នុងការរំលោភនេះ មិនត្រូវលើកហេតុផលសន្តិសុខជាតិធ្វើជាយុត្តិកម្មឲ្យវិធានការដែលមានគោលដៅបង្ក្រាបការជំទាស់នឹងការរំលោភនេះ ឬមានគោលដៅធ្វើឲ្យកើតជាទម្លាប់នៃការបង្ក្រាបប្រឆាំងនឹងប្រជាជនខ្លួនឯងទេ។

រដ្ឋាភិបាល និងអ្នកការពារសិទ្ធិមនុស្សមានពេលខ្លះមានមតិមិនស្របគ្នាលើបញ្ហាតាក់តែងច្បាប់បង្កើតបទល្មើសញុះញង់ដោយផ្ទាល់ដែលមានន័យទូលំទូលាយ។ រដ្ឋាភិបាលតែងគិតផ្តល់អាទិភាពនៃសណ្តាប់ធ្នាប់សាធារណៈ សន្តិសុខជាតិ និងប្រសិទ្ធិភាពក្នុងការអនុវត្តច្បាប់។ អ្នកការពារសិទ្ធិមនុស្សតែងគិតដល់អានុភាពនៃច្បាប់ដែលធ្វើឲ្យសិទ្ធិសេរីភាពរបស់ពលរដ្ឋរួញស្វិត។ ខាងក្រោមនេះជាឧទាហរណ៍នៃការតវ៉ារបស់អ្នកការពារសិទ្ធិមនុស្សនៅប្រទេសបែលហ្ស៊ិកស្តីពីបទញុះញង់ដោយផ្ទាល់ឲ្យប្រព្រឹត្តភេរវកម្ម។ សូមមើលការវិភាគតវ៉ារបស់សម្ពន្ធការពារសិទ្ធិមនុស្សនៅប្រទេសបែលហ្ស៊ិកក្នុងទំព័រ ៖

http://www.liguedh.be/espace-presse/-123communiques-de-presse--1650/2012lincitation-indirecte-au-terrorisme-un-terme-qui-piege-la-liberte-dexpression

សេចក្តីព្រាងច្បាប់របស់ប្រទេសបែលហ្ស៊ិកមួយមានសេចក្តីថា ៖

> ត្រូវផ្តន្ទាទោស "ជនណាដែលផ្សព្វផ្សាយ ឬដាក់ឲ្យសាធារណជនទទួលបានតាមរបៀបណាក៏ដោយនូវសារមួយ ដោយមានចេតនាញុះញង់ឲ្យប្រព្រឹត្តបទល្មើសណាមួយក្នុងបណ្តាបទល្មើសនានា... កាលណាទង្វើនោះ ទោះបីគាំទ្រដោយផ្ទាល់ក្តី ឬដោយប្រយោលក្តី ដល់ការប្រព្រឹត្តបទល្មើសជាលក្ខណៈភេរវកម្ម បង្កើតជាហានិភ័យឲ្យបទល្មើសមួយ ឬច្រើនអាចប្រព្រឹត្តបាន"។

សម្ពន្ធសិទ្ធិមនុស្សនេះចោទថាច្បាប់នេះមិនចាំបាច់ទេ ព្រោះក្រមព្រហ្មទណ្ឌបែលហ្សិកមានចែងពីបទល្មើសដែលបង្ក្រាបការបង្កដោយផ្ទាល់ឲ្យប្រព្រឹត្តបទឧក្រិដ្ឋ និងបទមជ្ឈិមរួចហើយ (ស្រដៀងគ្នានឹងមាត្រា ៤៩៥ ខ្មែរដែរ) ដែលនេះរួមមានបទឧក្រិដ្ឋភេរវកម្មផងដែរ។ សម្ពន្ធនេះរិះគន់ថា ដោយយោងទៅលើពាក្យថា "បង្កដោយប្រយោល" ឬនិយាយម្យ៉ាងទៀតគឺថា សារមិនបានថាច្បាស់ៗថាឲ្យប្រព្រឹត្តបទល្មើសភេរវកម្មផងនោះ ដូច្នេះចៅក្រមត្រូវតែវាយស្មានពីអត្ថន័យនៃបទបញ្ញត្តិនេះ។ ការបកស្រាយ "ចេតនាប្រយោល" ជារបៀបមួយអត្តនោម័តខ្លាំងណាស់ និងប្រកបដោយគ្រោះថ្នាក់។ ពាក្យ "បង្កើតជាហានិភ័យឲ្យបទល្មើសមួយ ឬច្រើនអាចប្រព្រឹត្តបាន" ក៏នាំឲ្យចៅក្រមស្ទង់មើលខួរក្បាលនៃអ្នកស្តាប់ ដើម្បីកំណត់ថាតើអ្នកណាម្នាក់ ដែលទទួលសារនោះ នឹងទទួលឥទ្ធិពលនៃសារនោះដែរឬទេ។

## ៥. ធាតុផ្សំនៃបទល្មើសញុះញង់ដោយផ្ទាល់

### ក. ធាតុផ្សំនីត្យានុកូលភាព

នីត្យានុកូលភាពមានន័យថា បទល្មើសនេះត្រូវតែមានចែងនៅក្នុងច្បាប់។ ឧទាហរណ៍ នៅក្នុងព្រហ្មទណ្ឌខ្មែរមានបទល្មើសញុះញង់ដោយផ្ទាល់ ឲ្យអនីតិជនបរិភោគគ្រឿងស្រវឹង (មាត្រា ៣៤៣)។ នេះជាបទល្មើសញុះញង់តែម្តង មិនមែនជាអំពើញុះញង់ដែលត្រូវទទួលខុសត្រូវដោយសារការប្រព្រឹត្តរបស់អ្នកដទៃទេ។ ចំពោះមាត្រា ៤៩៥ នៃក្រមព្រហ្មទណ្ឌដែលផ្តន្ទាទោសអំពើញុះញង់ដោយផ្ទាល់ឲ្យប្រព្រឹត្តបទឧក្រិដ្ឋ បទល្មើសញុះញង់ដោយផ្ទាល់អាចកើតឡើងបាន លុះត្រាតែសំដី ឬកាយវិការនៃការញុះញង់ដោយផ្ទាល់នោះអំពាវនាវឲ្យប្រព្រឹត្តអំពើណាមួយ ដែលបង្កើតជាធាតុផ្សំនៃបទឧក្រិដ្ឋណាមួយដែលចែងនៅក្នុងក្រម និងបញ្ញត្តិព្រហ្មទណ្ឌ។ ឧទាហរណ៍ ការញុះញង់ដោយផ្ទាល់ឲ្យចូលកម្ទេចហាងទំនិញណាមួយ គឺជាអំពើដែលបង្កើតជាបទល្មើសលួចដែលប្រព្រឹត្តដោយការកាប់គាស់ទម្លុះទម្លាយដែលត្រូវផ្តន្ទាទោសពី បី ទៅ ដប់ឆ្នាំ (ដែលជាបទឧក្រិដ្ឋមួយ)។ តែការញុះញង់ឲ្យប្រព្រឹត្តអំពើដែលចូលជាបទមជ្ឈិមមិនបានរួមផ្សំធាតុនីត្យានុកូលនៃបទញុះញង់ដោយផ្ទាល់ក្រោមមាត្រា ៤៩៥ ទេ។ ឧទាហរណ៍ ការញុះញង់ដោយផ្ទាល់ឲ្យលួចកង់ (ដែលជាបទមជ្ឈិម) មិនចូលជាបទញុះញង់ឲ្យប្រព្រឹត្តបទឧក្រិដ្ឋ ក្នុងន័យនៃមាត្រា ៤៩៥ ទេ។

បទល្មើសញុះញង់ក្នុងមាត្រា ៤៩៥ មិនមែនជាការញុះញង់តាមមាត្រា ២៨ នៃក្រមព្រហ្មទណ្ឌទេ។ បើអនុវត្តតាមមាត្រា ២៨ ការញុះញង់ឬបញ្ចុះបញ្ចូលឲ្យអនីតិជនផឹកស្រា អ្នកញុះញង់ ឬអ្នកបញ្ចុះបញ្ចូលគ្មានទោសទេ ព្រោះបើអនីតិជននោះផឹកតាមអ្នកញុះញង់ អនីតិជននោះមិនបានប្រព្រឹត្តបទល្មើសផឹកគ្រឿងស្រវឹងទេ ព្រោះគ្មានបទល្មើសអនីតិជនផឹកគ្រឿងស្រវឹងឡើយ។ ដូច្នេះ អ្នកញុះញង់ក៏គ្មានទោសដែរ។ ដោយឡែកនៅក្នុងបទល្មើសញុះញង់<u>ដោយផ្ទាល់</u>ឲ្យអនីតិជនផឹកគ្រឿងស្រវឹង អ្នកញុះញង់ត្រូវមានទោសតែម្តង ដោយគ្រាន់តែបញ្ចុះបញ្ចូលអនីតិជនឲ្យផឹកគ្រឿងស្រវឹង។ បទល្មើសញុះញង់ដោយផ្ទាល់ ជាបទល្មើសឯករាជ្យ គឺមិនអាស្រ័យលើការប្រព្រឹត្តបទល្មើសដែលអ្នកញុះញង់ចង់បាននោះទេ។

### ខ. ធាតុផ្សំសត្យានុម័ត

នៅក្នុងបទល្មើសញុះញង់ដោយផ្ទាល់ អំពើដែលជនជាប់ចោទធ្វើដែលនាំឲ្យមានការទទួលខុសត្រូវព្រហ្មទណ្ឌនោះ គឺការប្រើពាក្យ កាយវិការ ឬរូបភាព នៅចំពោះមុខអ្នកដែលត្រូវញុះញង់ ឬតាមមធ្យោបាយផ្សព្វផ្សាយនានាដូចជាទូរគមនាគមន៍ សោតទស្សន៍ជាដើម។ ឧទាហរណ៍ ការបោះពុម្ពផ្សាយអត្ថបទពន្យល់អ្នកអានកុំឲ្យយកជនជាតិភាគតិចចូលធ្វើការនៅក្នុងរោងចក្រកាត់ដេរ ដោយចោទថាជនជាតិភាគតិចមិនអាចធ្វើការនោះបាន នេះជាអំពើញុះញង់ដោយផ្ទាល់ឲ្យមានការរើសអើង តាមមាត្រា ៤៩៦។ ធាតុផ្សំ

សត្យានុម័ត គឺការបោះពុម្ពផ្សាយអត្ថបទដែលមានន័យរើសអើង។ អំពើផ្សព្វផ្សាយនេះត្រូវបានហាមឃាត់ដោយច្បាប់ព្រហ្មទណ្ឌ។ ការល្មើសនឹងការហាមប្រាមនេះ ធ្វើឲ្យអ្នកល្មើសជាប់ការទទួលខុសត្រូវ។ ការបញ្ចុះបញ្ចូលឲ្យអនីតិជនសុំទាននៅតាមចិញ្ចើមផ្លូវ ក៏ជាអំពើញុះញង់ដោយផ្ទាល់ឲ្យអនីតិជនសុំទាន (ដែលហាមឃាត់ដោយមាត្រា ៣៩៤)។

### គ. ធាតុផ្សំអត្តនោម័ត

អ្នកញុះញង់ត្រូវតែមានចេតនាជាក់លាក់ដើម្បីធ្វើឲ្យអ្នកដែលទទួលសារញុះញង់ធ្វើអំពើអ្វីមួយដែលខ្លួនចង់ឲ្យធ្វើ។ មានន័យថា បើអ្នកនិពន្ធម្នាក់គ្រាន់តែរាយការណ៍ពីផលិតភាពរបស់ជនជាតិភាគតិចនៅក្នុងកិច្ចការរោងចក្រកាត់ដេរ ហើយគ្មានចេតនាដើម្បីបង្កឲ្យម្ចាស់រោងចក្រមិនជួលជនជាតិភាគតិចធ្វើការនោះទេ នោះគេមិនអាចសន្និដ្ឋានថាអ្នកនិពន្ធមានចេតនាឲ្យរោងចក្ររើសអើងនឹងជនជាតិភាគតិចទេ។

### ឃ. លទ្ធផល

ដូចបានបរិយាយខាងលើហើយ បទញុះញង់ដោយផ្ទាល់មិនទាមទារឲ្យអ្នកដែលត្រូវបានញុះញង់ប្រព្រឹត្ត ឬប៉ុនប៉ងប្រព្រឹត្តអំពើអ្វីមួយ ដើម្បីឲ្យអ្នកញុះញង់ទទួលទោសនោះទេ។ គ្រាន់តែញុះញង់ និងមានចេតនាឲ្យគេធ្វើអ្វីមួយតាមការញុះញង់របស់ខ្លួន អ្នកញុះញង់នោះត្រូវទទួលទោសតែម្តង។ តាមឧទាហរណ៍ខាងលើ ទោះបីរោងចក្រមិនរើសអើងនឹងជនជាតិភាគតិចក្តី អនីតិជនមិនបានទៅសុំទានតាមការបញ្ចុះបញ្ចូលក្តី អ្នកដែលញុះញង់ត្រូវទទួលខុសត្រូវចំពោះអំពើរបស់ខ្លួន។

## ៦. បទល្មើសញុះញង់ដោយផ្ទាល់ និងជាសាធារណៈ (មាត្រា ៤៩៥)

### ក. ធាតុផ្សំសត្យានុម័ត

បទល្មើសត្រូវតែប្រព្រឹត្តិនៅទីសាធារណៈ។

**ភាពសាធារណៈនៃអំពើ៖** ដើម្បីឲ្យអ្នកញុះញង់មួយត្រូវបានដាក់ទណ្ឌកម្មតាមមាត្រា៤៩៥ នៃក្រមព្រហ្មទណ្ឌ ការនិយាយឬកាយវិការត្រូវតែធ្វើនៅទីសាធារណៈ។ ខាងក្រោមនេះអាចចាត់ទុកជាទីសាធារណៈ៖

- ទីកន្លែងសាធារណៈ (ឧទាហរណ៍ ទីលានសាធារណៈ)
- ការប្រជុំសាធារណៈ (ដូចជា ការប្រមូលផ្តុំគ្នា ការធ្វើបាតុកម្ម)
- ផ្ទាំងក្តា ឬប៉ាណូផ្សព្វផ្សាយ
- សោតទស្សន៍ព័ត៌មាន។

សម្រាប់ព័ត៌មានលម្អិតអំពីទីកន្លែងសាធារណៈសូមអានជំពូក១ ស្តីពីការបរិហារកេរ្តិ៍ជាសាធារណៈ។

**ប្រភេទនៃប្រាស្រ័យទាក់ទង ៖** អាចធ្វើឡើងដោយ និយាយពាក្យសំដី ការសរសេរ គំនូរ ឬការផ្សព្វផ្សាយ តាមរយៈសារព័ត៌មាន។

### ខ. ធាតុផ្សំអត្តនោម័ត

ដើម្បីដាក់ទណ្ឌកម្មលើបទល្មើសញុះញង់ដោយផ្ទាល់ និងសាធារណៈបានគេត្រូវរកឲ្យឃើញនូវចេតនារបស់អ្នកញុះញង់ដើម្បីញ៉ាំងឲ្យមនុស្សផ្សេងទៀតដុះគំនិតដើម្បីប្រព្រឹត្តបទល្មើស ឬធ្វើឲ្យមនុស្សផ្សេងនោះមានការចាប់ចិត្តនឹងបទល្មើសដែលអ្នកញុះញង់បានអំពាវនាវ។

តុលាការបារាំងបានចេញវិធានថាការញុះញង់អាចកើតឡើង លុះត្រាតែមានទំនាក់ទំនងជាក់ច្បាស់ និងមិនអាចជំទាស់បាន និងមានចំណងជិតស្និទ្ធរវាងអំពើបង្ក និង បទល្មើសដែលត្រូវប្រព្រឹត្ត (25 févr. 1954: Bull. Crim n° 89). 1883: DP 1884)។ មានន័យថា ពាក្យបង្កនោះត្រូវតែមានន័យជាក់លាក់មិនព្រលាំ មិនអាចបកស្រាយបានច្រើនយ៉ាង ហើយពាក្យបង្កនោះ ត្រូវតែស៊ីគ្នានឹងអំពើដែលនឹងត្រូវប្រព្រឹត្ត។ ឧទាហរណ៍ មនុស្សម្នាក់បានស្រែកទៅហ្វូងមនុស្សថា "ចោរៗ! អ្នកពាក់អាវសហ្នឹងហើយជាចោរឆក់ខ្សែក ជួយចាប់ខ្ញុំផង"។ ពាក្យដែលគាត់ស្រែកនេះមិនមានចំណងជិតស្និទ្ធរវាងពាក្យស្រែកបង្ក និងបទល្មើសណាមួយទេ ព្រោះគាត់និយាយច្បាស់ថាឲ្យ "ជួយចាប់" តែមិនបានបង្កឲ្យហ្វូងមនុស្សវាយមនុស្សពាក់អាវសនោះទេ។ តែបើគាត់ស្រែកឲ្យហ្វូងមនុស្ស "វាយវាឲ្យងាប់ទៅ" នោះពាក្យបង្ករបស់គាត់មានទំនាក់ទំនងជាក់ច្បាស់មិនអាចជំទាស់បាន និងមានចំណងជិតស្និទ្ធជាមួយអំពើសម្លាប់មនុស្ស។

ធាតុផ្សំអត្តនោម័ត គឺអ្នកញុះញង់មានឆន្ទៈជាក់លាក់ដើម្បីញ៉ាំងឲ្យមនុស្សដទៃទៀតកើតចិត្តរំភើបចង់ប្រព្រឹត្ត ឬ មានការទាក់ទាញចិត្តឲ្យប្រព្រឹត្តអំពើមួយដែលបង្កើតបានជាបទល្មើសញុះញង់ដោយផ្ទាល់ (Crim. 29 oct. 1936): Bull. Crim. N° 104) (សូមមើល Dalloz Code pénal 110e edition, p. 2585)។ និយាយម្យ៉ាងទៀតគឺថា ការញុះញង់គឺជាល្បិចដែលធ្វើដោយដឹងខ្លួនដែលមានគោលដៅធ្វើឲ្យកើតចិត្តរំភើបខ្លាំង និងបង្កើតមានសិកភាព (ផ្ទត់គំនិត) ដែលឈានទៅរកការប្រព្រឹត្តបទល្មើស។ ដូច្នេះអ្នកញុះញង់ត្រូវតែមានចេតនាជាក់លាក់ មិនមែនជាការផ្លោយមាត់ដោយធ្វេសប្រហែស ឬនិយាយលេងនោះទេ។ ពាក្យសំដី ឬកាយវិការញុះញង់ត្រូវមានលក្ខណៈច្បាស់គ្មានព្រលាំ ដែលនឹងធ្វើឲ្យអ្នកដែលទទួលសារញុះញង់យល់ច្បាស់ថាខ្លួនត្រូវធ្វើអ្វីដើម្បីឆ្លើយតបទៅនឹងការញុះញង់នោះ។ នេះជាការផ្ចិតចេតនារបស់អ្នកញុះញង់បញ្ចូលទៅក្នុងចិត្តរបស់អ្នកដែលរងការញុះញង់។ អ្នកញុះញង់ត្រូវតែដឹងឲ្យបានពេញលេញនូវអ្វីដែលខ្លួនកំពុងធ្វើ និងអ្វីដែលនឹងកើតមានឡើង។

នៅក្នុងសំណុំរឿងលេខ ០០១ នៃអង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា ដើម្បីឲ្យការញុះញង់កើតមានបាន "ជនសង្ស័យត្រូវតែមានចេតនាចង់បង្ក ឬញ៉ាំង [អ្នកផ្សេង] ឲ្យប្រព្រឹត្តបទល្មើស ឬត្រូវបានដឹងពីអភិតវនីយភាព [ភាពទំនងយ៉ាងខ្លាំង] ថាបទល្មើសមួយនឹងត្រូវបានប្រព្រឹត្តតាមការញុះញង់"។

ទោះបីមានមូលហេតុ និងគោលដៅចុងក្រោយយ៉ាងណាក៏ដោយ អ្នកញុះញង់ត្រូវតែមានឆន្ទៈជំរុញឲ្យបង្កើតចិត្តតែម្យ៉ាងដើម្បីជំរុញឲ្យមានការប្រព្រឹត្តដែលធ្វើឲ្យខូចខាតដល់ជីវិត ឬ បូរណភាពរាងកាយរបស់មនុស្ស ឬមួយអ្នកបង្កដឹងថាពាក្យដែលខ្លួននិយាយ ឬសំណេរដែលខ្លួនផ្សព្វផ្សាយអាចធ្វើឲ្យអ្នកណាម្នាក់ប្រព្រឹត្តបទល្មើស (Rouen, 14 déc. 2005: JCP 2006. IV. 2412)។ ការប្រើអត្ថបទមួយដែលមានសណ្ឋានជាការបង្កអធិករណ៍ (ការរករឿង) (aggressive) ជេរប្រមាថ និងហិង្សា ដោយគ្មានភស្តុតាង ឬសញ្ញាណាមួយដែលធ្វើឲ្យគេសន្មតលើអ្នកនិពន្ធនិងអ្នកបកប្រែ ថាមានឆន្ទៈធ្វើឲ្យសាធារណជនមានចិត្ត និងបានឱកាសប្រព្រឹត្តអំពើធ្វើឲ្យប៉ះពាល់ដល់ជីវិត ឬ បូរណភាពរាងកាយរបស់អ្នកដទៃ (មន្ត្រីប៉ូលីស និង តំណាងរដ្ឋ) មិនទាន់គ្រប់គ្រាន់ដើម្បីចាត់ទុកថាជាធាតុផ្សំអត្តនោម័តនៃបទល្មើសដែលចោទប្រកាន់នោះទេ។

ដើម្បីអាចផ្តន្ទាទោសបាន ការបង្កដែលគ្មានផល ត្រូវតែជាការញុះញង់ដោយផ្ទាល់ មិនមែនតែនៅក្នុងស្មារតីប៉ុណ្ណោះទេ តែត្រូវចេញជាពាក្យសំដីផងដែរ ថាឲ្យប្រព្រឹត្តអំពើជាក់ស្តែងជាកំណត់ ហើយអំពើនោះជាធាតុផ្សំនៃបទល្មើសណាមួយ (T.corr. Beauvais, 20 déc. 1950: Gaz. Pal. 1951)។ ដូច្នេះការ

រិះគន់ ឬការសម្តែងមតិមិនមែនជាការបង្កទេ។ ការបង្កដោយផ្ទាល់ គឺជាការបង្កដែលញ៉ាំងឲ្យអ្នកស្តាប់ ឬអ្នកមើល ឲ្យប្រែគំនិតទៅរកបទល្មើស (Rouen, 14 déc. 2005: JCP 2006. IV. 2412)។

### គ. លទ្ធផល

ដោយសារបទល្មើសញុះញង់ជាសាធារណៈ និងដោយផ្ទាល់ ជាប្រភេទបទល្មើសញុះញង់ដោយផ្ទាល់ ដែលមានចែងក្នុងមាត្រា ៤៩៤ និងមាត្រា ៤៩៥នៃក្រមព្រហ្មទណ្ឌ បទល្មើសនេះមិនតម្រូវឲ្យមានលទ្ធផលនៃអំពើនៃការញុះញង់ឡើយ។ នេះមានន័យថា មិនតម្រូវឲ្យមានការប្រព្រឹត្ត ឬប៉ុនប៉ងឡើយ។ បុគ្គលដែលត្រូវបានគេញុះញង់មិនចាំបាច់ធ្វើអំពើឡើយ។

## ៧. បន្ទុកភស្តុតាងនៃបទល្មើសញុះញង់ជាសាធារណៈនិង ដោយផ្ទាល់

ខាងអយ្យការត្រូវលើកភស្តុតាងមកបង្ហាញទាក់ទងនឹងរឿងខាងក្រោមនេះ ៖

### ក. ភាពជាសាធារណៈនៃអំពើ

- ទីកន្លែងដែលពាក្យពេចន៍ត្រូវបានបន្លឺ ឬទំនាក់ទំនងត្រូវបានធ្វើ។
- មធ្យោបាយនៃគមនាគមន៍ ៖ ព័ត៌មានសោតទស្សន៍។

ឧទាហរណ៍ មនុស្សម្នាក់សុំឲ្យហាងចម្លងខិត្តប័ណ្ណមួយដែលមានន័យសុំកងកម្លាំងបែរអាវុធទៅរករដ្ឋាភិបាលវិញ។ ខិត្តប័ណ្ណនោះមិនបានចែកចាយទៅណាទេ ដោយម្ចាស់ហាងដាក់នៅក្នុងប្រអប់ក្រដាស។ មានអតិថិជនម្នាក់ចូលមកឃើញក្រដាសមួយសន្លឹកនៅសល់លើម៉ាស៊ីន រួចក៏យកទៅប្តឹងប៉ូលីស។ ខិត្ត-ប័ណ្ណនេះមិនត្រូវបានផ្សាយជាសាធារណៈទេ ព្រោះវាមិនបានដាក់បង្ហាញ ឬចែកចាយដល់សាធារណៈជនទេ។

### ខ. ការញុះញង់ដោយផ្ទាល់

- បញ្ជាក់ថា អំពើដែលអ្នកញុះញង់អំពាវនាវបង្កើតបានជាធាតុផ្សំនៃបទល្មើស**ឧក្រិដ្ឋ**ណាមួយដែលត្រូវបានចែងនៅក្នុងច្បាប់ព្រហ្មទណ្ឌ។ ឧទាហរណ៍ បើការចោទប្រកាន់អ្នកញុះញង់ពីបទញុះញង់ដើម្បីប្រព្រឹត្តអំពើចោរកម្ម គេត្រូវបញ្ជាក់ថា តើពាក្យដែលអ្នកញុះញង់ប្រើក្នុងការអំពាវនាវឲ្យអ្នកផ្សេងធ្វើនោះជាពាក្យសំដៅលើអំពើអ្វី (ដូចជាហៅឲ្យប្រើកម្លាំងសម្រុកចូលក្នុងហាងទំនិញ ហើយយកចំណីមកចែកគ្នាបរិភោគ) អំពើនោះចាត់ចូលជាធាតុផ្សំនៃបទល្មើសប្លន់ (លួចដោយមានស្ថានទម្ងន់) ដែរឬទេ។
- បង្ហាញភស្តុតាងថា តើពាក្យដែលអ្នកញុះញង់និយាយមានភាពច្បាស់ និងអាចឲ្យគេយល់បានថាគាត់ចង់ឲ្យគេប្រព្រឹត្តបទល្មើសណាមួយជាក់លាក់ដែរឬទេ។ ឧទាហរណ៍ ក្នុងករណីខាងលើ ខាងចោទត្រូវតែបញ្ជាក់ថា តើអ្នកស្តាប់/អ្នកមើល យល់ថាអ្នកញុះញង់ពិតជាចង់ឲ្យពួកគេប្រព្រឹត្តអំពើចោរកម្មមែន ឬទេ។

### គ. ចេតនា

- ខាងចោទត្រូវបញ្ជាក់ថា អ្នកញុះញង់ត្រូវមានចេតនាជាក់លាក់ក្នុងការល្បួងសាធារណជនឲ្យប្រព្រឹត្តបទឧក្រិដ្ឋមួយ ឬត្រូវតែបានដឹងថាបទល្មើសឧក្រិដ្ឋមួយទំនងយ៉ាងខ្លាំងថានឹងត្រូវបានប្រព្រឹត្តដោយសារការអំពាវនាវរបស់ចុងចោទ។ មានទំនាក់ទំនងយ៉ាងជិតស្និត

រវាងការញុះញង់ និងអភិភវនីយភាព (substantial likelihood) នៃការកើតឡើងនៃបទល្មើស។

# ៨. មធ្យោបាយការពារ

## ក. ការញុះញង់ឲ្យប្រព្រឹត្តបទឧក្រិដ្ឋ

(១) ចារីធ្វើអំពើដោយខ្លួនរបស់គេ ៖ ឧទាហរណ៍ ក្នុងការធ្វើបាតុកម្ម មនុស្សមួយចំនួនបានប្រព្រឹត្តអំពើចោរកម្មដោយខ្លួនឯង អ្នករៀបចំមិនបានអំពាវនាវ ឬស្នើឲ្យពួកគេប្រព្រឹត្ត អំពើចោរកម្មឡើយ។

(២) ពាក្យញុះញង់ មិនមានខ្លឹមសារអំពាវនាវឲ្យប្រព្រឹត្តអំពើឧក្រិដ្ឋឡើយ ៖ ដោយសារតែការបញ្ចេញនូវពាក្យពេចន៍ដែលអំពាវនាវដល់សាធារណជនត្រូវតែមានភាពជាក់ច្បាស់ និងអាចយល់បានដល់សាធារណជន ដូច្នេះពាក្យសំដីដែលគ្មានន័យចង់ឲ្យមានការប្រព្រឹត្តិបទឧក្រិដ្ឋ មិនបង្កើតបានជាការញុះញង់សាធារណៈ និងដោយផ្ទាល់ទេ ពីព្រោះវាមិនគ្រប់គ្រាន់ដើម្បីបង្កើតធាតុចេតនារបស់អ្នកនិយាយឡើយ។ ការនិយាយដោយធ្វេសប្រហែសមិនបង្កើតបានជាចេតនាជាក់លាក់ដើម្បីញុះញង់ និងបង្កឲ្យមានការប្រព្រឹត្តិបទឧក្រិដ្ឋឡើយ។

(៣) ការអំពាវនាវឲ្យធ្វើសកម្មភាពមិនមែនជាអំពើខុសច្បាប់ឡើយ ៖ ជួនកាលការអំពាវនាវឲ្យធ្វើសកម្មភាពមួយដែលមិនខុសច្បាប់ ទោះបីជាវាប្រឆាំងទៅនឹងគោលនយោបាយក៏ដោយ ក៏ការអំពាវនាវនោះក៏មិនមែនជាការញុះញង់ដោយផ្ទាល់ឡើយ។

(៤) ការអំពាវនាវឲ្យប្រព្រឹត្តអំពើមួយដែលមានលក្ខណៈជាបទមជ្ឈិម មិនចូលក្នុងជាធាតុផ្សំនៃបទល្មើសញុះញង់ជាសាធារណៈ និងដោយផ្ទាល់ក្នុងន័យនៃមាត្រា ៤៩៤-៤៩៥ ឡើយ។

## ខ. ការញុះញង់ប្រព្រឹត្តអំពើបង្កឲ្យមានភាពវឹកវរធ្ងន់ធ្ងរដល់សន្តិសុខសង្គម

(១) មិនមាននិយមន័យនៃពាក្យសន្តិសុខសង្គម។ សូម្បីតែពាក្យ "សន្តិសុខសង្គម" ត្រូវបានបកស្រាយដូចជា ការធ្វើឲ្យមានភាពវឹកវរដល់ចរាចរនេះមិនមែនជាចំណុចគ្រប់គ្រាន់សម្រាប់បង្កើតឲ្យប្រព្រឹត្តបទឧក្រិដ្ឋឡើយ។ ដូច្នេះមាត្រា៤៩៥ មានលក្ខណៈខុសពីនេះ។ សំណួរអាចចោទឡើងថា អ្វីជាគោលបំណងនៃច្បាប់នេះ? តើជាការរារាំងការបញ្ចេញមតិដែលញុះញង់ឲ្យមានការប្រព្រឹត្តបទឧក្រិដ្ឋ ឬបទបជ្ឈឹម ឬបទលហុ (ដូចជា ការបំពានចរាចរ)?

(២) សេចក្តីណែនាំពីគណកម្មាធិការសិទ្ធិមនុស្ស អត្ថាធិប្បាយទូទៅលេខ ៣៤ នៃកិច្ចប្រជុំលើកទី ១០២ ថ្ងៃទី១១ ដល់ ២៩ កក្កដា ឆ្នាំ២០១១។ សូមពិភាក្សាថាតើ មាត្រា៤៩៤ និង មាត្រា៤៩៥ ចូលទៅក្នុងការរិតត្បិតដែលអាចធ្វើបាន ស្របតាមកតិកាសញ្ញាអន្តរជាតិស្តីពី សិទ្ធិពលរដ្ឋ និងសិទ្ធិនយោបាយដែរឬទេ?។ អត្ថាធិប្បាយលេខ ៣៤ ចែងថា ច្បាប់ដែលអាចរឹតត្បិតសេរីភាពនៃការនិយាយស្តី អាចបង្កើតបានលុះត្រាណាច្បាប់នោះមានន័យជាក់ច្បាស់គ្រប់គ្រាន់ ដើម្បីធ្វើជាប្រទីបនាំផ្លូវឲ្យពលរដ្ឋដឹងថាសំដីអ្វីដែលច្បាប់ហាមឃាត់សំដីអ្វីដែលច្បាប់មិនហាមឃាត់។ ច្បាប់នោះក៏ជាប្រទីបនាំផ្លូវឲ្យមន្ត្រីអនុវត្តច្បាប់ដឹងថា សំដីណាដែលត្រូវទប់ស្កាត់ សំដីណាដែលមិនត្រូវទប់ស្កាត់។ ខាងក្រោមនេះ ជាកថាខណ្ឌទី ២៥ នៃអត្ថាធិប្បាយលេខ ៣៤ នៃគណកម្មាធិការសិទ្ធិមនុស្ស ៖

> "២៥. សម្រាប់គោលបំណងនៃកថាខ័ណ្ឌទី៣ និយាមមួយដែលត្រូវបានចាត់ទុកថាជា "ច្បាប់" ត្រូវតែសរសេរឲ្យបានច្បាស់គ្រប់គ្រាន់ ដើម្បីឲ្យបុគ្គលម្នាក់ៗអាចតម្រែតម្រង់កិរិយារបស់ខ្លួនទៅតាមសេចក្តីនៃច្បាប់នោះ និងត្រូវតែសរសេរយ៉ាងណាឱ្យសាធារណៈជនទូទៅងាយយល់បាន។ ច្បាប់

មិនអាចផ្តល់ដល់អ្នកទទួលបន្ទុកអនុវត្តច្បាប់នូវឆន្ទានុសិទ្ធិគ្មានព្រំដែន ដើម្បីរឹតត្បិតដល់សេរីភាពនៃការបញ្ចេញមតិឡើយ។ ច្បាប់ត្រូវតែផ្តល់នូវមាគ៌ាគ្រប់គ្រាន់ដល់អ្នកទទួលបន្ទុកអនុវត្តច្បាប់ ដើម្បីធ្វើយ៉ាងណាឲ្យពួកគេយល់ច្បាស់ ថាតើការបញ្ចេញមតិប្រភេទណាដែលត្រូវបានរិតត្បិតយ៉ាងត្រឹមត្រូវ និង តើការបញ្ចេញមតិបែបណាដែលមិនត្រូវបានរិតត្បិត។"

ប្រការដែលមាត្រា ៤៩៥ នៃក្រមព្រហ្មទណ្ឌ និយាយយោងដល់ "ភាពវឹកវរធ្ងន់ធ្ងរដល់សន្តិសុខសង្គម" នាំឲ្យមាត្រានេះ មិនស្របតាមស្មារតីនៃអត្ថាធិប្បាយលេខ ៣៤ ព្រោះថាពាក្យ "ធ្ងន់ធ្ងរ" ជាពាក្យមានន័យមិន**ជាក់ច្បាស់** ព្រោះអាចមានការបកស្រាយផ្សេងៗទៅតាមអារម្មណ៍ ឬផលប្រយោជន៍នៃបុគ្គលដែលបកស្រាយដូច្នេះមិនអាចធ្វើជាមាគ៌ានាំផ្លូវឲ្យបុគ្គលណាម្នាក់ ឬមន្ត្រីអនុវត្តច្បាប់ណាម្នាក់ដឹងច្បាស់ថា អំពើណាដែលធ្ងន់ធ្ងរគួររឹតត្បិត អំពើណាមិនធ្ងន់ធ្ងរគួររឹតត្បិត។ ពាក្យ "សន្តិសុខសង្គម" ក៏ជាពាក្យដែលគ្មាននិយមន័យ ដែលមិនអាចឲ្យមនុស្សគ្រប់គ្នាយល់ដូចគ្នាពីពាក្យនេះដែរ។ អ្នកខ្លះអាចបកស្រាយ សន្តិសុខស្មើនឹងសន្តិភាព អ្នកខ្លះអាចបកស្រាយថា ជាភាពរញ៉េរញ៉ៃលើផ្លូវ ឬទីសាធារណៈ អ្នកខ្លះទៀតអាចបកស្រាយថា ជាការរំខានដល់ចរាចរសាធារណៈ។ល។ សរុបមក ពាក្យ "ភាពវឹកវរធ្ងន់ធ្ងរដល់សន្តិសុខសង្គម" ជាពាក្យទាក់ទាញឲ្យមានការបកស្រាយបែបអត្តនោម័ត (subjective interpretation) ដែលជាការបកស្រាយតាមការចូលចិត្តរបស់ខ្លួន។

## ៤. ការប្រៀបធៀបជាមួយប្រទេសផ្សេងទៀត

នៅសហរដ្ឋអាមេរិក ពាក្យញុះញង់ដែលគ្មានអានុភាពអ្វីសោះ មិនអាចផ្តន្ទាទោសបានទេ។ នេះជាសេចក្តីសម្រេចរបស់តុលាការកំពូលអាមេរិកក្នុងរឿងក្តីរវាង Brandenburg និង Ohio[48] ដែលថា "កិច្ចធានារបស់រដ្ឋធម្មនុញ្ញនូវសេរីភាពនៃការបញ្ចេញមតិ និងសេរីភាពនៃសារព័ត៌មាន មិនអនុញ្ញាតឲ្យរដ្ឋធ្វើការហាមប្រាម ឬបដិសេធការតស៊ូមតិឲ្យប្រើប្រាស់កំលាំង ឬរំលោភច្បាប់ទេ **លើកលែងតែការតស៊ូមតិមានទិសដៅញុះញង់ ឬបង្កើតនូវសកម្មភាពឥតច្បាប់ និងទំនងជាញុះញង់ ឬបង្កើតឲ្យមានសកម្មភាពបែបនោះ**" ហើយ "ការបង្រៀនដែលមានលក្ខណៈអរូបីតែមួយមុខ.....ពីភាពត្រឹមត្រូវខាងសីលធម៌ ឬក៏ពីភាពចាំបាច់ខាងសីលធម៌ដែលត្រូវប្រើកំលាំងនិងហិង្សាក្តី ក៏វាមិនដូចគ្នា**ការរៀបចំក្រុមមួយឲ្យធ្វើសកម្មភាពហិង្សា និងនាំក្រុមនោះទៅរកសកម្មភាពបែបនោះដែរ...**។ ច្បាប់ដែលខកខានក្នុងការគូសបន្ទាត់សម្រាប់ធ្វើការបែងចែកនេះ ជាច្បាប់ដែលរំលោភដែលមិនអាចអនុញ្ញាតបានលើសេរីភាពដែលធានាដោយវិសោធនកម្មលើកទី១ និងទី ១៤"។

យោងតាមការសម្រេចនេះ ការតស៊ូមតិមួយអាចដាក់ទណ្ឌកម្មបានប្រសិនបើមានទំនាក់ទំនងយ៉ាងជិតស្និទ្ធជាពេលវេលា រវាងអំពើញុះញង់ និងលទ្ធផលដែលបង្កើតបានជាទម្រង់នៃសកម្មភាពឥតច្បាប់ទម្លាប់ ឧទាហរណ៍ ការត្រៀមរៀបចំសកម្មភាពហិង្សាជាដើម។

ច្បាប់ព្រហ្មទណ្ឌស្តីពីសមាគមជនឧក្រិដ្ឋ នៃរដ្ឋអូហៃយ៉ូ ដាក់ទណ្ឌកម្មចំពោះបុគ្គលដែល "ធ្វើការតស៊ូមតិ ឬបង្រៀនពីកាតព្វកិច្ច ភាពចាំបាច់ ឬភាពត្រឹមត្រូវ" នៃអំពើហិង្សា "ជាមធ្យោបាយមួយដើម្បីធ្វើឲ្យសម្រេចនូវកំណែទម្រង់ឧស្សាហកម្ម ឬកំណែទម្រង់នយោបាយ" ឬបុគ្គលដែលបោះពុម្ព ឬផ្សាយបន្ត ឬតាំង

---

[48] Brandenburg v. Ohio, 395 U.S. 444 (June 9, 1969), អាចស្វែងរកបានតាមរយៈ ៖ http://www.law.cornell.edu/supct/html/historics/USSC_CR_0395_0444_ZO.html

បង្ហាញនូវសៀវភៅ ឬក្រដាសដែលមានការតស៊ូមតិ បែបនោះ ឬបុគ្គលដែល "ធ្វើយុត្តិកម្ម" ការប្រព្រឹត្តអំពើហិង្សា "ដោយមានចេតនាធ្វើជាឧទាហរណ៍ ផ្សាយ ឬតស៊ូមតិអំពីភាពត្រឹមត្រូវនៃទ្រឹស្តីពីសមាគមជនឧក្រិដ្ឋ" ឬបុគ្គលដែល "ប្រជុំគ្នាដោយស្ម័គ្រចិត្ត" ជាមួយក្រុមមួយទៀតដែលបង្កើតឡើងសម្រាប់ "បង្រៀន ឬតស៊ូមតិពីទ្រឹស្តីនៃសមាគមជនឧក្រិដ្ឋ"។

ក្នុងករណីនេះ មេដឹកនាំនៃក្រុម Ku Klux Klan ត្រូវកាត់ទោសតាមច្បាប់ព្រហ្មទណ្ឌស្តីពីសមាគមជនឧក្រិដ្ឋពីបទអំពាវនាវឲ្យទទួលស្គាល់កាតព្វកិច្ច ភាពចាំបាច់ ឬភាពត្រឹមត្រូវនៃបទល្មើសវិទ្ធេទកម្ម អំពើហិង្សា ឬវិធីមិនស្របច្បាប់នៃភេរវកម្ម ជាមធ្យោបាយមួយដើម្បីឲ្យសម្រេចបាននូវកំណែទម្រង់ ឧស្សាហកម្ម ឬនយោបាយ និងពីបទប្រមូលផ្តុំដោយស្ម័គ្រចិត្តជាមួយសមាគម ក្រុម ឬការប្រមូលផ្តុំបុគ្គលដើម្បីបង្រៀន ឬតស៊ូមតិនូវទ្រឹស្តីនៃសមាគមជនឧក្រិដ្ឋ។ ប្រធានក្រុមនេះត្រូវបានផាកពិន័យចំនួនមួយពាន់ដុល្លារ និងកាត់ទោសឲ្យជាប់ពន្ធនាគារ ពី១ឆ្នាំ ដល់ ១០ឆ្នាំ។ ដំណើររឿងមានដូចខាងក្រោម ៖

បុរសម្នាក់បានទូរស័ព្ទទៅអ្នករាយការណ៍ព័ត៌មាននៃស្ថានីយទូរទស្សន៍ Cincinnati ហើយអញ្ជើញគាត់ទៅចូលរួមនៅក្នុងការជួបជុំនៃក្រុម Ku Klux Klan។ ដោយមានកិច្ចសហការពីអ្នករៀបចំជាច្រើននាក់ អ្នករាយការណ៍ព័ត៌មាន និងអ្នកថតរូបបានចូលរួមក្នុងជួបជុំ និងថតភាពយន្តពីព្រឹត្តិការណ៍នោះ។ បន្ទាប់មក ឆាកខ្លះនៃភាពយន្តត្រូវបានចាក់ផ្សាយនៅតាមស្ថានីយ៍ក្នុងស្រុក និងតាមបណ្តាញថ្នាក់ជាតិ។ រដ្ឋអាជ្ញាបង្ហាញអត្តសញ្ញាណរបស់បុរសនោះថាជាមនុស្សដែលទាក់ទងជាមួយអ្នករាយការណ៍ ហើយជាអ្នកដែលនិយាយនៅក្នុងពេលប្រជុំនោះ។ រដ្ឋអាជ្ញាក៏បានបង្ហាញរបស់ជាភស្តុតាងជាច្រើនដែលឃើញនៅក្នុងភាពយន្ត រួមទាំងកាំភ្លើងដៃមួយ កាំភ្លើងមួយ កាំភ្លើងបាញ់សត្វមួយ គ្រាប់រំសេវ ព្រះគម្ពីមួយក្បាល និងឈ្នួតក្បាលក្រហមចាស់មួយដែលអ្នកនិយាយនៅក្នុងភាពយន្តពាក់។

ភាពយន្តមួយបានបង្ហាញពីអ្នកដែលមានឈ្នួតតក្បាលចំនួន ១២ នាក់ អ្នកខ្លះក្នុងចំណោមនោះបានកាន់កាំភ្លើង។ ពួកគេបានប្រមូលផ្តុំគ្នានៅជុំវិញឈើឆ្កាងមួយធំដែលគេដុត។ គ្មាននរណាម្នាក់មានវត្តមានក្រៅពីអ្នកចូលរួម និងអ្នកយកព័ត៌មានដែលថតសកម្មភាពនោះឡើយ។ ពាក្យពេចន៍ដែលបន្លឺឡើងនៅក្នុងទស្សនីយភាពនោះមិនអាចគេយល់បានថាដូចម្តេចទេ ប៉ុន្តែមានឃ្លានេះម៉ុំនោះម៉ុំដែលអាចឲ្យគេយល់បានថា ជាពាក្យមើលងាយដល់ជនស្បែកខ្មៅ និងឃ្លាមួយទៀតនិយាយមើលងាយជនជាតិជ្វីហ្វ។ ឆាកមួយទៀតនៅក្នុងភាពយន្តដដែលបង្ហាញពីបុរសនោះ នៅក្នុងសំលៀកបំពាក់បែបប្រពៃណី Klan កំពុងធ្វើសុន្ទរកថា។ ខ្លឹមសារនៃសន្ទរកថានោះមានដូចខាងក្រោម ៖

> នេះជាការជួបប្រជុំរបស់អ្នករៀបចំ។ ថ្ងៃនេះយើងមានសមាជិកថ្មីមួយចំនួនដែរគឺយើងមានសមាជិករាប់រយនាក់ទូទាំងរដ្ឋអូហៃយ៉ូ។ ខ្ញុំអាចដកស្រង់សំដីពីអត្ថបទកាសែត Dispatch មកពី Columbus, Ohio ដែលផ្សាយនៅព្រឹកថ្ងៃអាទិត្យកាលពី ៥ សប្តាហ៍មុន។ ក្រុម Klan មានសមាជិកច្រើនជាងអង្គការផ្សេងៗទៀតក្នុងរដ្ឋអូហៃយ៉ូ។ យើងមិនមែនជាអង្គការចងគំនុំនោះទេ ប៉ុន្តែបើប្រធានាធិបតីរបស់យើង សភារបស់យើង តុលាការកំពូលរបស់យើង បន្តកៀបសង្កត់ពួកស្បែកស ជាពូជសាសន៍ Caucasian វាអាចមានការសងសឹកកើតឡើង។
>
> យើងនឹងដង្ហែក្បួនទៅសភានៅថ្ងៃទី ៤ ខែកក្កដា ដែលមានមនុស្ស ៤០ ម៉ឺននាក់។ ចេញពីទីនោះ យើងនឹងបំបែកជាពីរក្រុម មួយក្រុមដង្ហែតាមបណ្តោយផ្លូវ Augustine រដ្ឋ Florida, និងក្រុមផ្សេងទៀត ដង្ហែទៅ Mississippi។ សូមអរគុណ!។

ខ្សែភាពយន្តទី២បង្ហាញមនុស្សពាក់ឈ្នួតក្បាល ៦ នាក់ ម្នាក់ក្នុងចំណោមនោះ (បន្ទាប់មកមានអត្តសញ្ញាណជាជនជាប់ចោទ) បាននិយាយសាឡើងវិញនូវពាក្យដែលស្រដៀងគ្នាទៅនឹងសំដីដែលថតនៅក្នុងខ្សែភាពយន្តទី១។ ការនិយាយអំពីលទ្ធភាពនៃ "ការសងសឹក" ត្រូវបានកាត់ចេញ ហើយបន្ថែមប្រយោគមួយ ៖ "ជាមតិខ្ញុំ ខ្ញុំជឿជាក់ថាពួកស្បែកខ្មៅគួរតែត្រឡប់ទៅប្រទេសអាហ្វ្រិក ជនជាតិជ្វីហ្វទៅប្រទេសអ៊ីស្រាអែលវិញ"។ ទោះបីជាជាមនុស្សមួយចំនួននៅក្នុងខ្សែភាពយន្តនោះមានកាន់អាវុធ ប៉ុន្តែអ្នកធ្វើសុន្ទរកថាមិនបានកាន់ទេ។

# ជំពូក ៤

# បទប្រឆាំងនឹងអ្នករាជការសាធារណៈ

## ១. ប្រវត្តិនៃច្បាប់

បទបញ្ញត្តិច្បាប់ទាក់ទងនឹងការប្រឆាំងនឹងអ្នករាជការសាធារណៈមានគោលបំណងទីមួយការពារបូរណភាពរូបរាងកាយរបស់អ្នករាជការដែលកំពុងអនុវត្តបេសកកម្មរបស់ខ្លួនឲ្យរួចផុតពីការឃាយីផងទាំងពួង និងទីពីរក្នុងគោលបំណងធ្វើឲ្យបេសកកម្មរបស់អ្នករាជការបានសម្រេច។ ក្នុងន័យនេះបទល្មើសប្រឆាំងនឹងអ្នករាជការសាធារណៈគ្រសោបនូវបទល្មើសមួយ គឺបទល្មើសប្រឆាំងលើរូបកាយរបស់អ្នករាជការដែលកំពុងបំពេញបេសកកម្មរបស់ខ្លួន។ ដូច្នេះច្បាប់នេះដាក់ទណ្ឌកម្មលើជនល្មើសណាដែលប្រើអំពើហិង្សាទៅលើអ្នករាជការ មិនមែនទៅលើការជំទាស់អហិង្សាទៅលើអ្នករាជការទេ។ បទប្រឆាំងនឹងអ្នករាជការសាធារណៈនេះមានខ្លឹមសារដូចគ្នានឹងច្បាប់បារាំង ដែលហៅថា Rebellion ដែលភាសាខ្មែរពីដើមហៅថាឧទ្ទាមកម្ម។ មាត្រា ៤៣៣-៦ នៃច្បាប់បារាំងចែងថា ៖

> ចាត់ជាបទឧទ្ទាមកម្ម អំពើប្រឆាំងដោយប្រើការតតាំងហិង្សាទល់នឹងមនុស្សម្នាក់ដែលកាន់កាប់អំណាចសាធារណៈ ឬមានភារៈទទួលបេសកកម្មនៃសេវាកម្មសាធារណៈ ដែលនៅក្នុងការអនុវត្តមុខងាររបស់ខ្លួន ធ្វើសកម្មភាពដើម្បីអនុវត្តច្បាប់ បញ្ជានៃអាជ្ញាធរសាធារណៈ សេចក្តីសម្រេច ឬដីកាតុលាការ។

## ២. និយមន័យ

មាត្រា ៥០៣ នៃក្រមព្រហ្មទណ្ឌប្រទេសកម្ពុជាកំណត់និយមន័យនៃបទប្រឆាំងនឹងអ្នករាជការសាធារណៈថាជា ៖

> អំពើប្រឆាំងដោយប្រើការតទល់ដោយហិង្សា នឹងអ្នករាជការសាធារណៈដែលធ្វើសកម្មភាពដើម្បីអនុវត្តច្បាប់ បញ្ជារបស់អាជ្ញាធរសាធារណៈ ឬសេចក្តីសម្រេចរបស់តុលាការ។
> ការរំលោភលើមាត្រានេះនឹងនាំឲ្យមានការផ្តន្ទាទោសដាក់ពន្ធនាគារពីមួយខែទៅបីខែ និងពិន័យជាប្រាក់ពីមួយសែនរៀល ទៅប្រាំសែនរៀល។

## ៣. ធាតុផ្សំនៃបទប្រឆាំងនឹងអ្នករាជការសាធារណៈ

### ក. លក្ខខណ្ឌជាមុន ៖ ឋានៈ និង សកម្មភាពរបស់ជនដែលត្រូវរងការប្រឆាំង

ដើម្បីឲ្យអំពើប្រឆាំងមួយអាចផ្តន្ទាទោសបានតាមមាត្រា ៥០៣ កត្តាពិចារណាដំបូងគឺឋានៈរបស់ជនដែលត្រូវប្រឆាំង និងធាតុនៃសកម្មភាពដែលគេត្រូវចោទថាត្រូវបានប្រឆាំង។ ការពិចារណាដល់ឋានៈរបស់បុគ្គលនេះជាការសំខាន់ ព្រោះបទល្មើសប្រឆាំងអ្នករាជការសាធារណៈមានអនុបទល្មើស (បទល្មើសហិង្សា) នៅជាប់ជាមួយ។ អនុបទល្មើសហិង្សាជាបទល្មើសដែលអនុវត្តទៅលើបុគ្គលទូទៅ មិនមែនសំរាប់

តែអ្នករាជការក្នុងបេសកកម្មប៉ុណ្ណោះទេ។ បើការប្រព្រឹត្តហិង្សាទៅលើបុគ្គលមួយដែលមិនមែនជាអ្នករាជ-ការសាធារណៈ នោះបទល្មើសហិង្សាទូទៅ (មាត្រា ២១៧ ស្តីពីហិង្សាដោយចេតនា) ត្រូវយកមកអនុវត្តវិញ។

**ក.១ តើជនណាដែលត្រូវចាត់ទុកថាជាអ្នករាជការសាធារណៈ?** ជាទូទៅអ្នករាជការសាធារណៈគឺជាបុគ្គលទាំងឡាយណាដែលទទួលបៀវត្សពីរដ្ឋាភិបាល ប៉ុន្តែ មិនមែនបុគ្គលដែលទទួលបៀវត្សពីរដ្ឋាភិបាលសុទ្ធតែជាអ្នករាជការទេ ឧទាហរណ៍ បុគ្គលិកជាប់កិច្ចសន្យាជាមួយរដ្ឋាភិបាល។ ហើយបុគ្គលដែលធ្វើការឲ្យអ្នករាជការសម្រាប់បេសកកម្មសាធារណៈក៏មិនអាចចាត់ទុកថាជាអ្នករាជការសាធារណៈបានដែរ ឧទាហរណ៍ កម្មករដែលសាលាក្រុងជួលមករុះរើទីលំនៅរបស់សហគមន៍មួយ មិនមែនជាអ្នករាជការសាធារណៈទេ ថ្វីបើពួកគាត់ធ្វើការឲ្យស្ថាប័នសាធារណៈក្តី។ អ្នករាជការសាធារណៈត្រូវបានកំណត់និយមន័យនៅក្នុងមាត្រា ៣០ នៃក្រមព្រហ្មទណ្ឌ។ មាត្រានេះចែងថា ៖

១- អ្នករាជការសាធារណៈមានន័យថា ៖

ក. បុគ្គលដែលបំរើការងារនៅក្នុងស្ថាប័ននីតិប្បញ្ញត្តិ ស្ថាប័ននីតិប្រតិបត្តិ ឬ ស្ថាប័នតុលាការដែលត្រូវបានតែងតាំងដោយលិខិតបទដ្ឋានគតិយុត្ត ទោះជាអចិន្ត្រៃយ៍ ឬជាបណ្តោះអាសន្នក្តី ទោះជាបានទទួល ឬមិនបានប្រាក់ឈ្នួលក្តី ដោយមិនគិតពីឋានៈ អាយុរបស់បុគ្គលនោះឡើយ។

ខ. បុគ្គលឯទៀត ដែលធ្វើការក្នុងមុខងារសាធារណៈ រួមទាំងទីភ្នាក់ងារសាធារណៈ ឬសហគ្រាសសាធារណៈ ព្រមទាំងស្ថាប័នសាធារណៈដទៃទៀត ដែលមានចែងនៅក្នុងច្បាប់នៃព្រះរាជាណាចក្រកម្ពុជា។

២- ពលរដ្ឋទទួលអាណត្តិសាធារណៈដោយការបោះឆ្នោត មានន័យថាជាសមាជិកព្រឹទ្ធសភា រដ្ឋសភា ក្រុមប្រឹក្សារាជធានី ក្រុមប្រឹក្សាខេត្ត ក្រុមប្រឹក្សាក្រុង ក្រុមប្រឹក្សាស្រុក ក្រុមប្រឹក្សាខណ្ឌ និងសមាជិកក្រុមប្រឹក្សាឃុំ សង្កាត់ ព្រមទាំងពលរដ្ឋដែលទទួលអាណត្តិសាធារណៈដោយការបោះឆ្នោតដើម្បីបំពេញមុខងារសាធារណៈដទៃទៀត។

ឧទាហរណ៍នៃអ្នករាជការសាធារណៈមាន នគរបាល កងអាវុធហត្ថ មន្ត្រីគយ ព្រះរាជអាជ្ញា គ្រូបង្រៀន និងវេជ្ជបណ្ឌិតរបស់រដ្ឋ ព្រោះអ្នកទាំងនេះត្រូវបានតែងតាំងដោយព្រះរាជក្រិត្យ អនុក្រិត្យ ឬប្រកាស។ សមាជិកក្រុមប្រឹក្សាឃុំជាអ្នករាជការសាធារណៈដែរ ព្រោះគាត់ជាមន្ត្រីជ្រើសតាំងដោយការបោះឆ្នោត។

**ក.២ បំពេញសកម្មភាពរបស់អាជ្ញាធរសាធារណៈ** ៖ បទល្មើសប្រឆាំងនឹងអ្នករាជការសាធារណៈអាចត្រូវផ្តន្ទាទោសបានតែនៅពេលណាបុគ្គលជាអ្នករាជការនោះកំពុងបំពេញមុខងាររបស់ខ្លួននៅកន្លែងនិងពេលវេលាដែលត្រូវអនុវត្តមុខងារ មិនមែននៅក្រៅម៉ោងធ្វើការរបស់ខ្លួនឡើយ។ សកម្មភាពរបស់អាជ្ញាធរសាធារណៈមាន សកម្មភាពអនុវត្តច្បាប់ (ឧ. ប៉ូលីសចរាចរកំពុងឈរត្រួតចរាចរណ៍ ប៉ូលីសកំពុងតាមចាប់ជនល្មើស) សកម្មភាពអនុវត្តបញ្ជារបស់អាជ្ញាធរសាធារណៈ (ឧ. ប៉ូលីសអនុវត្តបញ្ជាឲ្យរុះរើតូប៉ាន់ចេញពីផ្លូវសាធារណៈ) សកម្មភាពអនុវត្តសេចក្តីសម្រេចរបស់តុលាការ (ឧ. ព្រះរាជអាជ្ញាកំពុងចុះអនុវត្តសាលក្រមតុលាការ)។

## ខ. ធាតុផ្សំសត្យានុម័ត ៖ ការប្រព្រឹត្តអំពើហិង្សាទៅលើអ្នករាជការ

ដើម្បីកំណត់ធាតុផ្សំសត្យានុម័ត ជនជាប់ចោទត្រូវតែបានប្រព្រឹត្តអំពើហិង្សាលើអ្នករាជការ។ ច្បាប់ខ្មែរមិនបានចែងថាអ្វីទៅដែលចាត់ទុកថាជាអំពើហិង្សាទេ។ មានបទបញ្ញត្តិនៅក្នុងផ្នែក ២ ជំពូក ២ នៃមាតិកាទី ២ នៃក្រមព្រហ្មទណ្ឌដែលចែងពីអំពើហិង្សា ប៉ុន្តែផ្នែកនេះក៏មិនបានឲ្យនិយមន័យអ្វីទៅដែលជាអំពើហិង្សា ប៉ុន្តែគ្រាន់តែបញ្ជាក់ពីទណ្ឌកម្មដែលត្រូវទទួលពីការប្រព្រឹត្តហិង្សា។

ជាការយល់ទូទៅ ហិង្សាសំដៅដល់ការប្រើកម្លាំងទៅលើរូបបុគ្គលណាម្នាក់ ដូចជាការវាយទាត់ធាក់ ការគប់ដុំថ្មទៅលើមនុស្ស ការប្រើអាវុធជាដើម។

ដើម្បីចោទប្រកាន់ពីបទប្រឆាំងនឹងអ្នករាជការសាធារណៈ យុត្តិសាស្ត្របារាំងតម្រូវឲ្យចៅក្រមប្រើឆន្ទានុសិទ្ធដើម្បីកំណត់អំពើប្រឆាំងមួយ ជាអំពើហិង្សាឬជាការឈ្លានពាន (Crim. 24 oct. 1984: Bull. crim. No 320)។ បើអំពើប្រឆាំងនោះកើតជាអំពើហិង្សា ឬជាអំពើឈ្លានពាន នោះទើបចាត់ទុកជាបទល្មើសប្រឆាំងនឹងអ្នករាជការបាន។ នៅក្នុងផ្នែកសំអាងហេតុ បើតុលាការ ខកខានមិនបានកំណត់ថាអំពើអ្វីខ្លះរបស់ចុងចោទ ដែលបង្កើតបានជាអំពើហិង្សា និងការឈ្លានពានទៅលើអ្នករាជការ នោះសាលក្រមនោះត្រូវចាត់ទុកជាមោឃៈ (Crim. 19 déc. 1946: Bull. crim. No 245)។

ក្នុងការណែនាំក្នុងការកំណត់ថាអ្វីជាអំពើហិង្សានោះ យុត្តិសាស្ត្របារាំងមួយទៀតបញ្ជាក់ថា "ការប្រឆាំងដោយហិង្សាទៅលើជនដែលទទួលអំណាចសាធារណៈត្រូវតែជាអំពើប្រឆាំងសកម្មទល់នឹងអន្តរាគមន៍របស់ជនទាំងនោះ ៖ ការប្រឆាំងអកម្មតែប៉ុណ្ណោះ និងកម្លាំងគ្មានចលនា[49] មិនមែនជាធាតុផ្សំរបស់បទមជ្ឈិមប្រឆាំងនឹងអ្នករាជការសាធារណៈទេ" (Crim. 1er mars 2006: Bull. crim. No 58; D. 2006. IR 948)។

ការប្រើកម្លាំងទល់នឹងអ្នករាជការសាធារណៈគឺជាការតទល់សកម្ម។ ឧទាហរណ៍ផ្សេងទៀតនៃការតទល់សកម្មមានដូចជា ការកាន់កាំភ្លើងរួចតម្រង់ទៅរកអ្នករាជការ ការព្យាយាមវាយដណ្ដើមរំដោះមនុស្សដែលប៉ូលីសចាប់ហ្វូងមនុស្សចាប់អ្នករាជការដែលកំពុងបំពេញបេសកកម្មធ្វើលិខិតស្នាម ឬកំណត់ហេតុផ្សេងៗ។

ការតទល់អកម្មមិនអាចចាត់ទុកជាបទប្រឆាំងអ្នករាជការសាធារណៈបានទេ។ ការតទល់អកម្មគឺជាការសំដែងមិនទទួលយកសកម្មភាពរបស់អ្នករាជការសាធារណៈ តែមិនបានប្រើកម្លាំងទេ។ យុត្តិសាស្ត្របារាំងបានឲ្យឧទាហរណ៍អំពើដូចតទៅនេះ ៖

- មិនព្រមដើរ ដេកនៅនឹងដី ឬទុកឲ្យភ្នាក់ងារនៃអាជ្ញាធរអូសយកចេញ។ (Crim. 27 juin 1908: Bull. crim. No 272)
- ការគ្រាន់តែលូកដៃទៅរកមន្ត្រីសាធារណៈក្នុងគោលបំណងឆក់យករបស់ដែលមន្ត្រីនេះកាន់ មិនមានលក្ខណៈមួយដែលច្បាប់ចាត់ទុកជាអំពើហិង្សាទេ។ (T. corr. Chalon-sur-Saône, 17 févr. 1950)

---

[49] Force d'inertie: ការតទល់បែបអកម្មដូចជាការមិនគោរពតាម មិនព្រមធ្វើតាមអ្វីដែលបញ្ជា,ការមិនបញ្ចេញសកម្មភាពឬថាមពល។

- ជនដែលត្រូវចាប់ខ្លួនធ្វើកាយវិការច្រងេងច្រងាងដើម្បីរារាំងមិនឲ្យប៉ូលីសស្ទាបខ្លួន តែមិនបានប៉ះខ្លួនប៉ូលីសទេ (Dalloz Code Pénal, 110e édition, 2013, p.1282, commentaire 11) ។
- ការគ្រាន់តែមិនគោរពបញ្ជា និង ការតទល់អកម្មតែប៉ុណ្ណោះ ឧទាហរណ៍ ដេកនៅនឹងដីដោយគ្មានប្រើហិង្សា ហើយទុកឲ្យភ្នាក់ងាររាជការអូស។ បទល្មើសនេះមិនកើតឡើងទេ កាលណាជនដែលត្រូវចាប់គ្រាន់តែចង់តទល់បែបអកម្ម នៅពេលដែលគាត់ត្រូវបានចាប់ជាប់ឲ្យនៅស្ងៀមមួយកន្លែងដោយដៃជាប់ខ្នោះគ្មានចេតនាប៉ះពាល់ដល់ខ្លួនប៉ូលីស។

### គ. ធាតុផ្សំអត្តនោម័ត

បទល្មើសប្រឆាំងនឹងអ្នករាជការសាធារណៈទាមទារឲ្យមានចេតនាជាក់លាក់ គឺចង់តទល់នឹងអ្នករាជការសាធារណៈ ដែលកំពុងបំពេញមុខងាររបស់ខ្លួនដើម្បីអនុវត្តច្បាប់ ឬបទបញ្ជាអាជ្ញាធរសាធារណៈ ឬសេចក្តីសម្រេចរបស់តុលាការ។ ដូច្នេះជនជាប់ចោទត្រូវតែបានដឹងពីអត្តសញ្ញាណរបស់ជនដែលខ្លួនចង់តទល់ថាជាអ្នករាជការសាធារណៈ និងពីសារជាតិនៃអន្តរាគមន៍ ឬកិច្ចការដែលជននោះត្រូវអនុវត្ត។ សញ្ញាសំគាល់របស់ជននោះអាចជាឯកសណ្ឋាន ឬ/និងលិខិតបញ្ជាក់បេសកកម្ម។

យុត្តិសាស្ត្របារាំងបញ្ជាក់ថា ហិង្សាទៅលើមន្ត្រីរាជការជាបទល្មើសដាច់ដោយឡែកពីបទប្រឆាំងនឹងអ្នករាជការសាធារណៈ។ យុត្តិសាស្ត្រនោះនិយាយថា ៖

> "ដោយហេតុថាលក្ខណៈរួមដែលជាធាតុផ្សំរបស់បទមជ្ឈិមទាំងពីរស្ថិតលើហិង្សា បទប្រឆាំងនឹងអ្នករាជការសាធារណៈអាចសំគាល់បានដោយសារចេតនាគិតទុកជាមុនរបស់ចារីដើម្បីបង្កើតឧបសគ្គដល់ការអនុវត្តច្បាប់ ឬកិច្ចការរបស់អាជ្ញាធរសាធារណៈ ចំណែកឯចារីនៃបទមជ្ឈិមហិង្សាវិញ គ្មានចេតនាអ្វីផ្សេងទៀតក្រៅតែពីវាយខ្លួនប្រាណរបស់អ្នករាជការនោះទេ"។
> (T.corr. Nanterre, 29 avr. 1975: Gaz.Pal 1976.1.367)

## ៤. បន្ទុកភស្តុតាង

ខាងចោទត្រូវបង្ហាញនូវភស្តុតាងដូចជា ៖

### ក. ការបំពេញមុខងារសាធារណៈ

អ្នករាជការសាធារណៈត្រូវមានភស្តុតាងបង្ហាញពីបេសកកម្មរបស់ខ្លួន។ មន្ត្រីរាជការដែលធ្វើកិច្ចការដែលគ្មានការអនុញ្ញាតឬ បំពេញការងារដែលមិនស្ថិតក្នុងរង្វង់អាណត្តិរបស់ខ្លួន មិនអាចមានហេតុផលត្រឹមត្រូវដើម្បីគាំទ្រការចោទប្រកាន់បានឡើយ។ ឧទាហរណ៍ មាត្រា ៦៩ នៃក្រមនីតិវិធីព្រហ្មទណ្ឌចែងថានគរបាលយុត្តិធម៌ត្រូវគោរពវិធាននៃសមត្ថកិច្ចដែនដីដែលបានបញ្ញត្តជាដាច់ខាត បើមិនគោរពទេ កិច្ចទាំងឡាយដែលបំពេញដោយមន្ត្រីនគរបាលនោះត្រូវទុកជាមោឃៈ។ ដូច្នេះនគរបាលនៃខេត្តកំពង់ស្ពឺមិនអាចមកបំពេញកិច្ចការឆែកឆេរផ្ទះលើដីខេត្តតាកែវបានទេ។ ម្យ៉ាងទៀត នគរបាលត្រូវតែបង្ហាញដីកាឆែកឆេររបស់តុលាការដល់ជនជាប់ចោទ (មាត្រា ៧០)។

### ខ. ការបង្ហាញពីអំពើហិង្សា

ដូចបានអធិប្បាយខាងលើ ហិង្សាជាស្នូលនៃធាតុផ្សំនៃបទល្មើសប្រឆាំងនឹងអ្នករាជការសាធារណ:។ ខាងដើមចោទត្រូវបង្ហាញភស្តុតាងនៃអំពើហិង្សាដែលជនជាប់ចោទប្រព្រឹត្តមកលើខ្លួន។ ហិង្សានោះជាហិង្សាសកម្មដូចបានពិភាក្សាខាងលើ។

## ៥. មធ្យោបាយការពារ

### ក. ការតទល់អកម្ម

ខាងចុងចោទត្រូវបង្ហាញពីការតទល់អកម្ម។ ការតទល់អកម្មជាអំពើដែលមិនយាយីដល់បូរណភាពរាងកាយរបស់អ្នករាជការសាធារណ:។ ឧទាហរណ៍មានដូចជាការគ្រាន់តែមិនធ្វើតាមបញ្ជាតែមិនបានប្រើកម្លាំងតបត។

## ៦. បញ្ហាខាងនីតិវិធី

### ក. បទល្មើសប្រឆាំងនឹងអ្នករាជការសាធារណៈ និង ហិង្សាដោយចេតនា

ដោយសារអំពើហិង្សាបង្កប់នៅក្នុងបទប្រឆាំងអ្នករាជការសាធារណ: តុលាការមិនអាចសម្រេចលើបទល្មើសពីរបានទេ។ បទហិង្សាដោយចេតនាត្រូវបានកំណត់នៅក្នុងមាត្រា ២១៧ នៃក្រមព្រហ្ម ទណ្ឌ។

### ខ. ការប៉ុនប៉ង

ដោយសារបទប្រឆាំងនឹងអ្នករាជការសាធារណ:ជាបទមជ្ឈិម ហើយច្បាប់មិនបានចែងពីបទប៉ុនប៉ង ដូច្នេះគ្មានបទល្មើសប៉ុនប៉ងប្រឆាំងនឹងអ្នករាជការសាធារណ:ទេ។ ស្ថានទម្ងន់ទោសនៃបទល្មើសនេះនាំឲ្យមានការផ្តន្ទាទោសអតិបរិមា ១ ឆ្នាំ។

### គ. ការញុះញង់

មានបទល្មើសញុះញង់ដោយផ្ទាល់ឲ្យប្រព្រឹត្តអំពើប្រឆាំងនឹងអ្នករាជការសាធារណ: (មាត្រា ៥០៥) ដែលជាប្រភេទនៃបទញុះញង់ដោយផ្ទាល់។ ការញុះញង់ដោយផ្ទាល់ឲ្យប្រឆាំងនឹងអ្នករាជការសាធារណ:មានកំរិតទោសតែពី១ថ្ងៃទៅ ១ ខែប៉ុណ្ណោះ។ តែការញុះញង់ឲ្យប្រឆាំងនឹងអ្នករាជការសាធារណ:អាចអនុវត្តបានតាមមាត្រា ២៨ ទោសអាចដល់ទៅ ១ខែ ទៅ៣ខែ បើសិនជាការញុះញង់នោះបានសម្រេច។

### ឃ. ដើមបណ្តឹងរដ្ឋប្បវេណី

គេមិនដឹងថាតើនៅក្នុងតុលាការកម្ពុជា អ្នករាជការដែលរងគ្រោះដោយបទប្រឆាំងនឹងអ្នករាជការអាចទាមទារសំណងរដ្ឋប្បវេណីតាមរយៈការតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណីបានឬយ៉ាងណាទេ។ នៅប្រទេសបារាំង ដោយសារអ្នករាជការជាបុគ្គលិករបស់រដ្ឋ ដូច្នេះរដ្ឋជានិយោជករដ្ឋមានកាតព្វកិច្ចសងការខូចខាតរបស់បុគ្គលិករបស់ខ្លួន ដូច្នេះ បណ្តឹងទាមទារសំណងរដ្ឋប្បវេណីរបស់អ្នករាជការមិនអាចទទួលយកបានទេ[50]។

[50] Michèle-Laure Rassat, Droit pénal spécial, Dalloz, 6e édition, p. 1257

## ៧. ប្រៀបធៀបជាមួយច្បាប់ប្រទេសដទៃទៀត

បទប្រឆាំងនឹងអ្នករាជការសាធារណៈនៅប្រទេសបារាំងចែកចេញជាកំរិតផ្សេងៗ និងមានកំរិតទោសផ្សេងៗ៖

1) បទប្រឆាំងនឹងអ្នករាជការសាធារណៈធម្មតា
2) បទប្រឆាំងនឹងអ្នករាជការសាធារណៈប្រព្រឹត្តជាក្រុម
3) បទប្រឆាំងនឹងអ្នករាជការសាធារណៈដោយប្រើអាវុធ
4) បទប្រឆាំងនឹងអ្នករាជការសាធារណៈដោយប្រើអាវុធជាក្រុម
5) បទប្រឆាំងនឹងអ្នករាជការសាធារណៈប្រព្រឹត្តដោយជនដែលជាប់ក្នុងការឃុំឃាំង
6) ការញុះញង់ដោយផ្ទាល់ឲ្យប្រព្រឹត្តបទប្រឆាំងនឹងអ្នករាជការសាធារណៈ តាមរយៈការស្រែក ការធ្វើសុន្ទរកថាសាធារណៈ សំណេរបិទផ្សាយឬចែកចាយ ឬមធ្យោបាយផ្សព្វផ្សាយសោតទស្សន៍។

## ៨. ការប្រៀបធៀបទៅនឹងបទហិង្សា

### មាត្រា ២១៧ បទហិង្សាដោយចេតនា

អំពើហិង្សាប្រព្រឹត្តដោយចេតនាទៅលើអ្នកដទៃ ត្រូវផ្តន្ទាទោសដាក់ពន្ធនាគារពីមួយឆ្នាំ ទៅបីឆ្នាំ និងពិន័យជាប្រាក់ពី ពីរលានទៅប្រាំលានរៀល។

### មាត្រា ២២៨ បទហិង្សាស្រាល

អំពើហិង្សាប្រព្រឹត្តទៅលើអ្នកដទៃនូវហិង្សាស្រាល ដែលមិននាំឲ្យមានរបួសទេនោះ ត្រូវផ្តន្ទាទោស ពិន័យជាប្រាក់ពី ប្រាំពាន់រៀល ទៅ មួយសែនរៀល។

# ជំពូក ៥

# ការបំផ្លិចបំផ្លាញ ការធ្វើឲ្យទ្រុឌទ្រោម និងការធ្វើឲ្យខូចខាត

## ១. ប្រវត្តិនៃច្បាប់

ការបំផ្លាញទ្រព្យសម្បត្តិរបស់អ្នកដទៃអាចជាអំពើអនីត្យានុកូល តាមទស្សនាទាននៃក្រមរដ្ឋប្បវេណី ដែលបានព្រាងឡើងក្រោមជំនួយបច្ចេកទេសរបស់ប្រទេសជប៉ុន។ មាត្រា ៧៤២ នៃក្រមរដ្ឋប្បវេណីចែងពីអំពើដែលបង្កឲ្យមានការខូចខាតទ្រព្យសម្បត្តិ ឬមនុស្ស។ អំពើអនីត្យានុកូលនេះមានទាំងអំពើដែលគណនាទុកជាមុន (ចេតនា) និងទាំងអំពើធ្វេសប្រហែស។ មាត្រា ៧៤៣ នៃក្រមរដ្ឋប្បវេណីតម្រូវឲ្យអ្នកប្រព្រឹត្តអំពើអនីត្យានុកូលដោយចេតនាក្ដី ឬអចេតនាក្ដី ត្រូវសងការខូចខាតដល់អ្នករងគ្រោះ។

ទន្ទឹមនឹងការដាក់អំពើដែលធ្វើឲ្យខូចខាតទ្រព្យសម្បត្តិអ្នកដទៃជាកំហុសរដ្ឋប្បវេណី ក្រមព្រហ្មទណ្ឌដែលបានព្រាងក្រោមជំនួយបច្ចេកទេសនៃប្រទេសបារាំង ក៏បានបញ្ចូលអំពើបែបនេះជាកំហុសព្រហ្មទណ្ឌផងដែរ។ អំពើបំផ្លាញទ្រព្យសម្បត្តិនៅក្នុងក្រមព្រហ្មទណ្ឌនេះរួមមានអំពើប្រព្រឹត្តដោយចេតនា (មាត្រា ៤១០) និងដោយធ្វេសប្រហែស(មាត្រា ៤១៩)។ នេះជាការសំខាន់ ព្រោះនៅពេលអំពើនេះកើតឡើង តើគេត្រូវចាត់ការបណ្ដឹងតាមតុលាការណា តុលាការរដ្ឋប្បវេណី ឬតុលាការព្រហ្មទណ្ឌ? ចម្លើយគឺស្ថិតនៅលើគោលនយោបាយអ្វីដែលអំពើបំផ្លាញទ្រព្យសម្បត្តិអ្នកដទៃចាំបាច់ត្រូវផ្ដន្ទាដោយច្បាប់ព្រហ្មទណ្ឌ។

យោងតាមច្បាប់បារាំង អង្គនីតិបញ្ញត្តិបារាំងយកចិត្តទុកដាក់នឹងការដាក់ជាបទល្មើសព្រហ្មទណ្ឌនូវអំពើបំផ្លាញទ្រព្យសម្បត្តិទាំងឡាយណាដែលបាននាំមកជាមួយនូវគ្រោះថ្នាក់ដល់មនុស្សផងដែរ និងការបំផ្លាញណាដែលមានលក្ខណៈធ្ងន់ធ្ងរ។ ការបំផ្លាញដែលមានលក្ខណៈស្រាលជាបទលហុដែលត្រូវពិន័យជាប្រាក់មិនលើសពី ១,៥០០ អឺរ៉ូ (មាត្រា ៦៣៥-១)។ ដូច្នេះ ច្បាប់បារាំងមានបំណងការពារសុវត្ថិភាពរបស់មនុស្សពីលទ្ធផលនៃការបំផ្លាញទ្រព្យសម្បត្តិ ដូចជាការប្រើអគ្គីភ័យ ការប្រើគ្រឿងផ្ទុះ ឬការការពារទ្រព្យសម្បត្តិដែលមានតម្លៃ[51] មិនមែនសៀវភៅមួយក្បាល រូបថតមួយសន្លឹក ឬបង្អួចរបងពីរបីនោះទេ។

ប៉ុន្តែ ទោះជាយ៉ាងណាក្ដី នៅក្នុងការអនុវត្តគេនៅតែពិបាកនឹងកំណត់ថា តើការបំផ្លាញណាខ្លះដែលចាត់ទុកថាជាការធ្ងន់ធ្ងរ ដូច្នេះធ្វើឲ្យបទបំផ្លិចបំផ្លាញ ការធ្វើឲ្យទ្រុឌទ្រោម និងការធ្វើឲ្យខូចខាតនៅតែអាចត្រូវបានប្រើដោយគ្មានព្រំដែនពិតប្រាកដ។

## ២. និយមន័យ

មាត្រា ៤១០ នៃក្រមព្រហ្មទណ្ឌប្រទេសកម្ពុជាចែងពីទណ្ឌកម្មដែលត្រូវដាក់លើការធ្វើឲ្យខូចខាតទ្រព្យសម្បត្តិអ្នកដទៃដោយចេតនា ៖

---

[51] សូមមើលបន្ថែម Michèle-Laure Rassat, Droit pénal spécial, Dalloz, 6e édition, p. 318-319.

អំពើប្រព្រឹត្តដោយចេតនា ដោយបំផ្លិចបំផ្លាញ ធ្វើឲ្យទ្រុឌទ្រោម ឬធ្វើឲ្យខូចខាតទ្រព្យរបស់អ្នកដទៃនោះត្រូវផ្តន្ទាទោសដាក់ពន្ធនាគារពី ៦ ខែ ទៅ ២ ឆ្នាំ និងពិន័យជាប្រាក់ពី ១ លានរៀល ទៅ ៤ លានរៀល លើកលែងតែការខូចខាតនោះមានលក្ខណៈស្រាល។

## ៣. ធាតុផ្សំនៃការបំផ្លិចបំផ្លាញ ការធ្វើឲ្យទ្រុឌទ្រោម និងការធ្វើឲ្យខូចខាត

បទបញ្ញត្តិស្តីពីការបំផ្លាញ ការធ្វើឲ្យទ្រុឌទ្រោម និងការធ្វើឲ្យខូចខាតមានគោលដៅការពារទ្រព្យសម្បត្តិ និងមនុស្សដោយសារការបំផ្លិចបំផ្លាញខ្លះបណ្តាលឲ្យគ្រោះថ្នាក់ដល់មនុស្ស។

ការបំផ្លាញ ការធ្វើឲ្យទ្រុឌទ្រោម និងការធ្វើឲ្យខូចខាតដែលមានលក្ខណៈស្រាលជាបទលហុ (មាត្រា ៤១៨)។

### ក. លក្ខខណ្ឌជាមុន

<u>ទ្រព្យសម្បត្តិខ្លួនឯង</u> ៖ បទល្មើសនៃការបំផ្លាញ ការធ្វើឲ្យទ្រុឌទ្រោម និងការធ្វើឲ្យខូចខាតអនុវត្តបានចំពោះតែទ្រព្យសម្បត្តិអ្នកដទៃ ជាចលនទ្រព្យក្តី ជាអចលនទ្រព្យក្តី។ គេមិនអាចផ្តន្ទាទោសនៅក្រោមបទបញ្ញត្តិនេះបានទេ កាលណាមនុស្សម្នាក់បំផ្លាញទ្រព្យសម្បត្តិខ្លួនឯង លើកលែងតែក្នុងករណីខ្លះដូចជាបំផ្លាញទ្រព្យសម្បត្តិខ្លួនឯងដើម្បីបំភ័ន្តក្រុមហ៊ុនធានារ៉ាប់រង ឬម្ចាស់បំណុល (ដែលត្រូវគ្រប់គ្រងដោយបទបញ្ញត្តិដទៃទៀតទាក់ទងនឹងការឆបោក)។ កម្មសិទ្ធិលើទ្រព្យសម្បត្តិត្រូវកំណត់ដោយវិធាននៃច្បាប់រដ្ឋប្បវេណី។

<u>ទ្រព្យជាកម្មសិទ្ធិពេញច្បាប់ផ្តាច់មុខរបស់អ្នកដទៃ</u> ៖ ច្បាប់ខ្មែរមិនបានបញ្ជាក់ពីលក្ខណៈនៃលទ្ធកម្មនៃទ្រព្យសម្បត្តិដែលត្រូវការពារពីការបំផ្លិចបំផ្លាញដោយចេតនាទេ។ ប៉ុន្តែ ទោះជាយ៉ាងណាក្តីទ្រព្យកម្មសិទ្ធិពេញច្បាប់ត្រូវតែបានការពារ លើកលែងតែមានភស្តុតាងផ្ទុយដែលបញ្ជាក់ថាការចុះបញ្ជីមានភាពមិនប្រក្រតីដែលមិនអាចធ្វើការកំណត់បានដាច់ខាតថាទ្រព្យនោះជាកម្មសិទ្ធិស្របច្បាប់របស់អ្នកដទៃឬជាទ្រព្យសម្បត្តិរបស់អ្នកបំផ្លាញ។ ឧទាហរណ៍ មនុស្សពីរនាក់មានជម្លោះលើកម្មសិទ្ធិលើទ្រព្យសម្បត្តិមួយ ហើយទ្រព្យសម្បត្តិនោះត្រូវបានធ្វើឲ្យខូចខាតដោយមនុស្សម្នាក់។ ម្នាក់ៗសុទ្ធតែអះអាងថាទ្រព្យនោះជាកម្មសិទ្ធិរបស់ខ្លួន។

<u>ទ្រព្យជាសហកម្មសិទ្ធិ</u> ៖ ចំពោះទ្រព្យសហកម្មសិទ្ធិវិញ បើតាមការវិភាគតាមបែបតក្កវិជ្ជា ទ្រព្យជាសហកម្មសិទ្ធិជាទ្រព្យរបស់អ្នកបំផ្លាញផង និងជាទ្រព្យរបស់អ្នកដទៃផង។ ឧទាហរណ៍ កាលណាប្តីបំផ្លាញទ្រព្យសម្បត្តិរួមរវាងប្តីប្រពន្ធ ទ្រព្យនោះមិនមែនជាទ្រព្យផ្តាច់មុខរបស់ប្តីទេ តែវាជាទ្រព្យរបស់ប្រពន្ធផង ដែរ។ ដូច្នេះ ប្តីនោះរំលោភបទបញ្ញត្តិស្តីពីការបំផ្លាញ ការធ្វើឲ្យទ្រុឌទ្រោម និងការធ្វើឲ្យខូចខាត។

<u>ទ្រព្យជាភោគៈ</u> ៖ ភោគៈ បើតាមក្រមរដ្ឋប្បវេណី ការកាន់កាប់អចលនវត្ថុមួយ ទោះបីដោយសន្តិវិធី និងដឹងឮជាសាធារណៈ សុចរិត និងគ្មានកំហុសនៅពេលចាប់ផ្តើមកាន់កាប់ ដោយមានឆន្ទៈយកជាកម្មសិទ្ធិក្តី ក្នុងកំលុង ១០ឆ្នាំ ជននោះក្លាយជាម្ចាស់នៃអចលនវត្ថុនោះ(មាត្រា ១៦២.២)។ ដូច្នេះ ការបំផ្លាញទ្រព្យសម្បត្តិនេះ នៅពេលលក្ខខណ្ឌទាំងនេះមិនទាន់បានបំពេញនោះវាអាចជាការបំផ្លាញទ្រព្យអ្នកដទៃ ឬទ្រព្យសាធារណៈ។ ករណីនេះអនុវត្តបានចាប់ពីក្រមរដ្ឋប្បវេណីចូលជាធរមាននៅថ្ងៃទី ១ ខែធ្នូ ឆ្នាំ២០១២។

ចំពោះភោគៈដែលស្ថិតនៅក្រោមច្បាប់ភូមិបាល ២០០១ វិញ អ្នកមានភោគៈប្រាំឆ្នាំ និងកាន់កាប់ដោយសន្តិវិធី សុចរិត និងត្រូវបានដឹងឮជាសាធារណៈ រហូតមកដល់ថ្ងៃចូលជាធរមាននៃច្បាប់

ភូមិបាលនៅថ្ងៃទី៣០ សីហា ២០០១ មនុស្សនោះជាម្ចាស់ផ្ដាច់មុខលើទ្រព្យនោះ ដោយមិនអាចអ្នកណាផ្សេងទៀតមកទាមទារថាជាម្ចាស់ដែរបានទេ។

ចំណែកឯអ្នកកាន់កាប់ទ្រព្យសម្បត្តិស្របតាមលក្ខខណ្ឌខាងលើ តែក្រោមប្រាំឆ្នាំ រហូតមកទាល់ថ្ងៃទី៣០ សីហា បុគ្គលនោះអាចបន្តពេលកាន់កាប់បន្តទៅទៀតដើម្បីបង្គ្រប់ប្រាំឆ្នាំ ដើម្បីក្លាយទៅជាម្ចាស់ផ្ដាច់មុខលើអចលនទ្រព្យនោះដែរ។ ឧទាហរណ៍ មនុស្សម្នាក់ចាប់ផ្ដើមកាន់កាប់ដីមួយកន្លែងនៅថ្ងៃទី២៩ សីហា ២០០១។ គាត់អាចកាន់កាប់បន្តទៅទៀតរហូតដល់ ថ្ងៃទី ២៨ ខែសីហា ឆ្នាំ២០០៦ ដើម្បីបានជាម្ចាស់ ភោគៈស្របច្បាប់ និងមានសិទ្ធិផ្ដាច់មុខលើទ្រព្យសម្បត្តិនោះ។ អ្នកផ្សេងដែលទាមទារក្រោយថ្ងៃ ២៨ សីហា ២០០៦ ថាខ្លួនជាម្ចាស់ទ្រព្យដែរនោះ អ្នកនោះមិនអាចមានសិទ្ធិលើទ្រព្យនោះបានទេ ព្រោះអ្នកទីមួយបានបំពេញលក្ខខណ្ឌគតិយុត្តគ្រប់អស់ហើយ។

បញ្ហាមួយដែលចោទនោះ គឺការចូលកាន់កាប់អចលនវត្ថុក្រោយថ្ងៃទី៣០ ខែសីហា ឆ្នាំ២០០១។ ជម្លោះដែលកើតជារឿយៗ គឺអ្នកកាន់កាប់ជាក់ស្ដែងអះអាងថាខ្លួនជាម្ចាស់ នៅពេលភាគីម្ខាងទៀតអះអាងថាគេបានទទួលសម្បទានដីពីរដ្ឋាភិបាល។ យោងតាមច្បាប់ភូមិបាល មាត្រា ២៩ អ្នកកាន់កាប់ដីក្រោយថ្ងៃ ៣០ សីហា ២០០១ មិនអាចមានភោគៈស្របច្បាប់ទេ។ ប៉ុន្តែ សេចក្ដីណែនាំលេខ ០១៨ សណន/កគដ នៃឧត្តមក្រុមប្រឹក្សាកំណែទម្រង់រដ្ឋ ក្រុមប្រឹក្សាគោលនយោបាយដីធ្លី ចុះថ្ងៃទី ២០ កក្កដា ២០១២ ក្នុងចំណុចទី ៥ ចែងថា ៖

> ចំពោះករណីប្រជាពលរដ្ឋដែលចូលទន្ទ្រានកាន់កាប់ដីរដ្ឋថ្មីៗ ក្រោយពីថ្ងៃទី០៧ ខែឧសភា ឆ្នាំ ២០១២[52] មិនអាចយកមកដោះស្រាយបានឡើយ។ ...

ចំណុចទី ៥ ខាងលើហាក់ដូចជាចង់និយាយថារដ្ឋាភិបាលនៅតែទទួលស្គាល់អ្នកកាន់កាប់ជាក់ស្ដែងជាម្ចាស់ភោគៈ និងត្រូវទទួលការវាស់វែងដី និងប្រគល់កម្មសិទ្ធិពីរដ្ឋាភិបាល ទោះបីពួកគេបានកាន់កាប់ដីក្រោយពីថ្ងៃទី ៣០ សីហា ២០០១ ក៏ដោយ។ ដូច្នេះ ការអនុវត្តបទបញ្ជារដ្ឋាភិបាលលេខ ០០១ បប បង្កើតបានជាករណីគំរូ (precedent) ថារដ្ឋាភិបាលអនុគ្រោះការកាន់កាប់ក្រោយថ្ងៃ ៣០ សីហា ២០០១ ទោះបីពួកគេគ្មានមូលដ្ឋានគតិយុត្តនៃការកាន់កាប់ដីក៏ដោយ។

<u>*ទ្រព្យសម្បត្តិសាធារណៈ*</u> ៖ គេមិនដឹងថាតើពាក្យថា"ទ្រព្យសម្បត្តិអ្នកដទៃ" នៅក្នុងមាត្រា ៤១០ រាប់បញ្ចូលទាំង"ទ្រព្យសម្បត្តិសាធារណៈ" ដែរឬទេ។ នៅក្នុងមាតិកាទី ២ ជំពូកទី ១ គេឃើញមានតែការបំផ្លាញទ្រព្យសម្បត្តិសាធារណៈ ម្យ៉ាងគឺប័ណ្ណប្រកាស ឬសេចក្ដីជូនដំណឹងជាផ្លូវការ (មាត្រា ៤២០) ហើយជាបទលហុតែប៉ុណ្ណោះ។ មានតែមាត្រា ៤១១ ទេ ដែលចែងផ្ទន្ទាទោសការបំផ្លាញទ្រព្យសម្បត្តិសាធារណៈ ក្នុងលក្ខណៈនៃស្ថានទម្ងន់ទោស ហើយមាត្រានេះទៀតសោតផ្ទន្ទាទោសតែការធ្វើ "ឲ្យខូចប្រយោជន៍ដល់សំណង់ គ្រឹះស្ថានសាធារណៈ ឬផ្លូវសាធារណៈ" និងការធ្វើ "ឲ្យខូចបង្គោលព្រំដែនអន្តរជាតិនៃព្រះរាជាណាចក្រកម្ពុជា"។ គេមិនឃើញមានការចែងបញ្ជាក់ចំៗពីការបំផ្លាញទ្រព្យសម្បត្តិសាធារណៈប្រភេទដទៃទៀតទេ។

តើគេអាចបកស្រាយ"ទ្រព្យសម្បត្តិអ្នកដទៃ" នោះថាជា "ទ្រព្យសម្បត្តិសាធារណៈ" ផងបានដែរឬទេ?

ជាភាសាសាមញ្ញអ្នកដទៃត្រូវតែជាបុគ្គលឯកជន មិនអាចជានីតិបុគ្គលសាធារណៈបានទេ។ ម្យ៉ាងវិញទៀត ក្រមព្រហ្មទណ្ឌហាមប្រាមក្នុងការបកស្រាយតាមបែបសទិសភាពឡើយ (មាត្រា ៥)។ សទិសភាព (analogy) គឺជាការបកស្រាយដោយធ្វើការប្រដូចនូវអ្វីដែលស្រដៀងគ្នា ឧទាហរណ៍ច្បាប់ហាមមិនឲ្យបររថយន្តចូលអង្គរវត្ត ដូច្នេះគេបកស្រាយថាច្បាប់ហាមរទេះសេះមិនឲ្យចូលអង្គរវត្តផងដែរ

[52] ថ្ងៃចេញបទបញ្ជា ០០១។

ព្រោះវាជាយានជំនិះដូចតែគ្នា។ ទ្រព្យសម្បត្តិឯកជន និងទ្រព្យសម្បត្តិសាធារណៈ ថ្វីបើវាជាទ្រព្យដូចគ្នា របបការពារត្រូវតែខុសគ្នា។

ច្បាប់បារាំងមានបទបញ្ញត្តិការពារ"ទ្រព្យសម្បត្តិអ្នកដទៃ" ដូចគ្នានឹងច្បាប់ខ្មែរ (មាត្រា ៣២២-១ ក្រមព្រហ្មទណ្ឌបារាំង) តែបារាំងបន្ថែមមាត្រាមួយទៀតដើម្បីការពារទ្រព្យសម្បត្តិសាធារណៈ គឺមាត្រា ៣២២-២។ មាត្រានេះផ្ដន្ទាទោសការបំផ្លាញ (១) ទ្រព្យសម្រាប់បម្រើផលប្រយោជន៍សាធារណៈ ឬដើម្បីដាក់តាំងជាសាធារណៈ និងទ្រព្យដែលជាកម្មសិទ្ធិរបស់ស្ថាប័នរដ្ឋាភិបាល (២) បញ្ជីកំណត់ហេតុ ឬ ឧបករណ៍របស់អាជ្ញាធររដ្ឋាភិបាល (៣) វត្ថុ ឬទីកន្លែងបុរាណវិទ្យា វត្ថុតាំងនៅសារមន្ទីរ បណ្ណាល័យ ប័ណ្ណសារជារបស់ស្ថាប័នសាធារណៈ។ល។

*<u>សម្បត្តិជាសម្បទាន</u>* ៖ ជាទ្រឹស្ដី ដីសម្បទានមិនមែនជាកម្មសិទ្ធិរបស់សម្បទានិកទេ តែជាដីកម្មសិទ្ធិរបស់រដ្ឋ។ សម្បទានិកជាម្ចាស់តាមព្រឹត្តិន័យ (de facto owner)។ សំណួរចោទសួរថាតើការបំផ្លាញដី សម្បទានជាការបំផ្លាញសម្បត្តិអ្នកដទៃ ឬសម្បត្តិសាធារណៈ?

អាចជាការបំផ្លាញសម្បត្តិឯកជន បើដីនោះត្រូវបានធ្វើសម្បទានដោយត្រឹមត្រូវតាមច្បាប់ ឬអាចជាការបំផ្លាញសម្បត្តិសាធារណៈ បើដីនោះនៅតែជាកម្មសិទ្ធិរបស់រដ្ឋនៅឡើយ ដោយហេតុថា ដីនោះមិនទាន់បានផ្ទេរត្រឹមត្រូវតាមច្បាប់នៅឡើយ។ យោងតាមច្បាប់ភូមិបាល ដីសម្បទានមានម្ចាស់ត្រឹមត្រូវលុះត្រាតែបានចុះបញ្ជីក្នុងបញ្ជីសុរិយោដី (មាត្រា ៥៣ ច្បាប់ភូមិបាល)។

## ខ. ធាតុផ្សំសត្យានុម័ត

ធាតុផ្សំនៃបទបំផ្លាញ ធ្វើឲ្យទ្រុឌទ្រោម និងធ្វើឲ្យខូចខាត គឺលទ្ធផលនៃអំពើនេះតែម្ដង។ ការបំផ្លាញត្រូវតែធ្ងន់។ បើស្រាល នោះវាជាបទលហុ។ បញ្ហាដែលចោទនោះគឺ តើគេអាចកំណត់បានយ៉ាងណាថាការខូចខាតមួយធ្ងន់ឬស្រាល?។

**ខ.១ ការបំផ្លាញ (destruction)** ៖ ការបំផ្លាញ គឺជាអំពើមួយធ្ងន់ធ្ងរ។ លទ្ធផលនៃការបំផ្លាញ គឺទ្រព្យសម្បត្តិមួយត្រូវខូចទាំងស្រុង ឬមួយផ្នែក ដែលលែងមានសម្បទាដើម្បីប្រើការបានតទៅទៀត។ ការបំផ្លាញនាំឲ្យវត្ថុមួយដែលបង្កើតមក ឬកើតមកសម្រាប់ប្រើការអ្វីមួយជាក់លាក់ត្រូវប្រើការលែងបានតាមគោលបំណងនៃការបង្កើត ឬតាមនិស្ស័យរបស់វា។ ឧទាហរណ៍ ការធ្វើឲ្យខ្ទេចខ្ទីដំណាំ ការកម្ទេចរថយន្តឲ្យខូចនិងលែងមានមុខងារជាយានជំនិះតទៅទៀត។

**ខ.២ ការធ្វើឲ្យទ្រុឌទ្រោម (degradation)** ៖ ការធ្វើឲ្យទ្រុឌទ្រោម ជាអំពើដែលធ្វើឲ្យវត្ថុមួយខូច តែមិនដល់បាត់បង់មុខងារចំបងរបស់វានោះទេ។ ឧទាហរណ៍ រថយន្តមួយដែលទ្រុឌទ្រោម គឺរថយន្តនោះមិនទាន់បាត់មុខងារជាយានជំនិះនៅឡើយទេ ប៉ុន្តែប្រសិទ្ធភាពនៃរថយន្តនោះត្រូវចុះថយ ដូចជាមិនអាចបរទៅមុខបានដោយសារខូចម៉ាស៊ីន បែកកង់។

**ខ.៣ ការធ្វើឲ្យខូច (deterioration)** ៖ ការធ្វើឲ្យខូចគឺជាអំពើធ្វើឲ្យវត្ថុមួយបាត់បង់តម្លៃរបស់វា ប៉ុន្តែ ក្រោយពីការជួសជុលទៅ វត្ថុនោះអាចប្រើការបានឡើងវិញ។

ដូច្នេះ បើតាមការវិភាគតាមន័យនិរុត្តិសាស្ត្រ (ឫសនៃពាក្យ) (etymology) ខាងលើពាក្យថា "ធ្ងន់"អាចកំណត់បានទៅតាម ៖

១. បូរណភាពនៃវត្ថុ (entirety) ៖ ភាពនៅទាំងមូល។ ក្នុងន័យនេះ វត្ថុមួយត្រូវបានរលាយរូបរាងទាំងស្រុង។

២. ភាពប្រើការបាន (functionality)។ របស់មួយដែលទ្រុឌទ្រោមមានន័យថារបស់នោះមិនបាត់បង់រូបរាងទេ តែគេមិនអាចស្តារឡើងវិញបាន ឬបើស្តារបាន ក៏យកមកដំណើរការដូចដើមវិញមិនបានដែរ ឬត្រូវចំណាយពេលនិងធនធានច្រើន។
៣. វិការភាពឬទុព្វលភាពនៃវត្ថុ (degradability or defect) ៖ សភាពអន់ថយខាងគុណភាព ឬភាពអាចប្រើការបាន ដែលធ្វើឲ្យវត្ថុមួយចុះតម្លៃ ឬធ្វើការលែងសូវមានប្រសិទ្ធិភាព។

ឧទាហរណ៍នៃការបំផ្លាញដែលជាបទល្មើសបំផ្លាញ ធ្វើឲ្យទ្រុឌទ្រោម និងធ្វើឲ្យខូចខាត តាមយុត្តិសាស្ត្របារាំង ៖

១. ការសរសេរចារឹកលើផ្ទាំងគំនូរដែលមិនអាចលុបបានជាឧទាហរណ៍នៃការខូចខាតធ្ងន់ ព្រោះគេមិនអាចដកសំណេរនោះចេញបានដោយមិនធ្វើឲ្យខូចខាតដល់គំនូរនោះ (Crim. 1er juin 1994: Gaz. Pal. 1994. 2. 675)។

២. ការបញ្ចេញសញ្ញាអេឡិចត្រូនិចរំខានដល់យន្តហោះ ធ្វើឲ្យយន្តហោះនោះបាត់បង់ការបញ្ជា ហើយក៏ធ្លាក់។

### គ. ធាតុផ្សំអត្តនោម័ត

ការបំផ្លាញ ត្រូវធ្វើឡើងក្នុងចេតនាជាក់លាក់ដើម្បីបំផ្លាញឬធ្វើឲ្យខូចខាតទ្រព្យសម្បត្តិអ្នកដទៃ មិនមែនធ្វើឡើងដោយការធ្វេសប្រហែសទេ។ សភាពផ្លូវគំនិតរបស់ជនជាប់ចោទ ៖

១. ជននោះដឹងថាទ្រព្យនោះជារបស់អ្នកដទៃ និង
២. ដឹងថាអំពើរបស់ខ្លួននឹងបំផ្លាញ ធ្វើឲ្យទ្រុឌទ្រោម ឬធ្វើឲ្យខូចខាតទ្រព្យនោះ។

## ៤. បន្ទុកភស្តុតាង

ខាងចោទត្រូវបង្ហាញជាដំបូងថា ទ្រព្យសម្បត្តិដែលត្រូវបំផ្លាញឬធ្វើឲ្យខូចខាតនោះជារបស់អ្នកដទៃក្រៅពីអ្នកបំផ្លាញ ហើយអ្នកបំផ្លាញ ក៏ដឹងថាវត្ថុនោះជារបស់អ្នកដទៃដែរ ព្រមទាំងអ្នកបំផ្លាញដឹងថាអំពើរបស់ខ្លួននាំឲ្យខូចខាតដល់វត្ថុនោះ។ ខាងចោទក៏ត្រូវបង្ហាញផងដែរថា ការខូចខាតមិនមែនស្រាល។

## ៥. មធ្យោបាយការពារ

ខាងចុងចោទត្រូវការពារបញ្ច្រាស់ពីខាងចោទដូចជា ៖

- ស្ថានភាពនៃទ្រព្យសម្បត្តិដែលខូចខាតមិនទាន់អាចកំណត់បានថាជារបស់អ្នកណា។
- ការខូចខាតមិនធ្ងន់។
- គ្មានចេតនា គឺធ្វើដោយធ្វេសប្រហែស។
- ភាពចាំបាច់។ ឧទាហរណ៍ ៖ កម្ទេចទ្វារ ឬជញ្ជាំងដើម្បីរត់ចេញពីផ្ទះជួល នៅពេលដែលអគ្គីភ័យឆាបជិតដល់ផ្ទះ។ ករណីមួយនៅប្រទេសបារាំង ៖ ឪពុកម្នាក់មានប្រាក់ខែតិចហើយរស់នៅក្នុងបន្ទប់ជួលមួយនៅប៉ារីស។ គាត់មានកូនស្រីតូចមួយ។ គាត់បានដាក់ពាក្យសុំឲ្យរដ្ឋផ្តល់ជំនួយទីកន្លែងស្នាក់នៅ។ បីខែក្រោយពីការដាក់ពាក្យនៅតែគ្មានចម្លើយពីអាជ្ញាធររដ្ឋ។ ដោយគិតឃើញថាបន្ទប់កំពុងស្នាក់នៅនេះអាចមានគ្រោះថ្នាក់ពិតទៅលើកូនតូចនោះ ដែលមិនអាចពន្យល់បាន គាត់ក៏សម្រេចចិត្តអារត្រចៀកទ្វារចូលនៃផ្ទះល្វែងសម្រាប់ជួលហើយដែលគ្មាន

មនុស្សនៅ ដើម្បីឲ្យគ្រួសាររបស់គាត់ចូលស្នាក់នៅ។ តុលាការដំបូងក្រុងប៉ារីសចាត់ទុកថាជាប្រតិកម្មចាំបាច់ និងសមរម្យចំពោះមុខគ្រោះថ្នាក់ពិត និងអយុត្តិធម៌ ដែលកូន និងប្រពន្ធរបស់គាត់ត្រូវប្រឈម (TGI Paris, 28 nov. 2000)។

## ៦. បញ្ហាខាងនីតិវិធី

### ក. កម្មសិទ្ធិមិនទាន់បានកំណត់ដាច់ស្រេច

កន្លងមកមានបញ្ហាជាច្រើនទាក់ទងនឹងការចោទប្រកាន់ពីបទបំផ្លាញ ធ្វើឲ្យទ្រុឌទ្រោម និងធ្វើឲ្យខូចខាត ដោយហេតុថាតុលាការនៅពេលទទួលបណ្តឹងពីមនុស្សដែលអះអាងខ្លួនថាជាម្ចាស់នៃទ្រព្យដែលរងការខូចខាត ចាត់ការឃុំឃាំងបណ្តោះអាសន្នតែម្តងនូវជនដែលត្រូវចោទថាប្រព្រឹត្តការបំផ្លាញ ធ្វើឲ្យទ្រុឌទ្រោម និងធ្វើឲ្យខូចខាតទ្រព្យសម្បត្តិអ្នកដទៃ។ ជនជាប់ចោទតែងតែលើកឡើងថា ទ្រព្យសម្បត្តិដែលមានបញ្ហានោះជាទ្រព្យរបស់ខ្លួនដែរ។ បញ្ហានេះធ្វើឲ្យមានបញ្ហាបន្ទាន់បង្ខំកើតឡើងថា តើអ្នកណាជាម្ចាស់របស់ពិតប្រាកដ?។ មានតែវិធាននៃច្បាប់រដ្ឋប្បវេណីទេ ដែលអាចកំណត់សិទ្ធិកម្មសិទ្ធិលើវត្ថុមួយបាន។

កាលណាមានរឿងបែបនេះកើតឡើង តុលាការព្រហ្មទណ្ឌត្រូវបង្អង់នីតិវិធីរបស់ខ្លួនសិន។ ក្រមនីតិវិធីព្រហ្មទណ្ឌ មាត្រា ៣៤៣ ចែងថា ៖

> តុលាការត្រូវបង្អង់មិនទាន់សម្រេច កាលណាភាគីណាមួយលើកបញ្ហាបន្ទាន់បង្ខំដែលការពិនិត្យបញ្ហានេះជាសមត្ថកិច្ចផ្តាច់មុខរបស់តុលាការមួយផ្សេងទៀត។
> បញ្ហាបន្ទាន់បង្ខំអាចនឹងទទួលបានលុះត្រាតែបញ្ហានេះ អាចនឹងលុបលាងចរិតជាបទល្មើសពីអំពើដែលចោទប្រកាន់លើជនជាប់ចោទ។
> ក្នុងរឿងរដ្ឋប្បវេណី បញ្ហាស្តីពីសិទ្ធិខាងកម្មសិទ្ធិ សិទ្ធិប្រត្យក្សលើអចលនវត្ថុ និងឋានៈបុគ្គលជាសមត្ថកិច្ចផ្តាច់មុខរបស់តុលាការរដ្ឋប្បវេណី។

ខាងចោទតែងតែបង្ហាញភស្តុតាងជាប័ណ្ណកម្មសិទ្ធិ ឬ អះអាងថា ដីដែលត្រូវបានបំផ្លាញនោះជាដីសម្បទានដែលរដ្ឋាភិបាលបានប្រគល់ឲ្យ។ តើការបង្ហាញប៉ុណ្ណោះ គ្រប់គ្រាន់មិនចាំបាច់បង្អង់នីតិវិធីព្រហ្មទណ្ឌដែរឬទេ?

នៅប្រទេសកម្ពុជា មានជម្លោះដីធ្លីច្រើនណាស់ ដោយសារតែការចេញប័ណ្ណកម្មសិទ្ធិខ្លះមានភាពមិនប្រក្រតី។ ប័ណ្ណកម្មសិទ្ធិគ្រាន់តែជាភស្តុតាងដំបូងប៉ុណ្ណោះ តែមិនមែនជាភស្តុតាងផ្តាច់ព្រាត់ទេ ដោយសារតែមានភាពមិនប្រក្រតីនេះ។ ដើម្បីទប់ទល់នឹងបញ្ហាប័ណ្ណកម្មសិទ្ធិមិនប្រក្រតីនេះ ច្បាប់ភូមិបាលបានបញ្ចូលបទបញ្ញត្តិខាងក្រោមនេះ ៖

**មាត្រា ៣០**

បុគ្គលទាំងឡាយដែលបានអាស្រ័យផលនៃភោគៈដោយសន្តិវិធី និង មិនមានការជំទាស់ចាប់ពី ៥(ប្រាំ) ឆ្នាំ យ៉ាងតិចគិតមកដល់កាលបរិច្ឆេទនៃការប្រកាសឱ្យប្រើច្បាប់នេះលើអចលនវត្ថុដែលមានលក្ខណៈត្រឹមត្រូវតាមច្បាប់ក្នុងការកាន់កាប់ជាឯកជន មានសិទ្ធិស្នើសុំប័ណ្ណកម្មសិទ្ធិស្ថាពរ ។

ក្នុងករណីមានការជំទាស់ដល់ការផ្តល់ប័ណ្ណកម្មសិទ្ធិស្ថាពរនេះ អ្នកតវ៉ាត្រូវយកភស្តុតាងមកបញ្ជាក់ថា ខ្លួនឯងផ្ទាល់បានបំពេញលក្ខខណ្ឌនៃភោគៈដោយសន្តិវិធី និងមិនមានការជំទាស់ចាប់ពី៥(ប្រាំ)ឆ្នាំ នៅលើអចលនវត្ថុដែលមានទំនាស់ ឬយកភស្តុតាងដែលថាខ្លួនបាន

ទិញអចលនវត្ថុនោះពីភោគីដើម ឬពីសិទ្ធិវន្តស្របច្បាប់ ឬអ្នកទទួលផ្ទេរកម្មសិទ្ធិ ឬពីសន្តតិជនរបស់ខ្លួន។

មាត្រានេះមានន័យថា កាលបើមានទំនាស់រវាងមនុស្សពីរនាក់លើដីតែមួយ បើមនុស្សម្នាក់មានប័ណ្ណសំគាល់សិទ្ធិកាន់កាប់អចលនវត្ថុ (ដែលគេហៅជាទូទៅហៅថាប្លង់ទន់) ដែលចេញដោយអាជ្ញាធរសុរិយោដី ហើយមនុស្សម្នាក់ទៀតជាអ្នកកាន់កាប់ភោគៈជាក់ស្តែង ប័ណ្ណសំគាល់សិទ្ធិកាន់កាប់របស់មនុស្សទីមួយគ្រាន់តែជាភស្តុតាងដំបូងប៉ុណ្ណោះ (prima facie evidence) ប៉ុន្តែមិនមានន័យថាជាភស្តុតាងមិនអាចលុបចោលបាននោះទេ (non-rebuttable evidence)។ មនុស្សទីពីរត្រូវបង្ហាញពីភស្តុតាងភោគៈស្របច្បាប់របស់ខ្លួនដើម្បីផ្ទាញ់ភស្តុតាងមនុស្សទីមួយវិញ។ ភស្តុតាងពីភោគៈស្របច្បាប់មានអំណាចលប់លើភស្តុតាងជាប័ណ្ណសំគាល់សិទ្ធិកាន់កាប់អចលនវត្ថុ។

**មាត្រា ៤០**

ក្នុងការរង់ចាំការរៀបចំឡើងវិញនូវប្លង់សុរិយោដី និងសៀវភៅគោលបញ្ជីដី អាជ្ញាធរមានសមត្ថកិច្ចត្រូវបន្តចេញប័ណ្ណសំគាល់សិទ្ធិកាន់កាប់អចលនវត្ថុចំពោះភោគៈដែលមានកន្លងមក មុនច្បាប់នេះចូលជាធរមាន ។

ប័ណ្ណសំគាល់សិទ្ធិនេះជាវត្ថុតាងនៃសិទ្ធិកាន់កាប់ ប៉ុន្តែមិនមែនជាប័ណ្ណកម្មសិទ្ធិទេ ហើយក៏មិនមែនជាលិខិតដែលតវ៉ាមិនបាននោះដែរ ។

ប័ណ្ណសំគាល់សិទ្ធិនេះ អាចនឹងបង្កើតបានជាប័ណ្ណស្ថាពរនៃកម្មសិទ្ធិដែលមានលក្ខណៈ មិនអាចតវ៉ាបានលុះត្រាតែគ្មានការជំទាស់នៅពេលបង្កើតសៀវភៅគោលបញ្ជីដី។

ក្នុងករណីមានការជំទាស់ទាមទារ ការកំណត់ថានរណាជាភោគីស្របច្បាប់នៃអចលនវត្ថុនោះ ត្រូវផ្អែកលើការស៊ើបអង្កេតបន្ថែមនូវរាល់ភស្តុតាងដែលពាក់ព័ន្ធទាំងអស់។ ប័ណ្ណសំគាល់សិទ្ធិកាន់កាប់អចលនវត្ថុ គឺជាភស្តុតាងមួយប៉ុន្តែមិនអាចកំណត់តែឯកឯងបានទេ។

គំរូនៃប័ណ្ណសម្គាល់សិទ្ធិកាន់កាប់អចលនវត្ថុ
(សម័យថ្មីឥឡូវនេះ)

ទំព័រទីមួយ

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

# ប័ណ្ណសម្គាល់សិទ្ធិកាន់កាប់អចលនវត្ថុ

**លេខៈ .ក.ក ............**

ឃុំ - សង្កាត់ ៖
ក្រុង - ស្រុក - ខណ្ឌ ៖
រាជធានី - ខេត្ត ៖

ក្រចេះ ថ្ងៃទី ខែ ឆ្នាំ

**ត.ប រដ្ឋមន្ត្រី ក្រសួងរៀបចំដែនដី នគរូបនីយកម្ម និង សំណង់**
**ប្រធានមន្ទីររៀបចំដែនដី នគរូបនីយកម្ម សំណង់ និងសុរិយោដី**

(ហត្ថលេខា)

(ឈ្មោះ)

ទំព័រក្នុង

លេខ...... អក្ខរសញ្ញាខ្លួន..........

| ភិនភាគក្បាលដី | | | | អត្រានុកូលដ្ឋានអ្នកកាន់កាប់ | | | | ការផ្លាស់ប្តូរ | | សេចក្តីផ្សេងៗ |
|---|---|---|---|---|---|---|---|---|---|---|
| ប្រភេទ | ទំហំ | | | នាម ត្រកូលនិង នាមខ្លួន ទាំងប្តី ប្រពន្ធ | ថ្ងៃ ខែ ឆ្នាំ និងស្រុក កំណើត | សវតារ | សញ្ញា | លេខាចារិកដោយសង្ខេបនៃលិខិត សញ្ញា និងសាលក្រមតុលាការ | បន្ទុកលើ អចលនវត្ថុ | |
| | ហ | អ | ស | | | | | | | |
| | | | | | | | | | | |

ទំព័រទីបួន (ខាងខ្នងជាមួយទំព័រទីមួយ)

ឈ្មោះដី៖..........................................................................ឈ្មោះភូមិ..........................................

**<u>ព្រំប្រទល់</u>៖**

ខាងជើង៖.....................................................................

ខាងត្បូង៖.....................................................................

ខាងកើត៖.....................................................................

ខាងលិច៖.....................................................................

.........(ស្រុក)....................,ថ្ងៃទី...... ខែ..........ឆ្នាំ....................

ប្រធានការិយាល័យរៀបចំដែនដី នគរូបនីយកម្ម សំណង់ និងភូមិបាល

(ហត្ថលេខា)

(ឈ្មោះ)

<u>ប្រកាស</u>៖ បើលោកអ្នកបានទទួលប័ណ្ណសំគាល់សិទ្ធិកាន់កាប់អចលនវត្ថុនេះ ដោយបានចំណែក ជាកេរ្តិ៍ ទទួលទិញដូរក្តី ឬទទួលបញ្ចាំក្តី ចូរលោកអ្នកកុំភ្លេចនាំម្ចាស់អចលនវត្ថុទៅធ្វើលិខិតជាលាយលក្ខណ៍អក្សរ នៅចំពោះមុខមន្ត្រីមានសមត្ថកិច្ច ឬ ផ្លាស់ឈ្មោះនៅការិយាល័យរៀបចំដែនដី នគរូបនីយកម្ម សំណង់ និង ភូមិបាលក្រុង-ស្រុក-ខ័ណ្ឌ ព្រោះបើកាលណាមិនបានបំពេញកិច្ចទាំងនេះទេ អចលនវត្ថុនោះនឹងទុកជាធានាប្រាក់លោកអ្នកក៏មិនកើត ឬទុកជាសិទ្ធិកាន់កាប់របស់លោកអ្នកក៏ពុំបាន។

**គំរូនៃប័ណ្ណសម្គាល់សិទ្ធិកាន់កាប់អចលនវត្ថុ**

(សម័យរដ្ឋកម្ពុជា ដែលគេច្រើនហៅថាប័ណ្ណស្លាបមាន់)

ខាងមុខ

**រដ្ឋកម្ពុជា**

ឯករាជ្យ សន្តិភាព សេរីភាព សុភមង្គល

គណៈកម្មាធិការប្រជាជន

ខេត្ត.........

ស្រុក.........

លេខ៖............

# ប័ណ្ណសំគាល់សិទ្ធិ

## កាន់កាប់ប្រើប្រាស់ដីធ្លី

ភូមិ.................
ឃុំ..................

ខាងខ្នង

| | |
|---|---|
| ឈ្មោះអ្នកកាន់កាប់ដី___________________________________<br>ភេទ_________អាយុ _____ សញ្ជាតិ___________________<br>ទីលំនៅបច្ចុប្បន្ន ____________ ___ ____________________<br>__________________________________________________<br>ចំនួនសមាជិកគ្រួសារ _________<br>ទីកន្លែងដី ភូមិ_____________ ឃុំ ______________________ ស្រុក<br>_____________ ខេត្ត ____________________________<br>ប្រភេទដី (1) __________________________________________<br>ទំហំដី (2) ____________________________________________<br><br>ថ្ងៃទី ខែ ឆ្នាំ<br>ប្រធានការិយាល័យកសិកម្មស្រុក<br>(ហត្ថលេខា ត្រា និង ឈ្មោះ)<br>បានឃើញ<br>ប្រធានគណៈកម្មាធិការប្រជាជន<br>ស្រុក<br>(ហត្ថលេខា ត្រា និងឈ្មោះ) | គំនូសប្លង់ដី (3)<br><br>មាត្រាដ្ឋានៈ_________<br>(1) ដីសង់លំនៅឋាន ឬដីស្រែ ឬដីចំការ<br>(2) គិតជាម៉ែត្រក្រឡា ឬ ហិកតា<br>(3) មាត្រាដ្ឋាន1/5000-1/100 អាស្រ័យទំហំដី ធំ ឬ តូច និង បញ្ជាក់ឈ្មោះអ្នកកាន់កាប់ដី*ជាប់គ្នា* |

ចំពោះដីសម្បទានវិញ ជម្លោះតែងកើតមានរវាងអ្នកកាន់កាប់ជាក់ស្តែង (ភោគី) និង សម្បទានិកដែលបានការផ្តល់ដីសម្បទានពីរដ្ឋាភិបាល។ ដីសម្បទានដែលត្រូវបានផ្តល់ត្រូវឆ្លងកាត់ជាច្រើនដំណាក់ កាល។ ភស្តុតាងដែលបញ្ជាក់ថាសម្បទានិកម្នាក់ទទួលបានដីសម្បទានសេដ្ឋកិច្ច គឺគាត់ត្រូវមានកិច្ចសន្យា ដីសម្បទានសេដ្ឋកិច្ច និង ដីនោះត្រូវបានចុះបញ្ជីត្រឹមត្រូវតាមច្បាប់ជាដីសម្បទានសេដ្ឋកិច្ច។

**មាត្រា ៥២**

សម្បទានដីអាចបង្កើតបានតែសិទ្ធិក្នុងរយៈពេលមួយជាកំណត់តាមកិច្ចសន្យាដែលបានបង្កើត សម្បទាននោះស្របតាមបញ្ញត្តិនៃច្បាប់នេះ ។

សម្បទានដីមិនអាចឈានដល់ការបង្កើតនូវសិទ្ធិជាកម្មសិទ្ធិលើដីដែលបានផ្តល់ជាសម្បទានជាប្រយោជន៍ដល់សាមីជននោះទេ លើកលែងតែចំពោះសម្បទានដែលឆ្លើយតបទៅនឹងប្រយោជន៍សង្គម។

ពេលខ្លះសម្បទានិកគ្រាន់តែបានទទួលការអនុម័តជាគោលការណ៍ពីរដ្ឋាភិបាល ដើម្បីធ្វើការសិក្សាបន្ថែមទៀត ឆ្ពោះទៅរកការអនុម័តផ្តល់សម្បទានជាស្ថាពរ។ នៅក្នុង

ដំណាក់កាលនេះ គេប្រទះឃើញមានសម្បទានិកខ្លះមានទំនាស់ជាមួយនឹងអ្នកដែលតាំងទីលំនៅឬមានចំការដាំដុះនៅកន្លែងសម្បទាននោះ ដោយសម្បទានិកបណ្តេញអ្នកតាំងទីលំនៅទាំងនោះចេញពីដី។ ទំនាស់នេះកើតជាការខឹងសម្បារពីអ្នកតាំងទីលំនៅរហូតដល់បំផ្លាញរបងដែលសម្បទានិកព័ទ្ធដីនោះ។ ដោយសារសម្បទានិកមិនទាន់បានចុះកិច្ចសន្យាសម្បទានដីជាមួយរដ្ឋាភិបាល ដីនោះមិនទាន់ក្លាយទៅជាដីរបស់សម្បទានិកនៅឡើយទេ។ ដីសម្បទាននឹងក្លាយទៅជារបស់សម្បទានិក នៅពេលដែលដីនោះត្រូវបានចុះបញ្ជីសុរិយោដីជាមួយនឹងក្រសួងរៀបចំដែនដី នគរូបនីយកម្មនិងសំណង់ ដូចមានកំណត់ក្នុងមាត្រា ៥៣ ខាងក្រោមនៃច្បាប់ភូមិ បាល។ ក្រសួងនឹងចេញប័ណ្ណសំគាល់សម្បទាន ដូចគ្នាប័ណ្ណកម្មសិទ្ធិអញ្ចឹងដែរ។

**មាត្រា ៥៣**

សម្បទានដីមិនអាចកើតចេញពីស្ថានភាពកាន់កាប់ដីជាក់ស្តែងបានទេ។ សម្បទានដីត្រូវសំអាងលើលិខិតគតិយុត្តជាក់លាក់ដែលបានចេញ មុនការកាន់កាប់ដីដោយអាជ្ញាធរមានសមត្ថកិច្ច គឺរដ្ឋ ឬសមូហភាពដែនដីសាធារណៈ ឬគ្រឹះស្ថានសាធារណៈដែលជាកម្មសិទ្ធិករនៃដីដែលត្រូវបានផ្តល់ជាសម្បទាន។ សម្បទានត្រូវតែចុះបញ្ជីនៅក្រសួងរៀបចំដែនដី នគរូបនីយកម្ម និង សំណង់ ។

## គំរូនៃប័ណ្ណសម្គាល់សិទ្ធិសម្បទានសេដ្ឋកិច្ច

(សម័យបច្ចុប្បន្ននេះ)

ទំព័រទីមួយ

# ព្រះរាជាណាចក្រកម្ពុជា

**ជាតិ សាសនា ព្រះមហាក្សត្រ**

## វិញ្ញាបនបត្រសំគាល់សិទ្ធិសម្បទានដីសេដ្ឋកិច្ច

**លេខ៖** ............

ខេត្ត ក្រចេះ

ស្រុក ស្នួល

ឃុំ ស្រែចា

ភូមិ




មាត្រាដ្ឋាន ១/២០០០

សន្លឹកផែនទីលេខ៖

លេខក្បាលដី ៖

ទំហំ ៖ ១០,០០០ ម$^{២}$

ប្រភេទដី ៖

រូបភាពប្រើប្រាស់ដី៖

កម្មសិទ្ធិករនៃដី ៖

រយៈពេល...ឆ្នាំ ចាប់ពី............ដល់.....

ភ្នំពេញ, ថ្ងៃទី......ខែ........ឆ្នាំ

**ទេសរដ្ឋមន្ត្រី រដ្ឋមន្ត្រី ក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់**

ទំព័រក្នុង

# តារាងផ្លាស់ប្តូរ

| អត្រានុកូលដ្ឋានសម្បទានិក | | | ការផ្លាស់ប្តូរ | | សេចក្តីផ្សេងៗ |
|---|---|---|---|---|---|
| នាមត្រកូលនិងនាមខ្លួន / ប្រភេទទ្រព្យ | ថ្ងៃ ខែ ឆ្នាំ និងទីកន្លែងកំណើត | សរតារ | លេខាចារិកដោយសង្ខេបនៃលិខិតសញ្ញា និងសាលក្រមតុលាការ | បន្ទុកលើអចលនវត្ថុ | |
| | | | | | |
| ១ | ២ | ៣ | ៤ | ៥ | ៦ |
| | | | | | |
| | | | | | |
| | | | | | |

### ខ. តើការឃុំខ្លួនបណ្តោះអាសន្នអាចធ្វើទៅបានទេនៅពេលដែលកម្មសិទ្ធិមិនទាន់កំណត់ដាច់ស្រេច?

ក្នុងករណីដូចបានរៀបរាប់ខាងលើ នៅពេលភាពជាម្ចាស់ ឬកម្មសិទ្ធិនៅមិនទាន់បានកំណត់នៅឡើយនោះ គេមិនអាចកំណត់អំពើមួយចូលជាបទល្មើសមជ្ឈិមនៃការបំផ្លាញ ធ្វើឲ្យទ្រុឌទ្រោម និងធ្វើឲ្យខូចខាត ព្រោះលក្ខខណ្ឌជាមុន "ទ្រព្យសម្បត្តិអ្នកដទៃ" មិនទាន់បានបញ្ជាក់ឲ្យឃើញនៅឡើយ។ បើមិនទាន់ដឹងថាមាន ឬមិនមានបទល្មើសព្រហ្មទណ្ឌផង ការឃុំខ្លួនបណ្តោះអាសន្នក្នុងកាលៈទេសៈបែបនេះពុំត្រូវធ្វើឡើយ។

## ៧. បទបំផ្លាញ ធ្វើឲ្យទ្រុឌទ្រោម និងធ្វើឲ្យខូចខាតក្នុងទម្រង់ផ្សេងៗ

បទបំផ្លាញ ធ្វើឲ្យទ្រុឌទ្រោម និងធ្វើឲ្យខូចខាតបង្កើតឲ្យមានស្ថានទម្ងន់ទោសមានលក្ខណៈនៃការបំផ្លាញដូចខាងក្រោមនេះ ៖

៧.១ ***ប្រភេទនៃវត្ថុ***ដែលត្រូវបំផ្លាញ (មាត្រា ៤១១) ៖

- សំណង់គ្រឹះស្ថានសាធារណៈ ឬផ្លូវសាធារណៈ
- បង្គោលព្រំដែនអន្តរជាតិ
- ដំណាំ ឬ កសិផល

៧.២ ការបំផ្លាញ ក្នុងសកម្មភាពជា**សហចារី អ្នកសមគំនិត ឬជាអ្នកផ្តើមគំនិត**(មាត្រា ៤១១)។ សហចារីគឺមនុស្សម្នាក់ដែលបានព្រមព្រៀងប្រព្រឹត្តបទល្មើសរួមគ្នាដោយផ្ទាល់ជាមួយបុគ្គលដទៃទៀត (មាត្រា ២៦ ក្រមព្រហ្មទណ្ឌ)។

គេមិនត្រូវច្រឡំសហចារីជាមួយនឹង អ្នកសមគំនិតឡើយ។ សហចារីគឺជាបុគ្គលដែលមានការទទួលខុសត្រូវដោយផ្ទាល់ខ្លួន ហើយមិនអាស្រ័យលើអំពើរបស់ចារីដទៃទៀតទេ គឺគាត់ប្រព្រឹត្តអំពើល្មើសមួយដោយផ្ទាល់ដៃខ្លួនគាត់តែម្តង មិនមែនដូចអ្នកផ្តើមគំនិត ឬ អ្នកសមគំនិតដែលទទួលខុសត្រូវដោយសារអំពើរបស់អ្នកដទៃទេ។ សហចារីជាបុគ្គលក្នុងផ្នែកមួយដែលមិនអាចផ្តាច់ចេញពីផ្នែកទាំងមូលនៃក្រុមចារីដែលប្រព្រឹត្ត

អំពើមួយ ឬទាំងឡាយដែលចូលជាធាតុផ្សំនៃបទល្មើសមួយ។[53] ដូច្នេះ មនុស្សម្នាក់ដែលរួមជាមួយមនុស្សម្នាក់ទៀត ហើយធ្វើសកម្មភាពដូចមនុស្សម្នាក់ទៀតនោះ ដើម្បីលួចយកទ្រព្យរបស់គេគឺជាសហចារី ព្រោះគាត់ធ្វើសកម្មភាពដកហូតយកទ្រព្យអ្នកដទៃជាមួយគ្នា និងដូចគ្នានឹងមនុស្សម្នាក់ទៀត ប៉ុន្តែបើមនុស្សនោះមិនបានធ្វើសកម្មភាពដកហូតទ្រព្យសម្បត្តិទេ តែគ្រាន់តែជួយមនុស្សម្នាក់ទៀតឲ្យធ្វើសកម្មភាពកាត់សោយកទ្រព្យរបស់គេ មនុស្សនោះមិនមែនជាសហចារីទេ តែគាត់ជាអ្នកសមគំនិត។[54] មនុស្សម្នាក់ដែលចូលរួមបាតុកម្ម ហើយមានបាតុករខ្លះ បានដុតបំផ្លាញទ្រព្យសម្បត្តិរបស់រោងចក្រ តែមនុស្សម្នាក់នោះមិនបានធ្វើសកម្មភាពដុតជាមួយបាតុករដទៃទៀត មនុស្សនោះមិនមែនជាសហចារីនៃបទបំផ្លិចបំផ្លាញទ្រព្យសម្បត្តិអ្នកដទៃទេ។ ការគ្រាន់តែមានវត្តមាននៅក្នុងហ្វូងបាតុករមិនអាចចាត់ទុកគាត់ជាសហចារីបានទេ។

៧.៣ *ប្រភេទកន្លែង*នៃការប្រព្រឹត្ត (មាត្រា ៤១១) ៖

- ការបំផ្លាញរបស់ដែលនៅក្នុងទីលំនៅស្ថាន (កន្លែងដែលមនុស្សរស់នៅ)
- ការបំផ្លាញរបស់នៅកន្លែងសម្រាប់តម្កល់មូលនិធិ ទំនិញ ឬសម្ភារៈ ដូចជាធនាគារ ឃ្លាំងស្តុកឥវ៉ាន់

៧.៣ ការបំផ្លាញដែលនាំឲ្យខូចខាតដល់*វិជ្ជាជីវៈអ្នកដទៃ និងការគ្រប់គ្រងវិស័យយុត្តិធម៌* (មាត្រា ៤១២) ដូចជា ៖

- ការងាររបស់ចៅក្រម មេធាវី
- ការធ្វើឲ្យខូចវត្ថុតាង

៧.៤ ការបំផ្លាញដោយប្រើ*វិធីគ្រោះថ្នាក់* (មាត្រា ៤១៣) ៖

- អគ្គីភ័យ
- គ្រឿងផ្ទុះ

មាត្រា ៤១៣ ៖ អំពើប្រព្រឹត្តដោយចេតនាដើម្បីបំផ្លិចបំផ្លាញ ធ្វើឲ្យទ្រុឌទ្រោម ឬធ្វើឲ្យខូចខាងទ្រព្យសម្បត្តិដែលជាកម្មសិទ្ធិរបស់អ្នកដទៃ ដោយអនុភាពនៃគ្រឿងផ្ទុះ នៃអគ្គិសនី ឬគ្រប់វិធីដទៃទៀតដែលអាចនាំឲ្យមានគ្រោះថ្នាក់ដល់បុគ្គល ត្រូវផ្តន្ទាទោសដាក់ពន្ធនាគារពី ២ (ពីរ) ឆ្នាំ ទៅ ៥ (ប្រាំ) ឆ្នាំ និងពិន័យជាប្រាក់ពី ៤.០០០.០០០ (បួនលាន) រៀល ទៅ ១០.០០០.០០០ (ដប់លាន) រៀល។

៧.៥ ការបំផ្លាញទ្រព្យសម្បត្តិ*ដែលនាំឲ្យគ្រោះថ្នាក់ដល់មនុស្ស* (មាត្រា ៤១៣)

៧.៦ ការបំផ្លាញដែលនាំឲ្យខូចខាតដល់*មនុស្ស* (មាត្រា ៤១៤ ៤១៥ និង ៤១៧)

- ពិការ
- ស្លាប់
- របួសស្នាម -ល-។

៧.៥ ការបំផ្លាញដោយសារ*ការធ្វេសប្រហែស* (មាត្រា ៤១៩)

---

[53] Gaston et al., Droit penal general, Dalloz, 15e, 1994, p. 239 (កថាខណ្ឌ ២៩៤)។

[54] ប្រភពដូចខាងលើ (កថាខណ្ឌ ២៩៣)។

# ជំពូក ៦

# ភេរវកម្ម

## ១. ប្រវត្តិនៃច្បាប់

ច្បាប់ស្តីពីភេរវកម្មជាច្បាប់ថ្មីមួយដែលចម្លងមកពីច្បាប់ព្រហ្មទណ្ឌបារាំងនៃមាត្រា ៤១២-៣ (movement insurrectionnel)។ និយាយជាពាក្យសាមញ្ញច្បាប់នេះគឺជាច្បាប់ទប់ទល់នឹងចលនាឧទ្ទាម។ ដោយសារវាជាចលនា បទល្មើសនេះជាបទល្មើសមានទ្រង់ទ្រាយធំ មិនមែនជាអំពើធ្វើដោយមនុស្សចំនួនតូចទេ។ ច្បាប់បារាំងកំណត់និយមន័យថា (មាត្រា ៤១២-៣) ៖

> ការភេរវកម្មគឺជាអំពើហិង្សារួមដែលមានចរិតលក្ខណៈធ្វើឲ្យមានគ្រោះថ្នាក់ដល់ស្ថាប័ននៃសាធារណៈរបស់រដ្ឋ ឬធ្វើឲ្យខូចខាតដល់បូរណភាពទឹកដីជាតិ។

បន្ទាប់មកច្បាប់នោះដាក់ទណ្ឌកម្មចំពោះការចូលរួមក្នុងចលនាបះបោរ ឬភេរវកម្មតាមរយៈប្រើមធ្យោបាយផ្សេង ដើម្បីធ្វើឲ្យបានសម្រេចគោលដៅនៃចលនាបះបោរ ឬភេរវកម្មនេះ។ មធ្យោបាយទាំងនោះមានដូចជា (មាត្រា ៤១២-៤) ៖

1. ការសង់គ្រឿងទស់ទ័ព (របាំងការពារ) ជម្រកការពារ ឬសំណង់អ្វីផ្សេងទៀតដើម្បីទប់ទល់ ឬធ្វើជាឧបសគ្គដល់កម្លាំងសាធារណៈ។
2. ការកាន់កាប់ដោយប្រើកម្លាំងចេញមុខ ឬប្រើឧបាយកល ឬដោយបំផ្លាញអាគារ ឬទីតាំងអ្វីមួយ។
3. ដោយធានាការដឹកជញ្ជូន ការផ្គត់ផ្គង់ភស្តុភាទៅឲ្យ ឬការគមនាគមន៍គ្នារវាងពួកអ្នកបះបោរ។
4. ដោយញុះញង់ឲ្យមានការប្រមូលផ្តុំពួកអ្នកបះបោរ តាមមធ្យោបាយណាក៏ដោយ
5. ដោយខ្លួនឯងជាអ្នកកាន់អាវុធ។
6. ដោយតាំងខ្លួនឯងជំនួសអាជ្ញាធរស្របច្បាប់។

ដូច្នេះ ភេរវកម្ម ឬការបះបោរនេះកើតឡើងដោយធាតុផ្សំបីគឺ (១) អត្ថិភាពនៃចលនាភេរវកម្ម (២) ការចូលរួមក្នុងចលនាតាមមធ្យោបាយណាមួយដែលរៀបរាប់ខាងលើ និង (៣) ចេតនាដើម្បីធ្វើឲ្យអន្តរាយដល់ស្ថាប័ន និង/ឬបូរណភាពរបស់ជាតិ។

ការប្រើមធ្យោបាយណាមួយខាងលើតែឯកឯង មិនទាន់ចាត់ទុកជាការបះបោរនៅឡើយទេ លុះត្រាតែមធ្យោបាយទាំងនោះត្រូវបានប្រើសម្រាប់បំផ្លាញស្ថាប័ន ឬបូរណភាពទឹកដីរបស់ប្រទេស។ ឧទាហរណ៍ ការសង់របាំងកាត់ផ្លូវតែឯកឯងមិនអាចចាត់ទុកជាចាំបាច់ថាជាការបះបោរក្នុងន័យនៃច្បាប់នេះទេ។ តាមន័យខាងលើ ភេរវកម្ម ឬការបះបោរនេះមិនសំដៅទៅលើសកម្មភាពបាតុកម្មដែលប្រើមធ្យោបាយគាបសង្កត់រកដំណោះស្រាយណាមួយនោះទេ ប៉ុន្តែសំដៅដល់ចលនាបះបោរប្រឆាំងដោយកម្លាំងជារបៀប

"ទ័ព" ឬជា "ក្បួន" អ្វីមួយរៀបរយក្តី មិនរៀបរយក្តី ដែលមានបំណងបំផ្លាញស្ថាប័នជាតិចោល ឬដើម្បីដណ្តើមយកអំណាចជាតិមកគ្រប់គ្រងដោយក្រុមខ្លួនឯង។

ប៉ុន្តែមានការពិបាកមួយទាក់ទងនឹងការបកស្រាយថា អ្វីទៅ និងទំហំប៉ុនណាទៅដែលជាការធ្វើឲ្យប៉ះពាល់ដល់ស្ថាប័នជាតិ។ នៅក្នុងកំណត់ហេតុនៃការពិភាក្សារបស់ព្រឹទ្ធសភាបារាំង ថ្ងៃទី២៣ មេសា ១៩៩២ ក្នុងកំលុងពេលពិនិត្យសេចក្តីព្រាងក្រមព្រហ្មទណ្ឌថ្មីអំពីលក្ខខណ្ឌណាខ្លះដែលត្រូវផ្តន្ទាអំពើការបះបោរ គណៈកម្មការព្រឹទ្ធសភាកត់សំគាល់ថាផ្នែកដែលនិយាយពីកុបកម្មគឺគិតគូរតែពីកាលៈទេសៈណាដែលធ្ងន់ធ្ងរណាស់ ដែលគេមើលឃើញថាមានការប៉ះពាល់ដល់អាយុជីវិតរបស់ប្រទេសជាតិ [55] ។ លោក André Vitu ដែលជាអ្នកធ្វើអត្ថាធិប្បាយនៅក្នុងមូលដ្ឋានទិន្នន័យ Juris-classeur បានពិពណ៌នាថា ការប្រជុំគ្នា ការធ្វើបាតុកម្ម (ឬរហូតដល់ទៅការប្រមូលគ្នាដោយកាន់អាវុធ (armed gatherings on public road) ឬបទប្រឆាំងនឹងអាជ្ញាធរសាធារណៈ (rebellion) មិនទាន់គ្រប់គ្រាន់ដើម្បីចាត់ទុកថាជាកុបកម្មនោះទេប៉ុន្តែការប្រជុំបាតុកម្មនោះត្រូវបង្កើតឲ្យចេញជាការបះបោរពិតប្រាកដមានលក្ខណៈសឹងតែទូទៅប្រឆាំងនឹងអាជ្ញាធររដ្ឋាភិបាល ជាការធ្វើវិទ្ធង្សនាដែលពាក់ព័ន្ធនឹងប្រជាករចំនួនច្រើន[56]។

ពួកអ្នកធ្វើអត្ថាធិប្បាយបារាំងយល់ឃើញថា ការបះបោរនេះទាមទារឲ្យមានចេតនាជាក់លាក់ដើម្បីធ្វើវិទ្ធង្សនា ដោយសារថាអត្ថបទនៃមាត្រាស្តីពីការបះបោរនេះមានប្រើពាក្យ "អ្នកបះបោរ" (insurgés) ពាក្យ "ធានាផ្តល់ភស្តុភា" (subsistance) ដល់អ្នកបះបោរ គេគិតថាពាក្យទាំងនេះប្រើសម្រាប់យោធាជាជាងសម្រាប់ការផ្តល់ស្បៀងស៊ីវីល[57](ravitaillement civil)។

ពាក្យ"ស្ថាប័ន"នៃសាធារណរដ្ឋដែលពោលនៅក្នុងមាត្រា ៥១២-៣ នៃក្រមព្រហ្មទណ្ឌថ្មីបារាំងមានឫសគល់ចេញមកពីមាត្រា ៨៦ និង ៨៧ ស្តីពីឧបឃាត និងការរួមគំនិតក្បត់នៃក្រមព្រហ្មទណ្ឌចាស់ដែលការពារទល់នឹងអំពើដែលមានគោលបំណង "បំផ្លាញ ឬផ្លាស់ប្តូររបបធម្មនុញ្ញ" ដែលជាការផ្លាស់ប្តូររបបនយោបាយ ដូចជាប្រវត្តិសាស្ត្របារាំងបានបង្ហាញមកពីការបន្តរបបរាជាធិបតេយ្យ របបអធិរាជាណាចក្ររបបប្រជាធិបតេយ្យប្រជាមានិត ក៏ដូចជាការធ្វើឲ្យប៉ះពាល់ដល់តុល្យភាពអំណាចដែលកើតចេញពីដំណើរការប្រជាធិបតេយ្យ (ដូចជាការបំបាត់អង្គចាស់ឬការបង្កើតអង្គថ្មី ពង្រឹងអំណាចអង្គខ្លះធ្វើឲ្យខូចដល់អង្គផ្សេងទៀត) នៅក្នុងក្របខ័ណ្ឌនៃរបបដដែល[58]។ ការធ្វើឲ្យប៉ះពាល់ដល់បូរណភាពទឹកដីរាប់បញ្ចូលចលនាបំបែករដ្ឋ ឬការផ្តាច់ទឹកដីរបស់ប្រទេសខ្លួនទៅចូលជាមួយប្រទេសដទៃទៀត[59]។

## ២. និយមន័យ

និយមន័យនៃអំពើកុបកម្ម (ឬការបះបោរក្នុងភាសាសាមញ្ញ) មានចែងនៅក្នុង មាត្រា ៤៥៦ និង ៤៥៧ នៃក្រមព្រហ្មទណ្ឌខ្មែរ។ មាត្រាទាំងនេះជាការបកប្រែចេញពីមាត្រា ៤១២-៣ និង មាត្រា ៤១២-៤ នៃក្រមព្រហ្មទណ្ឌបារាំង។ មាត្រា ៤៥៦ ខ្មែរឲ្យនិយមន័យនៃអំពើកុបកម្មយ៉ាងដូច្នេះ ៖

---

[55] Sénat, Débats parlementaires, Journal Official de la République Française, Compte Rendu Intégral, 12e Séance jeudi 23 avril 1992, p. 798. អាចរកមើលបាននៅ http://www.senat.fr/comptes-rendus-seances/5eme/pdf/1992/04/s19920423_0779_0877.pdf

[56] អត្ថាធិប្បាយនេះអាចរកឃើញនៅក្នុងទំព័រ http://ledroitcriminel.free.fr/dictionnaire/lettre_i/lettre_i_instin.htm

[57] Michèle-Laure Rassat, Droit penal special, Dalloz 2011, 6e edition, p. 889

[58] ប្រភពដូចខាងលើ p. 882

[59] ប្រភពដូចខាងលើ p. 883

កុបកម្មគឺជាអំពើហិង្សាជាសម្ូហភាព ដែលអាចនាំឲ្យមានគ្រោះថ្នាក់ដល់ស្ថាប័ននៃព្រះរាជាណាចក្រកម្ពុជា ឬនាំឲ្យមានការប៉ះពាល់ដល់បូរណភាពនៃដែនដីជាតិ។

ធាតុសំខាន់នៃកុបកម្មគឺ ៖

- ការធ្វើហិង្សាជាសម្ូហភាព
- គ្រោះថ្នាក់ដល់ស្ថាប័ននៃប្រទេសកម្ពុជា
- ប៉ះពាល់ដល់បូរណភាពដែនដីជាតិ

យោងតាមនិយមន័យខាងលើ បទល្មើសកុបកម្មជាប្រភេទបទល្មើសជាទម្រង់ ព្រោះវាមិនទាមទារឲ្យមានលទ្ធផលនៃអំពើទេ។ នៅក្នុងមាត្រានេះ គេសង្កេតឃើញការប្រើពាក្យ "**ដែលអាចនាំឲ្យមានគ្រោះថ្នាក់**"។ ជាភាសាបារាំង កុបកម្មជាហិង្សាសម្ូហភាពដែល "មានលក្ខណៈ" (de nature à) ធ្វើឲ្យគ្រោះថ្នាក់ដល់ស្ថាប័ន...។ មានន័យថា កុបកម្មជាអំពើមួយដែលបង្ហាញឲ្យមជ្ឈដ្ឋានខាងក្រៅឃើញថាអំពើដែលប្រព្រឹត្តនោះមាន"ភាពទំនង" (likelihood) ឬមាន"និន្នាការ"ទៅរកគ្រោះថ្នាក់ដល់ស្ថាប័នជាតិ ឬបូរណភាពទឹកដី។ ដូច្នេះ ដើម្បីដាក់ទោសអំពើនោះ វាមិនចាំបាច់ដល់អំពើនោះបានសម្រេចគោលដៅនៃអំពើទេ។ ឧទាហរណ៍ នៅក្នុងការប្រមូលផ្តុំគ្នាដើម្បីបិទកំពង់ផែពាណិជ្ជកម្មក្នុងគោលបំណងខ្ទប់ដង្ហើមសេដ្ឋកិច្ច ក្នុងគោលដៅធ្វើឲ្យរដ្ឋាភិបាលរលំដួល អំពើប្រមូលផ្តុំនេះមិនចាំបាច់ដល់រដ្ឋាភិបាលអស់ស្បៀង សេដ្ឋកិច្ចលែងដើរទើបគេអាចដាក់ទោសអ្នកប្រមូលផ្តុំនោះទេ។ ប៉ុន្តែ ពាក្យ"ទំនងជា" "មាននិន្នាការ" ជាពាក្យបង្កប់ន័យអត្តនោម័ត (subjective) ដែលនាំឲ្យមានការបកស្រាយផ្សេងគ្នាពីមនុស្សម្នាក់ទៅមនុស្សម្នាក់។ ឧទាហរណ៍ មនុស្សខ្លះមើលឃើញស្ថានការណ៍ធ្ងន់ធ្ងរ ទើបគិតថាមាននិន្នាការទៅរកគ្រោះថ្នាក់ មនុស្សខ្លះមើលឃើញស្ថានការណ៍បន្តិចបន្តួចថាជាស្ថានការណ៍ធ្ងន់ធ្ងរ។

ក្នុងឧទាហរណ៍ខាងលើ ថ្វីបើអំពើខ្ទប់កំពង់ផែជាអំពើ<u>អាច</u>ធ្វើឲ្យស្ថាប័នសេដ្ឋកិច្ច ឬរដ្ឋាភិបាលរលំនៅមានចំណុចមួយដែលត្រូវពិចារណា ៖ តើការបិទកំពង់ផែជាអំពើហិង្សា ឬជាបាតុកម្មអហិង្សា? ការឲ្យនិយមន័យនៃពាក្យហិង្សា គឺប្រែប្រួលពីមនុស្សមួយទៅមនុស្សមួយដែរ។ ជាទូទៅគេយល់ថាអំពើហិង្សាកើតមានលុះត្រាណាតែមានការប្រើកម្លាំងរូបវន្តក្រៅច្បាប់ ជារឿយៗអមដោយការខឹងក្រេវក្រោធ ដូចជាការប្រើអាវុធ ការប្រើកម្លាំង ក្នុងចេតនាធ្វើឲ្យខូចខាតអ្វីមួយ (Black's Law Dictionrary)។ល។

ថ្វីបើកុបកម្មខ្លួនឯងជាបទល្មើសដែលច្បាប់ដាក់ទណ្ឌកម្មចំពោះ<u>ការចូលរួម</u> និង<u>ការដឹកនាំ</u>ចលនាកុបកម្ម។ ទណ្ឌកម្មចំពោះការចូលរួមក្នុងចលនាកុបកម្មមានចែងនៅក្នុងមាត្រា ៤៥៧ រីឯទណ្ឌកម្មចំពោះការដឹកនាំចលនាកុបកម្មមានចែងនៅក្នុងមាត្រា ៤៥៩។ អ្នកចូលរួមទទួលទណ្ឌកម្ម (៧-១៥ ឆ្នាំពន្ធនាគារ) តិចជាងអ្នកដឹកនាំ (២០-៣០ ឆ្នាំពន្ធនាគារ)។

ដើម្បីឲ្យជនណាម្នាក់មានការទទួលខុសត្រូវខាងព្រហ្មទណ្ឌនៃកុបកម្ម តាមរយៈការចូលរួម ជាដំបូងត្រូវមានចលនាកុបកម្មសិន។ ចំពោះអ្នកដឹកនាំចលនាកុបកម្ម មនុស្សនេះជាអ្នកជំរុញឲ្យមានចលនាកុបកម្ម ឬជាអ្នកទទួលនាទីជាអ្នកដឹកនាំចលនាកុបកម្មដែលមានស្រាប់។ ដូច្នេះគេត្រូវកំណត់ថា អ្វីជាចលនាកុបកម្ម។

## ៣. ធាតុផ្សំនៃកុបកម្ម

### ក. ធាតុផ្សំសត្យានុម័ត

**ក.១ ការប្រើហិង្សា** ៖ គ្មាននិយមន័យ ឬការកំណត់ពីទំហំនៃអំពើហិង្សាដែលចូលជាធាតុផ្សំនៃកុបកម្មនោះទេ។ មានសំណួរចោទសួរថាតើការប្រើដំបង ឬកម្លាំងកាយ ឬអាវុធដែលមិនមែនជាអាវុធសង្គ្រាមអាចរាប់បញ្ចូលជាអំពើហិង្សាក្នុងន័យនៃបទល្មើសកុបកម្មបានដែរឬយ៉ាងណា ព្រោះថា តើអាវុធទាំងនោះមានអំណាចលុបលើអំណាចអាវុធបង្ក្រាបរបស់អាជ្ញាធរសាធារណៈ ឬធ្វើឲ្យគ្រោះថ្នាក់ធ្ងន់ធ្ងរដល់កម្លាំងសាធារណៈដែរឬទេ។ ឧទាហរណ៍ ហ្វូងបាតុករអាចប្រើដុំថ្មគប់ ឬចោលដំបងទៅលើប៉ូលីស តើអំពើហិង្សាបែបនេះអាចរាប់បញ្ចូលជាហិង្សាក្នុងន័យនៃកុបកម្មដែរឬទេ។

ដោយសារកុបកម្មជាអំពើស្រដៀងនឹងឧទ្ទាមដែលគំរាមកំហែងដល់សន្តិសុខនៃរដ្ឋ កុបកម្មជាចលនាមួយមិនមែនជាអំពើកើតឡើងដោយចៃដន្យ ឬកើតឡើងដោយប្រតិកម្មគ្រេវគ្រោធដូចមាននៅក្នុងបាតុកម្មមហាជននោះទេ។ កុបកម្មមានលក្ខណៈរៀបចំ ហេតុដូច្នេះហើយបានជាច្បាប់បារាំងដាក់ចំណងជើងថាជា "ចលនាបះបោរ" ឬ "ចលនាកុបកម្ម" (mouvement insurrectionnel)។ ដោយសារកុបកម្មជាចលនាសំដៅទៅផ្លាស់ប្តូរ ឬបំផ្លាញស្ថាប័នជាតិ ឬបំផ្លាញបូរណភាពទឹកដី គេអាចប្រដូចចលនានេះទៅនឹងពួកធ្វើសង្គ្រាមបះបោរ ឬក្រុមវិទ្ធង្សនាដែរ។

**ក.២ ហិង្សាជាសមូហភាព** ៖ ពាក្យសមូហភាពនាំមកនូវន័យនៃសកម្មភាពរួមគ្នាមានគោលដៅដូចគ្នាដើម្បីធ្វើឲ្យអន្តរាយដល់ស្ថាប័នរបស់ប្រទេស មិនមែនជាសកម្មភាពដាច់ដោយឡែកនិងឯករាជពីគ្នាទេ។ ម្នាក់ៗរួមចំណែកបង្កើតអំពើហិង្សាឲ្យបានទំហំមួយធំគ្រប់គ្រាន់ដែលអាចធ្វើការផ្លាស់ប្តូរ ឬបំផ្លាញស្ថាប័នរបស់ប្រទេស ឬផ្តាច់ដែនដីរបស់ប្រទេស។ ហិង្សាដែលពួកនេះប្រព្រឹត្តមានលក្ខណៈជាហិង្សាសង្គ្រាម ដូចដែលមាត្រា ៤៥៧ នៃក្រមព្រហ្មទណ្ឌខ្មែរបានរៀបរាប់ដូចតទៅនេះ ៖

- ការសង់គ្រឿងសម្រាប់បិទផ្លូវ ការសង់គ្រឿងការពារទល់នឹងចលនារបស់កម្លាំងសាធារណៈ (ដូចជាការកាត់ផ្លូវ ការដាក់មីន ការដាក់ចម្រូងអង្គប់ ការសង់បង់គ័រដើម្បីទប់ស្កាត់ការរំកិលកម្លាំងរបស់រដ្ឋាភិបាល)។
- ការបំផ្លាញអគារ ឬបបនីយភណ្ឌ (ដូចជាបំផ្លាញអគារសាធារណៈ ឬឯកជន ការបំផ្លាញស្ពាន រោងចក្រអគ្គសនី ទំនប់វារីអគ្គសនី ទំនប់ទឹក។ល។)។
- ការរាំងរាំងការដឹកជញ្ជូន ឬផ្គត់ផ្គង់ព័ស្តុភារឲ្យកុបករ។
- ការញុះញង់ឲ្យមានការប្រមូលផ្តុំកុបករ (ដូចជាការជ្រើសរើសមនុស្សឲ្យចូលធ្វើជាកុបករ ការអំពាវនាវជាសាធារណៈឲ្យចូលរួមក្នុងចលនាកុបកម្ម)។
- ការកាន់កាប់ ឬយកតាមខ្លួននូវអាវុធ និង គ្រាប់រំសេវ។
- ការតាំងខ្លួនជំនួសអាជ្ញាធរស្របច្បាប់។

ចំពោះការរាំងរាំងការដឹកជញ្ជូន ឬផ្គត់ផ្គង់ព័ស្តុភារឲ្យកុបករ គេមិនត្រូវច្រឡំជាមួយនឹងអ្នកដំណើរសុំរថយន្តជិះដើម្បីទៅកន្លែងបាតុកម្ម ឬការផ្តល់ស្បៀងក្នុងលក្ខណៈមនុស្សធម៌ទេ[60]។ ហើយអ្នកដែលកាន់

[60] ប្រភពដូចខាងលើ p. 890

អាវុធនៅក្នុងបាតុកម្មដែលក្លាយទៅជាអំពើកុបកម្ម ក៏មិនមែនមានន័យថាជាកុបករដែរ អាស្រ័យលើជននោះកាន់អាវុធដោយដឹងថាខ្លួនចូលរួមក្នុងចលនាវិទ្ធង្សនា[61]។

ចំពោះការតាំងខ្លួនជំនួសអាជ្ញាធរសាធារណៈ គេអាចសំគាល់បានដោយការពាក់លក្ខណសញ្ញាឯកសណ្ឋាន ការដណ្ដើមយកតួនាទីសាធារណៈ។ល។[62]

### ខ. ធាតុផ្សំអត្តនោម័ត

ដូចបានបង្ហាញនៅក្នុងផ្នែកខាងលើ "ប្រវត្តិនៃច្បាប់" កុបកម្មទាមទារឲ្យមានចេតនា ដូចជាបទល្មើសដទៃទៀតដែរ ហើយជាចេតនាជាក់លាក់ ឬចេតនាពិសេស។ មាត្រា ៤ នៃក្រមព្រហ្មទណ្ឌ ចែងថា "ពុំមានបទល្មើសទេ ប្រសិនបើគ្មានចេតនាប្រព្រឹត្ត"។ នៅក្នុងបទកុបកម្ម ចេតនាប្រព្រឹត្តគឺ ៖

1. ការបង្កគ្រោះថ្នាក់ដល់ស្ថាប័ននៃព្រះរាជាណាចក្រកម្ពុជា ឬ
2. ការធ្វើឲ្យប៉ះពាល់ដល់បូរណភាពដែនដីជាតិ។

ជាដំបូង គេត្រូវកំណត់ថា តើស្ថាប័នអ្វីដែលអ្នកប្រព្រឹត្តចង់បំផ្លាញឬផ្លាស់ប្ដូរដោយមធ្យោបាយផ្ទុយនឹងច្បាប់និងរដ្ឋធម្មនុញ្ញ ឬដីផ្នែកណាដែលអ្នកប្រព្រឹត្តចង់ធ្វើឲ្យបាត់បង់។ ចំពោះពាក្យ"**ស្ថាប័ននៃព្រះរាជាណាចក្រកម្ពុជា**"នេះ តើច្បាប់ចង់សំដៅដល់ស្ថាប័នកំពូលថ្នាក់ជាតិដែលបង្កើតឡើងដោយរដ្ឋធម្មនុញ្ញ (ដូចជារាជានិយម, អំណាចនីតិបញ្ញត្តិ, អំណាចប្រតិបត្តិ, អំណាចតុលាការ, ក្រុមប្រឹក្សាធម្មនុញ្ញ, ឧត្តមក្រុមប្រឹក្សានៃអង្គចៅក្រម រហូតដល់ទៅសមាជជាតិ, របបសេដ្ឋកិច្ចទីផ្សារសេរី, របបប្រជាធិបតេយ្យសេរីពហុបក្ស, ព្រះពុទ្ធសាសនា) ឬការិយាល័យមួយ ឬមន្ទីរមួយរបស់រដ្ឋាភិបាល ឬអង្គភាពរដ្ឋបាលមួយ (administrative unit)?។ បន្ទាប់មក តើអ្នកប្រព្រឹត្តមានចេតនាចង់បំផ្លាញ ឬធ្វើឲ្យខូចស្ថាប័ននោះដែរឬទេ ឬ គ្រាន់តែជាអំពើប្រព្រឹត្តដោយធ្វេសប្រហែស។

បើតាមន័យទូទៅ កាលណាគេនិយាយពីស្ថាប័ននៃប្រទេសមួយ មនុស្សទូទៅយល់ថាជាអំណាចធំៗ ដែលបង្កើតដោយរដ្ឋធម្មនុញ្ញ ឧទាហរណ៍ដូចជាក្រសួងការបរទេសនៃប្រទេសបារាំងបង្ហាញពីស្ថាប័នរបស់ប្រទេសនេះនៅលើវេបសាយរបស់ខ្លួនមាន ៖ (១) រដ្ឋធម្មនុញ្ញ, (២) ក្រុមប្រឹក្សាធម្មនុញ្ញ, (៣) ប្រធានាធិបតី, (៤) នាយករដ្ឋមន្ត្រី និងរដ្ឋាភិបាល, (៥) រដ្ឋសភា និងព្រឹទ្ធសភា, (៦) តុលាការទាំងពីរប្រភេទ, (៧) ភ្លេងជាតិ, និង (៨) ទង់ជាតិ[63]។

បើគេគិតថាអំពើកុបកម្មជាអំពើដែលនាំឲ្យមានគ្រោះថ្នាក់ដល់ស្ថាប័នជាតិ អំពើនោះជាអំពើគំរាមកំហែងដល់អាយុជីវិតប្រទេសជាតិដែរ។ តើអំពើបែបណាទៅដែលចាត់ទុកថាគំរាមកំហែងដល់អាយុជីវិតប្រទេសជាតិ? គ្មានលក្ខណៈវិនិច្ឆ័យគតិយុត្តដើម្បីវាស់វែងអំពើបែបនោះទេ។ គោលការណ៍សៀរ៉ាគូស (ជាគោលការណ៍ដែលបានបង្ហាញនៅក្នុងជំពូកស្ដីពីការញុះញង់) បានហៅអំពើមួយដែលគំរាមកំហែងអាយុប្រទេសជាតិថាជាអំពើដែល ៖

(ក) ប៉ះពាល់ដល់ប្រជាជនទាំងមូល និងប៉ះពាល់ដល់ទឹកដីទាំងមូល ឬមួយផ្នែករបស់ប្រទេស និង

---

[61] ប្រភពដូចខាងលើ

[62] ប្រភពដូចខាងលើ

[63] http://www.diplomatie.gouv.fr/fr/venir-en-france-22365/connaitre-la-france/institutions-vie-politique/institutions-et-vie-politique/article/les-institutions-francaises

(ខ)	គំរាមកំហែងបូរណភាពរូបវន្តនៃប្រជាជន ឯករាជ្យភាពនយោបាយ ឬបូរណភាពទឹកដីរបស់ប្រទេស ឬអត្ថិភាព ឬកិច្ចដំណើរការជាមូលដ្ឋាននៃស្ថាប័នដែលចាំបាច់ខានមិនបានដើម្បីធានា និងការពារសិទ្ធិទាំងឡាយដែលទទួលស្គាល់នៅក្នុង [កតិកាសញ្ញាស្តីពីសិទ្ធិពលរដ្ឋ និងសិទ្ធិនយោបាយ]

**គ.	ព្យសនកម្ម**

យោងតាមនិយមន័យនៃមាត្រា ៤៥៦ គ្រោះថ្នាក់ដល់ស្ថាប័នជាតិមិនចាំបាច់បានកើតឡើងជាក់ស្តែងដោយសារអំពើកុបកម្មនោះទេ (ដូចជាស្ថាប័នមួយត្រូវរំលាយ) ព្រោះមាត្រានេះសំដៅតែអ្វីដែល"*អាចនាំឲ្យមាន*"គ្រោះថ្នាក់។ ដូច្នេះអំពើទាំងឡាយណាដែល"*ទំនងខ្លាំង*"ជានាំឲ្យមានគ្រោះថ្នាក់ដល់ស្ថាប័នជាតិនោះអំពើកុបកម្មបានសម្រេចឡើងតាមនិយមន័យនៃច្បាប់នេះ។ ចំពោះបូរណភាពនៃដែនដីក៏ដូចគ្នាដែរ កុបកម្មអាចសម្រេចបានដោយពុំចាំបាច់ទាល់តែប្រទេសជាតិបានបាត់បង់ទឹកដីជាក់ស្តែងនោះទេ ព្រោះមាត្រា ៤៥៦ កំណត់ថាអំពើកុបកម្មជាអំពើដែល"*នាំឲ្យមានការប៉ះពាល់*"ដល់បូរណភាពដែនដី។ មាត្រា ៤៥៦ និយាយពីហានិភ័យ (risk) ដែលឆ្ពោះទៅរកការខូចខាតដល់ស្ថាប័នជាតិ និងហានិភ័យនៃការបាត់បង់ទឹកដីនៃប្រទេសជាតិ។

សំណួរចោទសួរថាតើគេកំណត់បានយ៉ាងណាអំពីហានិភ័យនៃគ្រោះថ្នាក់ ឬការបាត់បង់។ ការកំណត់ហានិភ័យនេះមានលក្ខណៈអត្តនោម័តណាស់។ អ្នកខ្លះមើលឃើញឧបទ្ទវហេតុបន្តិចបន្តួច អាចវាយតម្លៃថាជាស្ថានការណ៍ធ្ងន់ធ្ងរ។ អ្នកខ្លះវាយតម្លៃឃើញជាការគ្រោះថ្នាក់នៅពេលណាមានស្ថានការណ៍អូសបន្លាយ និងរកផ្លូវច្រកចេញមិនរួច។ មនុស្សផ្សេងគ្នាវាយតម្លៃស្ថានការណ៍ផ្សេងគ្នា។

ដូចបានពិពណ៌នានៅផ្នែកខាងដើម គោលបំណងនៃច្បាប់កុបកម្មបារាំងមានគោលបំណងគ្របដណ្តប់តែលើកាលៈទេសៈធ្ងន់ធ្ងរដែលប៉ះពាល់ដល់អាយុជីវិតរបស់ប្រទេសជាតិ។ ឧទាហរណ៍ បាតុកម្មមួយដែលទាមទារឲ្យផ្លាស់ប្តូរអ្វីមួយ និងដែលអូសបន្លាយនិងក្លាយទៅជាហិង្សានិងអនាធិបតេយ្យ ព្រមទាំងរារាំងមិនឲ្យយន្តការរដ្ឋបាលនៃប្រទេសដំណើរការបាន បាតុកម្មនេះប្រហែលជាធ្វើឲ្យប៉ះពាល់ដល់អាយុជីវិតរបស់ប្រទេសជាតិ។

## ៤.	បន្ទុកភស្តុតាង

ជាដំបូង ខាងចោទត្រូវបង្ហាញពីអត្ថិភាពនៃកុបកម្ម ៖

១. **អំពើហិង្សាជាសមូហភាព** ៖ ជាហិង្សាប្រព្រឹត្តឡើងដោយមនុស្សច្រើនគ្នា ដែលមានការប្រទាក់ក្រឡាគ្នា ពោលគឺមិនមែនប្រព្រឹត្តឡើងដោយបុគ្គលម្នាក់ៗ ដោយឯករាជ្យពីគ្នាទេ។ តាមលោក Vitu អំពើហិង្សានេះមានលក្ខណៈទូលំទូលាយ ដែលបង្កើតបានជាហានិភ័យមួយដល់ប្រទេសជាតិ។

២. **ហានិភ័យ**នៃគ្រោះថ្នាក់ដែលមានទៅលើស្ថាប័ននៃព្រះរាជាណាចក្រកម្ពុជា ឬហានិភ័យនៃការបាត់បង់បូរណភាពទឹកដី។ ការគំរាមកំហែងលើស្ថាប័ន ឬបូរណភាពទឹកដីត្រូវតែមានពិត មិនមែនតាមការស្មានទេ។

៣. **ចេតនា** ៖ ក្រុមអ្នកប្រើហិង្សាទាំងនោះមានចេតនាបំផ្លាញ ឬធ្វើឲ្យខូចខាតដល់ស្ថាប័ននៃប្រទេសកម្ពុជា ឬបូរណភាពទឹកដីកម្ពុជា។

បន្ទាប់មកខាងចោទត្រូវបង្ហាញពីការចូលរួម ឬការដឹកនាំចលនាកុបកម្មនៃជនជាប់ចោទតាមរយៈមធ្យោបាយនានាដែលពិពណ៌នានៅក្នុងមាត្រា ៤៥៧។

## ៥. មធ្យោបាយការពារ

ខាងជនជាប់ចោទអាចបង្ហាញពីភស្តុតាងនៃការគ្មានចេតនាធ្វើឲ្យគ្រោះថ្នាក់ដល់ស្ថាប័នជាតិ ឬបូរណភាពទឹកដី។

# ជំពូក ៧

# បទផ្សព្វផ្សាយនូវអត្ថាធិប្បាយដើម្បីធ្វើសម្ពាធលើយុត្តាធិការ

## ១. ប្រវត្តិនៃច្បាប់

នៅក្នុងប្រព័ន្ធច្បាប់ខំម៉ន់លរ មានច្បាប់មួយគេហៅថា "ការប្រមាថតុលាការ" (Contempt of court) ដែលជាច្បាប់ការពារកុំឲ្យមានការជ្រៀតជ្រែកដល់ចៅក្រមក្នុងការគ្រប់គ្រងវិស័យយុត្តិធម៌ និងការពារសេចក្តីថ្លៃថ្នូររបស់ចៅក្រម។ ដែលហៅថាប្រមាថ គឺជាអំពើមិនស្តាប់បង្គាប់ ឬធ្វើមិនដឹងមិនឮដោយចេតនាចំពោះបទបញ្ជារបស់តុលាការ ឬបញ្ចេញអាកប្បកិរិយាមិនត្រឹមត្រូវនៅក្នុងតុលាការ សកម្មភាពដែលជ្រៀតជ្រែកដល់ការអាចគ្រប់គ្រងយុត្តិធម៌ ឬដែលប្រមាថដល់សេចក្តីថ្លៃថ្នូរនៃតុលាការ[64]។

ការប្រមាថតុលាការទាក់ទងនឹងការរារាំងដំណើរការយុត្តិធម៌ ការធ្វើមិនឲ្យកិច្ចការរបស់តុលាការដំណើរការទៅបានត្រឹមត្រូវ ដូចជាការគំរាមកំហែងចៅក្រម សាក្សី ឬការមិនស្តាប់បញ្ជារបស់តុលាការឲ្យបង្ហាញភស្តុតាង។[65] នៅក្នុងប្រទេសកាន់ប្រព័ន្ធខំម៉ន់ល័រ ដូចជាប្រទេសកាណាដាជាដើម ការប្រមាថតុលាការចែកចេញជាពីរប្រភេទ ៖ ការប្រមាថបែបស៊ីវិល និងការប្រមាថបែបព្រហ្មទណ្ឌ[66]។

ការប្រមាថបែបស៊ីវិលជាការបំពានលើបទបញ្ជារបស់តុលាការ ឬការសម្តែងអាកប្បកិរិយាមិនត្រឹមត្រូវនៅចំពោះមុខតុលាការ ដូចជាមិនព្រមធ្វើតាមបញ្ជាតុលាការ នៅពេលដែលតុលាការបញ្ជាឲ្យធ្វើអ្វីមួយឧទាហរណ៍ មិនព្រមដាក់ឯកសារឲ្យតុលាការ នៅពេលដែលតុលាការបង្គាប់ឲ្យដាក់ ឬធ្វើអ្វីដែលតុលាការហាមមិនឲ្យធ្វើ[67]។ ដើម្បីបង្កើតបានជាបទល្មើសប្រមាថស៊ីវិល ចុងចោទត្រូវមានឆន្ទៈធ្វើអ្វីផ្សេងពីអ្វីដែលតុលាការបង្គាប់ឲ្យធ្វើ ឬមានឆន្ទៈមិនធ្វើនូវអ្វីដែលតុលាការតម្រូវឲ្យធ្វើ។ ការប្រមាថបែបស៊ីវិលមានដូចជាការមិនគោរពតាមសាលក្រមឲ្យសង សាលក្រមឲ្យថែរក្សាកូន[68]។ ការប្រមាថបែបរដ្ឋប្បវេណីនាំឲ្យមានការដាក់ពន្ធនាគារ ពិន័យជាប្រាក់ ការដកទ្រព្យមិនឲ្យកាន់កាប់[69]។

---

[64] ឯកសារចំណាងជើង ទស្សនៈ និងដើមកំណើតច្បាប់ស្តីពីការប្រមាថ អាចរកបានតាមរយៈគេហទំព័រ http://shodhganga.inflibnet.ac.in/bitstream/10603/3570/10/10_chapter%202.pdf

[65] ប្រភពដូចខាងលើ។

[66] ដកស្រង់ចេញពីអត្ថបទគោលការណ៍ណែនាំស្តីពីការមិនគោរពតាមអំណាចតុលាការ ក្រុមប្រឹក្សាតុលាការកាណាដា ខែឧសភា ឆ្នាំ២០១១, ទំ.១០, អាចរកបាននៅលើគេហទំព័រ៖ https://www.cjc-ccm.gc.ca/cmslib/general/Contempt_Powers_2001_with_Header.pdf

[67] ប្រភពដូចខាងលើ។

[68] Michael Chesterman, 46 Int'l Comp. L.Q 521 1997, p.542.

[69] ប្រភពដូចគ្នា ទំ. ៥៤៣។

ការប្រមាថបែបព្រហ្មទណ្ឌ គឺជាបទល្មើសព្រហ្មទណ្ឌនៃអំពើមនុស្សម្នាក់ ដែលមិនគោរពជាសាធារណៈនូវបញ្ជាតុលាការ ឬជួយជ្រោមជ្រែងអ្នកដទៃឲ្យមិនគោរពបញ្ជាតុលាការ ជាអ្នកដែលប៉ុនប៉ងជាសាធារណៈ ដើម្បីជ្រៀតជ្រែកតាមគ្រប់រូបភាពដល់ដំណើរការយុត្តិធម៌ដែលតុលាការត្រូវបំពេញ។[70] ឧទាហរណ៍ការសរសេរសំអុយចៅក្រមជាសាធារណៈដើម្បីឲ្យសាធារណជនបាត់ជំនឿលើតុលាការ[71] ការធ្វើបុរេវិនិច្ឆ័យលើកិច្ចការរបស់តុលាការ រួមមានការផ្សាយដែលមាននិន្នាការពិត និងច្បាស់តែម្តងតាមសភាពជាក់ស្តែងដែលធ្វើឲ្យខូចខាតដល់សវនាការបច្ចុប្បន្ន ឬអនាគត[72] និងការប្រព្រឹត្តកោងកាចនៅចំពោះមុខតុលាការ ដូចជាសកម្មភាពបង្កវិបត្តិនៅពេលសវនាការ (គប់ចៅក្រម) ការជេរប្រមាថចៅក្រមនៅកណ្តាលសវនាការ[73]។

យោងតាមឯកសារមួយដែលដាក់បង្ហាញនៅក្នុងសិក្ខាសាលាស្តីពី"ការលើកស្ទួយសេរីភាពខាងការបញ្ចេញមតិ"ជាមួយនឹងអាណត្តិអន្តរជាតិពិសេស ថ្ងៃទី២៩-៣០ ខែវិច្ឆិកា ឆ្នាំ២០០០ តាមប្រព័ន្ធខំម៉ន់លរ បទល្មើសប្រមាថតុលាការអនុវត្តតែចំពោះការជ្រៀតជ្រែកទៅក្នុងនីតិវិធី**កំពុងដំណើរការ**ប៉ុណ្ណោះ ដូចជាការបោះពុម្ពផ្សាយរឿងដែលទំនងជាធ្វើឲ្យអន្តរាយដល់សិទ្ធិទទួលបានការកាត់ក្តីដោយត្រឹមត្រូវ ដែលការជ្រៀតជ្រែកបែបនេះធ្វើឲ្យគេមើលឃើញថា ជាការកាត់សេចក្តីមួយក្លាយទៅជាការកាត់សេចក្តីដោយសារព័ត៌មាន[74]។ ការប្រមាថរួមមាន ការផ្សាយដាក់សម្ពាធលើភាគីមួយឲ្យខ្លាចមិនហ៊ានចូលតុលាការ ការផ្សាយពីរឿងដែលច្បាប់មិនអនុញ្ញាតឲ្យបញ្ចូលជាភស្តុតាង ការផ្សាយដែលចោទថាជនជាប់ចោទម្នាក់មានពិរុទ្ធភាពមុនសវនាការចប់។

ការបង្កើតបទប្រមាថតុលាការនេះឈរលើមូលដ្ឋានបី ៖ **ទី១** ពលរដ្ឋត្រូវមានសិទ្ធិរកតុលាការដើម្បីឲ្យសម្រេចពីសិទ្ធិនិងកាតព្វកិច្ចរបស់គេ **ទី២** ពលរដ្ឋមានសិទ្ធិទទួលបានការសម្រេចដែលគ្មានការលំអៀងទៅរកភាគីណាមួយ ហើយសេចក្តីសម្រេចនោះផ្អែកតែលើអង្គហេតុដែលនាំមកបង្ហាញនៅមុខតុលាការប៉ុណ្ណោះ តាមនីតិវីធីផ្លូវច្បាប់មិនមែនតាមសម្រែករបស់ប្រភពក្រៅពីតុលាការទេ និង**ទី៣** នៅពេលដែលរឿងក្តីចូលដល់តុលាការហើយ ពលរដ្ឋត្រូវតែសង្ឃឹមថាគ្មានមនុស្សណាផ្សេងទៀតមកដណ្តើមយកមុខងាររបស់តុលាការ ដើម្បីនាំទៅរកលទ្ធផលណាមួយឡើយ[75]។

ការជ្រៀតជ្រែកជាពាក្យដែលមានន័យទូលំទូលាយ មានន័យថា តើការរាយការណ៍ ឬការអត្ថាធិប្បាយប៉ុនណាដែលហៅថាការជ្រៀតជ្រែកដែលសមល្មមត្រូវដាក់ទណ្ឌកម្ម។ ការបែងចែកមិនច្បាស់

---

[70] ដកស្រង់ចេញពីអត្ថបទ គោលការណ៍ណែនាំស្តីពីការមិនគោរពតាមអំណាចតុលាការ ក្រុមប្រឹក្សាតុលាការកាណាដា ខែឧសភា ឆ្នាំ២០១១ ទំ. ១១ អាចរកបានតាមរយៈគេហទំព័រ៖ https://www.cjc-ccm.gc.ca/cmslib/general/Contempt_Powers_2001_with_Header.pdf។

[71] Michael Chesterman, 46 Int’l Comp. L.Q 521 1997, p.530. ការសំអុយតុលាការមាន ៖ ការនិយាយបរិហារកេរ្តិ៍ ការចោទប្រកាន់ពីបទពុករលួយ ការគ្មានសុចរិតធម៌ ការមិនស្អាតស្អំ ឬការលំអៀង ការចោទប្រកាន់ថាចៅក្រមអោនទៅតាមបំណងរបស់បុគ្គលខាងក្រៅក្រុម ឬស្ថាប័នដាក់សម្ពាធ។

[72] ប្រភពដូចគ្នា ទំ. ៥៣៦។

[73] ប្រភពដូចគ្នា ទំ. ៥២៦។

[74] ដកស្រង់ចេញពីអត្ថបទសារតារស្តីពីសេរីភាពខាងការបញ្ចេញមតិ និងការមិនស្តាប់បង្គាប់របស់តុលាការ (សិក្ខាសាលាអន្តរជាតិស្តីពីការលើកកម្ពស់សិទ្ធិសេរីភាពខាងការបញ្ចេញមតិ និងអាណត្តិអន្តរជាតិពិសេស ក្នុងទីក្រុងឡុង ថ្ងៃទី២៩ ដល់ ថ្ងៃទី៣០ ខែវិច្ឆិកា ឆ្នាំ២០០០) ទំព័រ ៥ អាចមើលនៅលើគេហទំព័រ៖ http://www.article19.org/data/files/pdfs/publications/foe-and-contempt-of-court.pdf ។

[75] សេចក្តីដកស្រង់នៃយោបល់របស់តុលាការនៅក្នុងរឿងក្តី Attorney-General v. Time Newspaper Ltd. នៅក្នុងឯកសារក្នុងអត្ថបទ Background Paper on Freedom of Expression and Contempt of Court (International Seminar on Promoting Freedom of Expression With the Three Specialised International Mandates, London, 29-30 November 2000), p.5

លាស់រវាងការជ្រៀតជ្រែកដែលត្រូវយកចិត្តទុកដាក់ និងការជ្រៀតជ្រែកដែលត្រូវយកចិត្តទុកដាក់នាំឲ្យចោទជាបញ្ហាដល់សេរីភាពក្នុងការបញ្ចេញមតិ និងសេរីភាពក្នុងការផ្ដល់ព័ត៌មាន។

ដ្យាក្រាមខាងក្រោមបញ្ជាក់ពីផលប៉ះពាល់ទៅវិញទៅមក នៅពេលមានការពង្រីកដែនសេរីភាពនិងការរិតត្បិត។




ផលប្រយោជន៍នៃយុត្តិធម៌ត្រូវតែបានកំណត់ឲ្យបានសមរម្យ ដើម្បីឲ្យការអនុវត្តសេរីភាពនៃការបញ្ចេញមតិ សេរីភាពក្នុងការទទួលនិងការផ្ដល់ព័ត៌មានមិនត្រូវបានរិតត្បិតដោយទំនើងចិត្ត។

បញ្ហាជាក់ស្ដែងមានពីរ គឺ (១) តុលាការបំពេញមុខងាររបស់ខ្លួនដោយត្រឹមត្រូវ តែមានឥទ្ធិពលខាងក្រៅមកជ្រៀតជ្រែកធ្វើឲ្យដំណើរការយុត្តិធម៌នោះត្រូវបានរាំងស្ទះ ឬខូចខាត និង (២) តុលាការបំពេញការងាររបស់ខ្លួនមិនត្រឹមត្រូវដោយមានភាពលំអៀង និងគ្មានប្រសិទ្ធភាព ហើយមានសម្លេងខាងក្រៅរិះគន់ពីភាពលំអៀងនៃតុលាការ។ មានន័យថា ជួនកាលអត្ថាធិប្បាយមិនសមរម្យធ្វើឲ្យប៉ះពាល់ដល់ទំនុកចិត្តនៃសាធារណជនទៅលើតុលាការ ជួនកាលអត្ថាធិប្បាយសមរម្យ ឬមិនសមរម្យដែលមានគោលដៅបើកបង្ហាញពីភាពមិនត្រឹមត្រូវរបស់តុលាការត្រូវបានចាត់ទុកថាជ្រៀតជ្រែកដល់តុលាការ។ បទល្មើសប្រមាថតុលាការកាលពីសម័យមុនហាក់ដូចជាសន្មតជាមុនថា តុលាការជាស្ថាប័នស្អាតស្អំដែលគេមិនត្រូវបំពាន ដូច្នេះ អត្ថាធិប្បាយដែលប៉ះពាល់ដល់កិត្តិយសតុលាការត្រូវតែផ្ដន្ទាទោស។

ក្នុងសម័យបច្ចុប្បន្ននេះ មានមតិខ្លះគិតថា ស្ថាប័នតុលាការមិនមែនជាស្ថាប័នដែលគេប៉ះពាល់មិនបាននោះទេ។ ស្ថាប័នតុលាការត្រូវតែអាចគេធ្វើការរិះគន់បាន ដូចជាស្ថាប័នដទៃទៀតដែរ ឬនិយាយតាមរបៀបខ្មែរ គឺថាបើតុលាការជាមាសទឹកដប់ នោះតុលាការគ្មានអ្វីត្រូវខ្លាចភ្លើងទេ។ តទៅនេះជាសេចក្ដីសម្រេចរបស់តុលាការខ្លះ ដែលដកស្រង់ចេញពីឯកសារជាពត៌មានស្ដីពីសេរីភាពនៃការសំដែងចេញ និងការប្រមាថតុលាការ នៅក្នុងសវនាការអំពីការលើកស្ទួយសេរីភាពនៃការសំដែងចេញដោយមានអាណត្តិអន្តរជាតិឯកទេសបី (Background Paper on Freedom of Expression and Contempt of Court (International Seminar on Promoting Freedom of Expression With the Three Specialised International Mandates)៖

(១) នៅក្នុងរឿងក្តីមួយនៅអូស្ត្រាលី (NSW v. Mundey) អគ្គព្រះរាជអាជ្ញានិយាយថា ៖ "គ្មានហេតុផលអ្វីទាំងអស់ដែលថា ហេតុអ្វីបានជាអំពើរបស់តុលាការគេមិនគួររិះគន់ដោយគ្មានខ្លាចរអារដូចជាការរិះគន់លើអំពើរបស់ស្ថាប័នសាធារណៈនានា រួមមានសភាជាដើមដែរនោះ។ ការពិត គឺថាស្ថាប័នសាធារណៈនៅក្នុងសង្គមសេរីត្រូវឈរលើអំពើជាកុសលរបស់ខ្លួនផ្ទាល់ ៖ គេមិនអាចជ្រោងស្ថាប័នឲ្យឈរបានទេ បើអំពើរបស់ស្ថាប័នសាធារណៈទាំងនោះមិនទាក់ទាញសេចក្តីគោរព និងមានទំនុកចិត្តពីសហាគមន៍។ បើអំពើរបស់ស្ថាប័នសាធារណៈធ្វើឲ្យមានសេចក្តីគោរពនិងទំនុកចិត្តពីសហាគមន៍ ស្ថាប័ននោះមិនត្រូវការឲ្យមានវិធានពិសេសសម្រាប់ការពារខ្លួនទល់នឹងការរិះគន់ទេ"។

(២) នៅប្រទេសកាណាដា តុលាការឧទ្ធរណ៍ខេត្តអុងតារីយ៉ូសម្លេងភាគច្រើនមានមតិថា ៖ "ដោយសារសារៈសំខាន់របស់ខ្លួន តុលាការទាក់ទាញការធ្វើអត្ថាធិប្បាយ និងការរិះគន់។ ការធ្វើអត្ថាធិប្បាយ និងការរិះគន់ទាំងអស់មិនមែនសុទ្ធតែមានហេតុផលផ្អែមល្ហែមទេ។ គូក្តីដែលចាញ់អាចធ្វើអត្ថាធិប្បាយដែលប្រើពាក្យមិនពិរោះ។ ការរិះគន់ខ្លះអាចមានមូលដ្ឋានគ្រប់គ្រាន់។ គំនិតខ្លះដែលចង់ឲ្យមានការផ្លាស់ប្តូរគួរតែទទួលយក។ ប៉ុន្តែតុលាការមិនមែនជាផ្កាផុយស្រួយ ដែលនឹងស្វិតក្រញ៉ូមទៅតាមកម្តៅនៃភាពចម្រូងចម្រាស់នោះទេ... តុលាការបានដំណើរការមកល្អ និងមានប្រសិទ្ធិភាពនៅក្នុងពេលលំបាកនានា។ តុលាការទទួលបានការកោតសរសើរនៅក្នុងសហាគមន៍ ព្រោះគេសមនឹងទទួលសេចក្តីគោរព។ តុលាការមិនខ្លាចការរិះគន់ ហើយក៏មិនខ្លាចប្រឈមនឹងឧបសគ្គមិនចាំបាច់នៃការមិនសប្បាយចិត្តនឹងការងារ ឬសេចក្តីសម្រេចរបស់ខ្លួនដែរ"។

យោងតាមគំនិតខាងលើ គេគិតថាតុលាការមានសេចក្តីក្លាហាន ចេះគិតគូរដោយខ្លួនឯង និងមិនមែនរេទៅតាមខ្យល់នៃមតិសាធារណៈនោះទេ ដូច្នេះមិនចាំបាច់មានច្បាប់ការពារទប់ទល់នឹងការរិះគន់ពីមជ្ឈដ្ឋានខាងក្រៅទេ។

ប៉ុន្តែកតិកាសញ្ញាស្តីពីសិទ្ធិពលរដ្ឋ និងសិទ្ធិនយោបាយ ដែលប្រទេសខ្មែរបានធ្វើសច្ចាប័ន ចាត់ទុកថាច្បាប់ស្តីពីការប្រមាថតុលាការគឺជាការរិតត្បិតមួយដែលអនុញ្ញាតឲ្យធ្វើបាន។

នៅក្នុងកតិកសញ្ញាស្តីពីសិទ្ធិពលរដ្ឋនិងសិទ្ធិនយោបាយ សេរីភាពក្នុងការបញ្ចេញមតិ និងសេរីភាពក្នុងការទទួល និងផ្តល់ព័ត៌មាននៅក្នុងដំណើរការយុត្តិធម៌មិនដាច់ខាតទេ តែត្រូវបានថ្លឹងដោយកិច្ចការពារផលប្រយោជន៍យុត្តិធម៌។ មាត្រា ១៩ នៃកតិកាសញ្ញានោះបានចែងថា ៖

(១) មនុស្សម្នាក់ៗមានសិទ្ធិដើម្បីសម្តែងមតិដោយគ្មានការជ្រៀតជ្រែក

(២) មនុស្សម្នាក់ៗមានសិទ្ធិមានសេរីភាពខាងការបញ្ចេញមតិ។ សិទ្ធិនេះរួមមាន សេរីភាពដើម្បីស្វែងរក ទទួល និងផ្តល់ព័ត៌មាន និងគំនិតគ្រប់បែបយ៉ាងដោយមិនគិតពីព្រំដែន ជាពាក្យនិយាយ ជាពាក្យសរសេរ ឬជាការបោះពុម្ព ក្នុងទម្រង់ជាសិល្បៈ ឬតាមមធ្យោបាយដទៃទៀតតាមការជ្រើសរើសរបស់គេ។

ទន្ទឹមគ្នានេះ មាត្រា ១៤ នៃ កតិកាសញ្ញាដដែលក៏បានចែងថា ៖

(១) មនុស្សរាល់រូបមានសមភាពនៅចំពោះមុខតុលាការ និងសាលាជម្រះក្តី។ ... សារព័ត៌មាននិងសាធារណជនអាចមិនឲ្យចូលក្នុងសវនាការ...ក្នុងកម្រិតដែលចាំបាច់ដាច់ខាតក្នុងទស្សនៈរបស់តុលាការ នៅក្នុងកាលៈទេសៈពិសេស កាលណាការផ្សាយនឹងធ្វើឲ្យអន្តរាយដល់ផលប្រយោជន៍យុត្តិធម៌...

(២) មនុស្សម្នាក់ៗ... ត្រូវមានសិទ្ធិឲ្យគេសន្មតខ្លួនថាគ្មានទោសរហូតទាល់តែត្រូវបានបញ្ជាក់ភស្តុតាងថាមានទោសស្របតាមច្បាប់។

សេចក្តីអធិប្បាយទូទៅលេខ ៣២ របស់គណៈកម្មាធិការសិទ្ធិមនុស្សនៃអង្គការសហប្រជាជាតិបានពន្យល់ពីទស្សនាទាននៃការជំនុំជម្រះដោយយុត្តិធម៌ (Fair trial) ដែលថា ដើម្បីឲ្យការជំនុំជម្រះមួយបានប្រព្រឹត្តទៅដោយយុត្តិធម៌ តុលាការមិនត្រូវរងសម្ពាធបែបណាមួយពីមជ្ឈដ្ឋានខាងក្រៅឡើយ។ កថាខណ្ឌទី ២៥ នៃសេចក្តីអធិប្បាយនេះចែងថា ៖

> សញ្ញាណនៃការជំនុំជម្រះដោយយុត្តិធម៌រួមមាន ការធានាប់រងឲ្យមានសវនាការប្រព្រឹត្តទៅដោយយុត្តិធម៌ និងជាសាធារណៈ។ ភាពយុត្តិធម៌នៃនីតិវិធីចាំបាច់មិនត្រូវមានឥទ្ធិពលដោយផ្ទាល់ ឬដោយប្រយោល សម្ពាធ ឬការបំភិតបំភ័យ ឬ ការជ្រៀតជ្រែកពីខាងណាក៏ដោយ និងដោយសារមូលហេតុអ្វីក៏ដោយ។ សវនាការមិនប្រព្រឹត្តិទៅដោយយុត្តិធម៌ ឧទាហរណ៍ បើចុងចោទនៅក្នុងរឿងព្រហ្មទណ្ឌត្រូវប្រឈមមុខនឹងការបញ្ចេញឥរិយាបថរបៀបដូចជាសត្រូវពីសាធារណជន ឬការគាំទ្រភាគីមួយត្រូវបានអនុគ្រោះដោយតុលាការ...

កថាខណ្ឌទី ៣០ នៃសេចក្តីអធិប្បាយដដែលបន្តទៀតចំពោះការសន្មតនៃនិរទោស ៖

> ... អាជ្ញាធរសាធារណៈទាំងអស់មានករណីយកិច្ចចៀសវាងកុំឲ្យមានបុរេវិនិច្ឆ័យទៅលើលទ្ធផលនៃការជំនុំជម្រះ។ ឧទាហរណ៍ ចៀសវាងកុំនិយាយជាសាធារណៈដែលថា អ្នកនេះមានទោស ឬគ្មានទោស...សារព័ត៌មានត្រូវចៀសវាងការផ្សាយព័ត៌មានណាដែលបំផ្លាញដល់ការសន្មតនៃនិរទោស...

ដោយសារហេតុផលនៃការការពារផលប្រយោជន៍នៃដំណើរការយុត្តិធម៌ គណៈកម្មាធិការសិទ្ធិមនុស្សនៃអង្គការសិទ្ធិមនុស្ស តាមរយៈសេចក្តីអធិប្បាយទូទៅលេខ ៣៤ កថាខណ្ឌទី ២៤ ពិពណ៌នាថា រដ្ឋអាចធ្វើច្បាប់ស្តីពីការប្រមាថតុលាការបាន។ ប៉ុន្តែ ច្បាប់នោះក៏ត្រូវសរសេរយ៉ាងណាឲ្យមានភាពជាក់ច្បាស់គ្រប់គ្រាន់ (Precise) ដើម្បីឲ្យមនុស្សម្នាក់អាចតម្រង់ទិសអាកប្បកិរិយារបស់គេទៅតាមន័យនៃច្បាប់នោះ (កថាខណ្ឌទី ២៥)។ បើនិយាយពីច្បាប់ស្តីពីការប្រមាថតុលាការ ច្បាប់នោះត្រូវតែគូសព្រំដែនឲ្យបានច្បាស់ពីអ្វីដែលចាត់ចូល ឬមិនចាត់ចូលជាការជ្រៀតជ្រែកក្នុងដំណើរការយុត្តិធម៌។

ប្រទេសបារាំងមានច្បាប់ប្រមាថតុលាការមួយដែរ ដែលដាក់ទណ្ឌកម្មដល់ការជ្រៀតជ្រែកតុលាការក្នុងកំលុងពេលមុនធ្វើសេចក្តីសម្រេច។ មាត្រា ៤៣៤-១៦ នៃក្រមព្រហ្មទណ្ឌចែងថា ៖

> ការផ្សាយមុនសេចក្តីសម្រេចរបស់តុលាការចូលជាស្ថាពរ នូវសេចក្តីអធិប្បាយដែលសំដៅដាក់សម្ពាធក្នុងគោលបំណងជះឥទ្ធិពលដល់ចម្លើយរបស់សាក្សី ឬសេចក្តីសម្រេចរបស់ចៅក្រមស៊ើបសួរ ឬចៅក្រមជំនុំជំរះ ត្រូវផ្តន្ទាទោសដាក់គុកប្រាំមួយខែ និងពិន័យជាប្រាក់ ៧៥០០ អឺរ៉ូ។

យោងតាមយុត្តិសាស្ត្រនានានៃប្រទេសបារាំង ច្បាប់ "ផ្តន្ទាទោសតែសេចក្តីអធិប្បាយណាដែលបោះពុម្ពផ្សាយមុនអន្តរាគមន៍នៃសេចក្តីសម្រេចជាស្ថាពររបស់តុលាការក្នុងកម្រិតដែលសេចក្តីអធិប្បាយនោះសំដៅដាក់សម្ពាធលើសេចក្តីប្រកាសរបស់សាក្សី ឬសេចក្តីសម្រេចរបស់យុត្តាធិការស៊ើបសួរ ឬយុត្តាធិការជំនុំជម្រះ" (Crim. 15 mai 1961: Bull. Crim. No 257; Bull. Crim. No 388, 27 oct. 1992)។ មានន័យថា នៅពេលដែលតុលាការមិនទាន់ចេញសេចក្តីសម្រេចជាស្ថាពរ នៅក្នុងកំលុងពេលស៊ើបសួរ គេមិនអាចធ្វើអត្ថាធិប្បាយណាមួយ ដែលដាក់សម្ពាធលើសាក្សីឲ្យឆ្លើយខុសពីឆន្ទៈរបស់គេទេ។ ម្យ៉ាងវិញទៀត គេក៏មិនអាចធ្វើសេចក្តីអធិប្បាយដើម្បីគាបសង្កត់សេរីភាពនៃការដឹកនាំសវនាការរបស់ចៅក្រមដែរ។ ដើម្បី

វាយតម្លៃថា តើសេចក្តីអធិប្បាយមួយសំដៅដាក់សម្ពាធលើសាក្សី ឬតុលាការដែរឬទេនោះ តុលាការត្រូវពិនិត្យឲ្យដឹងថាតើ "ពាក្យសំដី និងទម្រង់នៃការអធិប្បាយនោះសំដៅដាក់សម្ពាធទាំងនោះ" ដែរឬទេ។

ច្បាប់បារាំងមួយទៀតដែលផ្តន្ទាទោសដល់ការរិះគន់តុលាការគឺមាត្រា ៤៣៤-២៥ ៖

> ការស្វែងរកបង្ខូចកិត្យានុភាពជាសាធារណៈ តាមរយៈអំពើ ពាក្យសំដី សំណេរ ឬ រូបភាព ដល់កិច្ច ឬសេចក្តីសម្រេចរបស់តុលាការ ក្នុងលក្ខខណ្ឌទៅរកការធ្វើឲ្យប៉ះពាល់ដល់អំណាច ឬឯករាជ្យភាពតុលាការ ត្រូវផ្តន្ទាទោសដាក់ពន្ធនាគារ ប្រាំមួយខែ និងពិន័យជាប្រាក់ ៧៥០០ អឺរ៉ូ។
> បទបញ្ញត្តិនៅក្នុងកថាខណ្ឌខាងលើមិនអនុវត្តចំពោះ ការធ្វើសេចក្តីអធិប្បាយបច្ចេកទេស អំពើ ការនិយាយ សំណេរ ឬរូបភាព ទោះក្នុងប្រភេទណាក្តី ដែលសំដៅដល់ការស្វែងរកការកែមោឃភាព ឬពិនិត្យឡើងវិញនូវសេចក្តីសម្រេចឡើយ។
> កាលណាបទល្មើសត្រូវបានប្រព្រឹត្តដោយសារព័ត៌មានដែលបោះពុម្ព ឬដោយមធ្យោបាយសោតទស្សន៍ បទបញ្ញត្តិពិសេសនៃច្បាប់ទាំងឡាយដែលគ្រប់គ្រងសាច់រឿងទាំងនោះ ត្រូវយកមកអនុវត្តក្នុងការកំណត់ជនដែលទទួលខុសត្រូវ។
> អាជ្ញាយុកាលត្រូវអស់ក្នុងរយៈពេលបីខែ រាប់ចាប់ពីថ្ងៃដែលបទល្មើសដែលកំណត់ក្នុងមាត្រានេះត្រូវបានប្រព្រឹត្ត បើសិនជា នៅក្នុងចន្លោះពេលនេះ មិនមានកិច្ចស៊ើបសួរ ឬចោទប្រកាន់ទេនោះ។

មាត្រានេះខុសពីមាត្រា ៤៣៤-១៦ ដោយប្តូរពីការដាក់សម្ពាធ មកជាការសំអុយកេរ្តិ៍ឈ្មោះ ដើម្បីធ្វើឲ្យប៉ះពាល់ដល់ឯករាជ្យភាពតុលាការ ក្នុងចេតនាអាក្រក់ ទោះបីនៅមុនពេលសម្រេចក្តី ឬក្រោយពេលសម្រេចក្តី។ ឧទាហរណ៍ (ក្នុងយុត្តិសាស្ត្របារាំង) ការនិយាយថាឲ្យចៅក្រមម្នាក់ថា "ជាស្នាដៃឯកខាងត្រឡប់ត្រឡិន និយាយផ្តេសផ្តាស រំលោភច្បាប់" គឺជាការសំដៅធ្វើឲ្យប៉ះពាល់ដល់អំណាចតុលាការ។ ការដែលប្រធានសហជីពផ្ញើទូរសារចោទប្រកាន់សេចក្តីសម្រេចរបស់តុលាការថាជា"យុត្តិធម៌ប្រកាន់វណ្ណៈ" ហើយថាចៅក្រមជា "ស្នាដៃកខ្វក់នៃឆ្នាំ និងឆ្កែបម្រើមូលធននិយម" គឺជាសំដីចោទប្រកាន់អំពីការលំអៀង។ ឧទាហរណ៍ ផ្សេងទៀតតាមយុត្តិសាស្ត្របារាំងដែលធ្វើឲ្យប៉ះពាល់ដល់អំណាច និងឯករាជ្យភាពរបស់តុលាការមានដូចជាការសរសេរអត្ថបទចោទប្រកាន់ចៅក្រមអំពីភាពលំអៀង ដោយប្រើពាក្យជ្រុលហួសហេតុដើម្បីបង្ហាញឲ្យគេឃើញថាជា "អយុត្តិធម៌តុលាការ"។

សរុបមកច្បាប់បារាំងផ្តន្ទាទោសចំពោះការធ្វើអត្ថាធិប្បាយណាដែលគាបសង្កត់សាក្សីនៅក្នុងដំណាក់ការស៊ើបសួរ ឬការគាបសង្កត់លើចៅក្រមនៅពេលដែលចៅក្រមនោះមិនទាន់ធ្វើសេចក្តីសម្រេចជាចុងក្រោយលើសាច់រឿងណាមួយ។ ច្បាប់ក៏ផ្តន្ទាទោសលើការបង្ខូចកេរ្តិ៍ឈ្មោះចៅក្រម ឬតុលាការ ទាក់ទងនឹងអំណាច ឬឯករាជ្យភាពតុលាការ។

យ៉ាងណាក្តី លក្ខណៈ និងទម្ងន់នៃសំដីនៅក្នុងការធ្វើអត្ថាធិប្បាយ ដែលត្រូវផ្តន្ទាទោសនៅតែជាបញ្ហាដែលពិបាកកំណត់។

បើពិចារណាដល់សេចក្តីអធិប្បាយលេខ ៣៤ ខាងលើ ដែលទាមទារឲ្យរដ្ឋជាសមាជិកគូសព្រំដែនឲ្យបានច្បាស់រវាងអ្វីដែលហៅថាការជ្រៀតជ្រែក និងការជ្រៀតជ្រែកទំហំប៉ុនណាដែលអាចផ្តន្ទាទោសបាននោះ ច្បាប់បារាំងខាងលើមិនបានបញ្ជាក់ពីលទ្ធផលនៃការជ្រៀតជ្រែកទេ ប៉ុន្តែច្បាប់នោះដាក់ទោសចំពោះអំពើណាដែល "**សំដៅ**" ដាក់សម្ពាធ ឬជះឥទ្ធិពល ឬធ្វើឲ្យប៉ះពាល់ ដែលពាក្យទាំងនេះត្រូវការយុត្តិសាស្ត្របន្ថែមទៀត ដើម្បីគូសព្រំដែនឲ្យបានកាន់តែច្បាស់ថាអ្វីដែលអាចនិយាយបាន ធ្វើបាន និងអ្វីដែលមិនគួរនិយាយ ឬធ្វើ។ ឧទាហរណ៍ ការថតរូបជនជាប់ចោទ ហើយឲ្យកាន់កាំភ្លើងធ្វើបង្ហាញឆាកប្លន់នៅក្នុង

ទូរទស្សន៍ នៅពេលរឿងក្តីមួយមិនទាន់ចាប់ផ្តើមស៊ើបអង្កេតផងនោះ គឺជាក់ច្បាស់ជាការប្រមែប្រមូលមតិសាធារណជនឲ្យជឿថា ជនជាប់ចោទនោះមានពិរុទ្ធភាពពីបទប្លន់។ ប៉ុន្តែបើកាសែតមួយរាយការណ៍ថា ជនជាប់ចោទនោះធ្លាប់បានប្រព្រឹត្តបទល្មើសប្លន់ពីមុន តើការរាយការណ៍ប៉ុណ្ណេះ អាចចាត់ទុកថាជាការជះឥទ្ធិពលដល់រឿងក្តីដែរឬទេ?។ ជួនកាលមនុស្សមានទស្សនៈខុសគ្នាចំពោះរឿងមួយ ៖ អ្នកខ្លះថាអ្វីដែលផ្សាយជាសាធារណៈអាចជះឥទ្ធិពលដល់ការគិតរបស់ចៅក្រម ព្រោះចៅក្រមខ្លាចការថ្កោលទោសពីសាធារណជន បើគេសម្រេចអ្វីដែលសាធារណជនមិនចង់បាន។ តែក៏មានអ្នកខ្លះនិយាយថា រឿងគ្រាន់តែលើកពីប្រវត្តិរបស់មនុស្សម្នាក់ វានឹងគ្មានឥទ្ធិពលដល់ការគិតរបស់ចៅក្រមទេ ព្រោះចៅក្រមធ្លាប់ប្រឈមនឹងរឿងដូច្នោះជាយូរមកហើយ។

ជាជាងផ្តន្ទាទោសលើលក្ខណៈនៃការជ្រៀតជ្រែក ច្បាប់អង់គ្លេសស្តីពីការប្រមាថតុលាការចង់សំដៅដល់**ទំហំនៃការជ្រៀតជ្រែក**។ ច្បាប់អង់គ្លេសចាត់ទុកបទល្មើសប្រមាថតុលាការជាបទល្មើសមួយដែលមានការទទួលខុសត្រូវដាច់ខាត បានន័យថា មិនទាមទារឲ្យមានលទ្ធផលទេ។ ប៉ុន្តែការជ្រៀតជ្រែកដែលត្រូវ ផ្តន្ទានោះ គឺសំដៅដល់ការជ្រៀតជ្រែកដែលបង្កើត**ហានិភ័យក្រាស់ក្រែល**នៃការលំអៀង ឬ**រាំងស្ទះធ្ងន់ធ្ងរ**ដល់ដំណើរការយុត្តិធម៌[76]។ ច្បាប់អង់គ្លេសចែងថា ៖

> វិធាននៃការទទួលខុសត្រូវដាច់ខាតអនុវត្តចំពោះតែការផ្សព្វផ្សាយណាដែលបង្កើតហានិ ភ័យក្រាស់ក្រែល ដែលធ្វើឲ្យដំណើរការរកយុត្តិធម៌នៅក្នុងរឿងក្តីមួយ ត្រូវបានរាំងស្ទះ ឬត្រូវបានធ្វើឲ្យលំអៀងយ៉ាងធ្ងន់ធ្ងរ"។

## ២. និយមន័យ

បទផ្សព្វផ្សាយនូវការអត្ថាធិប្បាយដើម្បីធ្វើសម្ពាធលើយុត្តាធិការមានវិសាលភាពគ្របដណ្តប់លើការគាបសង្កត់ចៅក្រមក្នុងការធ្វើសេចក្តីសម្រេចណាមួយ។ រីឯការអត្ថាធិប្បាយដែលគាបសង្កត់លើសាក្សីត្រូវស្ថិតនៅក្នុងមាត្រាដោយឡែកមួយទៀត។ បទល្មើសមួយទៀត គឺបទធ្វើឲ្យបាត់ជំនឿលើសេចក្តីសម្រេចរបស់តុលាការ ដែលមិនទាក់ទងនឹងឥទ្ធិពលទៅលើចៅក្រម ឬដំណើរការនីតិវិធីតុលាការទេ តែទាក់ទងនឹងសណ្តាប់ធ្នាប់សាធារណៈ ឬស្ថាប័នជាតិ។

> មាត្រា ៥២២ ៖ បទផ្សព្វផ្សាយនូវការអត្ថាធិប្បាយដើម្បីធ្វើសម្ពាធលើយុត្តាធិការ
>
> ការផ្សព្វផ្សាយមុនសេចក្តីសម្រេចជាស្ថាពររបស់តុលាការនូវអត្ថាធិប្បាយ ដោយមានគោលដៅធ្វើការគាបសង្កត់ទៅលើតុលាការដែលទទួលបណ្តឹង ដើម្បីជះឥទ្ធិពលទៅលើសេចក្តីសម្រេចរបស់តុលាការត្រូវផ្តន្ទាទោសដាក់ពន្ធនាគារពី ១ (មួយ) ខែ ទៅ ៦ (ប្រាំមួយ) ខែ និងពិន័យជាប្រាក់ពី ១០០.០០០ (មួយសែន) រៀល ទៅ ១.០០០.០០០ (មួយលាន) រៀល។
>
> មាត្រា ៥៤៩ ៖ បទផ្សព្វផ្សាយក្នុងគោលបំណងធ្វើការគាបសង្កត់លើសាក្សី
>
> ការផ្សព្វផ្សាយមុនសេចក្តីសម្រេចស្ថាពររបស់តុលាការនូវអត្ថាធិប្បាយ ដែលមានគោលបំណងធ្វើការគាបសង្កត់លើសាក្សីដើម្បីជះឥទ្ធិពលទៅលើសក្ខីកម្មរបស់សាក្សីនេះ ត្រូវផ្តន្ទាទោសដាក់ពន្ធនាគារពី ៦ (ប្រាំមួយ) ថ្ងៃ ទៅ ១ (មួយ) ខែ និងពិន័យជាប្រាក់ពី ១០.០០០ (មួយម៉ឺន) រៀល ទៅ ១០០.០០០ (មួយសែន) រៀល។

[76] សូមមើលអត្ថបទច្បាប់ Contempt of Court Act 1981 នៅទំព័រ៖ http://www.legislation.gov.uk/ukpga/1981/49

មាត្រា ៥២៣ ៖ បទធ្វើឲ្យបាត់ជំនឿលើសេចក្តីសម្រេចរបស់តុលាការ

អំពើរិះគន់លិខិត ឬសេចក្តីសម្រេចរបស់តុលាការ ក្នុងគោលដៅបង្កឲ្យមានភាពវឹកវរដល់សណ្តាប់ធ្នាប់សាធារណៈ ឬក៏បង្កឲ្យមានគ្រោះថ្នាក់ដល់ស្ថាប័ននៃព្រះរាជាណាចក្រកម្ពុជា ត្រូវផ្តន្ទាទោសដាក់ពន្ធនាគារពី ១ (មួយ) ខែ ទៅ ៦ (ប្រាំមួយ) ខែ និងពិន័យជាប្រាក់ពី ១០០.០០០ (មួយសែន) រៀល ទៅ ១.០០០.០០០ (មួយលាន) រៀល។

អំពើដែលមិនអនុវត្តសេចក្តីសម្រេចរបស់តុលាការ ត្រូវផ្តន្ទាទោសដូចគ្នានឹងទោសដែលមានចែងនៅក្នុងកថាខណ្ឌទី ១ ខាងលើ។

## ៣. ធាតុផ្សំនៃបទផ្សព្វផ្សាយនូវការអត្ថាធិប្បាយដើម្បីធ្វើសម្ពាធលើយុត្តាធិការ (មាត្រា ៥២២)

### ក. លក្ខខណ្ឌជាមុននៃបទល្មើស

លក្ខខណ្ឌជាមុនដែលត្រូវបំពេញដើម្បីធ្វើការចោទប្រកាន់ពីបទផ្សព្វផ្សាយនូវការអត្ថាធិប្បាយដើម្បីធ្វើសម្ពាធលើយុត្តាធិការ គឺការកំណត់នូវដំណាក់កាលណាដែលគេមិនអាចធ្វើអត្ថាធិប្បាយបាន។

ក.១ ដំណាក់កាលដែលត្រូវហាមឃាត់ការធ្វើអត្ថាធិប្បាយ ៖ ជារួម ទោះនៅក្នុងរឿងរដ្ឋប្បវេណីក្តី រឿងព្រហ្មទណ្ឌក្តី គេអាចបែងចែកដំណាក់ការនៃនីតិវិធីតុលាការជាដំណាក់កាលស៊ើបសួរ ការជំនុំជម្រះ និងដំណាក់ការឧទ្ធរណ៍ និងសារទុក្ខ។ មាត្រា ៥២២ ហាមឃាត់ការផ្សាយអត្ថាធិប្បាយដែលមានឥទ្ធិពលគាបសង្កត់ទៅលើតុលាការដែលទទួលបណ្តឹង មានន័យថា បើតុលាការដំបូង (តុលាការខេត្ត ក្រុង) ជាអ្នកទទួលបណ្តឹង ការធ្វើអត្ថាធិប្បាយទាក់ទងនឹងតុលាការថ្នាក់នេះត្រូវហាមឃាត់។ សំណួរដែលចោទចំពោះមាត្រានេះគឺ តើការធ្វើអត្ថាធិប្បាយអាចធ្វើបានដែរ ឬទេ បើសេចក្តីសម្រេចនៅតុលាការដែលទទួលបណ្តឹងត្រូវបានធ្វើរួចហើយ?។ ឧទាហរណ៍ តុលាការក្រុងភ្នំពេញ បានសម្រេចរឿងក្តីមួយរួចហើយ បន្ទាប់មក ភាគីមួយបានប្តឹងឧទ្ធរណ៍ រួចមានមនុស្សម្នាក់បានធ្វើអត្ថាធិប្បាយពីតុលាការភ្នំពេញ តើមាត្រា ៥២២ អាចអនុវត្តលើករណីនេះបានដែរ ឬទេ?។ មាត្រា ៥២២ មិនបានបែងចែកតុលាការជាដំណាក់ៗទេ ដោយគ្រាន់តែបញ្ជាក់ពីការ "គាបសង្កត់" តុលាការមុន"សេចក្តីសម្រេចជាស្ថាពរ"។ ពាក្យ "គាបសង្កត់" ទាក់ទងនឹង អត្ថាធិប្បាយណាមួយ ដែលមានបំណងសំដៅទៅរកលទ្ធផលអ្វីមួយ។ បើការធ្វើអត្ថាធិប្បាយធ្វើឡើង ក្រោយពីសេចក្តីសម្រេចណាមួយដែលបានធ្វើចប់សព្វគ្រប់ហើយនោះ គេមិនអាចនិយាយថា ការធ្វើអត្ថាធិប្បាយនោះមានការគាបសង្កត់ដើម្បីបង្កឲ្យមានលទ្ធផលអ្វីមួយបានទេ ព្រោះលទ្ធផលបានចេញរួចហើយ គឺ "សេចក្តីសម្រេច"។

មាត្រា ៥២២ ក៏មិនបានចែកដំណាក់កាលនៃនីតិវិធីនៅក្នុងតុលាការដែលបានទទួលបណ្តឹងនោះដែរ។ ឧបមាថា តុលាការព្រហ្មទណ្ឌ បានបញ្ចប់នីតិវិធីស៊ើបសួររួចហើយ ហើយមានមនុស្សម្នាក់ធ្វើអត្ថាធិប្បាយរិះគន់ចៅក្រមស៊ើបអង្កេត តើការរិះគន់អាចចាត់ជាអត្ថាធិប្បាយដែល "មានគោលដៅធ្វើការគាបសង្កត់ទៅលើ"ចៅក្រមស៊ើបសួរបានដែរ ឬទេ បើចៅក្រមនោះបានសម្រេចបិទការស៊ើបសួររួចទៅហើយនោះ?។ ការគាបសង្កត់អាចបង្កឲ្យមានលទ្ធផលបាន បើការគាបសង្កត់នោះត្រូវបានធ្វើចំពោះនីតិវិធីណាមួយដែលមិនទាន់បានចាប់ផ្តើម ឬកំពុងប្រព្រឹត្តទៅ។

## ខ. ធាតុផ្សំសត្យានុម័ត

ដើម្បីផ្ដន្ទាទោសពីបទផ្សព្វផ្សាយនូវការអត្ថាធិប្បាយដើម្បីធ្វើសម្ពាធលើយុត្តាធិការ អ្នកធ្វើអត្ថាធិប្បាយនោះត្រូវតែបានផ្សព្វផ្សាយសេចក្ដីអត្ថាធិប្បាយ។

ខ.១ <u>អត្ថាធិប្បាយ</u> ៖ ដែលហៅថាអត្ថាធិប្បាយ (Commentaires) គឺ ជាការបញ្ចេញគំនិតដែលកើតមកពីការវិនិច្ឆ័យតាមការយល់ឃើញខ្លួនឯងផ្ទាល់ ដោយមិនផ្អែកលើអង្គហេតុ។ [77] និយាយសរុបមក អត្ថាធិប្បាយ គឺជាការថ្លែងដោយគ្មានអង្គហេតុយកមកសំអាង។

ខ.២ <u>ការផ្សព្វផ្សាយ</u> ៖ អត្ថាធិប្បាយត្រូវតែបានផ្សព្វផ្សាយទៅដល់សាធារណជន។

## គ. ធាតុផ្សំអត្តនោម័ត

មាត្រា ៥២២ ចែងថា ការអត្ថាធិប្បាយមានគោលដៅធ្វើការគាបសង្កត់ទៅលើតុលាការដែលទទួលបណ្ដឹង។ ថ្វីបើមាត្រានេះ មិនទាមទារឲ្យមានលទ្ធផលជាការគាបសង្កត់ជាក់ស្ដែងទៅលើតុលាការក្ដី សភាពផ្លូវគំនិតរបស់អ្នកធ្វើអត្ថាធិប្បាយ ដែលគណនាទុកសម្រាប់គាបសង្កត់ត្រូវតែមានដើម្បីបញ្ជាក់ពីធាតុផ្សំអត្តនោម័តនៃបទល្មើសនេះ។ មានន័យថាជនជាប់ចោទត្រូវតែដឹងថាការអត្ថាធិប្បាយរបស់គាត់ពិតជាធ្វើការគាបសង្កត់តុលាការឲ្យធ្វើសេចក្ដីសម្រេចមួយដែលគេមិនចង់សម្រេច។ ការនិយាយច្រឡំ ឬការធ្វេសប្រហែសនៅក្នុងការធ្វើអត្ថាធិប្បាយ មិនអាចចាត់ទុកជាការគណនាទុកបានទេ។

បទល្មើសនៃការផ្សព្វផ្សាយនូវការអត្ថាធិប្បាយដើម្បីធ្វើសម្ពាធលើយុត្តាធិការ មិនទាមទារឲ្យមានលទ្ធផលជាការផ្លាស់ប្ដូរសេចក្ដីសម្រេចរបស់តុលាការដែលទទួលបណ្ដឹងទេ តែជាបទល្មើសដែលបង្ហាញពី <u>*និន្នាការ*</u> នៃការអត្ថាធិប្បាយ។ គេអាចប្រមាណពីអត្ថិភាពនៃនិន្នាការ ដោយពិនិត្យទៅលើថា តើសំដីរបស់ជនល្មើសធ្វើឡើងក្នុងគោលបំណងធ្វើឲ្យមានការផ្លាស់ប្ដូរឥរិយាបថរបស់ចៅក្រមចំពោះរឿងណាមួយដែរឬទេ។ ឧទាហរណ៍ នៅក្នុងការពិចារណាពីការលើកលែងទោសជនជាប់ចោទម្នាក់ ចៅក្រមមានឥរិយាបថថាមនុស្សដែលជាប់ចោទប្រហែលជាមានពិរុទ្ធភាព តែការធ្វើអត្ថាធិប្បាយមួយទំនងជាធ្វើឲ្យចៅក្រមប្ដូរជំហរ ឬឥរិយាបថរបស់ខ្លួនទៅជាថាគ្មានពិរុទ្ធភាពទៅវិញ។

ក្នុងជីវិតជាក់ស្ដែង គេពិបាកនឹងរកឧទាហរណ៍ណាមួយមកបង្ហាញពីពាក្យសំដីបែបណាដែលមាននិន្នាការផ្លាស់ប្ដូរឥរិយាបថចៅក្រម ក្រៅតែពីការគាបសង្កត់តាមរយៈការគំរាមកំហែងតាមផ្លូវចិត្ត ឬតាមផ្លូវកាយទៅលើចៅក្រម ឬការកៀងគរមតិសាធារណជនឲ្យជឿទៅតាមពាក្យអត្ថាធិប្បាយ ហើយបើចៅក្រមមិនប្ដូរឥរិយាបថតាមសាធារណជនទេ នោះចៅក្រមនឹងទទួលការតិះដៀល ឬស្អប់ពីសាធារណជន។

ចំពោះការវិភាគរបស់អ្នកណាម្នាក់ដែលផ្អែកលើអង្គហេតុ និងអង្គច្បាប់ តើគេអាចចាត់ទុកការវិភាគនោះមាននិន្នាការប្ដូរឥរិយាបថរបស់ចៅក្រមដែរឬទេ ព្រោះថាចៅក្រមមានការហ្វឹកហ្វឺន និងមានចំណេះដឹងពិតប្រាកដរបស់ខ្លួន? មានន័យថាចៅក្រមដែលទទួលការហ្វឹកហ្វឺនត្រឹមត្រូវ (ដូច្នេះមានទំនុកចិត្តខ្លួនឯងរឹងមាំ) អាចនឹងប្ដូរឥរិយាបថរបស់ខ្លួនទៅតាមការវិភាគនោះដែរឬទេ? ហើយចុះបើការវិភាគមានមូលដ្ឋានគ្រប់គ្រាន់ តើហេតុអ្វីចៅក្រមមិនអាចទទួលយកការវិភាគនោះហើយប្ដូរការគិតរបស់ខ្លួន? (ដូចករណីដែលតុលាការខ្លះទទួលយក "សារណាមិត្តតុលាការ" (Amicus Curiae) ដើម្បីជាជំនួយស្មារតីក្នុងការសម្រេចរបស់ខ្លួន)។

---

[77] Michèle-Laure Rassat, Droit pénal spécial, Dalloz, 6e édition, 2011, p.1020.

ដើម្បីកំណត់ថាអត្ថាធិប្បាយមួយ សំដៅធ្វើឲ្យមានការផ្លាស់ប្តូរឥរិយាបថរបស់ចៅក្រមនៅក្នុងសេចក្តីសម្រេចខ្លួននោះ គេអាចយកចៅក្រមជាសម្មតិកម្មមួយមកធ្វើតេស្តដើម្បី កំណត់ថា តើនៅក្នុងកាលៈទេសៈបែបហ្នឹងនោះចៅក្រមជាសម្មតិកម្មនោះទំនងជាទោរទៅតាមការអត្ថាធិប្បាយនោះដែរឬទេ?។

## ៤. ធាតុផ្សំនៃបទផ្សព្វផ្សាយក្នុងគោលបំណងធ្វើការគាបសង្កត់សាក្សី (មាត្រា ៥៤៩)

### ក. លក្ខខណ្ឌជាមុននៃបទល្មើស

លក្ខខណ្ឌជាមុនដែលត្រូវបំពេញដើម្បីធ្វើការចោទប្រកាន់ពីបទផ្សព្វផ្សាយក្នុងគោលបំណងគាបសង្កត់សាក្សី អនុវត្តនៅជំណាក់ការស៊ើបសួរ និងនៅតំណាក់ការជំនុំជម្រះ ក្នុងខណៈដែលសាក្សីនឹងត្រូវឆ្លើយនៅចំពោះមុខចៅក្រមស៊ើបសួរ និងចៅក្រមជំនុំជម្រះ ។

### ខ. ធាតុផ្សំសត្យានុម័ត

ដូចគ្នានឹងបទផ្សព្វផ្សាយនូវការអត្ថាធិប្បាយដើម្បីធ្វើសម្ពាធលើយុត្តាធិការដែរ បទផ្សព្វផ្សាយក្នុងគោលបំណងធ្វើការគាបសង្កត់សាក្សី ទាមទារឲ្យមានធាតុផ្សំសត្យានុម័ត"អត្ថាធិប្បាយ" និង ការផ្សព្វផ្សាយ" ទៅកាន់សាធារណជន។

### គ. ធាតុផ្សំអត្តនោម័ត

ដូចគ្នានឹងបទផ្សព្វផ្សាយនូវការអត្ថាធិប្បាយដើម្បីធ្វើសម្ពាធលើយុត្តាធិការដែរ បទផ្សព្វផ្សាយក្នុងគោលបំណងធ្វើការគាបសង្កត់សាក្សី ទាមទារឲ្យមានចេតនាដាក់សម្ពាធលើសាក្សី គឺចុងចោទត្រូវតែដឹងថាការអត្ថាធិប្បាយរបស់ខ្លួនពិតជាសំដៅដាក់សម្ពាធដល់សាក្សី។ ការនិយាយច្រឡំ ឬការធ្វេសប្រហែសនៅក្នុងការធ្វើអត្ថាធិប្បាយមិនអាចចាត់ទុកជាការគណនាទុកបានទេ។

ចំពោះនិន្នាការដើម្បីប្តូរឥរិយាបថសាក្សីនៅក្នុងការប្តូរ ឬប្រែប្រួលសក្ខីកម្មរបស់ខ្លួន គេត្រូវវិភាគថាទម្ងន់នៃការអត្ថាធិប្បាយទំនងជាធ្វើឲ្យមានការប្តូរឥរិយាបថរបស់សាក្សីដែរឬទេ (សូមមើលការវែកញែកនៅក្នុងធាតុផ្សំអត្តនោម័ត ក្នុងបទផ្សព្វផ្សាយនូវការអត្ថាធិប្បាយដើម្បីធ្វើសម្ពាធលើយុត្តាធិការខាងលើ)។

## ៥. ធាតុផ្សំនៃបទធ្វើឲ្យបាត់ជំនឿលើសេចក្តីសម្រេចរបស់តុលាការ (មាត្រា ៥២៣)

ថ្វីបើចំណងជើងនៃមាត្រា ៥២៣ នៃក្រមព្រហ្មទណ្ឌសំដៅដល់ការធ្វើអត្ថាធិប្បាយក្នុងគោលបំណងធ្វើឲ្យបាត់បង់ទំនុកចិត្តលើតុលាការ ផ្ទុយទៅវិញសេចក្តីនៃមាត្រាសំដៅដល់ការឆក់ឱកាសពីសេចក្តីសម្រេចរបស់តុលាការដើម្បីធ្វើឲ្យមានភាពវឹកវរដល់សណ្តាប់ធ្នាប់សាធារណៈ ឬឲ្យមានគ្រោះថ្នាក់ដល់ស្ថាប័នណាមួយនៃព្រះរាជាណាចក្រកម្ពុជាតាមរយៈការរិះគន់ដល់សេចក្តីសម្រេចរបស់តុលាការ។ នៅក្នុងក្រមព្រហ្មទណ្ឌបារាំង គេហាក់ដូចជាមិនឃើញមានបទល្មើសណាសមមូលនឹងបទល្មើសនេះទេ។ នៅក្នុងក្រមបារាំងមានបទល្មើសមួយដែលកៀកនឹងបទល្មើសនេះ គឺបទល្មើសដែលរិះគន់សេចក្តីសម្រេចរបស់តុលាការដើម្បីបង្ខូចដល់អំណាចតុលាការទាំងមូល (មាត្រា ៣៣៤-២៥) តែមិនមែនជាការរិះគន់ដើម្បីឲ្យអន្តរាយដល់សណ្តាប់សាធារណៈ ឬស្ថាប័នណាមួយរបស់ប្រទេសទេ[78]។ មាត្រា ៥២៣ នៃក្រមព្រហ្មទណ្ឌខ្មែរចែងថា ៖

[78] មាត្រា ៤៣៤-២៥ នៃក្រមព្រហ្មទណ្ឌបារាំងចែងថា៖ "ការស្វែងរកការបង្ខូចលិខិត ឬ សេចក្តីសម្រេចរបស់តុលាការ ដោយពាក្យសំដី សំណេរ ឬរូបភាព ក្នុងលក្ខខណ្ឌដែលនាំឲ្យខូចដល់អំណាចតុលាការ ឬឯករាជ្យភាពតុលាការ ត្រូវផ្តន្ទាទោសប្រាំមួយខែ និងពិន័យជាប្រាក់ ៧,៥០០អឺរ៉ូ។

អំពើរិះគន់លិខិត ឬសេចក្តីសម្រេចរបស់តុលាការក្នុងគោលដៅបង្កឲ្យមានភាពរឹករវដល់សណ្តាប់ធ្នាប់សាធារណៈ ឬក៏បង្កឲ្យមានគ្រោះថ្នាក់ដល់ស្ថាប័ននៃព្រះរាជាណាចក្រកម្ពុជា ត្រូវផ្តន្ទាទោសដាក់ពន្ធនាគារពី ១ (មួយ) ខែ ទៅ ៦ (ប្រាំមួយ) ខែ និងពិន័យជាប្រាក់ពី ១០០.០០០ (មួយសែន) រៀល ទៅ ១.០០០.០០០ (មួយលាន) រៀល។

អំពើដែលមិនអនុវត្តសេចក្តីសម្រេចរបស់តុលាការ ត្រូវផ្តន្ទាទោសដូចគ្នានឹងទោសដែលមានចែងនៅក្នុងកថាខណ្ឌទី ១ ខាងលើ។

## ក. លក្ខខណ្ឌជាមុននៃបទល្មើស

បទល្មើសដែលពិពណ៌នាពីខាងមុន (បទផ្សព្វផ្សាយនូវការអត្ថាធិប្បាយដើម្បីធ្វើសម្ពាធលើយុត្តាធិការ និងបទផ្សព្វផ្សាយក្នុងគោលបំណងធ្វើការគាបសង្កត់សាក្សី) ហាមប្រាមដល់អត្ថាធិប្បាយមុនពេលតុលាការធ្វើសេចក្តីសម្រេច និងមុនការបង្ហាញសក្ខីកម្មនៃសាក្សី ។ ផ្ទុយទៅវិញ បទល្មើសធ្វើឲ្យបាត់ជំនឿលើសេចក្តីសម្រេចរបស់តុលាការ អនុវត្តលើអត្ថាធិប្បាយដែលធ្វើឡើងក្នុងខណៈដែលតុលាការបានធ្វើសេចក្តីសម្រេចរួចហើយ។

## ខ. ធាតុផ្សំសត្យានុម័ត

ធាតុផ្សំនៃបទល្មើសនេះគឺជាការរិះគន់។ មាត្រានេះមិនបានបញ្ជាក់ពីភាពសាធារណៈនៃការរិះគន់ទេ។ តែទោះជាយ៉ាងណាក្តី ដោយសារការរិះគន់នេះទាក់ទងនឹងការទាក់ទាញឲ្យមានប្រតិកម្មពីសាធារណជន (ដូចជាការបង្កឲ្យមានការរឹករវដល់សណ្តាប់ធ្នាប់សាធារណៈ) គេអាចយល់បានថាការរិះគន់នេះជាការរិះគន់តាមមធ្យោបាយសាធារណៈ។ ដូច្នេះមាត្រានេះស្រដៀងគ្នានឹងការញុះញង់ដោយផ្ទាល់ និងជាសាធារណៈដែរ ព្រោះជាការសម្តែងគំនិតលើសេចក្តីសម្រេចរបស់តុលាការដែលអាចបង្កគ្រោះថ្នាក់ដល់សន្តិភាពសាធារណៈ (សូមមើលមាត្រា ៤៩៤ និង ៤៩៥) ព្រោះការរិះគន់នេះមិនចាំបាច់មានលទ្ធផលទេ គឺគ្រាន់តែមាននិន្នាការធ្វើឲ្យរឹករវជាសាធារណៈ ក៏នាំឲ្យមានការទទួលខុសត្រូវព្រហ្មទណ្ឌបានដែរ។

## គ. ធាតុផ្សំអត្តនោម័ត

ដូចគ្នានឹងបទល្មើសមុនៗដែរ បទធ្វើឲ្យបាត់ជំនឿលើសេចក្តីសម្រេចរបស់តុលាការទាមទារឲ្យមាន "**ចេតនា**" បង្កភាពរឹករវដល់សណ្តាប់ធ្នាប់សាធារណៈ ឬបង្កឲ្យមានគ្រោះថ្នាក់ដល់ស្ថាប័នជាតិ។ ដូច្នេះ ការរិះគន់ស្ថាបនា ឬការរិះគន់ដោយសុទ្ធចិត្ត មិនបានបង្ហាញពីចេតនាធ្វើឲ្យរឹករវដល់សណ្តាប់ធ្នាប់សាធារណៈ ឬធ្វើឲ្យគ្រោះថ្នាក់ដល់ស្ថាប័នជាតិទេ។

ទោះជាយ៉ាងណាក៏ដោយ អ្វីដែលគួរឲ្យបារម្ភអំពីមាត្រានេះ គឺការឲ្យនិយមន័យនៃសណ្តាប់ធ្នាប់ និងស្ថាប័នជាតិ។ ពាក្យពីរនេះមានន័យទូលំទូលាយ ដែលងាយឲ្យគេភ្ជាប់ទំនាក់ទំនងរវាងការរិះគន់ (ដែលជាហេតុ) និងសណ្តាប់ធ្នាប់សាធារណៈ និងស្ថាប័នជាតិ (ដែលជាផល)។ ឧទាហរណ៍ ការរិះគន់លើសេចក្តី

---

បទបញ្ញត្តិនាំកថាខណ្ឌខាងលើមិនអនុវត្តចំពោះអត្ថាធិប្បាយបច្ចេកទេស, អំពើ, ពាក្យសំដី, សំណេរ, ឬរូបភាពគ្រប់ប្រភេទដែលស្វែងរកការកែប្រែ [réformation] ការបដិសេធ [cassation] [ដោយតុលាការកំពូល] ឬ ការសើរើ [révision] នៃសេចក្តីសម្រេចទេ។"

កំណត់អ្នកនិពន្ធ៖ ពាក្យ "កែប្រែ" ខាងលើស្មើនឹងពាក្យបារាំង "réformation" ដែលមានន័យថាសាលាឧទ្ធរណ៍ធ្វើមោឃភាពសាលក្រមនៃតុលាការដំបូង និងចេញសាលដីកាខ្លួនឯងជំនួសវិញ។ យោងតាម៖ http://www.justice-en-ligne.be/article66.html ។ ចំណែកពាក្យ សើរើ (Révision) គឺជានីតិវិធីសើរើរបស់តុលាការកំពូល ដែលពិនិត្យឡើងវិញនូវសេចក្តីសម្រេចរបស់តុលាការដែលបានចូលជាស្ថាពរហើយ។

សម្រេចរបស់តុលាការ **(ហេតុ)** នៅក្នុងរឿងក្ដីជម្លោះដីធ្លីរវាងសហគមន៍មួយ និងក្រុមហ៊ុនមួយដែលអាចញ៉ាំងឲ្យសហគមន៍ដែលទទួលរងផលប៉ះពាល់ពីសេចក្ដីសម្រេចនោះរំជួលចិត្ត ហើយអាចប្រមូលគ្នាធ្វើបាតុកម្មប្រឆាំងនឹងសេចក្ដីសម្រេចនោះ **(ផល)** អាចធ្លាក់ចូលក្នុងការបកស្រាយថា ការធ្វើបាតុកម្មនេះជាការបង្កភាពវឹកវរដល់សណ្ដាប់ធ្នាប់សាធារណៈ ក្នុងខណៈដែលសិទ្ធិធ្វើបាតុកម្មត្រូវបានការពារដោយរដ្ឋធម្មនុញ្ញ។

## ៤. បន្ទុកភស្តុតាង

បទល្មើសទាំងបីខាងលើជាបទល្មើសដែលមិនទាមទារឲ្យមានលទ្ធផលទេ តែជាបទល្មើសដែលបង្ហាញពីនិទ្ទាការនៃអំពើ (ធាតុផ្សំសត្យានុម័ត)។ តាមប្រព័ន្ធច្បាប់បារាំងបទល្មើសទាំងនេះគេហៅថាបទល្មើសដែលមានជាទម្រង់ ឬ Infractions formelles។ ខាងចោទមិនចាំបាច់បង្ហាញពីលទ្ធផលដែលកើតចេញពីការអត្ថាធិប្បាយ ឬការរិះគន់ទេ។ ខាងចោទមានកាតព្វកិច្ចក្នុងការបង្ហាញពីអត្ថិភាពនៃអត្ថាធិប្បាយ និងចេតនា។

នៅក្នុងបទល្មើសខាងលើគេត្រូវបង្ហាញពីចេតនា ៖

១. ក្នុងការប្រើឥទ្ធិពលដើម្បីផ្លាស់ប្ដូរឥរិយាបថរបស់ចៅក្រម នៅក្នុងរឿងដែលចៅក្រមបម្រុងសម្រេច (មាត្រា ៥២២)។ ក្នុងករណីនេះខាងចោទត្រូវបង្ហាញថាតើលក្ខណៈ និងខ្លឹមសារនៃការអត្ថាធិប្បាយបែបហ្នឹង ទំនងជាជះឥទ្ធិពលលើឥរិយាបថរបស់ចៅក្រមដែរ ឬទេ?

២. ក្នុងការប្រើឥទ្ធិពលដើម្បីផ្លាស់ប្ដូរឥរិយាបថរបស់សាក្សីនៅក្នុងរឿងដែលសាក្សីបម្រុងនឹងថ្លែង ឬផ្ដល់សក្ខីកម្ម (មាត្រា ៥៤៩)។ ក្នុងករណីនេះខាងចោទ ត្រូវបង្ហាញថាតើលក្ខណៈ និងខ្លឹមសារនៃការអត្ថាធិប្បាយបែបហ្នឹង ទំនងជាជះឥទ្ធិពលលើឥរិយាបថរបស់សាក្សីដែរ ឬទេ?

៣. ក្នុងការបង្កឲ្យមានភាពវឹកវរសង្គម ឬគ្រោះថ្នាក់ដល់ស្ថាប័នជាតិ។ ក្នុងករណីនេះ ខាងចោទត្រូវបង្ហាញថា តើលក្ខណៈ និងខ្លឹមសារនៃការរិះគន់ទំនងជានាំឲ្យមានការបង្កភាពវឹកវរឬ គ្រោះថ្នាក់ដល់ស្ថាប័នជាតិដែរ ឬទេ?

ដោយសារបទល្មើសទាំងនេះមិនតម្រូវឲ្យបង្ហាញភស្តុតាងនៃលទ្ធផល គេពិបាកកំណត់ពីទំនាក់ទំនងរវាងអំពើ និងគោលបំណងនៃអំពើ។ ទំនាក់ទំនងនេះអាចកំណត់បានតែពីការស្មាន ឬការយល់ឃើញប៉ុណ្ណោះថា បើគេនិយាយដូច្នេះ លទ្ធផលនៃការនិយាយនោះប្រហែលជាដូច្នោះ។ បញ្ហាដែលចោទធំនោះគឺអ្នកណាជាអ្នកកំណត់ទំនាក់ទំនងនេះ ៖ ចៅក្រម? ដោយសារវាជាការស្មាន ឬជាការយល់ឃើញ តើចៅក្រមអាចកំណត់ទំនាក់ទំនងនោះដោយសត្យានុម័តបានដែរឬទេ?។

## ៥. មធ្យោបាយការពារ

ខាងចុងចោទអាចលើកពីការគ្មានចេតនាដើម្បីផ្លាស់ប្ដូរឥរិយាបថចៅក្រម ឬសាក្សី ឬគ្មានចេតនាបង្កភាពវឹកវរក្នុងសង្គម ឬធ្វើឲ្យគ្រោះថ្នាក់ដល់ស្ថាប័នជាតិ។

ចុងចោទក៏អាចលើកពីគោលការណ៍នៃសុទ្ធចិត្ត និងផលប្រយោជន៍សាធារណៈនៃការធ្វើអត្ថាធិប្បាយដើម្បីបង្ហាញពីការគ្មានចេតនាប្រើការគាបសង្កត់ទៅលើតុលាការ។

# ជំពូក ៨

## សេចក្ដីជូនដំណឹងលេខ ៤៧៤, ៣៣០ និង ០៥២

### ១. ប្រវត្តិនៃសេចក្ដីជូនដំណឹងលេខ ៤៧៤, ៣៣០ និង ០៥២

នៅឆ្នាំ ១៩៩៤ ក្រសួងមហាផ្ទៃបានចេញសេចក្ដីជូនដំណឹងមួយលេខ ៤៧៤ ចុះថ្ងៃទី ៦ កក្កដា ១៩៩៤ ដើម្បីណែនាំប្រតិភូរាជរដ្ឋាភិបាលប្រចាំនៅរាជធានីភ្នំពេញ និងអភិបាលខេត្តទាំងអស់កុំឲ្យអាជ្ញាធរខេត្ត-រាជធានីសម្រេចអនុញ្ញាតឲ្យសមាគមបើកការិយាល័យរបស់ខ្លួននៅតាមខេត្ត-ក្រុងតទៅទៀតដោយឯកចិត្ត ប៉ុន្តែត្រូវឲ្យខេត្ត-ក្រុងទាំងនោះសុំយោបល់ពីក្រសួងមហាផ្ទៃជាមុនសិន។

ជាមួយគ្នានេះដែរ សេចក្ដីជូនដំណឹងដដែលបានណែនាំឲ្យខេត្ត-ក្រុងដែលមានទីស្នាក់ការសមាគមនៅទីនោះជូនដំណឹងទៅរដ្ឋអំណាចមូលដ្ឋានឲ្យបានជ្រាបជាមុន ៥ ថ្ងៃ មុនពេលសមាគមទាំងនោះធ្វើសន្និបាត សិក្ខាសាលា ឬការប្រជុំនានានៅក្នុងមូលដ្ឋាននោះ។

នៅឆ្នាំ ២០០៤ ក្រសួងមហាផ្ទៃចេញសេចក្ដីជូនដំណឹងមួយទៀតលេខ ៣៣០ ចុះថ្ងៃទី ១០ វិច្ឆិកា ២០០៤ ជូនដល់អភិបាលខេត្តពោធិសាត់ ដើម្បីណែនាំអភិបាលខេត្តនេះឲ្យអនុវត្តតាមសេចក្ដីនៃសេចក្ដីជូនដំណឹងលេខ ៤៧៤ ខាងលើ ដោយបញ្ជាក់ថា"សមាគម ឬអង្គការមិនមែនរដ្ឋាភិបាល ដែលបានចុះបញ្ជីនៅក្រសួងមហាផ្ទៃរួចហើយ មានបំណងបើកទីស្នាក់ការសាខារបស់ខ្លួននៅតាមបណ្ដាខេត្ត-ក្រុង ផ្សេងក្រៅពីខេត្ត-ក្រុង ដែលជាទីតាំងនៃទីស្នាក់ការកណ្ដាលរបស់សមាគម ឬអង្គការមិនមែនរដ្ឋាភិបាលនោះ ត្រូវដាក់ពាក្យស្នើសុំការអនុញ្ញាតពីក្រសួងមហាផ្ទៃ ឬអាជ្ញាធរខេត្ត-ក្រុង ដែលសាមីសមាគម ឬអង្គការមិនមែនរដ្ឋាភិបាលមានបំណងនឹងបោះទីតាំងធ្វើសកម្មភាពរបស់ខ្លួននោះ"។

សេចក្ដីជូនដំណឹងនេះមិនបានបញ្ជាក់ថា តើសមាគម ឬអង្គការមិនមែនរដ្ឋាភិបាលដែលសុំការអនុញ្ញាតបើកការិយាល័យនៅតាមខេត្ត ត្រូវសុំយោបល់ពីក្រសួងមហាផ្ទៃជាមុនសិនដូចជាសេចក្ដីជូនដំណឹងលេខ ៤៧៤ ឬយ៉ាងណានោះទេ។ ប៉ុន្តែសេចក្ដីជូនដំណឹងនេះ លើកយកសំដីនៃសេចក្ដីជូនដំណឹងលេខ ៤៧៤ ដដែលស្ដីពីសកម្មភាពដែលសមាគម ឬអង្គការមិនមែនរដ្ឋាភិបាលត្រូវធ្វើនៅមូលដ្ឋាន ដោយបញ្ជាក់ថា "សមាគម ឬអង្គការមិនមែនរដ្ឋាភិបាលណាដែលបានអនុញ្ញាតអោយតាំងទីស្នាក់ការនៅក្នុងខេត្ត-ក្រុងរួចហើយ ហើយមានបំណងបើកបង្រៀនវិជ្ជាជីវៈ បើកសន្និបាត ឬធ្វើសិក្ខាសាលា ឬធ្វើការប្រជុំនានា សមាគម ឬអង្គការមិនមែនរដ្ឋាភិបាលនោះ ត្រូវជូនព័ត៌មានទៅរដ្ឋអំណាចមូលដ្ឋានអោយបានជ្រាបរយៈពេល ០៥ ថ្ងៃជាមុន"។

សេចក្ដីជូនដំណឹងនេះត្រូវបានចម្លងជូនសាលាខេត្ត-ក្រុងទាំងអស់នៅទូទាំងប្រទេស។

នៅឆ្នាំ ២០០៨ ក្រសួងមហាផ្ទៃចេញសេចក្ដីជូនដំណឹងមួយទៀតលេខ ០៥២ ចុះថ្ងៃទី ១៤ មករា ២០០៨ ជូនដល់អភិបាលខេត្តស្ទឹងត្រែងដើម្បីណែនាំអភិបាលខេត្តនេះ និងអាជ្ញាធរគ្រប់ខេត្ត-ក្រុងស្ដីពីការរៀបចំវេទិការបស់សមាគម និងអង្គការក្រៅរដ្ឋាភិបាល ដោយតម្រូវឲ្យអាជ្ញាធរខេត្ត-ក្រុងណែនាំបន្តដល់សមាគម ឬអង្គការក្រៅរដ្ឋាភិបាលឲ្យជូនដំណឹងដល់អាជ្ញាធរខេត្ត-ក្រុងពីការរៀបចំវេទិកាសម្ដែងមតិ ដោយជូនភ្ជាប់ពីប្រធានបទ ទីកន្លែងនិងពេលវេលានៃវេទិកានោះ។ សេចក្ដីជូនដំណឹងតម្រូវឲ្យអាជ្ញាធរការពារ

សន្តិសុខ និងសុវត្ថិភាពដល់វេទិកាសម្តែងមតិ។ សេចក្តីជូនដំណឹងថ្លែងថា វិធានការនេះធ្វើឡើងដើម្បីគោរពតាមស្មារតីនៃ មាត្រា ១៩ និង ២១ នៃកតិកាសញ្ញាស្តីពីសិទ្ធិពលរដ្ឋ និងសិទ្ធិនយោបាយ ព្រមទាំងមាត្រា ៤១ នៃរដ្ឋធម្មនុញ្ញកម្ពុជា។ ដូចគ្នានឹងសេចក្តីជូនដំណឹងពីរមុនដែរ សេចក្តីជូនដំណឹងនេះត្រូវបានចម្លងជូនសាលាខេត្ត-ក្រុងទាំងអស់នៅទូទាំងប្រទេស។

## ២. ការអនុវត្តសេចក្តីជូនដំណឹង

តើសេចក្តីជូនដំណឹងជាសេចក្តីណែនាំ ឬជាកាតព្វកិច្ចដែលដាក់បង្គាប់លើអាជ្ញាធរខេត្ត-ក្រុង និងសមាគម និងអង្គការក្រៅរដ្ឋាភិបាល?

ក្នុងឋានៈជាលិខិតរដ្ឋបាល អាជ្ញាធរដែលនៅក្រោមបង្គាប់ក្រសួងមហាផ្ទៃមានកាតព្វកិច្ចត្រូវគោរពតាមលិខិតនោះ ព្រោះវាជាការណែនាំដល់អាជ្ញាធរនៅក្រោមបង្គាប់ យ៉ាងហោចណាស់ឲ្យអនុវត្តគោលការណ៍របស់ក្រសួង(ថ្វីបើមិនមែនជាច្បាប់ក្តី)។ ការមិនគោរពតាមនាំឲ្យមានវិធានការរដ្ឋបាលទៅលើអាជ្ញាធរដែលមិនគោរព។

ចំពោះសមាគម និងអង្គការក្រៅរដ្ឋាភិបាលវិញ លិខិតនេះមិនមានកម្លាំងច្បាប់ដែលអាចចាប់បង្ខំឲ្យខ្លួនចាំបាច់ត្រូវតែគោរពតាមទេ។ សមាគម និងអង្គការក្រៅរដ្ឋាភិបាលអាចជំទាស់នឹងលិខិតនោះ បើគេយល់ថា លិខិតនោះរំលោភលើសិទ្ធិរបស់គេ ប៉ុន្តែការនេះត្រូវធ្វើតាមនីតិវិធីច្បាប់។

វិវាទអាចកើតឡើងរវាងអាជ្ញាធរខេត្ត-ក្រុង និងសមាគម និងអង្គការក្រៅរដ្ឋាភិបាលលើចំណុចថា ខាងអាជ្ញាធរខេត្ត-ក្រុងត្រូវធ្វើយ៉ាងណាឲ្យការណែនាំរបស់ក្រសួងមានប្រសិទ្ធភាព ចំណែកខាងសមាគម និងអង្គការក្រៅរដ្ឋាភិបាលយល់ឃើញថា ការជូនដំណឹងទៅអាជ្ញាធរគឺជាការគួរសមចំពោះពួកគាត់ប៉ុណ្ណោះ ហើយមិនមែនជាកាតព្វកិច្ចផ្លូវច្បាប់ដែលខ្លួនត្រូវតែគោរពគ្រប់ពេលវេលានោះទេ ដោយសារពេលខ្លះកម្មវិធីបង្រៀនប្រជាជនមូលដ្ឋានត្រូវបានធ្វើឡើងដោយប្រញាប់ប្រញាល់ និងដោយសារបញ្ហាការិយាធិបតេយ្យផង។

## ៣. ករណីដែលបានកើតឡើងទាក់ទងនឹងសេចក្តីជូនដំណឹងលេខ ៣៣០ និង ០៥២

នៅខែ សីហា ២០១១ មជ្ឈមណ្ឌលសិទ្ធិមនុស្សកម្ពុជា រួមសហការណ៍ជាមួយអង្គការការពារធនធានធម្មជាតិ បានបើកវគ្គបណ្តុះបណ្តាលនៅឃុំដងកាំបិត ស្រុកសណ្តាន់ ក្នុងខេត្តកំពង់ធំដល់ប្រជាពលរដ្ឋចំនួន ៧០នាក់មកពីខេត្តបីដើម្បីរៀនពីសិទ្ធិមនុស្ស និងការការពារធនធានធម្មជាតិ។ មេឃុំដងកាំបិតព្រមទាំងនគរបាលប្រដាប់អាវុធបានមកបញ្ឈប់ការបង្រៀននោះ តែអ្នករៀបចំកម្មវិធីមិនព្រមធ្វើតាម។ ពីរថ្ងៃក្រោយមកលោកមេឃុំព្រមទាំងនគរបាលច្រើនជាងមុនបានមកឃាត់ម្តងទៀត។ គាត់និយាយថា គាត់មិនមែនមកបញ្ឈប់ទេ តែគ្រាន់តែចង់បានកិច្ច



សហការពីអ្នករៀបចំកម្មវិធី គឺគេមិនបានជម្រាបអាជ្ញាធរឃុំជាមុន។ លោកអភិបាលស្រុកសណ្ដាន់បញ្ជាក់ថា អ្នករៀបចំត្រូវធ្វើតាមនីតិវិធី ហើយត្រូវជូនដំណឹងអាជ្ញាធរជាមុន។[79]

នៅខែកញ្ញា ឆ្នាំ២០១១ មជ្ឈមណ្ឌលសិទ្ធិមនុស្សកម្ពុជា និងអង្គការការពារធនធានធម្មជាតិ បានព្យាយាមបើកវគ្គបណ្តុះបណ្តាលម្តងទៀតនៅវត្តគីរីបុត្តារាមក្នុងឃុំដងកាំបិត ស្រុកសណ្ដាន់ តែត្រូវខកខានទៅវិញដោយសារព្រះចៅអធិការមិនអនុញ្ញាតឲ្យធ្វើនៅក្នុងវត្ត ព្រោះខាងប្រធានធម្មការស្រុកហាមមិនឲ្យធ្វើបើគ្មានការអនុញ្ញាតពីអាជ្ញាធរឃុំ ហើយលោកក៏មិនចង់ឃើញមេឃុំនាំនគរបាលមកបំបែកការបង្រៀនដូចលើកមុនដែរ[80]។ ការពិតនៅថ្ងៃទី ៣០ សីហា មជ្ឈមណ្ឌលសិទ្ធិមនុស្សកម្ពុជាបានដាក់លិខិតជូនដំណឹងដល់លោកអភិបាលខេត្តកំពង់ធំដើម្បីជម្រាបពីគម្រោងបង្រៀននៅឃុំដងកាំបិត និងឃុំមានឫទ្ធិនៅថ្ងៃទី ៧ ដល់ ៩ កញ្ញាដែរ។

ដោយសារព្រះចៅអធិការមិនអនុញ្ញាតឲ្យបង្រៀនក្នុងវត្ត អ្នករៀបចំកម្មវិធីគ្រោងនឹងរៀបចំកម្មវិធីនៅតាមផ្ទះអ្នកភូមិវិញ នៅក្នុងឃុំមានឫទ្ធិក្នុងស្រុកសណ្ដាន់ ខេត្តកំពង់ធំ ឲ្យដល់ប្រជាពលរដ្ឋមួយចំនួនមកពីខេត្តបួនគឺ ព្រះវិហារ ស្ទឹងត្រែង ក្រចេះ និង កំពង់ធំ ដើម្បីផ្សព្វផ្សាយពីសិទ្ធិមនុស្ស និងជាពិសេស សិទ្ធិលើធនធានធម្មជាតិ និងសិទ្ធិចិញ្ចឹមជីវិត។[81] សិក្ខាកាមទាំងនោះជាសកម្មជនការពារព្រៃឡង់។ នៅពេលនោះព្រៃឡង់ កំពុងទទួលការគំរាមកំហែងពីការកាប់ព្រៃឈើខុសច្បាប់។

នៅពេលចាប់ផ្តើមការបង្រៀន អភិបាលស្រុករង តម្រួតយោធា និងនគរបាលបានចូលមកក្នុងបន្ទប់បង្រៀនហើយបង្ខំឲ្យអ្នករៀបចំកម្មវិធីបញ្ឈប់ការបង្រៀនដោយសំអាងថា ការបង្រៀននោះគ្មានការអនុញ្ញាតពីអាជ្ញាធរខេត្ត។ អាជ្ញាធរគំរាមបិទការិយាល័យខេត្តរបស់អង្គការ បើពួកគេនៅតែទទឹងបន្តការបង្រៀននោះតទៅទៀត ដោយចោទថាសកម្មភាពរបស់គេទុកដូចជាការញុះញង់អ្នកភូមិឲ្យប្រឆាំងនឹងក្រុមហ៊ុនកៅស៊ូវៀតណាមឈ្មោះ ស៊ីអរស៊ីខេ[82]។ ក្រោយពីនោះមក មជ្ឈមណ្ឌលសិទ្ធិមនុស្សកម្ពុជាព្រមទាំងអង្គការលីកាដូ មជ្ឈមណ្ឌលអប់រំច្បាប់សម្រាប់សហគមន៍ និងការិយាល័យនៃឧត្តមស្នងការអង្គការសហប្រជាជាតិទទួលបន្ទុកសិទ្ធិមនុស្សនៅកម្ពុជា បានជួបជាមួយអភិបាលរងស្រុកសណ្ដាន់ ដែលនៅពេលនោះលោកអភិបាលរងបានព្រមានថា មជ្ឈមណ្ឌលសិទ្ធិមនុស្សកម្ពុជា និងក្រុមដទៃទៀតដែលគ្មានការិយាល័យនៅក្នុងខេត្តកំពង់ធំ មិនអាចធ្វើសកម្មភាពក្នុងខេត្តកំពង់ធំបានទៀតទេ បើគ្មានការអនុញ្ញាត ហើយក៏មិនអាចនាំប្រជាពលរដ្ឋពីខេត្តក្រៅមកបង្រៀននៅក្នុងខេត្តកំពង់ធំបានដែរ[83]។



[79] កាសែតភ្នំពេញប៉ុស្ដិ៍ ថ្ងៃទី ១១ សីហា ២០១១។

[80] គុជ ណារ៉ែន, កាសែត *ខេម បូឌាដេលី* ថ្ងៃទី ៧ កញ្ញា ២០១១ និង ម៉ៃ ទិត្យថារា, កាសែត *ភ្នំពេញប៉ុស្ដិ៍* ថ្ងៃទី ៧ កញ្ញា ២០១១។

[81] ព័ត៌មានលម្អិត សូមមើលគេហទំព័រ ៖ http://sithi.org/temp.php?url=photo_gallery1.php&parent_id=95&

[82] គុជ ណារ៉ែន, កាសែតខេមបូឌាដេលី ថ្ងៃទី ៧ កញ្ញា ២០១១។

[83] សេចក្តីប្រកាសព័ត៌មានរួម, មជ្ឈមណ្ឌលសិទ្ធិមនុស្សកម្ពុជា, លីកាដូ, មជ្ឈមណ្ឌលអប់រំច្បាប់សម្រាប់សហគមន៍, ថ្ងៃទី ៩ កញ្ញា ២០១១។ អាចរកឃើញក្នុងទំព័រ៖ http://sithi.org/temp.php?url=publication_detail.php&mid=4853&lg=

ក្នុងខែតុលា ឆ្នាំ២០១១ មជ្ឈមណ្ឌលសិទ្ធិមនុស្សកម្ពុជាបានដាក់លិខិតមួយដើម្បីតវ៉ាទៅក្រសួងមហាផ្ទៃអំពីការរារាំងរបស់អាជ្ញាធរឃុំ និងស្រុកមិនឲ្យបើកវគ្គបង្រៀននៅកំពង់ធំ។ មន្ត្រីក្រសួងបានជួបជាមួយបុគ្គលិកនៃមជ្ឈមណ្ឌល តែមិនមានការដោះស្រាយអ្វីលើបញ្ហានេះទេ ដោយគ្រាន់តែរំលឹកឲ្យមជ្ឈមណ្ឌលសហការណ៍ជាមួយអាជ្ញាធរមូលដ្ឋាន។

## ៤. វិភាគអំពីមូលដ្ឋានគតិយុត្តនៃលិខិតជូនដំណឹង

យោងតាមសេចក្តីជូនដំណឹងលេខ ៤៧៤ ហេតុផលដែលក្រសួងមហាផ្ទៃទាមទារឲ្យអង្គការ-សមាគមសុំការអនុញ្ញាតពីក្រសួងដើម្បីបើកការិយាល័យខេត្តនៃអង្គការឬសមាគមនោះ គឺដោយសារទម្លាប់អាជ្ញាធរខេត្តខ្លះអនុញ្ញាតឲ្យអង្គការ/សមាគមបើកការិយាល័យ ហើយទើបសុំយោបល់ក្រសួងតាមក្រោយ រីឯខេត្តខ្លះទៀតសុំយោបល់មុនទើបអនុញ្ញាតជាក្រោយ ដែលជាការគ្មានភាពឯកភាពគ្នានៅក្នុងនីតិវិធី។ ហេតុដូច្នេះទើបក្រសួងសម្រេចថា ខ្លួនតែមួយគត់ដែលមានអំណាចសម្រេចអនុញ្ញាតឲ្យបើកការិយាល័យខេត្តរបស់អង្គការ-សមាគម។ រីឯសកម្មភាពវិញ ក្រសួងមិនបានបញ្ញត្តិថា អង្គការ-សមាគមដែលគ្មានការិយាល័យនៅតាមខេត្តត្រូវតែសុំការអនុញ្ញាត ឬជូនដំណឹងទៅអាជ្ញាធរខេត្ត ដើម្បីធ្វើសកម្មភាពនៅក្នុងខេត្តនោះទេ។ សេចក្តីជូនដំណឹងនេះទាមទារឲ្យអង្គការ-សមាគមដែលមានការិយាល័យនៅក្នុងខេត្តត្រូវជូនដំណឹងជាមុនទៅអាជ្ញាធរមូលដ្ឋានដើម្បីធ្វើសកម្មភាពប្រជុំ ឬបង្រៀន។ សេចក្តីជូនដំណឹងលេខ ៣៣០ បន្តតាមស្មារតីនៃសេចក្តីជូនដំណឹងលេខ ៤៧៤។

ចំពោះវេទិកាសម្តែងមតិវិញ ក្រសួងសំអាងលើមាត្រា ១៩ និង ២១ នៃកតិកាសញ្ញាស្តីពីសិទ្ធិពលរដ្ឋនិងសិទ្ធិនយោបាយ និងមាត្រា ៤១ នៃរដ្ឋធម្មនុញ្ញ ជាមូលដ្ឋាននៃការតម្រូវឲ្យជូនដំណឹងទៅអាជ្ញាធរខេត្ត-ក្រុងមុននឹងធ្វើសកម្មភាពនេះ។

មាត្រា ១៩ និង ២១ នៃកតិកាចែងថា ៖

**មាត្រា ១៩ ៖**

១. ជនគ្រប់រូបមានសិទ្ធិប្រកាន់យកមតិយោបល់ដោយគ្មានការជ្រៀតជ្រែក។

២. ... សិទ្ធិនេះត្រូវរាប់បញ្ចូលទាំងសេរីភាពស្រាវជ្រាវព័ត៌មាន ទទួលនិងផ្សព្វផ្សាយព័ត៌មាន និងគំនិតសព្វបែបយ៉ាង... ដោយមធ្យោបាយដទៃទៀតក្តីតាមការជ្រើសរើសរបស់ខ្លួន។

៣. ការប្រើសិទ្ធិដែលចែងក្នុងកថាខណ្ឌ ២ នៃមាត្រានេះ តម្រូវឲ្យមានករណីយកិច្ចនិងការទទួលខុសត្រូវពិសេស។ ដូច្នេះការប្រើសិទ្ធិនេះ អាចមានការរិតត្បិតមួយចំនួន ដែលត្រូវកំណត់ដោយច្បាប់និងដែលចាំបាច់ដើម្បី ៖

...

(ខ) ការពារសន្តិសុខជាតិ សណ្តាប់ធ្នាប់សាធារណៈ សុខភាព ឬសីលធម៌សាធារណៈ

**មាត្រា ២១ ៖**

សិទ្ធិប្រជុំដោយសន្តិវិធី ត្រូវតែទទួលស្គាល់។ ការប្រើសិទ្ធិនេះអាចមានការរិតត្បិតដែលកំណត់ដោយច្បាប់តែប៉ុណ្ណោះ និងដែលចាំបាច់ក្នុងសង្គមប្រជាធិបតេយ្យ ក្នុងផលប្រយោជន៍នៃ

សន្តិសុខជាតិ ឬសុវត្ថិភាពសាធារណៈ សណ្តាប់ធ្នាប់សាធារណៈ ការការពារសុខភាពសាធារណៈ ឬ សីលធម៌ ឬការការពារសិទ្ធិ និងសេរីភាពអ្នកដទៃ។

មាត្រា ៤១ នៃរដ្ឋធម្មនុញ្ញខ្មែរចែងថា ៖

ប្រជាពលរដ្ឋខ្មែរមានសេរីភាពខាងការបញ្ចេញមតិរបស់ខ្លួន... សេរីភាពខាងការប្រជុំ។ ជនណាក៏ដោយមិនអាចឆ្លៀតប្រើសិទ្ធិនេះ ដោយរំលោភនាំអោយប៉ះពាល់ដល់កិត្តិយស...ដល់សណ្តាប់ធ្នាប់សាធារណៈ និងដល់សន្តិសុខជាតិបានឡើយ។

ក្រសួងមហាផ្ទៃ ដោយអាងលើមាត្រាទាំងនេះហើយ បានជាទាមទារនៅក្នុងសេចក្តីជូនដំណឹងលេខ ០៥២ ឲ្យសមាគម-អង្គការក្រៅរដ្ឋាភិបាលជូនដំណឹងដល់អាជ្ញាធរខេត្ត-ក្រុងជាមុនពីការរៀបចំវេទិកាសម្តែងមតិ និងឲ្យអាជ្ញាធរខេត្ត-ក្រុងបង្កលក្ខណៈងាយស្រួល និងសហការការពារសន្តិសុខ សុវត្ថិភាពដល់វេទិកាសាធារណៈ។ បើមើលពីខាងជ្រុងវិជ្ជមាន ការទាមទារឲ្យជូនដំណឹងជាមុនអាចជាការមួយស្រួលដល់អាជ្ញាធរមូលដ្ឋានជួយការពារសន្តិសុខ និងសណ្តាប់ធ្នាប់ក្នុងការធ្វើវេទិកាបញ្ចេញមតិដែរ ព្រោះអាចមានជម្លោះកើតចេញពីការជជែកខ្វែងគំនិត ឬការប្រកាន់និន្នាការនយោបាយខុសគ្នា។

ប៉ុន្តែការបិទការបង្រៀន ឬការធ្វើវេទិកាសាធារណៈ ដោយសារការមិនគោរពតាមសេចក្តីជូនដំណឹង គឺជាវិធានការវិសមាមាត្រ។ បើក្រសួងអាងលើមាត្រា ១៩ និង ២១ នៃកតិកាសញ្ញាស្តីពីសិទ្ធិពលរដ្ឋ និងសិទ្ធិនយោបាយ ក្រសួងក៏ត្រូវអានឲ្យបានច្បាស់នូវអធិប្បាយទូទៅលេខ ៣៤ របស់គណកម្មាធិការសិទ្ធិមនុស្ស ដែលជាអង្គឃ្លាំមើលការអនុវត្តសន្ធិសញ្ញាសិទ្ធិមនុស្ស និងជាអង្គដែលមានអំណាចធ្វើការបកស្រាយសន្ធិសញ្ញាទាំងនោះ។ គណកម្មាធិការសិទ្ធិមនុស្សផ្តល់ការណែនាំថា ពេលណារដ្ឋដាក់វិធានការកម្រិតលើសិទ្ធិ (ដូចជាហាមមិនឲ្យបើកវេទិកាសាធារណៈ ការហាមមិនឲ្យបង្រៀន) រដ្ឋមិនត្រូវធ្វើឲ្យសិទ្ធិនោះ(ដូចជាសិទ្ធិបញ្ចេញមតិក្នុងវេទិកា សិទ្ធិទទួលការផ្សព្វផ្សាយពីសិទ្ធិមនុស្ស) ទទួលក្តីអន្តរាយឡើយ[84]។

គណកម្មាធិការថ្លែងថា បើចង់ដាក់វិធានការកម្រិតលើសិទ្ធិទាំងនោះ រដ្ឋត្រូវធ្វើច្បាប់ដាក់កំហិតលើការអនុវត្តសិទ្ធិទាំងនោះ មិនមែនដោយពាក្យបញ្ជារបស់អាជ្ញាធររដ្ឋបាលឡើយ ហើយច្បាប់នោះទៀតសោតត្រូវតែស្របតាមលក្ខខណ្ឌនៃ "ភាពចាំបាច់" និង "សមាមាត្រ"[85]។ អាជ្ញាធរអាចកម្រិតលើសិទ្ធិទាំងនេះដោយមានយុត្តិកម្មផ្អែកគតិយុត្ត (ការសំអាងលើបទបញ្ញត្តិច្បាប់) មិនមែនលើការយល់ឃើញផ្ទាល់ខ្លួនរបស់មន្ត្រីណាមួយក្នុងឋានៈណាមួយនោះឡើយ[86]។ បើរដ្ឋមានច្បាប់ដាក់កំហិតលើសិទ្ធិ រដ្ឋត្រូវចែងពីសេចក្តីលម្អិតនៃច្បាប់ និងបញ្ជាក់ឲ្យពលរដ្ឋបានយល់ច្បាស់ថា សកម្មភាពណាខ្លះដែលស្ថិតក្នុងវង្វង់នៃការដាក់កំហិតនោះ។[87]

## ៥. ឧបាស្រ័យក្នុងករណីមានការរំលោភសិទ្ធិដែលរដ្ឋធម្មនុញ្ញប្រទានឲ្យ

សេរីភាពក្នុងការបញ្ចេញមតិត្រូវបានបង្កើតដោយរដ្ឋធម្មនុញ្ញកម្ពុជា។ សិទ្ធិសេរីភាពដែលប្រគល់ឲ្យដោយរដ្ឋធម្មនុញ្ញជាសិទ្ធិសារវន្ត (fundamental rights) ដែលត្រូវតែបានដោះស្រាយដោយក្រុមប្រឹក្សាធម្មនុញ្ញ ពេលណាមានវិវាទទាក់ទងនឹងការអនុវត្តសិទ្ធិនេះ។ ច្បាប់ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅនៃក្រុម

---

[84] កថាខណ្ឌទី ២១ នៃអធិប្បាយលេខ ៣៤។

[85] កថាខណ្ឌទី ២២ នៃអធិប្បាយលេខ ៣៤។

[86] កថាខណ្ឌទី ២៧ នៃអធិប្បាយលេខ ៣៤។

[87] ដូចគ្នាខាងលើ។

ប្រឹក្សាធម្មនុញ្ញ បើកឲ្យប្រជាពលរដ្ឋដែលសិទ្ធិធម្មនុញ្ញ (constitutional rights) របស់ខ្លួនត្រូវបានរំលោភអាចប្ដឹងទៅក្រុមប្រឹក្សាធម្មនុញ្ញដើម្បីដោះស្រាយ។ មាត្រា ១៩ នៃច្បាប់នេះចែងថា ៖

> បុគ្គលដែលជាប់ពាក់ព័ន្ធក្នុងរឿងក្ដីណាមួយហើយរឿងក្ដីនោះឡើងដល់តុលាការ បុគ្គលនោះអាចលើកអំពីធម្មនុញ្ញភាពនូវបទប្បញ្ញត្តិណាមួយនៃច្បាប់ ឬសេចក្ដីសម្រេចរបស់ស្ថាប័ននានាដែលគេអះអាងថាប៉ះពាល់ដល់សិទ្ធិសេរីភាពជាសារវន្តណាមួយរបស់គេជូនតុលាការ។ បើយល់ឃើញថាការលើកឡើងនេះមានមូលដ្ឋានគ្រប់គ្រាន់ តុលាការត្រូវលើកករណីនេះទៅតុលាការកំពូលក្នុងរយៈពេល ១០ ថ្ងៃយ៉ាងយូរ។
>
> តុលាការកំពូលត្រូវចាត់ការពិនិត្យ និងប្ដឹងទៅក្រុមប្រឹក្សាធម្មនុញ្ញក្នុងរយៈពេល ១៥ ថ្ងៃយ៉ាងយូរ លើកលែងតែតុលាការកំពូលយល់ឃើញថា ពាក្យប្ដឹងតវ៉ានោះមិនអាចទទួលបាន។

នេះជានីតិវិធីដែលត្រូវអនុវត្តតាម។ ជាដំបូងអ្នកដែលត្រូវរំលោភត្រូវប្ដឹងទៅតុលាការខេត្ត-ក្រុងដើម្បីទាមទារឲ្យជួសជុលសិទ្ធិដែលត្រូវបានរំលោភនោះដោយសេចក្ដីសម្រេចរបស់អាជ្ញាធរ (ឧ. ប្រកាស សេចក្ដីសម្រេច សេចក្ដីជូនដំណឹង ដីកា)។ បន្ទាប់មកជននោះត្រូវប្ដឹងទាមទារឲ្យតុលាការខេត្ត-ក្រុងនោះលើកអំពីធម្មនុញ្ញភាពនៃសេចក្ដីសម្រេចនោះ ថាបានរំលោភលើបញ្ញត្តិណាមួយនៃរដ្ឋធម្មនុញ្ញ[88] ឧទាហរណ៍ ដូចជាការរំលោភលើមាត្រា ៤១ ស្ដីពីសេរីភាពនៃការសម្ដែងមតិ ឬមាត្រា ៤២ ស្ដីពីសេរីភាពនៃការបង្កើតសមាគម ឬមាត្រា ៦៥ ស្ដីពីសិទ្ធិក្នុងការអប់រំនៅគ្រប់កម្រិត។ តុលាការត្រូវចាត់ទុកពាក្យប្ដឹងនោះជាបញ្ហាបន្ទាន់បង្ខំដែលត្រូវដោះស្រាយដោយក្រុមប្រឹក្សាធម្មនុញ្ញ ព្រោះក្រុមប្រឹក្សានេះមានសមត្ថកិច្ចពិសេសសម្រាប់ដោះស្រាយពីបញ្ហាធម្មនុញ្ញភាព។

បន្ទាប់មកតុលាការខេត្ត-ក្រុងត្រូវបញ្ជូនពាក្យប្ដឹងនោះទៅតុលាការកំពូល។ តុលាការអាចបដិសេធមិនបញ្ជូនពាក្យប្ដឹងនោះទៅតុលាការកំពូលបាន ប្រសិនបើពាក្យប្ដឹងនោះមិនពាក់ព័ន្ធនឹងរឿងធម្មនុញ្ញភាព ឧទាហរណ៍ ដូចជាការលើកឡើងថា សេចក្ដីសម្រេចនោះរំលោភលើមាត្រាណាមួយនៃច្បាប់ណាមួយ (ឧទាហរណ៍ រំលោភលើក្រមព្រហ្មទណ្ឌ ឬក្រមរដ្ឋប្បវេណី ឬច្បាប់ចរាចរ) ដែលបញ្ហាទាំងនេះជាបញ្ហាច្បាប់ដែលតុលាការមានសមត្ថភាពនិងសមត្ថកិច្ចគ្រប់គ្រាន់អាចដោះស្រាយបាន។

តុលាការកំពូលពិនិត្យម្ដងទៀតលើពាក្យប្ដឹងដែលតុលាការខេត្ត-ក្រុងបញ្ជូនមក ក្នុងគោលបំណងមើលឲ្យប្រាកដថាបញ្ហាដែលលើកឡើងនោះជាបញ្ហាធម្មនុញ្ញ មិនមែនជាបញ្ហាច្បាប់ធម្មតា។

ការពិនិត្យទាំងអស់នេះមិនមែនជាការធ្វើឲ្យរាំងស្ទះដល់គូក្ដីមិនឲ្យទទួលបានសិទ្ធិទទួលឧបាស្រ័យពីស្ថាប័នធម្មនុញ្ញកំពូលនេះទេ។ គោលបំណងនៃនីតិវិធីនេះ គឺគ្រាន់តែចង់ច្រោះយករឿងដែលមិនបានការ ឬរឿងដែលក្រុមប្រឹក្សាបានសម្រេចពីមុនមកហើយដើម្បីកុំឲ្យរំខានស្ថាប័ននេះតែប៉ុណ្ណោះ ព្រោះបើទទួលគ្រប់តែរឿង ស្ថាប័ននេះមិនអាចដំណើរការបានដោយសារតែចំនួនសំណុំរឿងគរដូចភ្នំ។

នៅពេលដែលតុលាការកំពូលបញ្ជូនរឿងមកក្រុមប្រឹក្សាធម្មនុញ្ញហើយ ក្រុមប្រឹក្សានេះត្រូវសម្រេចថា តើសេចក្ដីសម្រេចរបស់ស្ថាប័ននោះស្រប ឬផ្ទុយនឹងរដ្ឋធម្មនុញ្ញ។ សេចក្ដីសម្រេចរបស់ក្រុមប្រឹក្សាធម្មនុញ្ញត្រូវបញ្ជូនមកតុលាការដើមដែលកំពុងពិចារណារឿងក្ដីនោះវិញ។ តុលាការនេះត្រូវដំណើរការនីតិវិធីរបស់ខ្លួនឡើងវិញ និងសម្រេចចេញសាលក្រម ដោយយកសេចក្ដីសម្រេចរបស់ក្រុមប្រឹក្សាធម្មនុញ្ញមកធ្វើជាកត្តាអនុវត្ត។ សាលក្រមតុលាការមានអំណាចអនុវត្តដែលត្រូវតែគោរព។ បើក្រុមប្រឹក្សាធម្មនុញ្ញសម្រេច

[88] គេមិនអាចលើកពីការរំលោភលើបញ្ញត្តិណាមួយនៃច្បាប់បានទេ ព្រោះក្រុមប្រឹក្សាពិនិត្យតែលើការរំលោភលើមាត្រាណាមួយនៃរដ្ឋធម្មនុញ្ញប៉ុណ្ណោះ។

ថា ការបិទអង្គការមិនឲ្យបង្រៀនប្រជាពលរដ្ឋពីសិទ្ធិមនុស្ស និងសិទ្ធិការពារធនធានធម្មជាតិជាអំពើផ្ទុយនឹងរដ្ឋធម្មនុញ្ញ តុលាការដំបូងត្រូវតែប្រកាសថា អំពើរបស់អាជ្ញាធរត្រូវចាត់ទុកផ្ទុយនឹងធម្មនុញ្ញ និងត្រូវចាត់ទុកជាការរំលោភច្បាប់ ព្រមទាំងផ្តល់ការជួសជុលដល់អង្គការទៅតាមទំហំនៃការខូចខាត។

# ឧបសម្ព័ន្ធ

# មាត្រា ១៩ និង ២០ នៃកតិកាសញ្ញាស្តីពីសិទ្ធិពលរដ្ឋនិងនយោបាយ

## មាត្រា ១៩

១. មនុស្សគ្រប់រូបមានសិទ្ធិប្រកាន់នូវមតិដោយគ្មានការជ្រៀតជ្រែក

២. មនុស្សគ្រប់រូបមានសិទ្ធិដើម្បីបានសេរីភាពនៃការសម្តែងចេញ។ សិទ្ធិនេះរាប់បញ្ចូលសេរីភាពដើម្បីស្វែងរក ទទួល និងបញ្ចេញព័ត៌មាន និងគំនិតគ្រប់ប្រភេទ ដោយមិនគិតពីព្រំដែន ទោះជាដោយផ្ទាល់មាត់ក្តី ដោយសរសេរក្តី ឬជាការបោះពុម្ពក្តី ក្នុងទម្រង់ជាសិល្បៈក្តី ឬតាមរយៈមធ្យោបាយផ្សព្វផ្សាយតាមការជ្រើសរើសរបស់គេក្តី។

៣. ការអនុវត្តសិទ្ធិដែលចែងក្នុងកថាខណ្ឌ ទី ២ នៃមាត្រានេះនាំយកទៅជាមួយនូវករណីយកិច្ចនិងការទទួលខុសត្រូវ។ ដូច្នេះ ការអនុវត្តនេះអាចស្ថិតក្រោមការរិតត្បិតខ្លះ ប៉ុន្តែការរឹតត្បិតទាំងនោះត្រូវចែងដោយច្បាប់ និងតាមការចាំបាច់ប៉ុណ្ណោះ ៖

(ក) សម្រាប់ការគោរពសិទ្ធិ ឬកេរ្តិ៍ឈ្មោះអ្នកដទៃ

(ខ) សម្រាប់ការការពារសន្តិសុខជាតិ ឬការការពារសណ្តាប់ធ្នាប់សាធារណៈ ឬសុខភាព ឬសីលធម៌សាធារណៈ

## មាត្រា ២០

១. ការឃោសនាឲ្យធ្វើសង្គ្រាមត្រូវហាមឃាត់ដោយច្បាប់។

២. ការអំពាវនាវឲ្យមានការស្អប់ជាតិ ពូជសាសន៍ ឬសាសនា ដែលបង្កើតបានជាការញុះញង់ឲ្យមានការរើសអើង ភាពអមិត្ត ឬអំពើហិង្សាត្រូវហាមឃាត់ដោយច្បាប់។

**អង្គការសហប្រជាជាតិ** CCPR/C/GC/34

**កតិកាសញ្ញាអន្តរជាតិស្តីពី**

**សិទ្ធិពលរដ្ឋ និងសិទ្ធិនយោបាយ**

ចែកចាយ៖ ទូទៅ

១២ កញ្ញា ២០១១

ច្បាប់ដើម ៖ ភាសាអង់គ្លេស

**គណៈកម្មាធិការសិទ្ធិមនុស្ស**

**សម័យប្រជុំលើកទី១០២**

ទីក្រុងហ្សឺណែវ ថ្ងៃទី១១-២៩ កក្កដា ឆ្នាំ២០១១

# អត្ថាធិប្បាយទូទៅលេខ ៣៤

## មាត្រា១៩ ៖ សេរីភាពនៃគំនិត និងសេរីភាពខាងការបញ្ចេញមតិ

### កំណត់សំគាល់ទូទៅ

១. អត្ថាធិប្បាយទូទៅនេះ ដាក់ជំនួសអត្ថាធិប្បាយទូទៅលេខ ១០ (សម័យប្រជុំលើកទី ១៩)

២. សេរីភាពនៃមតិ និងសេរីភាពនៃការសម្តែងចេញ គឺជាលក្ខខណ្ឌដែលមិនអាចកាត់ផ្តាច់បានសម្រាប់ ការអភិវឌ្ឍន៍ពេញលេញរបស់មនុស្ស។ សេរីភាពទាំងនេះ មានសារៈសំខាន់ជាសារវន្តសម្រាប់សង្គមណាក៏ដោយ។[89] សេរីភាពទាំងនេះបង្កើតជាមូលដ្ឋានគ្រឹះដល់គ្រប់សង្គមប្រជាធិបតេយ្យ និងសេរី។ សេរីភាពទាំងពីរនេះមានទំនាក់ទំនងគ្នាយ៉ាងជិតដិត ដោយសេរីភាពនៃការសម្តែងចេញគឺជាយានសម្រាប់ការផ្លាស់ប្តូរ និងការអភិវឌ្ឍនៃមតិ។

៣. សេរីភាពនៃការសម្តែងចេញ គឺជាលក្ខខណ្ឌចាំចាច់មួយសម្រាប់ការធ្វើឲ្យសម្រេចបាននូវគោលការណ៍នៃតម្លាភាព និងគណនេយ្យភាព ដែលមានសារៈសំខាន់ដល់ការលើកស្ទួយនិងការការពារសិទ្ធិមនុស្ស។

៤. ក្នុងចំណោមមាត្រាដទៃទៀត ដែលមានចែងពីការធានាការពារសេរីភាពនៃមតិ និង/ឬសេរីភាពនៃការសម្តែងចេញ គឺមាត្រា១៨ ១៧ ២៥ និង មាត្រា២៧។ សេរីភាពនៃមតិនិងសេរីភាពនៃការសម្តែងចេញ បង្កើតជាមូលដ្ឋានមួយសម្រាប់ការទទួលបានទាំងស្រុងនូវសិទ្ធិមនុស្សដទៃទៀតកាន់តែទូលាយ។ ឧទាហរណ៍

[89] សូមមើលបណ្តឹងលេខ១១៧៣/២០០៣ រវាង*Benhadj និងប្រទេសអាល់ហ្សេរី* ទស្សនៈយល់ឃើញអនុម័តកាលពីថ្ងៃទី២០ កក្កដា ២០០៧ និងបណ្តឹងលេខ៦២៨/១៩៩៥ រវាង *Park និងសាធារណៈរដ្ឋកូរ៉េ* ទស្សនៈយល់ឃើញអនុម័តកាលពីថ្ងៃទី៥ កក្កដា ១៩៩៦

សេរីភាពនៃការសម្តែងចេញ គឺជាផ្នែកមិនអាចកាត់ផ្តាច់បាននៃការទទួលបានសិទ្ធិមានសេរីភាពខាងការប្រជុំ និងខាងសមាគម និងការអនុវត្តសិទ្ធិបោះឆ្នោត។

៥. ដោយពិចារណាអំពីពាក្យពេចន៍ជាក់លាក់នៃមាត្រា ១៩ កថាខ័ណ្ឌទី ១ ក៏ដូចជាទំនាក់ទំនងនៃមតិ និងគំនិត (មាត្រា១៨) ការដាក់ខលក្ខខណ្ឌលើកថាខ័ណ្ឌទី ១ នឹងមិនស្របជាមួយគោលដៅ និងគោលបំណងនៃកតិកាសញ្ញានេះទេ។[90] លើសពីនេះទៅទៀត ទោះជាសេរីភាពនៃមតិមិនបានរាប់បញ្ចូលនៅក្នុងចំណោមសិទ្ធិទាំងឡាយដែលមិនអាចត្រូវបានកាត់បន្ថយអានុភាព ដោយអនុលោមតាមបទប្បញ្ញត្តិនៃមាត្រា ៤ នៃកតិកាសញ្ញានេះក៏ដោយ ក៏ត្រូវតែរំលឹកឡើងវិញថា "នៅក្នុងបញ្ញត្តទាំងឡាយណានៃកតិកាសញ្ញា ដែលមិនបានរាយក្នុងមាត្រា ៤ កថាខ័ណ្ឌទី ២ នៅមានសេរីភាពខ្លះ ដែលតាមយោបល់របស់គណៈកម្មាធិការ មិនអាចត្រូវកាត់បន្ថយអានុភាពបាន លើកលែងតែការកាត់បន្ថយនោះស្របតាមច្បាប់តាមមាត្រា ៤"។[91] សេរីភាពនៃមតិគឺជាសេរីភាពមួយនៃសេរីភាពទាំងនោះ ដោយសារគ្មានអ្វីដែលចាំបាច់ត្រូវកាត់បន្ថយអានុភាពនៃសេរីភាពនេះនៅគ្រាអាសន្នឡើយ។[92]

៦. ដោយពិចារណាអំពីទំនាក់ទំនងរវាងសេរីភាពនៃការសម្តែងចេញជាមួយសិទ្ធិដទៃទៀតនៅក្នុងកតិកាសញ្ញានេះ ទោះជាការដាក់លក្ខខណ្ឌចំពោះតែសិទ្ធិណាខ្លះនៅក្នុងមាត្រា ១៩ កថាខ័ណ្ឌទី ២ អាចទទួលយកបានក្តី ក៏ការដាក់ខលក្ខខណ្ឌទូទៅមួយចំពោះសិទ្ធិទាំងអស់ដូចមានចែងក្នុងកថាខ័ណ្ឌទី ២ នឹងមិនស្របជាមួយគោលដៅ និងគោលបំណងនៃកតិកាសញ្ញានេះទេ។[93]

៧. កាតព្វកិច្ចគោរពសេរីភាពនៃមតិ និងការសម្តែងចេញចងរដ្ឋភាគីទាំងមូល។ គ្រប់ស្ថាប័នរបស់រដ្ឋភាគី (ស្ថាប័ននីតិប្រតិបត្តិ ស្ថាប័ននីតិបញ្ញត្តិ និងតុលាការ) និងអាជ្ញាធរសាធារណៈ ឬអាជ្ញាធររដ្ឋាភិបាលដទៃទៀត ទោះជានៅថ្នាក់ណាក៏ដោយ (ថ្នាក់ជាតិ តំបន់ ឬមូលដ្ឋាន) សុទ្ធតែមានតួនាទីអនុវត្តការទទួលខុសត្រូវរបស់រដ្ឋ។ [94] ការទទួលខុសត្រូវនេះ ក៏អាចអនុវត្តផងដែរដោយរដ្ឋភាគីក្រោមកាលៈទេសៈមួយចំនួនទាក់ទងនឹងអំពើរបស់អង្គភាពពាក់កណ្តាលរដ្ឋ។[95] កាតព្វកិច្ចនេះក៏តម្រូវផងដែរឲ្យរដ្ឋភាគី ធានាថាបុគ្គលគ្រប់រូបត្រូវបានការពារពីអំពើណាមួយរបស់អង្គភាព ឬបុគ្គលឯកជន ដែលនាំឲ្យប៉ះពាល់ដល់ការទទួល

---

[90]សូមមើលសេចក្តីពន្យល់ទូទៅលេខ២៤(១៩៩៤) របស់គណៈកម្មាធិការ ស្តីពីបញ្ហានានាពាក់ព័ន្ធនឹងការដាក់ខលក្ខខណ្ឌនៅពេលផ្តល់សច្ចាប័ន ឬចូលជាសមាជិកនៃកតិកាសញ្ញា ឬពិធីសារបន្ថែមនៃកតិកាសញ្ញានេះ ឬទាក់ទងនឹងការប្រកាសសេចក្តីតាមមាត្រា៤១នៃកតិកាសញ្ញានេះ កំណត់ហេតុផ្លូវការរបស់មហាសន្និបាតអង្គការសហប្រជាជាតិ សម័យប្រជុំលើកទី១៥ សំណៅបន្ថែមលេខ ៤0 vol. I (A/50/40 (Vol. I)), ឧបសម្ព័ន្ធ V.

[91] សូមមើលសេចក្តីពន្យល់ទូទៅលេខ២៩ (២០០១) របស់គណៈកម្មាធិការ ស្តីពីការធ្វើបដិបញ្ញត្តក្នុងពេលរដ្ឋមានគ្រាអាសន្ន កថាខ័ណ្ឌទី ១៣ កំណត់ហេតុផ្លូវការរបស់មហាសន្និបាតអង្គការសហប្រជាជាតិ សម័យប្រជុំលើកទី ៥៦ សំណៅបន្ថែមលេខ៤0 vol. I (A/56/40 (Vol. I)), ឧបសម្ព័ន្ធទី VI.

[92] អត្ថាធិប្បាយទូទៅលេខ ២៩ កថាខ័ណ្ឌទី ១១

[93] អត្ថាធិប្បាយទូទៅលេខ ២៤

[94]សូមមើលអត្ថាធិប្បាយទូទៅលេខ ៣១ (២០០៤) របស់គណៈកម្មាធិការស្តីពីចរិកលក្ខណៈនៃកាតព្វកិច្ចផ្លូវច្បាប់ជាទូទៅរបស់រដ្ឋភាគីចំពោះកតិកាសញ្ញា កថាខ័ណ្ឌទី ៤ កំណត់ហេតុផ្លូវការរបស់មហាសន្និបាតអង្គការសហប្រជាជាតិ សម័យប្រជុំលើកទី ៥៩ សំណៅបន្ថែមលេខ ៤0 vol. I (A/59/40 (Vol. I)), ឧបសម្ព័ន្ធទី III

[95] សូមមើលបណ្តឹងលេខ ៦១/១៩៧៩ រវាង *Hertzberg et al និងប្រទេសហ្វាំងឡង់* ទស្សនៈយល់ឃើញអនុម័តកាលពីថ្ងៃទី០២ មេសា ១៩៨២។

បានសេរីភាពនៃមតិ និងការសម្តែងចេញក្នុងកម្រិតដែលសិទ្ធិទាំងឡាយក្នុងកតិកាសញ្ញានេះ សមនឹងយកទៅអនុវត្តន៍រវាងអង្គភាព ឬបុគ្គលឯកជន។[96]

៨. រដ្ឋភាគីត្រូវបានតម្រូវឲ្យធានាថា សិទ្ធិដែលមានចែងក្នុងមាត្រា ១៩ នៃកតិកាសញ្ញានេះ ត្រូវមានអនុភាពទៅលើច្បាប់ជាតិរបស់រដ្ឋ ក្នុងឋានៈមួយដែលស្របតាមគោលការណ៍ណែនាំដែលគណៈកម្មាធិការបានផ្តល់ឲ្យនៅក្នុងអត្ថាធិប្បាយទូទៅរបស់ខ្លួនលេខ ៣១ ស្តីពីចរិតលក្ខណៈនៃកាតព្វកិច្ចគតិយុត្តទូទៅដែលដាក់បង្គាប់លើរដ្ឋភាគីនៃកតិកាសញ្ញានេះ។ គួររំលឹកដែរថា រដ្ឋភាគីគួរផ្តល់ឲ្យគណៈកម្មាធិការ ដោយអនុលោមតាមរបាយការណ៍ទាំងឡាយដែលបានដាក់ជូន ស្របតាមមាត្រា ៤០ នៃកតិកាសញ្ញានេះនូវវិធានគតិយុត្តជាតិដែលពាក់ព័ន្ធការអនុវត្តន៍ផ្នែករដ្ឋបាល និងសេចក្តីសម្រេចផ្សេងៗរបស់តុលាការ ក៏ដូចជាកម្រិតគោលនយោបាយពាក់ព័ន្ធ និងការអនុវត្តន៍តាមវិស័យផ្សេងៗ ទៀតទាក់ទងនឹងសិទ្ធិទាំងឡាយ ដែលត្រូវបានការពារដោយមាត្រា ១៩ ដោយយកមកពិចារណានូវ បញ្ហាដែលបានពិភាក្សានៅក្នុងអត្ថាធិប្បាយនេះ។ រដ្ឋភាគីគួរដាក់បញ្ចូលផងដែរ នូវព័ត៌មានស្តីពីការដោះស្រាយដែលមានស្រាប់ ប្រសិនបើសិទ្ធិទាំងនោះត្រូវបានរំលោភបំពាន។

## សេរីភាពនៃមតិ

៩. កថាខ័ណ្ឌទី ១ នៃមាត្រា ១៩ តម្រូវឲ្យមានការការពារសិទ្ធិប្រកាន់នូវមតិដោយគ្មានការជ្រៀតជ្រែក។ នេះគឺជាសិទ្ធិមួយដែលកតិកាសញ្ញានេះផ្តល់ឲ្យដោយគ្មានការលើកលែង ឬការរិតត្បិតឡើយ។ សេរីភាពនៃមតិរាប់ទាំងសិទ្ធិផ្លាស់ប្តូរមតិនៅពេលណា និងសម្រាប់ហេតុផលអ្វីក៏ដោយតាមតែបុគ្គលម្នាក់ជ្រើសរើសដោយសេរី។ គ្មានជនណាម្នាក់អាចត្រូវទទួលរងនូវការខូចខាតដល់សិទ្ធិណាមួយក្រោមកតិកាសញ្ញានេះទេដោយផ្អែកលើមតិជាក់ស្តែងដែលខ្លួនបានយល់ដឹង ឬដែលបានសន្មត់ឡើយ។ មតិតាមគ្រប់រូបភាពត្រូវបានការពារ រាប់ទាំងមតិដែលមានចរិតលក្ខណៈជានយោបាយ វិទ្យាសាស្ត្រ ប្រវត្តិសាស្ត្រ សីលធម៌ ឬសាសនា។ ការដាក់ជាបទព្រហ្មទណ្ឌចំពោះការប្រកាន់នូវមតិ មិនស្របនឹង កថាខ័ណ្ឌទី ១ នេះទេ។[97] ការយាយី ការបំភិតបំភ័យ ឬការលាភពណ៌បុគ្គលណាមួយ រាប់ទាំងការចាប់ខ្លួន ការឃុំខ្លួន ការជំនុំជម្រះឬការដាក់ពន្ធនាគារដោយសារមតិដែលពួកគេអាចប្រកាន់យក គឺជាការរំលោភបំពានលើមាត្រា១៩ កថាខ័ណ្ឌទី១ នេះ។[98]

១០. កិច្ចខិតខំប្រឹងប្រែងតាមរូបភាពណាក៏ដោយ ដើម្បីបង្ខិតបង្ខំឲ្យប្រកាន់យក ឬមិនប្រកាន់យកមតិណាមួយ ត្រូវបានហាមឃាត់។[99] សេរីភាពដើម្បីសម្តែងមតិរបស់បុគ្គលម្នាក់ ក៏ចាំបាច់ត្រូវរាប់បញ្ចូល សេរីភាពមិនសម្តែងមតិរបស់បុគ្គលនោះផងដែរ។

## សេរីភាពនៃការសម្តែងចេញ

---

96 អត្ថាធិប្បាយទូទៅលេខ៣១ កថាខ័ណ្ឌទី៨ សូមមើលបណ្តឹងលេខ៦៣៣/១៩៩៥ រវាង *Gauthier និងប្រទេសកាណាដា* ទស្សនៈយល់ឃើញអនុម័តកាលពីថ្ងៃទី៧ មេសា ១៩៩៩

97 *សូមមើលបណ្តឹងលេខ៥៥០/៩៣ រវាង Faurisson និងប្រទេសបារាំង* ទស្សនយល់ឃើញអនុម័តកាលពីថ្ងៃ៨ វិច្ឆិកា ១៩៩៦។

98 *សូមមើលបណ្តឹងលេខ១៥៧/១៩៨៣ រវាងMpaka-Nsusu និងប្រទេសហ្សាអៀ* ទស្សនយល់ឃើញអនុម័តកាលពីថ្ងៃទី២៦ មីនា ១៩៨៦ និងបណ្តឹងលេខ៤១៤/១៩៩០ រវាង *Mika Miha និងប្រទេសហ្គីនាអេក្វាទ័រ* ទស្សនយល់ឃើញអនុម័តកាលពីថ្ងៃទី៨ កក្កដា ១៩៩៤។

99 *សូមមើលបណ្តឹងលេខ៨៧៨/១៩៩៩ រវាង Kang និងសាធារណៈរដ្ឋកូរ៉េ* ទស្សនយល់ឃើញអនុម័តកាលពីថ្ងៃទី១៥ កក្កដា ២០០៣។

១១. កថាខ័ណ្ឌទី ២ តម្រូវឲ្យរដ្ឋភាគីធានាការពារសិទ្ធិមានសេរីភាពនៃការសម្តែងចេញ រាប់ទាំងសិទ្ធិស្វែងរក ទទួល និងចែករំលែកព័ត៌មាន និងគំនិតគ្រប់បែបយ៉ាង ដោយគ្មានដែនកំណត់។ សិទ្ធិនេះរាប់ទាំងការសម្តែងចេញ និងការទទួលយកនូវការផ្លាស់ប្តូរគ្រប់រូបភាពនៃគំនិត និងមតិដែលអាចបញ្ជូនបន្តទៅអ្នកដទៃទៀត តែត្រូវស្ថិតក្រោមលក្ខខណ្ឌនៃបទបញ្ញត្តិក្នុងមាត្រា ១៩ កថាខណ្ឌទី ៣ និងមាត្រា២០។[100] សិទ្ធិនេះរាប់ទាំងការនិយាយពីរឿងនយោបាយ[101] និងបទអត្ថាធិប្បាយអំពីកិច្ចការខ្លួនផ្ទាល់[102] និងអំពីកិច្ចការសាធារណៈ[103] ការបញ្ចុះបញ្ចូលរកការគាំទ្រ[104] ការពិភាក្សាអំពីសិទ្ធិមនុស្ស[105] វិជ្ជាជីវៈខាងសារព័ត៌មាន[106] ការសម្តែងចេញផ្នែកវប្បធម៌ និងសិល្បៈ[107] ការបង្រៀន[108] និងការនិយាយពីរឿងសាសនា។[109] សិទ្ធិនេះក៏អាចរាប់បញ្ចូល ទាំងការផ្សាយពាណិជ្ជកម្មផងដែរ។ វិសាលភាពនៃកថាខណ្ឌទី ២ រាប់ទាំងការសម្តែងចេញដែលអាចចាត់ទុកថាជាពាក្យសំដីជ្រុលទៅលើគេផងដែរ[110] ទោះបីជាការសម្តែងចេញបែបនេះអាចត្រូវបានរិតត្បិតអនុ-លោមតាមបញ្ញត្តិនៃមាត្រា ១៩ កថាខណ្ឌទី ៣ និងមាត្រា ២០ ក៏ដោយ។

១២. កថាខណ្ឌទី២ ការពារការសម្តែងចេញតាមគ្រប់ទម្រង់ និងមធ្យោបាយផ្សព្វផ្សាយ។ ទម្រង់ទាំងនេះរាប់បញ្ចូលភាសានិយាយ សរសេរ និងភាសាសញ្ញា ព្រមទាំងការសម្តែងចេញដោយមិនប្រើពាក្យសំដីទាំងឡាយ មានដូចជាតាមរយៈរូបភាព និងវត្ថុសិល្បៈជាដើម។[111] មធ្យោបាយសម្តែងចេញ រួមមានសៀវភៅកាសែត[112] បទវិចារណកថា[113] ប័ណ្ណប្រកាស បដា[114] សំលៀកបំពាក់ និងឯកសារច្បាប់នានា[115]រួមទាំងគ្រប់ទម្រង់ ដទៃទៀត តាមសោតទស្សន៍ ព្រមទាំងវិធីសម្តែងចេញតាមរយៈអ៊ីនធឺណែត និងអេឡិចត្រូនិកផង។

## សេរីភាពនៃការសំដែងចេញ និងប្រព័ន្ធសារព័ត៌មាន

១៣. សារព័ត៌មាន ឬប្រព័ន្ធផ្សព្វផ្សាយផ្សេងទៀតដែលសេរី គ្មានការត្រួតពិនិត្យ និងរិតត្បិត មានសារៈសំខាន់ក្នុងសង្គមណាក៏ដោយ ដើម្បីធានាដល់សេរីភាពនៃមតិ និងការសម្តែងចេញ និងការទទួលបានសិទ្ធិ

---

[100] សូមមើលបណ្តឹងលេខ៣៥៩/១៩៨៩ និងបណ្តឹងលេខ៣៨៥/១៩៨៩ រវាង *Ballantyne, Davidson និងMcIntyre និងប្រទេសកាណាដា* ទស្សនយល់ឃើញអនុម័តកាលពី ថ្ងៃទី១៨ តុលា ១៩៩០។

[101] សូមមើលបណ្តឹងលេខ៤១៤/១៩៩០ រវាង *Mika Miha* និងប្រទេសហ្គីនាអេក្វាទ័រ។

[102] សូមមើលបណ្តឹងលេខ១១៨៩/២០០៣ រវាង *Fernando* និងប្រទេសស្រីលង្កា ទស្សនយល់ឃើញអនុម័តកាលពីថ្ងៃទី៣១ មីនា ២០០៥។

[103] សូមមើលបណ្តឹងលេខ១១៥៧/២០០៣ រវាង *Coleman* និងប្រទេសអូស្ត្រាលី ទស្សនយល់ឃើញអនុម័តកាលពីថ្ងៃទី១៧ កក្កដា ២០០៦។

[104] សេចក្តីសង្កេតសន្និដ្ឋានសម្រាប់ប្រទេសជប៉ុន(CCPR/C/JPN/CO/5)។

[105] សូមមើលបណ្តឹងលេខ១០២២/២០០១ រវាង *Velichkin* និងប្រទេសបេឡារ៉ុស ទស្សនយល់ឃើញអនុម័តកាលពីថ្ងៃទី២០ តុលា ២០០៥។

[106] សូមមើលបណ្តឹងលេខ១៣៣៤/២០០៤ រវាង *Mavlonov and Sa'di* និងប្រទេសអ៊ុយបេគីស្ថាន ទស្សនយល់ឃើញអនុម័តកាលពីថ្ងៃទី១៩ មីនា ២០០៩។

[107] សូមមើលបណ្តឹងលេខ៩២៦/២០០០ រវាង *Shin* និងសាធារណរដ្ឋកូរ៉េ ទស្សនយល់ឃើញអនុម័តកាលពីថ្ងៃទី១៦ មីនា ២០០៤។

[108] សូមមើលបណ្តឹងលេខ៧៣៦/៩៧ រវាង *Ross* និងប្រទេសកាណាដា ទស្សនយល់ឃើញអនុម័តកាលពីថ្ងៃទី១៨ តុលា ២០០០។

[109] សូមមើលបណ្តឹងខាងលើ រវាង *Ross* និងប្រទេសកាណាដា

[110] សូមមើលបណ្តឹងខាងលើ រវាង *Ross* និងប្រទេសកាណាដា

[111] សូមមើលបណ្តឹងលេខ៩២៦/២០០០ រវាង *Shin* និងសាធារណរដ្ឋកូរ៉េ ទស្សនយល់ឃើញអនុម័តកាលពីថ្ងៃទី១៦ មីនា ២០០៤។

[112] សូមមើលបណ្តឹងលេខ១៣៤១/២០០៥ រវាង *Zundel* និងប្រទេសកាណាដា ទស្សនយល់ឃើញអនុម័តកាលពីថ្ងៃទី២០ មីនា ២០០៧។

[113] សូមមើលបណ្តឹងលេខ១០០៩/២០០១ រវាង *Shchetoko et al* និងប្រទេសបេឡារូស ទស្សនយល់ឃើញអនុម័តកាលពីថ្ងៃទី១១ កក្កដា ២០០៤។

[114] សូមមើលបណ្តឹងលេខ៤១២/១៩៩០ រវាង *Kivenmaa* និងប្រទេសហ្វាំងឡង់ ទស្សនយល់ឃើញអនុម័តកាលពីថ្ងៃទី៣១ មីនា ១៩៩៤។

[115] សូមមើលបណ្តឹងលេខ១១៨៩/២០០៣ រវាង *Fernando* និងប្រទេសស្រីលង្កា។

ដទៃទៀតនៃកតិកាសញ្ញានេះ។ សេរីភាពនេះបង្កើតជាសសរគ្រឹះមួយក្នុងចំណោមសសរគ្រឹះដទៃ ទៀតក្នុងសង្គមប្រជាធិបតេយ្យ។[116] កតិកាសញ្ញានេះ រាប់បញ្ចូលសិទ្ធិមួយ ដែលតាមរយៈសិទ្ធិនេះ ប្រព័ន្ធផ្សព្វផ្សាយអាចទទួលបានព័ត៌មាន ហើយលើពត៌មាននេះ ប្រព័ន្ធផ្សព្វផ្សាយអាចបំពេញមុខងាររបស់ខ្លួនបាន។[117] ការផ្លោះប្តូរដោយសេរីនូវព័ត៌មាន និងគំនិតអំពីបញ្ហាសាធារណៈ និងបញ្ហានយោបាយ រវាងប្រជាពលរដ្ឋបេក្ខជន និងតំណាងជាប់ឆ្នោតគឺជាការសំខាន់។ នេះមានន័យថា សារព័ត៌មានសេរី និងប្រព័ន្ធផ្សព្វផ្សាយផ្សេងទៀត អាចធ្វើអធិប្បាយអំពីបញ្ហាសាធារណៈដោយគ្មានការត្រួតពិនិត្យ ឬការដាក់កំហិត និងអាចជួយឲ្យសាធារណជនបង្កើតមតិរបស់គេបាន។[118] សាធារណៈជនក៏មានសិទ្ធិដូចគ្នាផងដែរ ក្នុងការទទួលបានព័ត៌មានពីប្រព័ន្ធផ្សព្វផ្សាយទាំងនេះ។[119]

១៤. ជាមធ្យោបាយមួយ ដើម្បីការពារសិទ្ធិអ្នកប្រើប្រាស់ប្រព័ន្ធព័ត៌មាន រាប់ទាំងសមាជិកនៃក្រុមនិគមជន និងជនភាគតិចខាងភាសា ក្នុងការទទួលបានព័ត៌មាន និងគំនិតយោបល់ផ្សេងៗយ៉ាងទូលំទូលាយ នោះរដ្ឋភាគីគួរយកចិត្តទុកដាក់ជាពិសេស លើកទឹកចិត្តឲ្យមានប្រព័ន្ធផ្សព្វផ្សាយចំរុះ និងឯករាជ្យ។

១៥. រដ្ឋភាគីគួរគិតគូរអំពីកំរិតនៃការវិវត្តន៍ផ្នែកបច្ចេកវិទ្យាព័ត៌មាន និងគមនាគមន៍ ដូចជា អ៊ីនធឺណែត និងប្រព័ន្ធផ្សព្វផ្សាយព័ត៌មានអេឡិចត្រូនិកចល័ត បានផ្លាស់ប្តូរជាដំកំភួន នូវរបៀបទំនាក់ទំនងគ្នាជុំវិញពិភពលោក។ បច្ចុប្បន្ននេះ មានបណ្តាញសកលមួយសម្រាប់ការផ្លាស់ប្តូរគំនិតយោបល់ ដែលមិន ចាំបាច់ពឹងផ្អែកលើអន្តរការីប្រព័ន្ធផ្សព្វផ្សាយមហាជនតាមបែបប្រពៃណីទៀតឡើយ។ រដ្ឋភាគីគួរចាត់រាល់វិធានការចាំបាច់ដើម្បីពង្រឹងឯករាជ្យភាពនៃប្រព័ន្ធផ្សព្វផ្សាយថ្មីទាំងនេះ ហើយធានាឲ្យបុគ្គលគ្រប់រូបទទួលបានប្រព័ន្ធទាំងនេះ។

១៦. រដ្ឋភាគី គួរធានាថាសេវាផ្សាយព័ត៌មានសាធារណៈ ដំណើរការប្រកបដោយឯករាជ្យ។[120] ដូច្នេះ រដ្ឋភាគីគួរតែធានាការពារឯករាជ្យភាព និងសេរីភាពខាងការផ្សាយរបស់ពួកគេ។ រដ្ឋភាគីគួរផ្តល់មូលនិធិក្នុងលក្ខណៈមួយដែលមិនធ្វើឲ្យប៉ះពាល់ដល់ឯករាជ្យភាពរបស់ពួកគេ។

១៧. បញ្ហាទាក់ទងនឹងប្រព័ន្ធផ្សព្វផ្សាយ ត្រូវបានពិភាក្សាថែមទៀតក្នុងផ្នែកនៃអត្ថាធិប្បាយទូទៅនេះ ដែលលើកឡើងអំពីការរិតត្បិតលើសេរីភាពនៃការបញ្ចេញមតិ។

## សិទ្ធិទទួលបានព័ត៌មាន

១៨. មាត្រា ១៩ កថាខ័ណ្ឌទី ២ គ្របដណ្តប់លើសិទ្ធិទទួលបានព័ត៌មានដែលនៅក្នុងដៃនៃស្ថាប័នសាធារណៈ។ ព័ត៌មាននេះមានឯកសារដែលកាន់កាប់ដោយស្ថាប័នសាធារណៈ ដោយមិនគិតពីទម្រង់ដែលព័ត៌មាននោះត្រូវរក្សាទុកប្រភព និងកាលបរិច្ឆេទនៃការផលិតនោះឡើយ។ ស្ថាប័នសាធារណៈ គឺជាស្ថាប័នដូចបានគូសបញ្ជាក់ក្នុងកថាខ័ណ្ឌទី ៧ នៃអត្ថាធិប្បាយទូទៅនេះ។ ស្ថាប័នទាំងនេះ ក៏អាចរាប់បញ្ចូលផងដែរនូវ

---

[116] សូមមើលបណ្តឹងលេខ១១២៨/២០០២ រវាង *Marques* និងប្រទេសអង់ហ្គោឡា ទស្សនយល់ឃើញអនុម័តកាលពីថ្ងៃទី២៩ មីនា ២០០៥។

[117] សូមមើលបណ្តឹងលេខ៦៣៣/៩៥ រវាង *Gauthier* និងប្រទេសកាណាដា។

[118] សូមមើលសេចក្តីពន្យល់ទូទៅលេខ២៥(១៩៩៦) របស់គណៈកម្មាធិការស្តីពីមាត្រា២៥ (ការចូលរួមក្នុងកិច្ចការសាធារណៈ និងសិទ្ធិបោះឆ្នោត) កថាខ័ណ្ឌទី២៥ កំណត់ហេតុ ផ្លូវការរបស់មហាសន្និបាតអង្គការសហប្រជាជាតិ សម័យប្រជុំលើកទី៥១ សំណៅបន្ថែមលេខ៤០ vol. I (A/51/40 (Vol. I)), ឧបសម្ព័ន្ធទី V

[119] សូមមើលបណ្តឹងលេខ១៣៣៤/២០០៤ រវាង *Mavlonov and Sa'di* និងប្រទេសអ៊ុយបេគីស្ថាន

[120] សេចក្តីសង្កេតសន្និដ្ឋានសម្រាប់សាធារណៈរដ្ឋម៉ុលដូវ៉ា (CCPR/CO/75/MDA)។

អង្គភាពដទៃទៀត នៅពេលដែលអង្គភាពទាំងនោះ បំពេញមុខងារសាធារណៈ។ ដូចបានកត់សំគាល់រួចហើយ ដោយគួបផ្សំនឹងមាត្រា២៥ នៃកតិកាសញ្ញានេះ សិទ្ធិទទួលបានព័ត៌មាន រាប់ទាំងសិទ្ធិដែលប្រព័ន្ធផ្សព្វផ្សាយទទួលបានព័ត៌មានអំពីកិច្ចការសាធារណៈ [121] និងសិទ្ធិរបស់សាធារណៈជនទូទៅក្នុងការទទួលបានព័ត៌មានតាមប្រព័ន្ធផ្សព្វផ្សាយ។[122] ធាតុផ្សំនៃសិទ្ធិទទួលបានព័ត៌មាន ក៏មានចែងផងដែរក្នុងបញ្ញត្តិផ្សេងៗនៃកតិកាសញ្ញានេះ។ ដូចដែលគណៈកម្មាធិការបានសង្កេតឃើញនៅក្នុងអត្ថាធិប្បាយទូទៅរបស់ខ្លួនលេខ ១៦ ពាក់ព័ន្ធនឹងមាត្រា ១៧ នៃកតិកាសញ្ញានេះ បុគ្គលគ្រប់រូបគួរមានសិទ្ធិដឹងច្បាស់តាមទម្រង់មួយដែលងាយយល់ ថាតើមានការរក្សាទុកទិន្នន័យដែរឬទេ ហើយបើមានមែន តើទិន្នន័យផ្ទាល់ខ្លួនអ្វីខ្លះដែលត្រូវបានរក្សាទុកក្នុងសំណុំឯកសារទិន្នន័យស្វ័យប្រវត្តិ និងសម្រាប់គោលបំណងអ្វីខ្លះ? បុគ្គលគ្រប់រូបគួរតែអាចដឹងច្បាស់ផងដែរថាតើអាជ្ញាធរសាធារណៈ ឬ បុគ្គលឯកជន ឬស្ថាប័នឯកជនណាមួយមានសិទ្ធិពិនិត្យ ឬអាចពិនិត្យសំណុំឯកសាររបស់គាត់បាន។ ប្រសិនជាសំណុំឯកសារបែបនេះមានទិន្នន័យផ្ទាល់ខ្លួនដែលមិនត្រឹមត្រូវ ឬត្រូវបានប្រមូល ឬចាត់ឲ្យប្រើប្រាស់ផ្ទុយនឹងបញ្ញត្តិនៃច្បាប់បុគ្គលគ្រប់រូបគួរតែមានសិទ្ធិឲ្យគេធ្វើការកែតម្រូវសំណុំឯកសាររបស់ខ្លួនឡើងវិញ។ អនុលោមតាមមាត្រា ១០ នៃកតិកាសញ្ញានេះ ជនជាប់ឃុំមិនត្រូវបាត់បង់សិទ្ធិពិនិត្យមើលឯកសារពេទ្យរបស់ខ្លួនឡើយ។[123] នៅក្នុងអត្ថាធិប្បាយទូទៅលេខ ៣២ ពីមាត្រា ១៤ នៃកតិកាសញ្ញានេះ គណៈកម្មាធិការបានកំណត់ពីការមានសិទ្ធិផ្សេងៗក្នុងការទទួលបានព័ត៌មានដែលគ្រប់គ្រងដោយជនត្រូវចោទពីបទព្រហ្មទណ្ឌ។[124] អនុលោមតាមបញ្ញតិនៃមាត្រា ២ បុគ្គលគ្រប់រូបគួរមានសិទ្ធិទទួលបានព័ត៌មានទាក់ទងនឹងសិទ្ធិជាទូទៅរបស់ខ្លួនក្នុងកតិកាសញ្ញានេះ។ [125] តាមមាត្រា ២៧ ការធ្វើសេចក្តីសម្រេចណារបស់រដ្ឋភាគី ដែលធ្វើឲ្យប៉ះពាល់យ៉ាងខ្លាំងដល់របៀបរបបរស់នៅ និងវប្បធម៌របស់ក្រុមជនភាគតិចណាមួយគួរតែត្រូវធ្វើឡើងក្នុងដំណើរការមួយដែលមានការពិគ្រោះយោបល់ និងការចែករំលែកព័ត៌មានជាមួយសហគមន៍ដែលទទួលរងផលប៉ះពាល់។[126]

១៩. ដើម្បីធ្វើឲ្យមានប្រសិទ្ធភាពដល់សិទ្ធិទទួលបានព័ត៌មាន រដ្ឋភាគីគួររៀបចំឲ្យបានសកម្មជាងមុន ក្នុងការបញ្ចូលជាពត៌មានសាធារណៈ នូវព័ត៌មានរបស់រដ្ឋាភិបាលណាដែលទាក់ទងនឹងផលប្រយោជន៍សាធា-រណៈ។ រដ្ឋភាគីគួរប្រឹងប្រែងគ្រប់បែបយ៉ាងដើម្បីធានាឲ្យមានការទទួលបានដោយងាយស្រួល ឆាប់រហ័ស មានប្រសិទ្ធភាព និងជាក់ស្តែង នូវព័ត៌មានសាធារណៈនោះ។ រដ្ឋភាគីគួរអនុម័តផងដែរ នូវនីតិវិធីចាំបាច់ ដែលតាមរយៈនីតិវិធីនេះ គេអាចទទួលបានព័ត៌មានដូចជាអនុម័តច្បាប់ស្តីពីសេរីភាពខាងព័ត៌មានជាដើម។ [127] នីតិវិធីនេះគួរចែងអំពីចំណាត់ការឲ្យបានទាន់ពេលវេលា លើសំណើសុំព័ត៌មានស្របតាមវិធាន

---

[121] សូមមើលបណ្តឹងលេខ៦៣៣/៩៥ រវាង *Gauthier* និងប្រទេសកាណាដា។

[122] សូមមើលបណ្តឹងលេខ១៣៣៤/២០០៤ រវាង *Mavlonov and Sa'di* និងប្រទេសអ៊ុយបេគីស្ថាន

[123] សូមមើលបណ្តឹងលេខ៧២៦/១៩៩៦ រវាង *Zheludkov និងប្រទេសអ៊ុយក្រែន* ទស្សនយល់ឃើញអនុម័តកាលពីថ្ងៃទី២៩ តុលា ២០០២។

[124] សូមមើលសេចក្តីពន្យល់ទូទៅលេខ៣២(២០០៧) របស់គណៈកម្មាធិការស្តីពីសិទ្ធិស្មើភាពគ្នានៅចំពោះមុខច្បាប់ និងសាលាជម្រះក្តី និងសិទ្ធិទទួលបានសវនាការត្រឹមត្រូវមួយ កថាខ័ណ្ឌទី៣៣ កំណត់ហេតុផ្លូវការរបស់មហាសន្និបាតអង្គការសហប្រជាជាតិ សម័យប្រជុំលើកទី៦២ សំណៅបន្ថែមលេខ៤០ vol. I (A/62/40 (Vol. I)), ឧបសម្ព័ន្ធទី VI

[125] សូមមើលអត្ថាធិប្បាយទូទៅលេខ ៣១

[126] សូមមើលបណ្តឹងលេខ១៤៥៧/២០០៦ រវាង *Poma និងប្រទេសប៉េរូ* ទស្សនយល់ឃើញអនុម័តកាលពីថ្ងៃទី២៧ មីនា ២០០៩។

[127] សូមមើលសេចក្តីសង្កេតសន្និដ្ឋានសម្រាប់ប្រទេសអាហ្សែបៃហ្សាន (CCPR/C/79/Add.38 (1994)).

ច្បាស់លាស់ដែលស្របនឹងកតិកាសញ្ញានេះ។ កម្រែសម្រាប់ការស្នើសុំព័ត៌មាននេះមិនគួរបង្កជាឧបសគ្គមិនសមហេតុផលដល់លទ្ធភាពទទួលបានព័ត៌មានឡើយ។ អាជ្ញាធរគួរតែ ផ្តល់ហេតុផលចំពោះការបដិសេធណាមួយពីការមិនផ្តល់សិទ្ធិទទួលបានព័ត៌មាន។ ត្រូវរៀបចំឲ្យមានយន្តការប្តឹងតវ៉ានឹងការបដិសេធមិនផ្តល់សិទ្ធិទទួលបានព័ត៌មាន ក៏ដូចជាករណីមិនមានការឆ្លើយតបនឹងការស្នើសុំនេះ។

## សេរីភាពខាងការបញ្ចេញមតិ និងសិទ្ធិនយោបាយ

២០. នៅក្នុងអត្ថាធិប្បាយទូទៅលេខ ២៥ ស្តីពីការចូលរួមក្នុងកិច្ចការសាធារណៈ និងសិទ្ធិបោះឆ្នោតគណៈកម្មាធិការបានបរិយាយអំពីសារៈសំខាន់នៃសេរីភាពនៃការសម្តែងចេញសម្រាប់ការប្រព្រឹត្តទៅនៃកិច្ចការសាធារណៈ និងការប្រើប្រាស់សិទ្ធិបោះឆ្នោតប្រកបដោយប្រសិទ្ធភាព។ ការផ្តល់ឲ្យគ្នាដោយសេរីនូវព័ត៌មាន និងគំនិតអំពីបញ្ហាសាធារណៈ និងនយោបាយរវាងប្រជាពលរដ្ឋ បេក្ខជន និងតំណាងជាប់ឆ្នោតគឺជាការសំខាន់។ នេះសឲ្យឃើញថាសារព័ត៌មាន និងប្រព័ន្ធផ្សព្វផ្សាយដទៃទៀតដែលមានលក្ខណៈសេរីអាចធ្វើអត្ថាធិប្បាយអំពីបញ្ហាសាធារណៈ និងជួយឲ្យសាធារណជនបង្កើតមតិបានដោយគ្មានការត្រួតពិនិត្យ ឬការរិត ត្បិត។[128] រដ្ឋភាគីទាំងឡាយត្រូវចាប់អារម្មណ៍លើការណែនាំនៅក្នុងអត្ថាធិប្បាយទូទៅលេខ ២៥ ស្តីពីការលើកស្ទួយ និងការការពារសេរីភាពនៃការបញ្ចេញមតិក្នុងបរិបទនេះ។

## ការអនុវត្តមាត្រា១៩ (៣)

២១. កថាខ័ណ្ឌទី៣ ចែងយ៉ាងច្បាស់ថាការប្រើប្រាស់សិទ្ធិមានសេរីភាពនៃការសម្តែងចេញនាំមកជាមួយទាំងភារកិច្ច ទាំងការទទួលខុសត្រូវពិសេស។ ដោយសារហេតុនេះ វិស័យពីរនៃការរិតត្បិតសិទ្ធិនេះត្រូវបានអនុញ្ញាតដែលអាចទាក់ទងនឹងការគោរពសិទ្ធិ ឬកេរ្តិ៍ឈ្មោះរបស់អ្នកដទៃ ឬការការពារសន្តិសុខជាតិ ឬសណ្តាប់ធ្នាប់សាធារណៈ សីលធម៌ ឬសុខភាពសាធារណៈ។ ទោះជាយ៉ាងណាក៏ដោយ កាលណារដ្ឋភាគីដាក់ការរិតត្បិតទៅលើការប្រើប្រាស់សេរីភាពនៃការសម្តែងចេញ ការរិតត្បិតទាំងនេះមិនអាចធ្វើឲ្យអន្តរាយដល់សិទ្ធិនេះឡើយ។ គណៈកម្មាធិការរំលឹកថាទំនាក់ទំនងរវាងសិទ្ធិ និងការរិតត្បិត និងទំនាក់ទំនងរវាងបទដ្ឋាន និងការលើកលែងមិនត្រូវធ្វើបញ្ច្រាស់ឡើយ។ [129] គណៈកម្មាធិការក៏បានរំលឹកផងដែរអំពីបទប្បញ្ញត្តិនៃមាត្រា៥ កថាខ័ណ្ឌទី១ នៃកតិកាសញ្ញានេះ ដែលមានន័យថា "គ្មានបទបញ្ញត្តិណាមួយនៅក្នុងកតិកាសញ្ញានេះ អាចត្រូវបានបកស្រាយថាជាការតម្រូវឲ្យរដ្ឋណាមួយ ក្រុមណាមួយ ឬបុគ្គលណាម្នាក់មានសិទ្ធិចូលរួមធ្វើសកម្មភាព ឬប្រព្រឹត្តអំពើអ្វីមួយដែលសំដៅដល់ការបំផ្លិចបំផ្លាញណាមួយនៃសិទ្ធិ និងសេរីភាពដែលត្រូវបានទទួលស្គាល់នៅក្នុងកតិកាសញ្ញានេះ ឬសំដៅ ដល់ការរិតត្បិត ដែលមានវិសាលភាពធំជាងកម្រិតដែលមានចែងនៅក្នុងកតិកាសញ្ញានេះឡើយ"។

---

[128] សូមមើលអត្ថាធិប្បាយទូទៅលេខ ២៥ ស្តីពីមាត្រា ២៥ នៃកតិកាសញ្ញា កថាខ័ណ្ឌទី២៥

[129] សូមមើលអត្ថាធិប្បាយទូទៅលេខ២៧ របស់គណៈកម្មាធិការស្តីពីមាត្រា១២ កំណត់ហេតុផ្លូវការរបស់មហាសន្និបាតអង្គការសហប្រជាជាតិ សម័យប្រជុំលើកទី៥៥ សំណៅ បន្ថែមលេខ៤០ vol. I (A/55/40 (Vol. I)), ឧបសម្ព័ន្ធទី VI ផ្នែក-ក

២២. កថាខ័ណ្ឌទី៣ចែងអំពីលក្ខខណ្ឌជាក់លាក់មួយចំនួន ហើយមានតែតាមលក្ខខណ្ឌទាំងនេះទេទើប ការរិតត្បិតអាចធ្វើទៅបាន ៖ ការរិតត្បិតនេះត្រូវតែមាន"ចែងដោយច្បាប់" ការរិតត្បិតនេះទៀតសោត អាចធ្វើទៅបាន ដោយឈរលើហេតុផលមួយក្នុងចំណោមហេតុផលទាំងឡាយ ដែលមានចែងនៅក្នុងអនុកថាខ័ណ្ឌ (ក) និង (ខ) នៃកថាខ័ណ្ឌទី ៣ ហើយត្រូវតែស្របនឹងតេស្តដាច់ខាតអំពីភាពចាំបាច់ និងភាពសមាមាត្រ។[130] ការរិតត្បិតមិនត្រូវបានអនុញ្ញាតទេ បើហេតុផលទាំងឡាយដែលផ្តល់ឲ្យមិនមានចែងជាក់លាក់ដូចក្នុងកថាខ័ណ្ឌទី ៣ នោះ ទោះបីជាហេតុផលនោះអាចធ្វើយុត្តិកម្មដល់ការរិតត្បិត សិទ្ធិដទៃទៀតដែលត្រូវបានការពារក្នុងកតិកាសញ្ញានេះក៏ដោយ។ ការរិតត្បិតត្រូវតែយកមកអនុវត្ត បានតែសម្រាប់គោលបំណងទាំងឡាយដែលត្រូវបានបញ្ញត្តិ ហើយត្រូវតែទាក់ទងដោយផ្ទាល់នឹង សេចក្តីត្រូវការជាក់លាក់ដែលត្រូវបានលើសំអាងលើ។[131]

២៣. រដ្ឋភាគីគួរដាក់ចេញនូវវិធានការមានប្រសិទ្ធភាពដើម្បីការពារប្រឆាំងនឹងការវាយប្រហារដែលមានគោលដៅបំបិទមាត់អ្នកទាំងឡាយដែលប្រើប្រាស់សិទ្ធិសេរីភាពនៃការសម្តែងចេញ។ គេមិនអាចលើកយកកថាខ័ណ្ឌទី ៣ មកធ្វើជាយុត្តិកម្មជាដាច់ខាតដើម្បីរិតត្បិតការតស៊ូមតិណាមួយនៃលិទ្ធិប្រជាធិបតេយ្យពហុបក្ស គោលការណ៍ប្រជាធិបតេយ្យ និងសិទ្ធិមនុស្សឡើយ។[132] ហើយទោះស្ថិតក្នុងករណីណាក៏ដោយ ក៏ការវាយប្រហារលើបុគ្គលណាមួយដោយសារតែបុគ្គលនោះប្រើប្រាស់សេរីភាពនៃមតិ ឬការសម្តែងចេញរបស់គេឡើយ រាប់ទាំងតាមទម្រង់នៃការវាយប្រហារ ដូចជាការចាប់ខ្លួនតាមទំនើងចិត្ត ការធ្វើទារុណកម្ម ការគំរាមកំហែងដល់អាយុជីវិត និងការគំរាមសំលាប់ជាដើម មិនអាចស្របនឹងមាត្រា១៩បានទេ។[133] ជារឿយៗ អ្នកសារព័ត៌មានតែងតែរងការគំរាមកំហែង ការបំភិតបំភ័យ និងការវាយប្រហារបែបនេះ ព្រោះតែសកម្មភាពរបស់ពួកគេ។[134] ដូចគ្នា បុគ្គលទាំងឡាយដែលចូលរួមក្នុងការប្រមូល និងការវិភាគព័ត៌មានស្តីពីស្ថានភាពសិទ្ធិមនុស្ស និងដែលបោះពុម្ពផ្សាយរបាយការណ៍ពាក់ព័ន្ធនឹងសិទ្ធិមនុស្ស រាប់ទាំងចៅក្រម និងមេធាវីក៏រងការវាយប្រហារបែបនេះដែរ។[135] ការវាយប្រហារទាំងនេះគួរតែត្រូវបានធ្វើការស៊ើបអង្កេតឲ្យបានហ្មត់ចត់ ទាន់ពេលវេលា ហើយជនល្មើសត្រូវបានផ្តន្ទាទោសតាមច្បាប់[136] ហើយជនរងគ្រោះ ឬតំណាងជនរងគ្រោះ ក្នុងករណីឃាតកម្ម ត្រូវទទួលបានការដោះស្រាយតាមទម្រង់សមរម្យ។[137]

---

[130] សូមមើលបណ្តឹងលេខ១០២២/២០០១ រវាង *Velichkin* និងប្រទេសបេឡារ៉ុស ទស្សនៈយល់ឃើញអនុម័តកាលពីថ្ងៃទី២០ តុលា ២០០៥។

[131] សូមមើលអត្ថាធិប្បាយទូទៅលេខ២២ របស់គណៈកម្មាធិការ កំណត់ហេតុផ្លូវការរបស់មហាសន្និបាតអង្គការសហប្រជាជាតិ សម័យប្រជុំលើកទី៤៨ សំណៅបន្ថែមលេខ៤០ (A/48/40), ឧបសម្ព័ន្ធទី VI

[132] សូមមើលបណ្តឹងលេខ៤៥៨/៩១ រវាង *Mukong* និងប្រទេសកាមារូន ទស្សនៈយល់ឃើញអនុម័តកាលពីថ្ងៃទី២១ កក្កដា ១៩៩៤។

[133] សូមមើលបណ្តឹងលេខ១៣៥៣/២០០៥ រវាង *Njaru* និងប្រទេសកាមារូន ទស្សនៈយល់ឃើញអនុម័តកាលពីថ្ងៃទី១៩ មីនា ២០០៧។

[134] ជាឧទាហរណ៍ សូមមើលសេចក្តីសង្កេតសន្និដ្ឋានសម្រាប់ប្រទេសអាល់ហ្សេរី (CCPR/C/DZA/CO/3) សេចក្តីសង្កេតសន្និដ្ឋានសម្រាប់ប្រទេសកូស្តារីកា (CCPR/C/CRI/CO/5) និងសេចក្តីសង្កេតសន្និដ្ឋានសម្រាប់ប្រទេសស៊ូដង់ (CCPR/C/SDN/CO/3)

[135] សូមមើលបណ្តឹងលេខ១៣៥៣/២០០៥ រវាង *Njaru* និងប្រទេសកាមារូន សេចក្តីសង្កេតសន្និដ្ឋានសម្រាប់ប្រទេសនីការ៉ាហ្គ័រ (CCPR/C/NIC/CO/3) សេចក្តីសង្កេតសន្និដ្ឋាន សម្រាប់ប្រទេសទុយនេស៊ី (CCPR/C/TUN/CO/5) សេចក្តីសង្កេតសន្និដ្ឋានសម្រាប់សាធារណៈរដ្ឋអារ៉ាប់ស៊ីរី (CCPR/CO/84/SYR) និងសេចក្តីសង្កេតសន្និដ្ឋានសម្រាប់ប្រទេសកូឡុំប៊ី (CCPR/CO/80/COL)

[136] ដូចខាងលើ និងសូមមើលសេចក្តីសង្កេតសន្និដ្ឋានសម្រាប់ប្រទេសហ្សកហ្ស៊ី (CCPR/C/GEO/CO/3)

[137] សូមមើលសេចក្តីសង្កេតសន្និដ្ឋានសម្រាប់ប្រទេសហ្គុយយ៉ាណា (CCPR/C/79/Add.121)

២៤. ការរិតត្បិតត្រូវតែមានចែងដោយច្បាប់។ ច្បាប់អាចរាប់ទាំងច្បាប់ស្តីពីបុព្វសិទ្ធិសភា[138] និងច្បាប់ស្តីពីការប្រមាថតុលាការ។[139] ដោយសារតែការរិតត្បិតណាមួយលើសេរីភាពនៃការបញ្ចេញមតិបង្កើតជាការកាត់បន្ថយធ្ងន់ធ្ងរមួយលើសិទ្ធិមនុស្ស វាមិនស្របនឹងកតិកាសញ្ញានេះទេ ចំពោះការរិតត្បិតណាមួយដែលមានចែងក្នុងច្បាប់ប្រពៃណី សាសនា ឬច្បាប់ទំនៀមទំលាប់ដទៃទៀត។[140]

២៥. សម្រាប់គោលបំណងនៃកថាខ័ណ្ឌទី ៣ បទដ្ឋានមួយដែលត្រូវបានចាត់ទុកថាជា"ច្បាប់" ត្រូវតែបានតាក់តែងឡើងឲ្យមានភាពជាក់ច្បាស់គ្រប់គ្រាន់ ដើម្បីឲ្យបុគ្គលម្នាក់ៗអាចរៀបចំកិរិយារបស់គេទៅតាមនោះ[141] ហើយច្បាប់នោះត្រូវងាយយល់និងដឹងដល់សាធារណៈជន។ ច្បាប់មិនអាចផ្តល់ឆន្ទានុសិទ្ធិគ្មានព្រំដែនដើម្បីរិតត្បិតសេរីភាពនៃការសម្តែងចេញដល់បុគ្គលណាដែលទទួលបន្ទុកអនុវត្តច្បាប់នោះឡើយ។ [142] ច្បាប់ត្រូវតែចង្អុលផ្លូវឲ្យបានគ្រប់គ្រាន់ដល់បុគ្គលដែលទទួលបន្ទុកអនុវត្តច្បាប់នោះ ដើម្បីឲ្យពួកគេដឹងច្បាស់ថា ការសម្តែងចេញបែបណាដែលត្រូវបានរិតត្បិតយ៉ាងត្រឹមត្រូវ ហើយការបញ្ចេញមតិបែបណាដែលត្រូវបានរិតត្បិតមិនត្រឹមត្រូវ។

២៦. ច្បាប់ដែលរិតត្បិតសិទ្ធិនានាដូចបានរៀបរាប់ក្នុងមាត្រា ១៩ កថាខ័ណ្ឌទី ២ រាប់ទាំងច្បាប់ដែលបានបញ្ជាក់ក្នុងកថាខ័ណ្ឌទី២៤ខាងលើ មិនត្រឹមតែត្រូវស្របតាមលក្ខខណ្ឌតម្រូវដ៏តឹងរឹងនៃមាត្រា១៩ កថាខណ្ឌទី ៣ នៃកតិកាសញ្ញានេះប៉ុណ្ណោះទេ ប៉ុន្តែច្បាប់នេះក៏ត្រូវតែស្របជាមួយបទប្បញ្ញត្តិ គោលដៅ និងគោលបំណងនៃកតិកាសញ្ញានេះផងដែរ។ [143] ច្បាប់ទាំងនេះ មិនត្រូវរំលោភបំពានលើបញ្ញត្តិមិនរើសអើង នៃកតិកាសញ្ញានេះឡើយ។ ច្បាប់ទាំងនេះ មិនត្រូវចែងពីទោសទណ្ឌដែលមិនស្របតាមកតិកាសញ្ញានេះឡើយ ជាអាទិ៍ ទណ្ឌកម្មលើរូបរាងកាយជាដើម។[144]

២៧. រដ្ឋភាគី ត្រូវជាប់បន្ទុកបង្ហាញពីមូលដ្ឋានច្បាប់សម្រាប់ការរិតត្បិតណាមួយលើសេរីភាពនៃការសម្តែងចេញ។[145] ទាក់ទងនឹងរដ្ឋភាគីដោយឡែកណាមួយ ប្រសិនបើគណៈកម្មាធិការ ត្រូវពិចារណាថាតើការរិតត្បិតដោយឡែកនោះ មានកំណត់ដោយច្បាប់ឬទេនោះ រដ្ឋភាគីនោះគួរផ្តល់សេចក្តីពន្យល់លំអិតអំពីច្បាប់និងវិធានការ ដែលស្ថិតក្នុងវិសាលភាពនៃច្បាប់នោះ។[146]

២៨. ហេតុផលធម្មានុរូបទីមួយសម្រាប់ការរិតត្បិតសិទ្ធិ ដូចមានចែងក្នុងកថាខ័ណ្ឌទី៣ គឺការគោរពសិទ្ធិ ឬកិត្តិសព្ទរបស់អ្នកដទៃ។ ពាក្យ"សិទ្ធិ" រាប់មានសិទ្ធិមនុស្សដូចបានទទួលស្គាល់ក្នុងកតិកាសញ្ញានេះ និងទទួលស្គាល់ទូទៅជាងនេះទៅទៀតនៅក្នុងច្បាប់សិទ្ធិមនុស្សអន្តរជាតិ។ ឧទាហរណ៍ ការរិតត្បិតសេរីភាព

---

[138] សូមមើលបណ្តឹងលេខ៦៣៣/៩៥ រវាង *Gauthier* និងប្រទេសកាណាដា។

[139] សូមមើលបណ្តឹងលេខ១៣៧៣/២០០៥ រវាង *Dissanayake* និងប្រទេសស្រីលង្កា ទស្សនៈយល់ឃើញអនុម័តកាលពីថ្ងៃទី២២ កក្កដា ២០០៨។

[140] សូមមើលសេចក្តីពន្យល់ទូទៅលេខ ៣២

[141] សូមមើលបណ្តឹងលេខ៥៧៨/១៩៩៤ រវាង *de Groot* និងប្រទេសហូឡង់ ទស្សនៈយល់ឃើញអនុម័តកាលពីថ្ងៃទី១៤ កក្កដា ១៩៩៥។

[142] សូមមើលអត្ថាធិប្បាយទូទៅលេខ ២៧

[143] សូមមើលបណ្តឹងលេខ៤៨៨/១៩៩២ រវាង *Toonen* និងប្រទេសអូស្ត្រាលី ទស្សនៈយល់ឃើញអនុម័តកាលពីថ្ងៃទី៣០ មីនា ១៩៩៤។

[144] សូមមើលសេចក្តីពន្យល់ទូទៅលេខ ២០ របស់គណៈកម្មាធិការ កំណត់ហេតុផ្លូវការរបស់មហាសន្និបាតអង្គការសហប្រជាជាតិ សម័យប្រជុំលើកទី ៤៧ សំណៅបន្ថែមលេខ៤០ (A/47/40), ឧបសម្ព័ន្ធទី VI ផ្នែកក

[145] សូមមើលបណ្តឹងលេខ១៥៥៣/២០០៧ រវាង *Korneenko et al* និងប្រទេសបេឡារូស ទស្សនៈយល់ឃើញអនុម័តកាលពីថ្ងៃទី៣១ តុលា ២០០៦។

[146] សូមមើលបណ្តឹងលេខ១៣២/១៩៨២ រវាង *Jaona* និងប្រទេសម៉ាដាហ្គាស្កា ទស្សនៈយល់ឃើញអនុម័តកាលពីថ្ងៃទី១ មេសា ១៩៨៥។

នៃការសម្តែងចេញ អាចជាធម្មានុរូបបាន ដើម្បីការពារសិទ្ធិបោះឆ្នោតក្រោមមាត្រា ២៥ ក៏ដូចជាសិទ្ធិទាំងឡាយក្រោមមាត្រា ១៧ (សូមមើលកថាខ័ណ្ឌ ៣៧ ខាងក្រោម)។[147] ការរិតត្បិតបែបនេះ ត្រូវតែសរសេរដោយប្រុងប្រយ័ត្ន ៖ ទន្ទឹមនឹងការរិតត្បិតនេះអាចត្រូវអនុញ្ញាតិដើម្បីការពារអ្នកបោះឆ្នោតកុំឲ្យបញ្ចេញមតិតាមទម្រង់ណាដែលបង្កឲ្យមានការបំភិតបំភ័យ ឬការបង្ខិតបង្ខំ ការរិតត្បិតបែបនេះមិនត្រូវរារាំងដល់ការជជែកដេញដោលគ្នាខាងនយោបាយ ឧទាហរណ៍ ដូចជាការអំពាវនាវឲ្យធ្វើ ពហិកាការបោះឆ្នោតដែលមិនបង្ខំ។[148] ពាក្យ"អ្នកដទៃ" សំដៅដល់បុគ្គលផ្សេងទៀតជាឯកត្តបុគ្គលក្តី ជាសមាជិកសហគមន៍ក្តី។[149] ដូច្នេះជាតួយ៉ាង ពាក្យនេះសំដៅដល់សមាជិកសហគមន៍ម្នាក់ៗ ដែលកំណត់ន័យដោយជំនឿសាសនា[150] ឬជាតិពន្ធុរបស់គេ។[151]

២៩. ហេតុផលធម្មានុរូបទីពីរគឺ ការការពារសន្តិសុខជាតិ ឬសណ្តាប់ធ្នាប់សាធារណៈ សីលធម៌ ឬសុខភាពសាធារណៈ។

៣០. រដ្ឋភាគីត្រូវយកចិត្តទុកដាក់បំផុតដើម្បីធានាថាច្បាប់ស្តីពីទោសក្បត់ជាតិ[152] និងបទប្បញ្ញត្តិស្រដៀងគ្នាទាក់ទងនឹងសន្តិសុខជាតិ ទោះជាហៅថាច្បាប់ស្តីពីការសម្ងាត់ផ្លូវការ ឬច្បាប់ស្តីពីការញុះញង់ឲ្យបះបោរ ឬហៅជាអ្វីផ្សេងពីនេះក៏ដោយ ត្រូវបានតាក់តែងឡើង និងអនុវត្តក្នុងលក្ខណៈមួយ ស្របតាមលក្ខខណ្ឌ តម្រូវដ៏តឹងរឹងនៃកថាខ័ណ្ឌទី ៣។ ឧទាហរណ៍ វាមិនស្របគ្នានឹងកថាខ័ណ្ឌទី ៣ នេះទេ ក្នុងការបង្កើតច្បាប់បែបនេះដើម្បីគាបសង្កត់ ឬដកហូតការផ្តល់ព័ត៌មានជាសាធារណៈដែលបម្រើឲ្យផលប្រយោជន៍សាធារណៈត្រឹមត្រូវ ដែលមិនប៉ះពាល់ដល់សន្តិសុខជាតិ ឬដើម្បីផ្តន្ទាទោសអ្នកសារព័ត៌មាន អ្នកស្រាវជ្រាវ សកម្មជនបរិស្ថាន អ្នកការពារសិទ្ធិមនុស្ស ឬអ្នកដទៃផ្សេងទៀត ដោយសារតែបានផ្សព្វផ្សាយព័ត៌មានបែបនេះ។[153]ម្យ៉ាងវិញទៀត ជាទូទៅ វាមិនសមស្របក្នុងការបញ្ចូលទៅក្នុងច្បាប់នេះទេ នូវប្រភេទព័ត៌មានទាំងឡាយដែលទាក់ទងនឹងវិស័យពាណិជ្ជកម្ម ធនាគារ និងការរីកចំរើនផ្នែកវិទ្យាសាស្ត្រនោះ។[154] គណៈកម្មាធិការបានរកឃើញក្នុងករណីមួយថា ការរិតត្បិតទៅលើការចេញសេចក្តីថ្លែងការណ៍មួយគាំទ្រដល់វិវាទការងារ រាប់ទាំងការកោះប្រជុំឲ្យមានកូដកម្មជាតិមួយមិនត្រូវបានអនុញ្ញាត ដោយផ្អែកលើហេតុផលសន្តិសុខជាតិ។[155]

---

[147]សូមមើលបណ្តឹងលេខ៩២៧/២០០០ រវាង *Svetik* និងប្រទេសបេឡារុស ទស្សនៈយល់ឃើញអនុម័តកាលពីថ្ងៃទី៨ កក្កដា ២០០៤។

[148]ដូចខាងលើ

[149]សូមមើលបណ្តឹងលេខ៧៣៦/៩៧ រវាង *Ross* និងប្រទេសកាណាដា ទស្សនៈយល់ឃើញអនុម័តកាលពីថ្ងៃទី១៨ តុលា ២០០០។

[150]សូមមើលបណ្តឹងលេខ៥៥០/៩៣ រវាង *Faurisson* និងប្រទេសបារាំង សេចក្តីសង្កេតសន្និដ្ឋានសម្រាប់ប្រទេសអូទ្រីស (CCPR/C/AUT/CO/4)

[151] សេចក្តីសង្កេតសន្និដ្ឋានសម្រាប់ប្រទេសស្លូវ៉ាគី (CCPR/CO/78/SVK); សេចក្តីសង្កេតសន្និដ្ឋានសម្រាប់ប្រទេសអ៊ីស្រាអែល (CCPR/CO/78/ISR)

[152] សេចក្តីសង្កេតសន្និដ្ឋានសម្រាប់កោះហុងកុង (CCPR/C/HKG/CO/2)

[153] សេចក្តីសង្កេតសន្និដ្ឋានសម្រាប់សហព័ន្ធរុស្សី (CCPR/CO/79/RUS)

[154] សេចក្តីសង្កេតសន្និដ្ឋានសម្រាប់ប្រទេសអ៊ុយបេគីស្ថាន (CCPR/CO/71/UZB)

[155] សូមមើលបណ្តឹងលេខ៥១៨/១៩៩២ រវាង *Sohn* និងសាធារណៈរដ្ឋកូរ៉េ ទស្សនៈយល់ឃើញអនុម័តកាលពីថ្ងៃទី១៨ មីនា ១៩៩៥។

៣១. ឈរលើមូលដ្ឋាននៃការរក្សាសណ្តាប់ធ្នាប់សាធារណៈ ជាឧទាហរណ៍ អាចត្រូវអនុញ្ញាតក្នុងករណីមួយចំនួនដើម្បីដាក់បញ្ញត្តិលើការនិយាយស្តីនៅកន្លែងសាធារណៈណាមួយ។[156] ការចាត់ការពីបទប្រមាថតុលាការទាក់ទងនឹងការសម្តែងចេញតាមទម្រង់ណាមួយ អាចត្រូវធ្វើបានដោយសារហេតុផលសណ្តាប់ធ្នាប់សាធារណៈ។ ដើម្បីឲ្យស្របតាមកថាខ័ណ្ឌទី ៣ គេត្រូវបង្ហាញថាការចាត់ការពីបទប្រមាថតុលាការ និងការដាក់ទោសទណ្ឌពីបទនេះ អាចធ្វើទៅបានតែក្នុងការអនុវត្តអំណាចតុលាការដើម្បីរក្សានីតិវិធីតុលាការឲ្យបានរៀបរយប៉ុណ្ណោះ។[157] ការចាត់ការបែបនេះ មិនគួរត្រូវបានប្រើប្រាស់ ទោះតាមវិធីណាក៏ដោយ ដើម្បីរិតត្បិតការអនុវត្តជាធម្មានរូបនៃសិទ្ធិការពារនោះឡើយ។

៣២. នៅក្នុងអត្ថាធិប្បាយទូទៅលេខ ២២ គណៈកម្មាធិការបានសង្កេតថា "ទស្សនៈខាងសីលធម៌មានប្រភពចេញមកពីប្រពៃណីជាច្រើន ផ្នែកសង្គម ទស្សនៈវិជ្ជា និងសាសនា ដូច្នេះការរិតត្បិត... សម្រាប់គោលបំណងនៃការការពារសីលធម៌ ត្រូវតែផ្អែកលើគោលការណ៍ផ្សេងៗដែលមិនមែនកើតចេញពីប្រពៃណីណាមួយដាច់មុខនោះទេ"។ ការរិតត្បិតណាមួយដូចនេះ ត្រូវតែគិតតាមស្មារតីនៃសកលភាពនៃសិទ្ធិមនុស្ស និងគោលការណ៍មិនរើសអើង។

៣៣. ការរិតត្បិតត្រូវតែមានភាព "ចាំបាច់" សម្រាប់គោលបំណងជាធម្មានរូប។ ដូច្នេះ ឧទាហរណ៍បម្រាមលើការផ្សាយពាណិជ្ជកម្មតាមភាសាមួយ ដោយមានគោលដៅការពារភាសារបស់សហគមន៍ជាក់លាក់មួយ គឺរំលោភលើលក្ខខណ្ឌនៃភាពចាំបាច់ ប្រសិនជាការការពារនេះ អាចសម្រេចបានតាមវិធីមួយផ្សេងទៀតដែលមិនរិតត្បិតដល់សេរីភាពនៃការសម្តែងមតិ។[158] ម្យ៉ាងវិញទៀតគណៈកម្មាធិការបានពិចារណាថា រដ្ឋភាគីមួយបានគោរពតាមលក្ខខណ្ឌនៃភាពចាំបាច់នៅពេលដែលរដ្ឋនោះបានផ្ទេរគ្រូបង្រៀនមួយរូប ដែលបានបោះពុម្ពផ្សាយសម្ភារៈសិក្សាដែលបង្ហាញពីអរិយភាពចំពោះសហគមន៍សាសនាមួយឲ្យទៅកាន់មុខតំណែងមួយទៀតដែលមិនបង្រៀនដើម្បីការពារសិទ្ធិ និងសេរីភាពរបស់កុមារដែលកាន់ជំនឿសាសនានោះនៅសាលារៀនក្នុងស្រុកមួយ។[159]

៣៤. ការរិតត្បិត មិនត្រូវមានវិសាលភាពធំធេងហួសពេកឡើយ។ នៅក្នុងអត្ថាធិប្បាយទូទៅលេខ ២៧ គណៈកម្មាធិការបានសង្កេតថា "វិធានការរិតត្បិតត្រូវតែស្របតាមគោលការណ៍នៃភាពសមាមាត្រ"។ វិធានការទាំងនេះត្រូវតែសមស្របដើម្បីសម្រេចបាននូវមុខងារការពាររបស់ខ្លួន។ វិធានការទាំងនេះត្រូវតែជាឧបករណ៍ដែលមានការបំពានតិចតួចបំផុតក្នុងចំណោមវិធានការរិតត្បិតទាំងឡាយ ដែលអាច សម្រេចបាននូវមុខងារការពាររបស់ខ្លួន។ វិធានការរិតត្បិត ត្រូវតែសមាមាត្រនឹងផលប្រយោជន៍ដែលត្រូវការពារ។ គោលការណ៍នៃភាពសមាមាត្រត្រូវតែទទួលបានការគោរព មិនត្រឹមតែក្នុងច្បាប់ដែលកំណត់ពីការរិតត្បិតប៉ុណ្ណោះទេ ប៉ុន្តែថែមទាំងត្រូវទទួលបានការគោរពដោយអាជ្ញាធររដ្ឋបាល និងអាជ្ញាធរតុលាការក្នុងការអនុ

---

[156] សូមមើលបណ្តឹងលេខ១១៥៧/២០០៣ រវាង *Coleman* និងប្រទេសអូស្ត្រាលី។

[157] សូមមើលបណ្តឹងលេខ១៣៧៣/២០០៥ រវាង *Dissanayake* និងប្រទេសស្រីលង្កា។

[158] សូមមើលបណ្តឹងលេខ៣៥៩/១៩៨៩ និងបណ្តឹងលេខ៣៨៥/១៩៨៩ រវាង *Ballantyne, Davidson និង McIntyre និងប្រទេសកាណាដា។ [ហាមមិនឲ្យផ្សាយជាភាសាអង់គ្លេស ព្រោះខ្លាចបាត់បង់ភាសាអង់គ្លេសនៃសហគមន៍នោះ]*

[159] សូមមើលបណ្តឹងលេខ៧៣៦/៩៧ រវាង *Ross* និងប្រទេសកាណាដា ទស្សនៈយល់ឃើញអនុម័តកាលពីថ្ងៃទី១៨ តុលា ២០០០។

វគ្គច្បាប់នេះ។ [160] គោលការណ៍នៃភាពសមាមាត្រ ក៏ត្រូវពិចារណាផងដែរអំពីទម្រង់នៃការបញ្ចេញមតិពីបញ្ហាអ្វីមួយ ក៏ដូចជាមធ្យោបាយនៃការផ្សព្វផ្សាយព័ត៌មានរបស់ខ្លួន។ ឧទាហរណ៍ កតិកាសញ្ញានេះបានផ្តល់តម្លៃយ៉ាងខ្ពស់ជាពិសេស ដល់ការបញ្ចេញមតិដោយចំហក្នុងកាលៈទេសៈនៃការជជែកដេញដោលជាសាធារណៈនៅក្នុងសង្គមប្រជាធិបតេយ្យ ទាក់ទងនឹងឥស្សរជនក្នុងជួរនយោបាយ និងក្នុងមុខងារសាធារណៈ។[161]

៣៥. នៅពេលដែលរដ្ឋភាគីមួយសំអាងហេតុផលស្របច្បាប់ សម្រាប់ការរឹតត្បិតសេរីភាពនៃការបញ្ចេញមតិ រដ្ឋនោះត្រូវតែបង្ហាញពីរបៀបមួយជាក់លាក់ និងមួយៗដាច់ដោយឡែក អំពីចរិតលក្ខណៈច្បាស់លាស់នៃការគំរាមកំហែង ព្រមទាំងភាពចាំបាច់និងភាពសមាមាត្រនៃវិធានការជាក់លាក់ណាមួយដែលបានចាត់ឡើងជាពិសេស ដោយបង្កើតនូវទំនាក់ទំនងដោយផ្ទាល់ និងជាបន្ទាន់រវាងការបញ្ចេញមតិ និងការគំរាមកំហែង។[162]

៣៦. គណៈកម្មាធិការរក្សាសិទ្ធិរបស់ខ្លួនក្នុងការវាយតម្លៃថាតើ ក្នុងស្ថានភាពជាក់លាក់មួយ អាចមាន កាលៈទេសៈដែលនាំឲ្យការរឹតត្បិតសេរីភាពនៃការបញ្ចេញមតិមានភាពចាំបាច់ឬទេ។ [163] ដូច្នេះគណៈកម្មាធិការរំលឹកថា វិសាលភាពនៃសេរីភាពនេះមិនត្រូវបានធ្វើការវាយតម្លៃដោយយោងទៅលើ "ឆន្ទានុសិទ្ធិក្នុងការវិនិច្ឆ័យ"[164]នោះទេ ហើយដើម្បីឲ្យគណៈកម្មាធិការបំពេញមុខងារនេះបាន រដ្ឋភាគីក្នុងករណីជាក់លាក់មួយត្រូវបង្ហាញឲ្យបានច្បាស់លាស់អំពីចរិតលក្ខណៈជាក់លាក់នៃការគំរាមកំហែងដល់ហេតុផលណាមួយ ដែលបានរៀបរាប់ក្នុងកថាខ័ណ្ឌទី ៣ ដែលបាននាំឲ្យខ្លួនត្រូវតែរឹតត្បិតសេរីភាពនៃការបញ្ចេញមតិ។[165]

**វិសាលភាពមានកម្រិតនៃការរឹតត្បិតលើសេរីភាពនៃការបញ្ចេញមតិក្នុងវិស័យជាក់លាក់មួយចំនួន**

៣៧. ក្នុងចំណោមការរឹតត្បិតទៅលើការនិយាយរឿងនយោបាយ ដែលជាបុព្វហេតុធ្វើឲ្យគណៈកម្មាធិការមានកង្វល់នោះ គឺបម្រាមស្វែងរកសំឡេងគាំទ្រតាមផ្ទះ [166] ការរឹតត្បិតលើចំនួន និងប្រភេទនៃអត្ថបទជាលាយលក្ខណ៍អក្សរដែលអាចត្រូវបានចែកចាយនៅក្នុងអំឡុងពេលយុទ្ធនាការបោះឆ្នោត [167] ការរារាំងលទ្ធភាពប្រើប្រាស់ប្រភពផ្សេងៗ នៅក្នុងអំឡុងពេលបោះឆ្នោត រាប់ទាំងប្រព័ន្ធផ្សព្វផ្សាយព័ត៌មានជាតិ និងអន្តរ

---

[160] សូមមើលអត្ថាធិប្បាយទូទៅលេខ២៧ កថាខ័ណ្ឌទី១៥។ សូមមើលផងដែរបណ្តឹងលេខ១១២៨/២០០២ រវាង *Marques* និងប្រទេសអង់ហ្គោឡា និងបណ្តឹងលេខ ១១៥៧/២០០៣ រវាង *Coleman* និងប្រទេសអូស្ត្រាលី។

[161] សូមមើលបណ្តឹងលេខ១១៨០/២០០៣ រវាង *Bodrozic* និងប្រទេសសែបប៊ី និងម៉ុងតេណេហ្គ្រូ ទស្សនៈយល់ឃើញអនុម័តកាលពីថ្ងៃទី៣១ តុលា ២០០៥។

[162] សូមមើលបណ្តឹងលេខ៩២៦/២០០០ រវាង *Shin* និងសាធារណៈរដ្ឋកូរ៉េ

[163] សូមមើលបណ្តឹងលេខ៥១៨/១៩៩២ រវាង *Sohn* និងសាធារណៈរដ្ឋកូរ៉េ

[164] សូមមើលបណ្តឹងលេខ៥១១/១៩៩២ រវាង *Ilmari Länsman et al* និងប្រទេសហ្វាំងឡង់ ទស្សនៈយល់ឃើញអនុម័តកាលពីថ្ងៃទី១៤ តុលា ១៩៩៣

[165] សូមមើលបណ្តឹងលេខ៥១៨/១៩៩២ រវាង *Sohn* និងសាធារណៈរដ្ឋកូរ៉េ និងបណ្តឹងលេខ៩២៦/២០០០ រវាង *Shin* និងសាធារណៈរដ្ឋកូរ៉េ

[166] សេចក្តីសង្កេតសន្និដ្ឋានសម្រាប់ប្រទេសជប៉ុន(CCPR/C/JPN/CO/5)។

[167] ដូចខាងលើ

ជាតិ ពីបទអត្ថាធិប្បាយនយោបាយ[168] និងការកំរិតលទ្ធភាពរបស់អ្នកនយោបាយ និងគណបក្សប្រឆាំង ក្នុងការប្រើប្រាស់កាណាល់នៃប្រព័ន្ធផ្សព្វផ្សាយព័ត៌មាន។ [169] រាល់ការរិតត្បិតគួរតែធ្វើស្របតាមកថាខ័ណ្ឌទី ៣។ ទោះជាយ៉ាងណាក៏ដោយ វាអាចមានភាពសមស្របសម្រាប់រដ្ឋភាគីក្នុងការរិតត្បិតការស្ទង់មតិនយោបាយដែលធ្វើកៀកថ្ងៃបោះឆ្នោត ដើម្បីរក្សាសុចរិតភាពនៃដំណើរការបោះឆ្នោត។[170]

៣៨. ដូចបានកត់សំគាល់ពីខាងដើមក្នុងកថាខ័ណ្ឌទី ១៣ និងទី ២០ ទាក់ទងនឹងខ្លឹមសារនៃការពិភាក្សាគ្នាពីរឿងនយោបាយ គណៈកម្មាធិការបានសង្កេតឃើញថា ក្នុងឱកាសនៃការជជែកដេញដោយជាសាធារណៈអំពីឥស្សរជនសាធារណៈក្នុងវិស័យនយោបាយ និងស្ថាប័នសាធារណៈ កតិកាសញ្ញានេះបានឲ្យតម្លៃ ខ្ពស់ជាពិសេសទៅលើការបញ្ចេញមតិដោយសេរី។[171] ដូច្នេះ ការដែលទម្រង់នៃការបញ្ចេញមតិខ្លះត្រូវបានគេចាត់ទុកជាការជេរប្រមាថដល់បុគ្គលសាធារណៈមួយនោះ គឺមិនគ្រប់គ្រាន់ទេ ក្នុងការធ្វើយុត្តិកម្មសម្រាប់ការដាក់ទោសទណ្ឌ សូម្បីតែបុគ្គលសាធារណៈ អាចទទួលបានប្រយោជន៍ផងដែរ ពីបទប្បញ្ញត្តិនៃកតិកាសញ្ញានេះក៏ដោយ។[172] លើសពីនេះទៅទៀត បុគ្គលសាធារណៈទាំងអស់ រួមមានបុគ្គលទាំងឡាយដែលប្រើប្រាស់អំណាចនយោបាយខ្ពស់បំផុត ដូចជាប្រមុខរដ្ឋ និងប្រមុខរដ្ឋាភិបាលជាដើម ត្រូវតែជាកម្មវត្ថុជាធម្មានុរូបនៃការរិះគន់ និងការប្រឆាំងផ្នែកនយោបាយ។[173] អាស្រ័យហេតុនេះ គណៈកម្មាធិការសម្តែងការព្រួយបារម្ភអំពីច្បាប់នានាស្តីពីបញ្ហាបែបនេះ ដូចជាការមិនគោរព ព្រះចេស្តា[174] ការប្រមាថអ្នកធំ[175] ការមិនគោរពអាជ្ញាធរ[176] ការមិនគោរពទង់ជាតិ និងនិមិត្តសញ្ញាជាតិ ការបរិហារកេរ្តិ៍ប្រមុខរដ្ឋ[177] និងការការពារកិត្តិយសមន្ត្រីសាធារណៈ[178] ហើយច្បាប់ទាំងនេះ មិនត្រូវចែងពីការដាក់ទោសទណ្ឌធ្ងន់ធ្ងរថែមទៀត ដោយគ្រាន់តែផ្អែកលើអត្តសញ្ញាណរបស់បុគ្គលដែលអាចរងការវាយប្រហារនោះឡើយ។ រដ្ឋភាគីមិនគួរហាមប្រាមការរិះគន់ស្ថាប័នផ្សេងៗ ដូចជាស្ថានប័នរដ្ឋ បាល ឬស្ថាប័នយោធាជាដើម។[179]

៣៩. រដ្ឋភាគីគួរធានាថា ក្របខ័ណ្ឌច្បាប់ និងរដ្ឋបាលសម្រាប់ការធ្វើនិយតកម្មពីប្រព័ន្ធផ្សព្វផ្សាយព័ត៌មានមហាជន ត្រូវស្របតាមបទប្បញ្ញត្តិនៃកថាខ័ណ្ឌ ៣។[180] ប្រព័ន្ធនិយតកម្មគួរយកមកពិចារណាពីភាពខុសប្លែកគ្នារវាងវិស័យបោះពុម្ព និងចាក់ផ្សាយ និងប្រព័ន្ធអ៊ីនធឺណែត ទន្ទឹមនឹងការកត់សំគាល់ផងដែរអំពីរបៀប

---

[168] សេចក្តីសង្កេតសន្និដ្ឋានសម្រាប់ប្រទេសទុយនេស៊ី (CCPR/C/TUN/CO/5)។

[169] សេចក្តីសង្កេតសន្និដ្ឋានសម្រាប់ប្រទេសតូហ្គោ(CCPR/CO/76/TGO) និងសេចក្តីសង្កេតសន្និដ្ឋានសម្រាប់ប្រទេសមុលដូវ៉ា (CCPR/CO/75/MDA)។

[170] សូមមើលបណ្តឹងលេខ៥៦៨/២០០១ រវាង *Kim* និងសាធារណៈរដ្ឋកូរ៉េ ទស្សនៈយល់ឃើញអនុម័តកាលពីថ្ងៃទី១៤ មីនា ១៩៩៦។

[171] សូមមើលបណ្តឹងលេខ១១៨០/២០០៣ រវាង *Bodrozic* និងប្រទេសសែបប៊ី និងម៉ុងតេណេហ្គ្រូ ទស្សនៈយល់ឃើញអនុម័តកាលពីថ្ងៃទី៣១ តុលា ២០០៥។

[172] ដូចខាងលើ

[173] សូមមើលបណ្តឹងលេខ១១២៨/២០០២ រវាង *Marques* និងប្រទេសអង់ហ្គោឡា

[174] សូមមើលបណ្តឹងលេខ៤២២-៤២៤/១៩៩០ រវាង *Aduayom et al.* និងប្រទេសតូហ្គូ ទស្សនៈយល់ឃើញអនុម័តកាលពីថ្ងៃទី៣០ មិថុនា ១៩៩៤។

[175] សូមមើលសេចក្តីសង្កេតសន្និដ្ឋានសម្រាប់សាធារណៈរដ្ឋដូមីនិកកាំង (CCPR/CO/71/DOM)

[176] សូមមើលសេចក្តីសង្កេតសន្និដ្ឋានសម្រាប់ប្រទេសហុងឌុយរ៉ាស់ (CCPR/C/HND/CO/1)

[177] សូមមើលសេចក្តីសង្កេតសន្និដ្ឋានសម្រាប់ប្រទេសហ្សំប៊ី (CCPR/ZMB/CO/3) វក្យខ័ណ្ឌទី២៥

[178] សូមមើលសេចក្តីសង្កេតសន្និដ្ឋានសម្រាប់ប្រទេសកូស្តារីកា (CCPR/C/CRI/CO/3) វក្យខ័ណ្ឌទី១១

[179] ដូចខាងលើ និងសូមមើលសេចក្តីសង្កេតសន្និដ្ឋានសំរាប់ប្រទេសទុយនេស៊ី (CCPR/C/TUN/CO/5) វក្យខ័ណ្ឌទី៩១

[180] សូមមើលសេចក្តីសង្កេតសន្និដ្ឋានសម្រាប់ប្រទេសវៀតណាម (CCPR/CO/75/VNM) កថាខ័ណ្ឌទី១៨ និងសេចក្តីសង្កេតសន្និដ្ឋានសម្រាប់ប្រទេសឡេសូតូ (CCPR/CO/79/Add.106) កថាខ័ណ្ឌទី ២៣

ដែលប្រព័ន្ធផ្សព្វផ្សាយព័ត៌មាននានាប្រមូលផ្តុំគ្នាមកតែមួយ ពោលគឺអាចរកបានព័ត៌មានទាំងអស់តាមប្រព័ន្ធអ៊ីនធឺណែត។ ការបដិសេធមិនអនុញ្ញាតឲ្យមានការបោះពុម្ពផ្សាយសារព័ត៌មាន និងប្រព័ន្ធបោះពុម្ពផ្សាយព័ត៌មាន ក្រៅពីកាលៈទេសៈជាក់លាក់នៃការអនុវត្តតាមកថាខ័ណ្ឌទី៣ គឺមិនស្របនឹង មាត្រា ១៩ នេះទេ។ កាលៈទេសៈដូចនេះ មិនអាចរាប់បញ្ចូលការហាមប្រាមលើការពុម្ពផ្សាយណាមួយឡើយ លើកលែងតែខ្លឹមសារជាក់លាក់ដែលមិនអាចបំបែកចេញពីការផ្សាយទាំងមូលអាចត្រូវបានហាមប្រាមជាធម្មានុរូប ក្រោមកថាខ័ណ្ឌទី ៣។ រដ្ឋភាគីត្រូវជៀសវាងការដាក់លក្ខខណ្ឌសម្រាប់ការចេញអាជ្ញាប័ណ្ណដែលមានលក្ខណៈស្មុគស្មាញ និងមានតម្លៃខ្ពស់ទៅលើប្រព័ន្ធព័ត៌មានចាក់ផ្សាយ រាប់ទាំងស្ថានីយ៍ព័ត៌មានពាណិជ្ជកម្ម និងស្ថានីយ៍ព័ត៌មានសហគមន៍ផងដែរ។[181] លក្ខណៈវិនិច្ឆ័យសម្រាប់អនុវត្តលក្ខខណ្ឌនេះ និងតម្លៃអាជ្ញាប័ណ្ណនេះ គួរតែសមហេតុផល និងសត្យានុម័ត[182] ច្បាស់លាស់[183] តម្លាភាព[184] មិនរើសអើង និងប្រសិនបើមិនដូច្នេះទេ ត្រូវស្របតាមកតិកាសញ្ញានេះ។ [185] របបចេញអាជ្ញាប័ណ្ណសម្រាប់ការផ្សាយតាម ប្រព័ន្ធផ្សព្វផ្សាយព័ត៌មាន ដែលកម្លាំងផ្សាយមានកំរិតដូចជា សេវាសោតទស្សន៍លើដី និងតាមផ្កាយរណប គួរត្រូវបានផ្តល់ការបែងចែកប្រកបដោយសមធម៌នូវលទ្ធភាពប្រើប្រាស់ និងរលកធាតុអាកាសរវាងប្រព័ន្ធផ្សាយព័ត៌មានសាធារណៈ ពាណិជ្ជកម្មនិងសហគមន៍។ គណៈកម្មាធិការផ្តល់អនុសាសន៍ថា រដ្ឋភាគីដែលមិនទាន់បានធ្វើដូច្នេះ គួរបង្កើតឲ្យមានអាជ្ញាធរសាធារណៈ និងឯករាជ្យមួយសម្រាប់ទទួលបន្ទុកការចេញអាជ្ញាប័ណ្ណផ្សាយព័ត៌មានដែលមានសមត្ថកិច្ចពិនិត្យពាក្យសុំផ្សាយនិងផ្តល់អាជ្ញាប័ណ្ណ។[186]

៤០. គណៈកម្មាធិការបញ្ជាក់ជាថ្មីអំពីសេចក្តីសង្កេតរបស់ខ្លួននៅក្នុងអត្ថាធិប្បាយទូទៅលេខ ១០ ថា "ដោយសារតែវឌ្ឍនភាពនៃប្រព័ន្ធផ្សព្វផ្សាយព័ត៌មានមហាជនសម័យថ្មី ទើបមានការចាំបាច់ចាត់វិធាន ការមានប្រសិទ្ធភាពដើម្បីបង្ការការត្រួតត្រាបែបនេះលើប្រព័ន្ធផ្សព្វផ្សាយព័ត៌មានថាអាចជ្រៀតជ្រែកដល់សិទ្ធិបុគ្គលគ្រប់រូបចំពោះសេរីភាពនៃការសម្តែងមតិ"។ រដ្ឋមិនគួរមានការត្រួតត្រាផ្តាច់មុខលើប្រព័ន្ធផ្សព្វផ្សាយព័ត៌មាន និងគួរលើកកម្ពស់ពហុភាពនៃប្រព័ន្ធផ្សព្វផ្សាយព័ត៌មាន។ [187] អាស្រ័យហេតុនេះ រដ្ឋភាគីគួរចាត់វិធានការសមស្របអនុលោមតាមកតិកាសញ្ញានេះ ដើម្បីបង្ការការត្រួតត្រាមិនត្រឹមត្រូវលើប្រព័ន្ធផ្សព្វផ្សាយព័ត៌មាន ឬការប្រមូលផ្តុំដោយក្រុមប្រព័ន្ធផ្សព្វផ្សាយព័ត៌មានដែលគ្រប់គ្រងដោយឯកជន ក្នុងស្ថានភាពផ្តាច់មុខដែលអាចប៉ះពាល់ដល់ភាពចម្រុះនៃប្រភព និងទស្សនៈយល់ឃើញ។

៤១. ត្រូវយកចិត្តទុកដាក់ដើម្បីធានាកុំឲ្យប្រើប្រព័ន្ធផ្តល់ប្រាក់គាំទ្ររបស់រដ្ឋាភិបាលដល់ប្រព័ន្ធផ្សព្វផ្សាយព័ត៌មាន និងការដាក់ការឃោសនារបស់រដ្ឋាភិបាល[188] ក្នុងករណីដែលការធ្វើបែបនេះនាំឲ្យមានការរាំងស្ទះ

---

[181] សូមមើលសេចក្តីសង្កេតសន្និដ្ឋានសម្រាប់ប្រទេសហ្គាំប៊ី (CCPR/CO/75/GMB)

[182] សូមមើលសេចក្តីសង្កេតសន្និដ្ឋានសម្រាប់ប្រទេសលីបង់ (CCPR/CO/79/Add.78) វាក្យខ័ណ្ឌទី ២៥

[183] សូមមើលសេចក្តីសង្កេតសន្និដ្ឋានសម្រាប់ប្រទេសគុយវ៉ែត (CCPR/CO/69/KWT) និងសេចក្តីសង្កេតសន្និដ្ឋានសម្រាប់ប្រទេសអ៊ុយក្រែន (CCPR/CO/73/UKR)

[184] សូមមើលសេចក្តីសង្កេតសន្និដ្ឋានសម្រាប់ប្រទេសគៀកជីស្ថាន (CCPR/CO/69/KGZ)

[185] សូមមើលសេចក្តីសង្កេតសន្និដ្ឋានសម្រាប់ប្រទេសអ៊ុយក្រែន (CCPR/CO/73/UKR)

[186] សូមមើលសេចក្តីសង្កេតសន្និដ្ឋានសម្រាប់ប្រទេសលីបង់ (CCPR/CO/79/Add.78)

[187] សូមមើលសេចក្តីសង្កេតសន្និដ្ឋានសម្រាប់ប្រទេសហ្គុយយ៉ាណា (CCPR/CO/79/Add.121) វាក្យខ័ណ្ឌទី១៩ សេចក្តីសង្កេតសន្និដ្ឋានសម្រាប់សហព័ន្ធរុស្ស៊ី (CCPR/CO/79/RUS) សេចក្តីសង្កេតសន្និដ្ឋានសម្រាប់ប្រទេសវៀតណាម (CCPR/CO/75/VNM) សេចក្តីសង្កេតសន្និដ្ឋានសម្រាប់ប្រទេសអ៊ីតាលី (CCPR/C/79/Add.37)

[188] សូមមើលសេចក្តីសង្កេតសន្និដ្ឋានសម្រាប់ប្រទេសឡេសូតូ (CCPR/CO/79/Add.106) កថាខ័ណ្ឌទី ២២

ដល់សេរីភាពនៃការសម្តែងចេញ។[189] លើសពីនេះទៅទៀត ប្រព័ន្ធផ្សព្វផ្សាយព័ត៌មានឯកជនមិនត្រូវដាក់ឲ្យស្ថិតក្នុងស្ថានភាពមួយចាញ់ប្រៀប បើធៀបទៅនឹងប្រព័ន្ធផ្សព្វផ្សាយព័ត៌មានរបស់រដ្ឋនៅក្នុងបញ្ហានេះឡើយ ជាអាទិ៍ លទ្ធភាពទទួលបានមធ្យោបាយនៃការផ្សព្វផ្សាយ/ការចែកចាយព័ត៌មាន និងលទ្ធភាពទទួលបានព័ត៌មាន។[190]

៤២. ការដាក់ទោសទណ្ឌចំពោះប្រព័ន្ធផ្សព្វផ្សាយព័ត៌មាន អ្នកបោះពុម្ពផ្សាយ ឬអ្នកសារព័ត៌មានដោយគ្រាន់តែរិះគន់រដ្ឋាភិបាល ឬប្រព័ន្ធសង្គមនយោបាយមួយដែលគាំទ្រដោយរដ្ឋាភិបាល[191] មិនដែលត្រូវ ចាត់ទុកថាជាការរិតត្បិតមួយចាំចាច់លើសេរីភាពនៃការសម្តែងមតិឡើយ។

៤៣. ការរិតត្បិតណាមួយលើប្រតិបត្តិការគេហទំព័រ បណ្តាញសង្គម ប្លក ឬប្រតិបត្តិការដទៃផ្សេងទៀតដែលផ្អែកលើប្រព័ន្ធអ៊ីនធឺណែត អេឡិកត្រូនិក ឬប្រព័ន្ធផ្សព្វផ្សាយព័ត៌មានផ្សេងទៀត រាប់ទាំងប្រព័ន្ធ ដែលគាំទ្រដល់ទំនាក់ទំនងទាំងនេះ ដូចជាអ្នកផ្តល់សេវាកម្មអ៊ីនធឺណែត ឬម៉ាស៊ីនស្វែងរក អាចអនុញ្ញាតបានតែក្នុងវិសាលភាពមួយដែលស្របតាមកថាខ័ណ្ឌទី ៣។ ជាទូទៅការរិតត្បិតដែលអាចអនុញ្ញាតបាន គួរធ្វើទៅលើសម្ភារៈដែលមានខ្លឹមសារជាក់លាក់។ បម្រាមទូទៅទៅលើប្រតិបត្តិការនៃ អសយដ្ឋានអ៊ីនធឺណែត និងប្រព័ន្ធខ្លះ គឺមិនស្របតាមកថាខ័ណ្ឌទី ៣ ឡើយ។ វាមិនស្របនឹងកថាខ័ណ្ឌទី ៣ ផងដែរ ចំពោះការបិទអសយដ្ឋានអ៊ិនធឺណែត ឬប្រព័ន្ធផ្សព្វផ្សាយព័ត៌មានណាមួយមិនឲ្យផ្សាយអត្ថបទ ដោយសារគ្រាន់តែអត្ថបទនេះ អាចមានការរិះគន់រដ្ឋាភិបាល ឬប្រព័ន្ធសង្គមនយោបាយមួយដែលរដ្ឋាភិបាលគាំទ្រ។[192]

៤៤. វិជ្ជាជីវៈសារព័ត៌មាន គឺជាមុខងារមួយដែលមានតួអង្គច្រើនចូលរួម រួមមានអ្នករាយការណ៍ និងអ្នកវិភាគវិជ្ជាជីវៈធ្វើការពេញម៉ោងព្រមទាំងមានអ្នកប្រើប្លុកផ្ទាល់ខ្លួន និងអ្នកឯទៀតដែលធ្វើការក្នុងឋានៈជាអ្នកបោះពុម្ពផ្សាយខ្លួនឯង នៅលើប្រព័ន្ធអ៊ីនធឺណែត ឬប្រព័ន្ធដទៃផ្សេងទៀត ហើយប្រព័ន្ធចុះបញ្ជី ឬផ្តល់អាជ្ញាប័ណ្ណជាទូទៅរបស់រដ្ឋដល់អ្នកសារព័ត៌មានមិនស្របនឹងកថាខ័ណ្ឌទី ៣ នេះទេ។ គម្រោងទទួលស្គាល់ជាផ្លូវការមានកំណត់ អាចអនុញ្ញាតបានតែក្នុងករណីចាំបាច់ប៉ុណ្ណោះ ដើម្បីផ្តល់ឲ្យអ្នកសារព័ត៌មាននូវបុព្វសិទ្ធិចេញ-ចូលទីកន្លែង និង/ឬព្រឹត្តិការណ៍មួយចំនួន។ គម្រោងដូចនេះ គួរត្រូវបានអនុវត្តក្នុងលក្ខណៈមួយដោយគ្មានការរើសអើង និងស្របតាមមាត្រា ១៩ និងបទបញ្ញត្តិដទៃទៀតនៃកតិកាសញ្ញានេះ ផ្អែកលើលក្ខណៈវិនិច្ឆ័យមួយជាក់លាក់ និងដោយពិចារណាថាវិជ្ជាជីវៈសារព័ត៌មាន គឺជាមុខងារមួយដែលមានតួអង្គចម្រុះចូលរួម។

៤៥. តាមធម្មតាវាមិនស្របនឹងកថាខ័ណ្ឌទី ៣ ទេ ក្នុងការរិតត្បិតសេរីភាពរបស់អ្នកសារព័ត៌មាន និងអ្នកដទៃទៀតដែលព្យាយាមអនុវត្តសេរីភាពនៃការសម្តែងចេញ (ដូចជា អ្នកដែលមានបំណងធ្វើដំណើរទៅចូលរួមក្នុងការប្រជុំផ្សេងៗទាក់ទងនឹងសិទ្ធិមនុស្ស) [193] ការធ្វើដំណើរចេញក្រៅរដ្ឋភាគី ការរិតត្បិតអ្នកសារ

---

[189] សូមមើលសេចក្តីសង្កេតសន្និដ្ឋានសម្រាប់ប្រទេសអ៊ុយក្រែន (CCPR/CO/73/UKR)

[190] សូមមើលសេចក្តីសង្កេតសន្និដ្ឋានសម្រាប់ប្រទេសស្រីលង្កា (CCPR/CO/79/LKA) និងសេចក្តីសង្កេតសន្និដ្ឋានសម្រាប់ប្រទេសតូហ្គោ (CCPR/CO/76/TGO) កថាខ័ណ្ឌទី ១៧

[191] សូមមើលសេចក្តីសង្កេតសន្និដ្ឋានសម្រាប់ប្រទេសប៉េរូ (CCPR/CO/70/PER)

[192] សូមមើលសេចក្តីសង្កេតសន្និដ្ឋានសម្រាប់សាធារណៈរដ្ឋអារ៉ាប់សេរី (CCPR/CO/84/SYR)

[193] សូមមើលសេចក្តីសង្កេតសន្និដ្ឋានសម្រាប់ប្រទេសអ៊ុយបេគីស្ថាន (CCPR/CO/83/UZB) និងសេចក្តីសង្កេតសន្និដ្ឋានសម្រាប់ប្រទេសម៉ូរ៉ុកកូ (CCPR/CO/82/MAR)

ព័ត៌មានបរទេសចំពោះការចូលក្នុងរដ្ឋភាគី ដល់អ្នកដែលមកពីប្រទេសជាក់លាក់មួយចំនួន [194] ឬរិតត្បិតសេរីភាពក្នុងការដើរហើររបស់អ្នកសារព័ត៌មាន និងអ្នកស៊ើបអង្កេតសិទ្ធិមនុស្សនៅក្នុងរដ្ឋភាគី (រាប់ទាំងទីកន្លែងដែលរងផលប៉ះពាល់ពីជម្លោះកន្លែងមានគ្រោះធម្មជាតិ និងកន្លែងដែលគេអះអាងថា មានការរំលោភបំពានសិទ្ធិមនុស្ស)។ រដ្ឋភាគីគួរទទួលស្គាល់ និងគោរពធាតុផ្សំនៃសិទ្ធិមានសេរីភាពនៃការសម្តែងចេញដែលក្រសោបទៅលើបុព្វសិទ្ធិមានដែនកំណត់របស់អ្នកសារព័ត៌មានក្នុងការមិនបញ្ចេញឲ្យដឹងពីប្រភពព័ត៌មាន។[195]

៤៦. រដ្ឋភាគីគួរធានាថា វិធានការប្រឆាំងភេរវកម្មត្រូវស្របនឹងកថាខ័ណ្ឌទី ៣។ បទល្មើសបែបនេះដូច ជា "ការលើកទឹកចិត្តភេរវកម្ម"[196] និង"សកម្មភាពជ្រុលនិយម"[197] ក៏ដូចជាបទល្មើសនៃអំពើភេរវកម្ម "តាមការកោតសរសើរ" "តាមការលើកឲ្យល្បីល្បាញ" ឬ "តាមការធ្វើយុត្តិកម្ម" គួរតែកំណត់ន័យឲ្យបាន ច្បាស់លាស់ដើម្បីធានាថា បទល្មើសទាំងនោះ មិននាំឲ្យមានការជ្រៀតជ្រែករំខានដែលមិនចាំបាច់ ឬ មិនសមាមាត្រជាមួយនឹងសេរីភាពនៃការសម្តែងចេញឡើយ។ ការរិតត្បិតហួសហេតុលើសិទ្ធិទទួលបានព័ត៌មាន ក៏ត្រូវតែជៀសវាងផងដែរ។ ប្រព័ន្ធផ្សព្វផ្សាយព័ត៌មាន ដើរតួនាទីមួយដ៏សំខាន់ក្នុងការ ផ្តល់ដំណឹងដល់សាធារណៈជនពីអំពើភេរវកម្ម និងសមត្ថភាពរបស់ខ្លួនដើម្បីប្រតិបត្តិការមិនគួរត្រូវបានរិតត្បិតដោយមិនត្រឹមត្រូវឡើយ។ ហេតុដូចនេះ អ្នកសារព័ត៌មានមិនគួរត្រូវបានដាក់ទោសទណ្ឌចំពោះការអនុវត្តសកម្មភាពត្រឹមត្រូវរបស់ខ្លួននោះឡើយ។

៤៧. ច្បាប់បរិហាកេរ្តិ៍ត្រូវតែបានតាក់តែងដោយយកចិត្តទុកដាក់ ដើម្បីធានាថាច្បាប់ទាំងនោះស្រប តាមកថាខ័ណ្ឌទី ៣ ហើយថា ក្នុងការអនុវត្តជាក់ស្តែងច្បាប់ទាំងនេះមិនបម្រើដល់ការរិតត្បិតលើសេរីភាពនៃការបញ្ចេញមតិឡើយ។[198] ច្បាប់ទាំងឡាយនេះ ជាពិសេសច្បាប់ដាក់បទបរិហាកេរ្តិ៍ជាបទព្រហ្មទណ្ឌ គួរតែដាក់បញ្ចូលបញ្ញត្តិនៃមធ្យោបាយការពារទល់នឹងការចោទប្រកាន់ ដូចជាយកការពិតជាមធ្យោបាយការពារ ហើយច្បាប់ទាំងនោះមិនគួរយកទៅអនុវត្តទាក់ទងនឹងទម្រង់នៃការសម្តែងចេញណាដែលគេមិនអាចផ្ទៀងផ្ទាត់បាន។ យ៉ាងហោចណាស់ ចំពោះសេចក្តីអធិប្បាយអំពីបុគ្គលសាធារណៈ គេគួរធ្វើការពិចារណាជៀសវាងការដាក់ទោសទណ្ឌ ឬជៀសវាងការចាត់សេចក្តីថ្លែងការណ៍មិនពិតដែលត្រូវបានចុះផ្សាយដោយភាន់ច្រឡំ ប៉ុន្តែមិនមានគំនិតព្យាបាទ ទៅជាសេចក្តីថ្លែងការណ៍មិនស្របច្បាប់ឡើយ។[199] ទោះក្នុងករណីណាក៏ដោយ ការរិះគន់ក្នុងផលប្រយោជន៍សាធារណៈ គួរតែត្រូវបានទទួលស្គាល់ថាជាមធ្យោបាយការការពារមួយ។ រដ្ឋភាគីគួរយកចិត្តទុកដាក់បញ្ចៀសវិធានការ និងទោសទណ្ឌជាទណ្ឌកម្មហួសហេតុ។ ប្រសិនជាពាក់ព័ន្ធ រដ្ឋភាគីគួរកំណត់ការទាមទាររបស់ចុងចោទក្នុងកម្រិតល្មមសមរម្យសងការខូចខាតដល់ភាគីដែលឈ្នះក្តី។ [200] រដ្ឋភាគីគួរពិចារណាអំពីការដកបទបរិហារកេរ្តិ៍ចេញពីបទល្មើសព្រហ្មទណ្ឌ [201] ហើយទោះជាក្នុង

---

[194] សូមមើលសេចក្តីសង្កេតសន្និដ្ឋានសាធារណៈរដ្ឋប្រជាធិបតេយ្យកូរ៉េ (CCPR/CO/72/PRK)

[195] សូមមើលសេចក្តីសង្កេតសន្និដ្ឋានសម្រាប់ប្រទេសគុយវ៉ែត (CCPR/CO/69/KWT)

[196] សូមមើលសេចក្តីសង្កេតសន្និដ្ឋានសម្រាប់សហរាជាណាចក្រនៃចក្រភពអង់គ្លេស និងអៀកឡង់ខាងជើង (CCPR/C/GBR/CO/6)

[197] សូមមើលសេចក្តីសង្កេតសន្និដ្ឋានសម្រាប់សហព័ន្ធរុស្ស៊ី (CCPR/CO/79/RUS)

[198] សូមមើលសេចក្តីសង្កេតសន្និដ្ឋានសម្រាប់សហរាជាណាចក្រនៃចក្រភពអង់គ្លេស និងអៀកឡង់ខាងជើង (CCPR/C/GBR/CO/6)

[199] ដូចខាងលើ

[200] ដូចខាងលើ

ករណីណាក៏ដោយ ការអនុវត្តច្បាប់ព្រហ្មទណ្ឌ គួរទទួលបានតែចំពោះករណីធ្ងន់ធ្ងរបំផុតប៉ុណ្ណោះ ហើយការដាក់ពន្ធនាគារមិនដែលជាទណ្ឌកម្មសមស្របនោះទេ។ គេមិនអនុញ្ញាតឲ្យរដ្ឋភាគីចោទប្រកាន់បុគ្គលណាម្នាក់ពីបទបរិហារកេរ្តិ៍ជាបទព្រហ្មទណ្ឌ រួចក្រោយមកមិនយកទៅជំនុំជម្រះឲ្យបានឆាប់រហ័សនោះឡើយ ការអនុវត្តបែបនេះ មានផលប៉ះពាល់មិនល្អដែលអាច រិតត្បិតមិនត្រឹមត្រូវលើការអនុវត្តសេរីភាពនៃការបញ្ចេញមតិរបស់សាមីជន និងអ្នកដទៃទៀត។[202]

៤៨. បំរាមចំពោះការបង្ហាញពីការមិនគោរពដល់សាសនា ឬប្រព័ន្ធជំនឿផ្សេងទៀត រាប់ទាំងច្បាប់ប្រមាថសាសនាផង គឺមិនស្របនឹងកតិកាសញ្ញានេះទេ លើកលែងតែក្នុងកាលៈទេសៈជាក់លាក់ ដែលមានចែងក្នុងមាត្រា២០ កថាខ័ណ្ឌទី ២ នៃកតិកាសញ្ញានេះ។ បម្រាមបែបនេះ ក៏ត្រូវតែស្របផងដែរនឹង លក្ខខណ្ឌតម្រូវយ៉ាងតឹងរឹងនៃមាត្រា ១៩ កថាខ័ណ្ឌទី ៣ ព្រមទាំងមាត្រាមួយចំនួន ដូចជាមាត្រា ២, ៥, ១៧, ១៨ និងមាត្រា ២៦។ ដូច្នេះ ជាឧទាហរណ៍ មិនអនុញ្ញាតចំពោះច្បាប់ទាំងឡាយណាដែលមាន ការរើសអើង ដោយការគាំទ្រ ឬប្រឆាំងសាសនាមួយ ឬសាសនាជាក់លាក់ ឬប្រព័ន្ធជំនឿ ឬអ្នកកាន់ សាសនាមួយទៅអ្នកកាន់សាសនាមួយទៀត ឬអ្នកមានជំនឿលើសាសនាមួយទៅអ្នកគ្មានជំនឿលើសាសនា។ វាក៏មិនអនុញ្ញាតឲ្យមានបម្រាមបែបនេះដើម្បីបង្ការ ឬដាក់ទោសទណ្ឌដល់មតិរិះគន់អ្នកដឹកនាំសាសនា ឬអ្នកអត្ថាធិប្បាយពីលិទ្ធិសាសនា និងគោលការណ៍នៃជំនឿ។[203]

៤៩. ច្បាប់ដែលដាក់ទោសទណ្ឌលើការបញ្ចេញមតិអំពីអង្គហេតុប្រវត្តិសាស្ត្រ គឺមិនស្របនឹងកាតព្វកិច្ចដែលកតិកាសញ្ញានេះកំណត់ទៅលើរដ្ឋភាគី ទាក់ទងនឹងការគោរពសេរីភាពនៃមតិ និងការសម្តែងចេញនោះទេ។[204] កតិកាសញ្ញានេះមិនអនុញ្ញាតឲ្យមានបម្រាមជាទូទៅលើការបញ្ចេញមតិដែលភាន់ច្រឡំ ឬការបកស្រាយមិនត្រូវអំពីព្រឹត្តិការណ៍ពីអតីតកាលនោះទេ។ ការរិតត្បិតសិទ្ធិសេរីភាពនៃការសម្តែងចេញមិនគួរត្រូវធ្វើ ហើយការរិតត្បិតទាំងនេះ មិនគួរធ្វើឲ្យហួសពីអ្វីដែលបានអនុញ្ញាតក្នុងកថាខ័ណ្ឌទី ៣ ឬអ្វីដែលបានតម្រូវក្រោមមាត្រា ២០ ឡើយ ទាក់ទងនឹងសេរីភាពនៃការបញ្ចេញមតិ។

## ទំនាក់ទំនងរវាងមាត្រា ១៩ និងមាត្រា ២០

៥០. មាត្រា ១៩ និងមាត្រា ២០ មានលក្ខណៈស្របគ្នា និងបំពេញឲ្យគ្នាទៅវិញទៅមក។ អំពើដែលមានចែងក្នុងមាត្រា ២០ សុទ្ធតែស្ថិតនៅក្រោមការរិតត្បិតស្របតាមមាត្រា ១៩ កថាខ័ណ្ឌទី ៣។ ដូច្នេះ ការរិតត្បិតណាមួយដែលត្រូវបានធ្វើយុត្តិកម្មផ្អែកលើមាត្រា ២០ ក៏ត្រូវតែស្របផងដែរនឹងមាត្រា ១៩ កថា ខ័ណ្ឌទី ៣។[205]

---

[201] សូមមើលសេចក្តីសង្កេតសន្និដ្ឋានសម្រាប់ប្រទេសអ៊ីតាលី (CCPR/C/ITA/CO/5) និងសេចក្តីសង្កេតសន្និដ្ឋានសម្រាប់អតីតសាធារណៈរដ្ឋយូហ្គោស្លាវី ម៉ាសេដូនី (CCPR/C/MKD/CO/2)

[202] សូមមើលបណ្តឹងលេខ៩០៩/២០០០ រវាង *Kankanamge* និងប្រទេសស្រីលង្កា ទស្សនៈយល់ឃើញអនុម័តកាលពីថ្ងៃទី២៧ កក្កដា ២០០៤។

[203] សូមមើលសេចក្តីសង្កេតសន្និដ្ឋានសម្រាប់សហរាជាណាចក្រនៃចក្រភពអង់គ្លេស និងអៀកឡង់ខាងជើង-ដែនដីរាជាណាចក្រ (CCPR/C/79/Add.119)។ សូមមើលផងដែរសេចក្តីសង្កេតសន្និដ្ឋានសម្រាប់ប្រទេសគុយវ៉ែត(CCPR/CO/69/KWT) ។

[204] ដែលត្រូវបានហៅថា "ឯកសារច្បាប់ជំនួយស្មារតី" សូមមើលបណ្តឹងលេខ៥៥០/៩៣ រវាង *Faurission* និងប្រទេសបារាំង។ សូមមើលផងដែរសេចក្តីសង្កេតសន្និដ្ឋានសម្រាប់ប្រទេសហុងគ្រី(CCPR/HUN/CO/5) វក្យខ័ណ្ឌទី ១៩

[205] សូមមើលបណ្តឹងលេខ៧៣៦/៩៧ រវាង *Ross* និងប្រទេសកាណាដា ទស្សនៈយល់ឃើញអនុម័តកាលពីថ្ងៃទី១៨ តុលា ២០០០។

៥១. អ្វីដែលញែកអំពើដែលមានចែងក្នុងមាត្រា ២០ ចេញពីអំពើផ្សេងទៀត ដែលអាចជាកម្មវត្ថុនៃការ រិតត្បិតក្រោមមាត្រា១៩ កថាខ័ណ្ឌទី៣នោះ គឺថាចំពោះអំពើដែលមានចែងក្នុងមាត្រា ២០ កតិកាសញ្ញា នេះបង្ហាញពីចម្លើយជាក់លាក់ដែលបានតម្រូវពីរដ្ឋ មានជាអាទិ៍ ការហាមប្រាមដោយច្បាប់របស់ខ្លួន។ មានតែស្ថិតក្នុងវិសាលភាពនេះប៉ុណ្ណោះ ដែលមាត្រា ២០ អាចត្រូវបានចាត់ទុកថាជាច្បាប់ពិសេស ទាក់ទងនឹងមាត្រា ១៩។

៥២. វាទាល់តែទាក់ទងនឹងទម្រង់ជាក់លាក់មួយចំនួននៃការសម្តែងមតិដែលបានគូសបញ្ជាក់ក្នុងមាត្រា ២០ ថារដ្ឋភាគីមានកាតព្វកិច្ចធ្វើការហាមប្រាមតាមផ្លូវច្បាប់។ គ្រប់ករណីដែលរដ្ឋធ្វើការរិតត្បិតសេរីភាពក្នុងការសម្តែងមតិ រដ្ឋចាំបាច់ត្រូវបង្ហាញហេតុផលត្រឹមត្រូវសម្រាប់ការហាមប្រាមនោះ ហើយការហាមប្រាមនោះត្រូវតែស្របទាំងស្រុងជាមួយមាត្រា ១៩។